Ellen G. White Estate

# ជំហានទៅកាន់ព្រះគ្រិស្ទ



ELLEN G. WHITE

# ជំហានទៅកាន់ព្រះគ្រិស្ទ

ជំពូក ១ — សេចក្តីស្រលាញ់របស់ព្រះចំពោះមនុស្ស...3
ជំពូក ២ — សេចក្តីត្រូវការព្រះគ្រិស្ទរបស់បាបជន..... 28
ជំពូកទី ៣ — ការប្រែចិត្ត............................................. 49
ជំពូកទី ៤ — ការលន់តួបាប.........................................102
ជំពូកទី ៥ — ការឧទ្ទិសខ្លួនចំពោះព្រះ........................118
ជំពូកទី ៦ — សេចក្តីជំនឿនិងការទទួលយកព្រះ.....136
ជំពូកទី ៧ — ការសាកល្បងនៃសាវ័កភាព................159
ជំពូកទី ៨ — ការរីកចំរើននៅក្នុងព្រះគ្រិស្ទ................188
ជំពូក ៩ — ការងារ និងជីវិត........................................ 219
ជំពូក ១០ — ការស្គាល់ព្រះ.........................................245
ជំពូក ១១ — សិទ្ធិនៃសេចក្តីអធិស្ឋាន........................271
ជំពូក ១២ — តើត្រូវធ្វើយ៉ាងណាចំពោះមន្ទិលសង្ស័យ.. 314
ជំពូក ១៣ — សេចក្តីអំណររីករាយក្នុងព្រះអម្ចាស់...344

https://m.egwwritings.org/km

# ជំពូក ១ — សេចក្តីស្រលាញ់របស់ព្រះចំពោះមនុស្ស

ធម្មជាតិនិងព្រះគម្ពីរសំដែងឲ្យឃើញច្បាស់នូវសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្ស។ព្រះវរបិតានៃយើងដែលគង់នៅឯស្ថានសួគ៌គឺជាប្រភពនៃជីវិតប្រាជ្ញានិងសេចក្តីអំណររីករាយ។បើយើងគយគន់ធម្មជាតិដ៏សែនស្រស់បំព្រងរួចពិចារណាមើលនូវភាពអស្ចារ្យក្នុងនោះយើងនឹងឃើញថាអ្វីៗបានសំរបទៅតាមសេចក្តីត្រូវការនិងសុភមង្គល។ការទាំងនេះមិនមែនសំរាប់តែមនុស្សប៉ុណ្ណោះទេប៉ុន្តែសំរាប់អស់ទាំងសត្វលោកពោលគឺអស់ទាំងជីវិតដែលព្រះបានបង្កើតមក។ពន្លឺព្រះអាទិត្យនិ

ងទឹកភ្លៀងដែលផ្តល់នូវអំណររីករាយ និងជីវិតដល់ផែនដីកូនភ្នំសមុទ្រនិងវាលទំនាបផងទាំងឡាយបានប្រាប់ដល់យើងពីសេចក្តីស្រលាញ់របស់ព្រះអាទិករ..គឺជាព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដីសំរាប់មនុស្ស។ព្រះជាម្ចាស់តែងផ្តល់នូវសេចក្តីត្រូវការប្រចាំថ្ងៃដល់ជីវិតទាំងឡាយដែលទ្រង់បានបង្កើតមក។

ពួកអ្នកលើកទំនុកតំកើងបានលើកកំណាព្យដ៏ពិរោះនៅក្នុងវគ្គមួយថា:

“ភ្នែកមនុស្សទាំងអស់សម្លឹងមើលទៅទ្រង់
ហើយទ្រង់ក៏ប្រទានអាហារដល់គេតាម
ត្រូវពេល(រដូវ)ទ្រង់លាព្រះហស្តក៏

បំពេញចិត្តប្រាថ្នានៃជីវិតទាំងឡាយ”
។ ..ទំនុកតំកើង ១៤៥:១៥.១៦

ព្រះទ្រង់បានបង្កើតមនុស្សមកបរិសុទ្ធ
និងរីករាយឥតខ្ចោះឯផែនដីក៏ល្អហ្មត់
ហ្មង។ផែនដីនិងមនុស្សគ្មានភាពពុករ
លួយឬស្រមោលនៃសេចក្ដីបណ្ដាសា
សូម្បីបន្តិចបន្តួចសោះឡើយនៅពេល
ដែលព្រះទ្រង់បានបង្កើតមកប៉ុន្តែដោ
យសារភាពបំពានល្មើសនឹងក្រឹត្យវិន័
យរបស់ព្រះជាម្ចាស់គឺជាច្បាប់នៃសេច
ក្ដីស្រលាញ់នោះហើយដែលបណ្ដាល
ឲ្យមានរងនូវសេចក្ដីវេទនានិងសេចក្ដី
ស្លាប់។ថ្វីបើស្ថិតនៅកណ្ដាលការលំបា
កវេទនាដែលជាលទ្ធផលនៃអំពើបាប
យ៉ាងណាក៏ដោយក៏ព្រះជាម្ចាស់នៅតែ
សំដែងសេចក្ដីស្រលាញ់របស់ទ្រង់ដ
ល់យើងជាដរាបដូចមានចែងក្នុងព្រះគ

ម្ពីរលោកុប្បត្តិ៣:១៧មកថា:“ព្រះដាក់បណ្ដាសាផែនដីក៏ដើម្បីជាប្រយោជន៍ដល់មនុស្ស”
។សេចក្ដីលំបាកវេទនានិងការល្បងលបងប្រៀបបានទៅនឹងបន្លាឬគុម្ពអញ្ចាញដែលតែងតែធ្វើឲ្យជីវិតរបស់គេខ្វល់ខ្វាយលំបាកប៉ុន្តែការទាំងនេះហាក់ដូចជាបានធ្វើឲ្យគេស៊ាំថ្មីកហើយជាផ្នែកមួយនៃការហ្វឹកហ្វឺនដ៏ត្រូវការបំផុតចំពោះផែនការរបស់ព្រះក្នុងការលើកស្ទួយគេឲ្យផុតពីការខ្ជះខ្ជាំនិងការទាបថោកដែលបាននាំមកដោយអំពើបាប
។ទោះបីជាពីភពលោកយើងនេះធ្លាក់ចុះដុនដាបយ៉ាងណាក្ដីក៏ពុំមែនមានតែសេចក្ដីទុក្ខព្រួយនិងភាពកំសត់ទុរគតិនោះឡើយ។ដំណឹងដ៏ល្អដែលផ្ដល់សេចក្ដីសង្ឃឹមនិងការល្បួងលោមបានបើកសំដែងតាមរយៈធម្មជាតិផ្ទាល់ជាតួយ៉ា

ងស្វម្បីនៅលើគុម្ពបន្លាឬទងក្លាបក៏
គង់មានបុប្ផាចំរុះពណ៌រីកយ៉ាងស្រស់បំ
ព្រង។

នៅលើផ្កាដែលរីកស្គុះស្គាយនិងទងស្មៅដែលកំពុងលូតលាស់មានចារិកនូវពាក្យថា: "ព្រះគឺសេចក្ដីស្រលាញ់" ។ បក្សាបក្សីដ៏ជាទីគាប់ចិត្តបានធ្វើឲ្យបរិយាកាសពោរពេញទៅដោយសំនៀងសប្បាយខ្សៀវខ្សា។បុប្ផាចំរុះពណ៌ដ៏ស្រស់ត្រកាលបានរំសាយក្លិនពិដោរបំពេញលំហអាកាស..រុក្ខជាតិនៃព្រៃស្រោងដែលមានស្លឹកខៀវខ្ចីជាភ័ស្តុតាងយ៉ាងជាក់ស្បាន់អំពីព្រះដែលយកព្រះទ័យទុកដាក់ថែរក្សាយើងនិងបំណងហាឬទ័យរបស់ទ្រង់ដែលចង់ឲ្យរាស្ត្ររបស់ទ្រង់មានសុភមង្គលប្រៀបបានទៅ

នឹងព្រហ្មវិហារធម៌របស់មាតាបិតាចំពោះកូនដូច្នោះដែរ។

ព្រះបន្ទូលរបស់ព្រះបានសំដែងឲ្យឃើញនូវលក្ខណៈរបស់ទ្រង់។ព្រះទ្រង់បានប្រកាសដោយអង្គទ្រង់ផ្ទាល់នូវសេចក្តីស្រលាញ់និងសេចក្តីអាណិតដ៏គ្មានព្រំ
ដែន។នៅពេលដែលោកម៉ូសេបានអធិដ្ឋានថា:"សូមបង្ហាញទូលបង្គំនូវសិរីល្អរបស់ទ្រង់"
នោះព្រះជាម្ចាស់ទ្រង់មានបន្ទូលថា:"អញនឹងឲ្យអស់ទាំងសេចក្តីសប្បុរសរបស់អញដើរកាត់ពីមុខឯង"
..និក្ខមនំ៣៣:១៨.១៩។នេះគឺជាសិរីល្អរបស់ទ្រង់។ព្រះជាម្ចាស់ទ្រង់យាងកាត់ពីមុខលោកម៉ូសេហើយប្រកាសថា:"ព្រះយេហូវ៉ាគឺជាព្រះដែលទ្រង់មានពុ

រះទ័យមេត្តាករុណានិងទន់សន្តោសទ្រង់យឺតនឹងខ្ញាល់ហើយមានសេចក្តីសប្បុរសនិងសេចក្តីទៀងត្រង់ជាបរិបូណ៌ដល់មនុស្សទាំងពាន់ក៏អត់ទោសចំពោះសេចក្តីទុច្ចរិតសេចក្តីរំលងនិងអំពើបាប”
និក្ខមនំ៣៤:៦.៧។“ព្រះទ្រង់យឺតនឹងខ្ញាល់តែមានសេចក្តីសប្បុរសជាបរិបូណ៌ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យក្នុងការសណ្តោសប្រោសប្រណី”..
មីកា៧:១៨។

ព្រះជាម្ចាស់ទ្រង់បានចងចិត្តយើងទៅនឹងទ្រង់ដោយទីសំគាល់ដ៏រាប់មិនអស់នៅលើផ្ទៃមេឃនិងផែនដីនេះ។ព្រះទ្រង់បានស្វះស្វែងដើម្បីបង្ហាញអង្គទ្រង់ដល់យើងតាមរយៈរបស់ទាំងឡាយក្នុងធម្មជាតិនិងចំណងមេត្រីភាពនៅនា

លោកិយនេះដ៏ជ្រាលជ្រៅនិងស្រទន់បំផុត។ទោះជាយ៉ាងនេះក្តីសេចក្តីស្រលាញ់របស់ទ្រង់ពុំមានអ្វីតំណាងឲ្យបានហ្មត់ហ្មងឥតខ្ចោះនោះឡើយ។ទោះបីគេមិនបានឃើញភាពជាក់ស្តែងទាំងអស់នេះយ៉ាងណាក្តីសត្រូវនៃសេចក្តីល្អបានបំបិទបំបាំងចិត្តមនុស្សមិនឲ្យគេមើលឃើញព្រះ។គេមានសេចក្តីភ័យខ្លាចហើយបែរជាយល់ថាព្រះអម្ចាស់ជាព្រះដ៏តឹងរឹងនិងគ្មានចិត្តសន្តោសប្រោសប្រណីទៅវិញ។វិញ្ញាណអាក្រក់(អារក្សសាតាំង)
បានដឹកនាំឲ្យមនុស្សគិតថាសេចក្តីយុត្តិធម៌របស់ព្រះតឹងតែងហួសហេតុហើយឲ្យមើលឃើញថាព្រះជាចៅក្រមដ៏ម៉ឹងម៉ាត់និងជាមេបំណុលដ៏តឹងរុឹង។អារក្សបានបង្ហាញរូបភាពរបស់ព្រះជាម្ចាស់ថាជាព្រះមួយអង្គដែលកំពុងតែឃ្លាំ

យាមមើលកំហុសរបស់មនុស្សលោក ដោយក្រសែភ្នែកច្រណែននិន្ទាដើម្បីនឹងវិនិច្ឆ័យទោសគេ។ដោយហេតុដូច្នោះ ហើយបានជាព្រះអម្ចាស់យេស៊ូបាន

យាងមករស់នៅក្នុងចំណោមមនុស្ស ដើម្បីបំបាត់ស្រមោលខ្មៅនេះចោលចេញដោយបង្ហាញឲ្យពិភពលោកទាំងមូលឃើញនូវសេចក្តីស្រលាញ់ដ៏គ្មានព្រះដែនរបស់ព្រះជាម្ចាស់។"ព្រះរាជបុត្រានៃព្រះបានយាងចុះមកពីស្ថានសួគ៌ ដើម្បីបើកសំដែងឲ្យយើងបានស្គាល់ព្រះវរបិតា។គ្មាននរណាដែលឃើញព្រះវរបិតាឡើយមានតែព្រះរាជបុត្រាតែមួយដែលគង់ជាប់នឹងព្រះវរបិតាប៉ុណ្ណោះដែលព្រះវរបិតាបានសំដែងឲ្យស្គាល់ទ្រង់" ..យ៉ូហាន១:១៨។" គ្មាននរណាម្នាក់អាចស្គាល់ព្រះរាជបុត្

រាទេមានតែព្រះវរបិតាហើយគ្មាននរ
ណាស្គាល់ព្រះវរបិតាលើកលែងតែព្
រះរាជបុត្រានិងអ្នកដែលព្រះរាជបុត្រា
សព្វព្រះរាជហឫទ័យឲ្យស្គាល់ទ្រង់”..
ម៉ាថាយ១១:២៧។នៅពេលដែលសាវ័
កម្នាក់បានទូលសូមដល់ទ្រង់ថា:“សូម
បង្ហាញឲ្យយើងខ្ញុំទាំងអស់គ្នាបានឃើ
ញព្រះវរបិតាផង”នៅគ្រានោះព្រះយេ
ស៊ូបានមានព្រះបន្ទូលតបថា“
ហ្វីលីពអើយ!
ខ្ញុំបានរស់នៅជាមួយអ្នករាល់គ្នាអស់រ
យ:ពេលជាយូរមកហើយតើអ្នករាល់គ្
នានៅតែមិនទាន់ស្គាល់ខ្ញុំទេឬអី?
អ្នកណាដែលបានឃើញខ្ញុំគឺបានឃើ
ញព្រះវរបិតាហើយហេតុដូចម្ដេចបាន
ជាអ្នកនិយាយថាសូមបង្ហាញឲ្យយើង
ខ្ញុំឃើញព្រះវរបិតាផងយ៉ាងដូចនេះ? ”
..យ៉ូហាន១៤:៨.៩។

ក្នុងការពិពណ៌នាអំពីបេសកកម្មរបស់ទ្រង់នៅលើផែនដីព្រះយេស៊ូមានព្រះបន្ទូលថា:“ព្រះវរបិតាបានចាក់ប្រេងតាំង
លើខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ់ទ្រង់បានចាត់ឲ្យខ្ញុំមកដើម្បីប្រោសមនុស្សដែលមានចិត្តសោកសង្រេងហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយនិងសេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ហើយរំដោះមនុស្សដែលត្រូវគេជិះជាន់ឲ្យបានរួច”
..លូកា៤:១៨។

នេះហើយជាការងាររបស់ទ្រង់។ទ្រង់បានយាងចេញទៅគ្រប់ច្រកល្ហកដើម្បីបំពេញនូវអំពើល្អនិងព្យាបាលអស់ទាំងមនុស្សផងទាំងឡាយដែលបៀតបៀ

នដោយអារក្សសាតាំង។ក្នុងក្រវល់ស្រុកភូមិទាំងឡាយដែលព្រះអង្គយាងកាត់នោះគ្មានសំលេងថ្ងូរដោយជំងឺក្នុងគេហដ្ឋានណាមួយឡើយព្រោះព្រះអង្គបានព្យាបាលអស់ទាំងជំងឺរបស់គេហើយ។កិច្ចការរបស់ទ្រង់ជាសក្ខីភាពបង្ហាញឲ្យឃើញថាព្រះអង្គជាព្រះប្រកបទៅដោយអំណាចចេស្តានៃព្រះដ៏ខ្ពស់បំផុត។គ្រប់សកម្មភាពក្នុងជីវិតរបស់ទ្រង់បានផ្សព្វផ្សាយនូវសេចក្តីស្រលាញ់សេចក្តីមេត្តាករុណានិងសេចក្តីអាណិតអាសូរជានិច្ច។ព្រះហឫទ័យរបស់ទ្រង់ពោរពេញទៅដោយភាពអាណិតអាសូរដ៏ស្រទន់ដល់មនុស្សទាំងអស់។ទ្រង់បានយកជាតិជាមនុស្សលោកដើម្បីទ្រង់អាចបំពេញសេចក្តីប្រាថ្នារបស់មនុស្ស។មនុស្សក្រីក្រនិងទន់ទាបបំផុតក៏អាចចូលមកទ្រង់បានដែ

។សូម្បីកូនក្មេងតូចៗក៏ស្រលាញ់ទ្រង់ដែរ។ពួកគេចូលចិត្តអង្គុយលើភ្លៅរបស់ព្រះអង្គហើយសម្លឹងមើលទៅរង្វង់ភក្រ្តទ្រង់ដែលពោរពេញទៅដោយព្រះវិចារណញ្ញាណសុភាពស្លូតបូតនិងសេចក្តីស្រលាញ់។

—

ព្រះយេស៊ូមិនបានបង្ខាំងសេចក្តីពិតមួយម៉ាត់ណាសោះឡើយប៉ុន្តែព្រះអង្គតែងមានព្រះបន្ទូលដោយសេចក្តីស្រលាញ់ជានិច្ច។ព្រះអង្គទ្រង់ឈ្លាសវៃជាទីបំផុត។វិញ្ញាណរបស់ទ្រង់ជិតជាប់នឹងសេចក្តីសប្បុរសនិងវិចារណញ្ញាណនៅក្នុងទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្សជាតិ។ទ្រង់មិនមានព្រះបន្ទូលដោយភាពទ្រគោះបោះបោកក៏មិនដែលមានព្រះបន្ទូលដោយពាក្យមិនបានការ

និងមិនដែលធ្វើឲ្យមានការឈឺចាប់ដល់មនុស្សណាម្នាក់ប្រសិនបើគ្មានការចាំបាច់នោះ។
ទ្រង់ពុំដែលតិទៀននូវភាពទន់ខ្សោយរបស់អ្នកណាម្នាក់ឡើយ។ទ្រង់មានព្រះបន្ទូលតែពាក្យសច្ចៈ (សេចក្តីពិត) ដែលប្រកបដោយសេចក្តីស្រលាញ់ជានិច្ច។ទ្រង់មិនសព្វព្រះហារទ័យចំពោះការលាក់ពុតភាពខ្វះសេចក្តីជំនឿនិងអំពើទុច្ចរិតប៉ុន្តែទ្រង់តែងមានសេចក្តីក្តួលអាណិតនៅពេលណាទ្រង់បានស្តីបន្ទោសដល់អ្នកណាម្នាក់។ទ្រង់ព្រះកន្សែងនៅឯទីក្រុងយេរូសាឡឹមទីក្រុងជាទីស្រលាញ់របស់ទ្រង់ដែលបដិសេដមិនទទួលយក
ទ្រង់ដែលជាផ្លូវជាសេចក្តីពិតនិងជាជីវិត។

ពួកគេបានបោះបង់ចោលទ្រង់ដែលជាព្រះអង្គសង្គ្រោះក៏ប៉ុន្តែទ្រង់នៅតែទទួលស្គាល់គេដោយក្ដីមេត្តាដ៏ស្រទន់។ជីវិតរបស់ទ្រង់ជាជីវិតដែលលះបង់មិនគិតពីខ្លួនឯងប៉ុន្តែទ្រង់តែងតែគិតដល់អ្នកដ៏ទៃ។មនុស្សទាំងឡាយមានតម្លៃចំពោះទ្រង់។នៅពេលដែលទ្រង់ដែលស្ថិតនៅក្នុងអំណាចជាព្រះនោះទ្រង់បានបន្ទាបអង្គទ្រង់ដោយសុភាពរាបសាបំផុតទៅកាន់គ្រប់សមាជិកក្នុងគ្រួសារនៃព្រះជាម្ចាស់។ក្នុងចំណោមមនុស្សទាំងអស់ទ្រង់ឃើញអ្នកដែលធ្លាក់ចុះគឺជាកាតព្វកិច្ចរបស់ទ្រង់ក្នុងកិច្ចជួយសង្គ្រោះ។

ភាពទាំងអស់នេះគឺជាចរិតរបស់ព្រះគ្រិស្ទដែលបានសំដែងនៅក្នុងជីវិតរបស់ទ្រង់ហើយក៏ជាចរិតរបស់ព្រះជាម្ចាស់

ដែលចេញពីដួងហឫទ័យនៃព្រះវរបិតា
ពោរពោរពេញដោយសេចក្តីមេត្តករុ
ណាដ៏អនេកអនន្តដែលសំដែងឲ្យឃើ
ញតាមរយៈព្រះយេស៊ូរួចបានបង្ហូរទៅ
ដល់តំណពូជមនុស្ស។“
ព្រះយេស៊ូដែលជាព្រះសង្គ្រោះដ៏ស្រទ
ន់និងមេត្តាករុណាគឺជាព្រះដែលលេច
មកក្នុងសាច់ឈាម” ..ធីម៉ូថេ១៣:១៦។

ដើម្បីលោះយើងរាល់គ្នាព្រះយេស៊ូគ្រិ
ស្ទបានយាងមករស់នៅលើផែនដីហើ
យទទួលការឈឺចាប់និងសុគត។ព្រះអ
ង្គបានក្លាយជា“អ្នករងទុក្ខព្រួយ”
ប្រយោជន៍ឲ្យយើងមានចំណែកក្នុងក្តី
សប្បាយរីករាយដ៏អស់កល្ប។ព្រះយេ
ហូវ៉ាបានអនុញ្ញាតិឲ្យរាជបុត្រារបស់ទ្រ
ង់ដែលប្រកបទៅដោយព្រះគុណនិង
សច្ចភាពយាងចុះពីពិភពដែលពោរពេ

ញទៅដោយសិរីល្អដ៏ឥតគណនាមក
កាន់លោកិយ៍ដែលពុករលួយដោកជាំ
ដោយអំពើបាបនិងគ្របដណ្ដប់ដោយ
ស្រមោលនៃសេចក្ដីស្លាប់និងបណ្ដា
សា។ព្រះវរបិតាអនុញ្ញាតិឲ្យព្រះរាជបុ
ត្រាចាកចេញពីសេចក្ដីស្រលាញ់របស់
ទ្រង់និងពីការគោរពប្រណិបត្តិនៃពពួក
ទេវតាមកទទួលរងការអាម៉ាស់សេចក្ដី
ប្រមាថការបន្ទះបង្អាប់សំអប់និងសេច
ក្ដីស្លាប់។ដើម្បីសេចក្ដីសុខរបស់យើង
ទ្រង់បានទទួលរងទណ្ឌកម្មដែលយើង
សោះជាអ្នកត្រូវទទួល។“
ទ្រង់ក៏ត្រូវរបួសដោយព្រោះអំពើរំលងរ
បស់យើងក៏ត្រូវបានគេវាយជាំដោយព្
រោះអំពើទុច្ចរិតរបស់យើងដែរឯការវា
យផ្ចាល់ដែលនាំឲ្យយើងបានជាមេត្រី
នោះបានធ្លាក់ទៅលើទ្រង់ហើយយើង
រាល់គ្នាបានប្រោសឲ្យជាដោយសារស្

នាមរំពាត់លើព្រះកាយទ្រង់”..អេសាយ៥៣:៥។

មើលព្រះអង្គទ្រង់នៅឯវាលរហោស្ថាន នៅឯសួនច្បារកេតសេម៉ានី..នៅលើឈើឆ្កាង!
ព្រះរាជបុត្រានៃព្រះអម្ចាស់ដែលគ្មានអំពើបាបសោះបានទទួលបន្ទុកនៃអំពើបានដាក់លើអង្គទ្រង់។ព្រះអម្ចាស់ដែលពីដើមគង់នៅជាមួយព្រះវរបិតាបានយល់ក្នុងចិត្តនូវការនឹរាស្តព្រាត់ប្រាសដ៏គួរឲ្យរន្ធត់ដែលអំពើបាបបានខណ្ឌញែកចន្លោះព្រះអម្ចាស់នឹងមនុស្ស។ ភាពក្រៀមក្រំនេះបានលេចចេញពីព្រះឱស្ឋទ្រង់ដោយសំរែកយ៉ាងឈឺចាប់ថា:“ឱព្រះអង្គៗនៃទូលបង្គំអើយ! ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ? ” ..ម៉ាថាយ២៧:៤៦។ដោយសារបន្ទុក

នៃអំពើបាបដែលមានទំហំធំធេងគួរឲ្យរន្ធត់និងដោយសារអំពើបាបដែលបានបំបែកបំបាក់ព្រលឹងវិញ្ញាញមនុស្សនឹងព្រះអម្ចាស់នោះបានធ្វើឲ្យព្រះរាជបុត្រានៃព្រះវរបិតាខ្លោចផ្សាចិត្តយ៉ាងខ្លាំង។

ក៏ប៉ុន្តែព្រះមហាពលីកម្មនេះក៏មិនមែនធ្វើឡើងដើម្បីបង្កើតឲ្យមានសេចក្តីស្រលាញ់ចំពោះមនុស្សនៅក្នុងព្រះហឫទ័យនៃព្រះវរបិតាទេក៏មិនមែនធ្វើឲ្យទ្រង់មានព្រះទ័យចង់សង្គ្រោះនោះដែរ..ទេ! ទេ!មិនមែនទេគឺ“ត្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកទេតើបានជាទ្រង់ប្រោសប្រទានព្រះរាជបុត្រាទ្រង់តែមួយដើម្បីឲ្យអស់អ្នកណាដែលជឿជាក់ដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយតែត្រូវទទួលបានជីវិតអស់កល្បជានិច្ច

វិញ”..យ៉ូហាន៣:១៦។ព្រះវបិតាស្រ
លាញ់យើងរាល់គ្នាគឺមិនមែនមកពីដង្
វាយផ្ទូនបាបនៃយើងនោះទេតែទ្រង់បា
នផ្តល់នូវដង្វាយនេះដោយព្រោះទ្រង់
ស្រលាញ់ដល់យើងរាល់គ្នា។ព្រះគ្រិស្ទ
គឺជាមជ្ឈបុគ្គលដែលគង់នៅចន្លោះយើ
ងនឹងព្រះវរបិតាដែលតាមរយៈទ្រង់
នោះហើយដែលព្រះអម្ចាស់អាចចាក់
បង្ហូរសេចក្តីស្រលាញ់ដ៏អនេកអនន្តរប
ស់ទ្រង់មកលើពិភពលោកដែលបាត់ប
ង់។“ព្រះវរបិតារួមនឹងព្រះគ្រិស្ទកំពុងផ្
សះផ្សារលោកិយ៍ដោយព្រះអង្គផ្ទាល់”.
.កូរិនថូសទី២៥:១៩។ទ្រង់ទទួលការ
ឈឺចាប់ជាមួយព្រះរាជបុត្រាទ្រង់។ព្
រះហឫទ័យដែលពោរពេញទៅដោយ
សេចក្តីស្រលាញ់ដ៏គ្មានព្រំដែននាំឲ្យទ្
រង់ស៊ូទ្រាំការឈឺចាប់វេទនានៅសួនច្
បារកេតសាម៉ានីនិងសុគតលើឈើឆ្កា

ងត្រង់កាល់វ៉ារីដើម្បីចេញថ្លៃលោះដល់យើងរាល់គ្នា។

ព្រះយេស៊ូមានព្រះបន្ទូលថា:“ព្រះវរបិតាស្រលាញ់ខ្ញុំពីព្រោះខ្ញុំបានលះបង់ជីវិតរបស់ខ្ញុំដើម្បីឲ្យបានជីវិតនោះមកវិញ”
..យ៉ូហាន១០:១៧។ព្រះវរបិតានៃខ្ញុំស្រលាញ់អ្នកដល់ម្លេះហើយទ្រង់ស្រលាញ់ខ្ញុំកាន់តែទ្វេរឡើងព្រោះខ្ញុំបានបូជាជីវិតខ្ញុំដើម្បីជាថ្លៃលោះបាបរបស់អ្នក។ខ្ញុំគឺជាទីស្រលាញ់នៃព្រះវរបិតាដោយសារខ្ញុំបានជំនួសអ្នករាល់គ្នានិងជាអ្នកធានារបស់អ្នកដោយលះបង់ជីពជន្មរបស់ខ្ញុំទទួលយកបំណុលបាបនិងអំពើរំលង់របស់អ្នករាល់គ្នា។ដោយសារការបូជាជីវិតរបស់ខ្ញុំព្រះវរបិតាទ្រង់បានប្រកបដោយយុត្តិធម៌រឺឯអ្នកណាដែលមានជំ

នឿដល់ព្រះយេស៊ូគ្រិស្ទនោះមានឈ្មោះថាជាអ្នកតម្រូវខ្លួនមកក្នុងព្រះហើយ។

គ្មាននរណាម្នាក់សោះក្រៅអំពីព្រះរាជបុត្រានៃព្រះដែលអាចសំរេចផែនការប្រោសលោះរបស់យើងបានគឺមានតែទ្រង់មួយប៉ុណ្ណោះដែលជាទីជិតស្និទ្ធនៃព្រះវរបិតាដែលអាចសំដែងឲ្យស្គាល់ទ្រង់(ព្រះវរបិតា)បាន។គឺមានតែព្រះអង្គតែមួយប៉ុណ្ណោះដែលដឹងនូវកំពស់និងជំរៅនៃសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ហើយអាចបង្ហាញនូវសេចក្ដីនេះបាន។គ្មានអ្វីក្រៅពីព្រះមហាពលិកម្មដ៏កាត់ថ្លៃ

ពុំបានដែលព្រះគ្រីស្ទជាម្ចាស់បានធ្វើដើម្បីមនុស្សមានបាបនោះទេដែលអា

ចសំដែងនូវសេចក្តីស្រលាញ់នៃព្រះវរបិតាចំពោះមនុស្សជាតិដែលបាត់បង់។

ព្រះវរបិតាទ្រង់ស្រលាញ់មនុស្សលោកដល់ម្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គមកដល់យើង។ ព្រះអង្គទ្រង់ប្រទានព្រះរាជបុត្រាមិនត្រឹមតែឲ្យមករស់នៅក្នុងចំណោមមនុស្សប៉ុណ្ណោះទេតែឲ្យមកទទួលអំពើបាបរបស់មនុស្សនិងសុគតដើម្បីជាដង្វាយលោះបាបដល់យើង។ព្រះវរបិតាបានប្រទានឲ្យព្រះគ្រិស្ទទៅកាន់សាសន៍ដែលវង្វេងពីទ្រង់។គេសំគាល់ឃើញទ្រង់យកព្រះទ័យទុកដាក់នឹងផលប្រយោជន៍និងសេចក្តីត្រូវការរបស់មនុស្សជាតិ។ព្រះអម្ចាស់ដែលធ្លាប់គង់ជាមួយព្រះវរបិតាបានផ្សារភ្ជាប់ព្រះអង្គទ្រង់ទៅនឹងមនុស្សជាតិដោយចំណងពិសេសមួ

យដែលមិនអាចបំបែកបំបាក់បាន។ព្រះយេស៊ូ“មិនខ្មាសនឹងគេហៅបងប្អូនទេ”
ហេព្រើ២:១១។ព្រះអង្គគឺជាដង្វាយលោះបាបរបស់យើងជាមេធាវីរបស់យើងជាបងប្អូនរបស់យើងដែលបានយកសណ្ឋានជាមនុស្សនៅចំពោះបល្ល័ង្កព្រះវរបិតា។ទ្រង់គឺជាកូនមនុស្សដែលគង់នៅជាមួយរាស្ត្រទ្រង់បានប្រោសលោះហើយ
ជាដរាបអស់កល្ប។ដោយសារអំពើទាំងនេះហើយទើបមនុស្សអាចត្រូវបានលើកឡើងអំពីភាពខ្មៅចខ្វាំនិងថោកទាបនៃអំពើបាបហើយអាចឆ្លុះបញ្ចាំងឲ្យឃើញនូវសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់និងរួមចំណែកដោយអំណរក្នុងភាពបរិសុទ្ធ។

ព្រះវរបិតានៃនគរស្ថានសួគ៌ដែលបានប្រទានព្រះរាជបុត្រារបស់ទ្រង់មកសុគតជំនួសយើងជាពលិកម្មដ៏ថ្លៃថ្លានោះគួរតែយើងរាល់គ្នាយល់ដឹងថាតើយើងគប្បីក្លាយខ្លួនទៅជាមនុស្សបែបណាតាមរយៈព្រះគ្រិស្ត។នៅពេលដែលសាវ័កយ៉ូហាននៅមានជីវិតនៅឡើយនោះលោកបានសង្កេតមើលនិងយល់នូវកំពស់និងជំរៅទំហំនៃសេចក្តីស្រលាញ់របស់ព្រះវរបិតាទៅកាន់សាសន៍ដែលកំពុងវិនាសអន្តរធាន។លោកមានសេចក្តីស្រលាញ់ដ៏ធំធេងព្រមទាំងសេចក្តីគោរពដ៏ជ្រាលជ្រៅរហូតដល់លោកមិនអាចរកពាក្យណាមកបញ្ជាក់ឲ្យបានស័ក្តសមនឹងសេចក្តីស្រលាញ់ដ៏ធំធេងនិងស្រទន់របស់ព្រះជាម្ចាស់បានឡើយ។គាត់បានហៅមនុស្សទាំងឡាយឲ្យសង្កេតមើលការទាំងនេះ។“

មើលសេចក្ដីស្រលាញ់យ៉ាងណាហ្ន៎ដែលព្រះវរបិតាផ្ដល់ឲ្យយើងរាល់គ្នាឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ” ..យ៉ូហានទី១ ៣:១។ឱ!
មនុស្សលោកមានតម្លៃយ៉ាងណាហ្ន៎ធំចំពោះព្រះនេត្រទ្រង់។ដោយសារការបំពានលើក្រិត្យវិន័យមនុស្សបានធ្លាក់ចុះទៅក្នុងអំណាចរបស់អារក្សសាតាំង។ក៏ប៉ុន្តែដោយសារការជឿទុកចិត្តក្នុងការបូជាជីវិតរបស់ព្រះគ្រិស្ទដើម្បីលោះបាបនៃយើងនោះកូនចៅអាដ័មបានត្រលប់ក្លាយជាកូនព្រះវិញ។ព្រះយេស៊ូបានយោនយកជាតិជាមនុស្សដើម្បីលើកស្ទួយមនុស្សជាតិ។តាមរយៈទំនាក់ទំនងនឹងព្រះយេស៊ូគ្រិស្ទមនុស្សដែលបានធ្លាក់ចុះក្នុងអំពើបាបបានត្រូវទទួលកន្លែងមួយដែលស័ក្តសមនឹងឈ្មោះថាជា “កូនព្រះ” ។

សេចក្តីស្រលាញ់បែបនេះគឺរកអ្វីមកប្រៀបផ្ទឹមស្មើពុំបានឡើយ។យើងនឹងសូរស៊ើចសរសើរដល់ព្រះឥតឈប់ឈរដោយឧទានសព្ទទាំងឡាយថា:យើងជាកូននៃព្រះអម្ចាស់សួគ៌! ឱ!
សេចក្តីសន្យារបស់ព្រះដល់យើងពិសិដ្ឋថ្លៃថ្លាមែន! ឱ!
នេះពិតជារឿងរ៉ាវមួយយ៉ាងសំខាន់សំរាប់ឲ្យយើងខ្ញុំផ្ចង់គំនិតគិតសញ្ជឹងដ៏ជ្រាលជ្រៅមែនហើយ!
ឱ!សេចក្តីស្រលាញ់របស់ព្រះដែលឥតមានអ្វីប្រៀបដូចបានចំពោះលោកិយដែលមិនស្រលាញ់ទ្រង់សោះ!
ឱ!ព្រះតំរិះដែលប្រកបដោយអំណាចធំលើសអស់
ទាំងព្រលឹងដែលអាចប្រមូលយកវិញ្ញាណឲ្យចុះចូលនឹងព្រះហប្ញទ័យនៃព្រះ!

កាលណាយើងសិក្សាកាន់តែច្រើនអំពីបុគ្គលិកលក្ខណៈនៃព្រះជាម្ចាស់តាមរយៈឈើឆ្កាងទ្រង់នោះយើងនឹងយល់កាន់តែច្បាស់ថែមទៀតអំពីសេចក្តីមេត្តាករុណាភាពទន់ភ្លន់និងលើកលែងទោស (នៃអំពើបាប)
ដែលលាយនឹងសមភាពនិងយុត្តិធម៌របស់ព្រះជាម្ចាស់។យើងនឹងឃើញកាន់តែច្បាស់ថែមទៀតនូវភ័ស្តុតាងនៃសេចក្តីស្រលាញ់មួយដែលឥតព្រំដែនសេចក្តីស្រលាញ់នៃព្រះលប់លើផងសេចក្តីអាណិតអាសូរដែលមាតាមានដល់កូនដែលឃ្លាតចេញពីខ្លួនទៅឥតទីដៅទៅទៀត។

# ជំពូក ២ — សេចក្ដីត្រូវការព្រះគ្រិស្ទរបស់បាបជន

កាលពីដំបូង ធម្មជាតិ បានផ្ដល់ដល់មនុស្សនូវអំណាចដ៏ខ្ពង់ខ្ពស់និងគំនិតដែលដឹងការខុសត្រូវដ៏ល្អប្រពៃ។ គេត្រឹមត្រូវឥតខ្ចោះក្នុងភាពជាមនុស្សលោក នឹងបិតក្នុងភាពចុះសំរុងជាមួយព្រះជាម្ចាស់។ ចិត្តគំនិតរបស់គេស្អាតស្អំរីឯគោលបំណងរបស់គេបរិសុទ្ធហ្មត់ហ្មង់ដែរ។ ក៏ប៉ុន្តែដោយសារការមិនស្តាប់បង្គាប់ដល់ព្រះជាម្ចាស់ អំណាចរបស់គេត្រូវបាននាំធ្លាក់ចុះទៅក្នុងផ្លូវអាក្រក់ ហើយអត្តទត្ថភាពឬភាពអាត្មានិយម(Selfishness)ក៏ចូល

មកជំនួសសេចក្តីស្រលាញ់ទៅវិញ។
សភាវធម្មជាតិរបស់គេក៏ចុះទន់ខ្សោយ
ដោយសារអំពើបាបដែលមិនអាចឲ្យ
គេពឹងផ្អែកលើកម្លាំងខ្លួនផ្ទាល់
ដើម្បីប្រឆាំងទប់ទល់នឹងអំណាចរបស់
អារក្សបានឡើយ។
គេបានធ្លាក់ចុះក្នុងកណ្តាប់ដៃរបស់អារ
ក្សសាតាំង
ហើយនឹងត្រូវស្ថិតនៅទីនេះជារៀងរហូ
ត
ប្រសិនបើព្រះជាម្ចាស់មិនបានជួយញៀ
កគេចេញទេនោះ។
គោលបំណងរបស់មេល្បងគឺធ្វើយ៉ាង
ណាឲ្យរាំងស្ទះផែនការនៃព្រះជាម្ចាស់
ក្នុងការបង្កើតមនុស្សជាតិ
នឹងធ្វើឲ្យពិភពលោកពោរពេញទៅដោ
យភពសត្រូវ
និងភាពក្រៀមក្រោះស្វិតស្រពោន។

ដល់ពេលនោះវា(អារ័ក្ស)នឹងចង្អុលបង្ហាញទៅអំពើទុច្ចរិតទាំងនោះថាជាលទ្ធផលនៃកិច្ចការរបស់ព្រះជាម្ចាស់ក្នុងការបង្កបង្កើតមនុស្សលោក។

—

កាលអំពើបាបមិនទាន់ចូលមកក្នុងលោកនេះ មនុស្សសប្បាយរីករាយនឹងទំនាក់ទំនងជាមួយព្រះ“ ដែលមានគ្រប់ទាំងផលថ្លៃវិសេសនៃប្រាជ្ញា និងចំណេះដឹង ដែលលាក់ទុកក្នុងទ្រង់ ”..កូលុស ២:៣។ ប៉ុន្តែបន្ទាប់ពីឋិតក្នុងអំពើបាបមក គេមិនអាចស្វែងរកឃើញនូវសេចក្តីសប្បាយរីករាយក្នុងភាពបរិសុទ្ធតទៅទៀតបានឡើយតែផ្ទុយទៅវិញគេខំគេច

វេះចេញអំពីវត្តមាននៃព្រះជាម្ចាស់។ សភាពបែបនេះគឺនៅតែមានចំពោះអ្នកដែលមិនបានកែប្រែចិត្តជាថ្មី។ ដោយគ្មាន ការចុះសំរុងជាមួយព្រះជាម្ចាស់ គេមិនអាចមានអំណរក្នុងទំនាក់ទំនងជាមួយទ្រង់ឡើយ។ មនុស្សមានបាបមិនអាចមានអំណរចំពោះវត្តមាននៃព្រះបានឡើយ គេនឹងគេចចេញពីការរួមប្រាស្រ័យ និងសេចក្តីមេត្រីជាមួយព្រះ។ប្រសិនបើគេអាចទទួលការអនុញ្ញាតិឲ្យចូលទៅកាន់ឋានសួគ៌ ក៏គេមិនមានសេចក្តីអំណររីករាយបានដែរ ព្រោះព្រះវិញ្ញាណនៃសេចក្តីស្រលាញ់ដ៏ទូលំទូលាយដែលគ្រងរាជ្យនៅទីនោះ..ចិត្តដែលឆ្លើយតបទៅនឹងសេច

ក្តីស្រលាញ់ដ៏គ្មានព្រំដែននឹងគ្មានន័យ
ចំពោះគេសោះឡើយ។
គំនិតរបស់គេ..ចំណង់ចំណូលចិត្តរប
ស់គេ មូលហេតុរបស់គេ
នឹងប្លែកពីអស់អ្នកផង
ដែលបណ្តាលឲ្យកើតក្តីក្តៅក្រហាយចំ
ពោះអ្នកដែលគ្មានបាបដែលរស់នៅទី
នោះ។ គេនឹងទៅជាភ្លាវតែឯង
មិនចុះសំរុងនឹងបទភ្លេងនៃស្ថានសួគ៌
ឡើយ។
ស្ថានសួគ៌នឹងក្លាយទៅជាកន្លែងធ្វើទ
ណ្ឌកម្មចំពោះរូបគេ។
គេនឹងខំលាក់ខ្លួនពួនអាត្មាអំពីព្រះដែ
លជាពន្លឺ
និងជាប្រភពនៃអំណររីករាយនៃនគរ
ឋានសួគ៌។ ខាងឯព្រះជាម្ចាស់
ពុំមានក្រិត្យក្រមណាដែលបដិសេធម
នុស្សអាក្រក់អំពីឋានសួគ៌នេះឡើយ

គឺខ្លួនគេផ្ទាល់បានធ្លាក់ចេញដោយខ្លួនឯងដោយការមិនត្រូវធាតុនឹងបរិយាកាសនៃនគរស្ថានសួគ៌។
សិរីល្អនៃព្រះជាម្ចាស់នឹងក្លាយជាភ្លើងដែលឆេះបំផ្លាញរូបគេ។
គេនឹងស្វែគមន៍ដល់ហាយនភាព
ព្រោះគេបានលាក់មុខអំពីព្រះភ័ក្រនៃព្រះជាម្ចាស់
ដែលសុគតដើម្បីជាថ្ងៃលោះប្រោសចំពោះរូបគេ។

អ្នកដែលបានលិចលង់ក្នុងជ្រោះនៃបាបកម្មទៅហើយនោះ
មិនអាចក្រោកចេញពីទីនោះបានដោយខ្លួនឯងឡើយ។
ចិត្តរបស់មនុស្សពោរពេញទៅដោយអំពើទុច្ចរិតដែលមិនអាចផ្លាស់ប្តូរបានទ្បើយ។ “

តើមានអ្នកណាអាចយកវត្ថុស្អាតចេញពីរបស់ស្មោគគ្រោកបានទេ?
គឺគ្មាននរណាអាចធ្វើបានទេ”
..យ៉ូប១៤:៤។“ព្រោះគំនិតខាងសាច់ឈាមនោះរមែងទាស់ទទឹងនឹងព្រះ
ឥឡិតមិនចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង ”
..រ៉ូម៨:៧។ចំណោះវិជ្ជាអរិយធម៌
ការប្រព្រឹត្តិក្នុងឆន្ទៈ
ការប្រឹងប្រែងរបស់មនុស្សសុទ្ធតែមានទីកំណាត់ត្រឹមត្រូវ
ក៏ប៉ុន្តែនៅទីនេះវាគ្មានឥទ្ធិពលអ្វីឡើយ
។
គេអាចបង្ហាញឲ្យឃើញនូវភាពត្រឹមត្រូវនៃផ្នែកខាងក្រៅដោយអកប្បកិរិយា
ក៏ប៉ុន្តែគេមិនអាចផ្លាស់ប្តូរចិត្ត(ផ្នែកខាងក្នុង)បានឡើយ..គេមិនអាចបន្សុទ្ធដំណើរល្ហូតលាស់នៃជីវិតបានទេ។

ត្រូវតែមានអំណាចមួយដែល
ធ្វើការពូជផ្ទៃក្នុងចិត្ត
គឺជាជីវិតថ្មីមួយដែលមកអំពីស្ថានសួគ៌
ដែលនាំមនុស្សឲ្យផ្លាស់ប្រែអំពើបាប
ទៅកាន់ភាបរិសុទ្ធ។
អំណាចនោះគឺព្រះគ្រិស្ទ។
ព្រះគុណរបស់ទ្រង់មួយព្រះអង្គប៉ុណ្ណោះ
អាចធ្វើឲ្យព្រលឹងដែលគ្មានជីវិតរបស់
មនុស្សបំផ្លាស់ប្រែហើយនាំគេទៅកាន់
ព្រះជាម្ចាស់
និងទៅកាន់ភាពបរិសុទ្ធឥតក្ដីមោះមន្ទិល។

ព្រះអង្គសង្គ្រោះមានបន្ទូលថា: “
លើកលែងតែមនុស្សដែលកើតអំពីស្ថានសួគ៌
”ស្ដីកណាតែគេបានទទួលនូវចិត្តថ្មី

ចំណង់ថ្មី គោលបំណង
និងបុព្វហេតុថ្មីដែលនាំទៅកាន់ជីវិតថ្មី
ពុំនោះទេ “
គេមិនអាចឃើញនគរព្រះបានទេ ”
..យ៉ូហាន៣:៣។គំនិតដែលគិតថា
ការចាំបាច់ដែលមនុស្សត្រូវធ្វើ
ជាការធ្វើតែអំពើល្អដែលចំរើនលូតលា
ស់ដោយឯកឯងនោះ
គឺជាការបោកបំភ័ន្តមួយដែលប្រកប
ដោយគ្រោះថ្នាក់។ “
ប៉ុន្តែមនុស្សខាងសាច់ឈាម
គេមិនទទួលសេចក្តីខាងព្រះវិញ្ញាណ
នៃព្រះទេ
ដោយគេយល់ថាជាសេចក្តីចំកួតដល់
គេ ក៏នឹងរកយល់មិនបានផង
ត្បិតត្រង់សេចក្តីនេះ
ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ
”..កូរិនថូសទី ១ ២:១៤។

ព្រះយេស៊ូមានព្រះបន្ទូលថា: “
កុំឲ្យឆ្ងល់ពីពាក្យដែល
ខ្ញុំប្រាប់ថាអ្នកត្រូវកើតជាថ្មីនោះឡើយ
” ..យ៉ូហាន ៣:៧។
ព្រះគម្ពីរបានចារិកទុកអំពីព្រះគ្រិស្ទ
ថា:

“ អ្នកដែលបានលិចលង់
ក្នុងជ្រោះនៃបាបកម្មទៅហើយះ
មិនអាចក្រោកចេញពីទីនោះ
ដោយខ្លួនឯងបានឡើយ។ ”

“ ក្នុងអង្គទ្រង់មានជីវិត
ហើយជីវិតនោះជាពន្លឺដល់អស់ទាំងម
នុស្សលោក ” ..យ៉ូហាន ១:៤។ “
គ្មាននាមណាទៀតបានប្រទានមកមនុ
ស្សលោក
ឲ្យយើងរាល់គ្នាបានសេចក្ដីសង្គ្រោះ

នោះឡើយ
គឺមានតែនាមព្រះយេស៊ូមួយប៉ុណ្ណោះ
ដែលផ្ដល់មកក្នុងចំណោមមនុស្សនៅ
លើលោកនេះ
ដែលយើងអាចបានសេចក្ដីសង្គ្រោះ ”
..កិច្ចការ ៤:១២។

យើងនៅតែមិនអាចយល់បានសេចក្ដី
មេត្រីសប្បុរសរបស់ព្រះជាម្ចាស់
និងអត្តចរិករបស់ទ្រង់
ដែលមានការមេត្តាប្រណី
និងការថ្នាក់ថ្នមដ៏ស្រទន់ដូចឪពុកមាន
ដល់កូននោះឡើយ។
យើងនៅតែមិនទាន់ស្កប់ចិត្តគ្រប់គ្រាន់
ល្មមនឹងដឹងយល់នូវប្រាជ្ញាញាណនិង
គតិយុត្តិធម៌នៃក្រឹត្យវិន័យរបស់ទ្រង់
ទោះបីជាបានឃើញថា
ក្រឹត្យវិន័យនោះបានស្ថាបនានៅលើគុ

រិះដ៏នៅអស់កល្បនៃសេចក្តីស្រលាញ់
ក៏ដោយ។
សាវ័កប៉ុលបានឃើញនូវការទាំងអស់
នេះ
ដែលគាត់បានឧទានឡើងយ៉ាងឱឡារិ
កថា: "
ខ្ញុំយល់ព្រមថាក្រិត្យវិន័យនេះល្អមែន "
..រ៉ូម៧:១៦។ "
ដូច្នេះក្រិត្យវិន័យបរិសុទ្ធ
ហើយសេចក្តីបញ្ញត្តិទ្រង់ក៏បរិសុទ្ធដែរ
"

..រ៉ូម៧:១២ប៉ុន្តែគាត់បានពោលបន្ថែម
ដោយពាក្យជូរចត់ដោយទង្គិះចិត្តនិងអ
ស់សង្ឃឹមថា: "
ឯខ្ញុំនៅខាងសាច់ឈាម( )វិញ
ដោយបានត្រូវលក់ទៅក្នុងអំណាចនៃ
អំពើបាប " ..រ៉ូម ៧:១៤។
សាវ័កប៉ុលប្រាថ្នាចង់បានយ៉ាងខ្លាំងនូវ

ភាពបរិសុទ្ធ
និងសេចក្ដីសុច្ចរិតដែលខ្លួនគាត់ផ្ទាល់
គ្មានអំណាចនឹងធ្វើឲ្យសំរេចបាន
ទើបគាត់ស្រែកឡើងថា: "
វេទនាណាស់ខ្ញុំ
តើនរណាអាចនឹងជួយឲ្យខ្ញុំរួចអំពីតួនៃ
សេចក្ដីស្លាប់នេះទៅបាន? " ..រ៉ូម
៧:២៤។ គេឮសម្រែកបែបនេះ
ពីមនុស្សដែលមានបន្ទុកដ៏ធ្ងន់ធ្ងរក្នុងផ្លូ
វចិត្តចេញពីគ្រប់មជ្ឈដ្ឋាន
និងគ្រប់យុគសម័យ។
ចំពោះបញ្ហាទាំងអស់នេះ
គឺមានតែចម្លើយមួយគត់ដូចមានចារិក
ទុកមកក្នុងព្រះគម្ពីរយ៉ូហាន ១:២៩
ថា: " នុះ ន៎!
កូនចៀមនៃព្រះជាអម្ចាស់ដែលដោះ
បាបមនុស្សលោក"។

—
មានការប្រៀបប្រដូចជាច្រើនដែលព្រះវិញ្ញាណបរិសុទ្ធនៃព្រះបានព្យាយាមនឹងបើកបង្ហាញនូវសច្ចៈធម៌ទាំងនេះ និងធ្វើឲ្យអ្នកដែលប្រាថ្នាចង់ឲ្យរួចអំពីបន្ទុកនៃទោសកំហុសនេះយល់បានដោយងាយ។
បន្ទាប់ពីបានបោកបញ្ឆោតអេសាវហើយយ៉ាកុបបានរត់គេចចេញពីគេហដ្ឋានរបស់ឪពុកគាត់។
យ៉ាកុបកើតក្តីព្រួយដែលចិត្តរបស់គាត់ប្រកបដោយពិរុទ្ធភាព។
គាត់នៅយ៉ាងត្រម៉ង់ត្រមោចនិងដាច់សង្វេង
ដោយឃ្លាតចាកចេញពីការរស់នៅដែលធ្លាប់តែមានការស្រលាញ់ថ្នាក់ថ្នម។
ពេលនោះមានគំនិតមួយដែលលប់លើសេចក្តីកង្វល់ផងនានា

បានដាក់សម្ពាធទៅលើព្រលឹងវិញ្ញាណរបស់គាត់
គឺការភ័យខ្លាចក្រែងអំពើបាបនោះពង្រាត់គាត់ចេញពីព្រះជាម្ចាស់
ហើយព្រះនឹងបោះបង់ចោលរូបគាត់។ យ៉ាកុបប្រុះខ្លួនទំរេតសំរាកទាំងក្តីក្រៀមក្រំ នៅទីដែលហ៊ុំព័ទ្ធដោយភាពឯកាឯនាយឮដំមេឃាមានតែហ្វូងគោរានិករកំដរពេលរាត្រីមួយដ៏ស្ងាត់ជ្រងំ។ នៅពេលដែលគាត់កំពុងនិន្ទ្រាលង់លក់នោះ
ស្រាប់តែមានពន្លឺចំលែកមួយបានលេចមកបង្ហាញចំពោះគាត់ មើលន៎!
ពីដីទីវាលរាបដែលគាត់សំរាន្តនោះ
មានរាងជាជណ្តើរធំមួយ
ដែលភ្ជាប់ពីផែនដីឡើងឆ្ពោះទៅកាន់ទ្វារនៃនគរស្ថានសួគ៌
ហើយនៅលើជណ្តើរនោះមានពពួកទេ

វតានៃព្រះកំពុងឡើងចុះត្រសង។
នៅឯខាងលើដែលជាទីប្រកបដោយ
សិរីល្អ
មានសម្លេងព្រះជាម្ចាស់ដែលផ្តល់នូវ
សារនៃសេចក្តីល្អងលោម
និងសេចក្តីសង្ឃឹម។
កិច្ចការទាំងនោះបានសំដែងមកចំ
ពោះមុខយ៉ាកុប
ដែលត្រូវនឹងសេចក្តីត្រូវការនិងសេចក្តី
ប៉ងប្រាថ្នានៃព្រលឹងវិញ្ញាណរបស់គាត់
..គឺសេចក្តីត្រូវការព្រះអង្គសង្គ្រោះ។
គាត់មានសេចក្តីអំណររីករាយនិងសេ
ចក្តីដឹងគុណជាខ្លាំងចំពោះព្រះ
ដែលបានបង្ហាញឲ្យគាត់ឃើញផ្លូវមួយ
ដែលមនុស្សមានបាបដូចជាគាត់អាច
ស្ថាបនាសម្ពន្ធភាពជាថ្មីឡើងវិញជាមួ
យព្រះអម្ចាស់។
ជណ្តើរអាថ៌កំបាំងនៃសុបិន្តនិម្មិតរបស់

គាត់តំណាងព្រះយេស៊ូដែលទ្រង់នោះ
ហើយជាមធ្យោបាយនិងជាមជ្ឈបុគ្គល
ដែលឋិតនៅចន្លោះយើងហើយនិងព្
រះវរបិតា។

សេចក្តីប្រៀបប្រដូចគ្នានេះដូចគ្នានឹងរូ
បភាពដែលព្រះយេស៊ូបានលើកសន្ទ
នាជាមួយនឹងណាថាណែល
ដែលនៅក្នុងពេលនោះព្រះអង្គទ្រង់មា
នបន្ទូលថា: "
អ្នកពាំល់គ្នានឹងឃើញមេឃបើកចំហ
និងពពួកទេវតានៃព្រះវរបិតានៃព្រះជា
ម្ចាស់ហោះឡើងចុះលើកូនមនុស្ស "
..យ៉ូហាន ១:៥១។
ដោយសារការបោះបង់ចោលសេចក្តីជំ
នឿ
មនុស្សបានផ្តាច់ភាពជិតស្និទ្ធរបស់ខ្លួន
អំពីព្រះជាម្ចាស់។ផែនដីត្រូវបានផ្តាច់

ចេញពីស្ថានសួគ៌ប្រៀបបាននឹងសមុទ្រ
ដែលធ្វើឲ្យទីកន្លែងពីរដាច់ស្រលះពីគ្នា។
ប៉ុន្តែតាមរយៈព្រះគ្រិស្ទផែនដីត្រូវបានផ្សាភ្ជាប់សារជាថ្មីឡើងវិញជាមួយស្ថានសួគ៌។
ដោយសារព្រះគុណព្រះអង្គផ្ទាល់
ព្រះគ្រិស្ទបានធ្វើជាស្ពានសំរាប់ឆ្លងកាត់លើសមុទ្រដែលអំពើបាបបានបង្កើតមក
ប្រយោជន៍ឲ្យពពួកទេវតាផ្សាយដំណឹងល្អអាចភ្ជាប់ទំនាក់ទំនងជាមួយមនុស្សលោកបាន។
ព្រះគ្រិស្ទភ្ជាប់មនុស្សមានបាបដែលមានភាពទន់ខ្សោយ
និងឯកោតែលតោលទៅនឹងប្រភពនៃអំណាចមួយដ៏គ្មានព្រំដែនកំណត់។

— ប៉ុន្តែជាការឥតប្រយោជន៍ទទេ ចំពោះការយល់សប្តិរវើរវាយរបស់មនុស្សនិងជាការឥតប្រយោជន៍សោះ ដែលមនុស្សប្រឹងលើកស្ទួយខ្លួនឯង ប្រសិនបើគេមិនយកចិត្តទុកដាក់នឹង “ ប្រភព ” មួយដែលជាក្តីសង្ឃឹម និងជាជំនួយចំពោះ សាសន៍ ដែលបាត់បង់។

“ គ្រប់ទាំងរបស់ដ៏ល្អ និងគ្រប់ទាំងរបស់ដ៏ឥតខ្ចោះ គឺមកពីព្រះជាម្ចាស់ ” ..យ៉ាកុប១:១៧។ ក្រៅអំពីទ្រង់ពុំមានអត្តចរិកដ៏ឥតខ្ចោះ ពិតប្រាកដសោះឡើយ។ ផ្លូវដែលនាំទៅព្រះវរបិតានោះមានតែមួយគត់ គឺតាមរយៈព្រះគ្រិស្ទ។ ព្រះអង្គមានបន្ទូលថា: “ខ្ញុំជាផ្លូវ

ជាសេចក្តីពិតនិងជីវិត
បើមិនមកតាមខ្ញុំនោះអ្នកគ្មានអ្នកណា
ទៅឯព្រះវរបិតាបានឡើយ”..យ៉ូហាន
១៤:៦។

ព្រះហឫទ័យព្រះវរបិតា
អាណិតអាសូរដោយក្តីស្រលាញ់
ចំពោះមនុស្សទាំងអស់ដែលរស់នៅ
លើលោកិយនេះគឺធំជាងសេចក្តីស្លាប់
ទៅទៀត។
តាមរយៈការលះបង់ព្រះរាជបុត្រារប
ស់ទ្រង់ៗបានផ្តល់ដល់យើង
នូវអំណោយមកពីស្ថានសួគ៌។ ព្រះជន្ម
ការសុគត
សេចក្តីអង្វរកររបស់ព្រះអង្គសង្គ្រោះជំ
នួសយើងរាល់គ្នាកិច្ចការបរិសុទ្ធរបស់
ពពួកទេវតា
សេចក្តីអំពាវនាវនៃព្រះវិញ្ញាណបរិសុទ្ធ

..ព្រះវរបិតាដែលធ្វើការក្នុងគ្រប់អ្វីៗទាំងអស់
ដោយឥតឈប់ឈរជាមួយទេវតាទ្រង់គឺដើម្បីជាកិច្ចជួយប្រោសលោះដល់យើងរាល់គ្នា។

— សូមយើងទាំងអស់គ្នាសម្លឹងមើលទៅពលីកម្មដ៏គួរឲ្យស្ញប់ស្ញែងដែលព្រះបានប្រទានមកឲ្យយើង!
ចូរយើងសរសើរតំកើងនូវកិច្ចការនិងថាមពលដែលនគរឋានសួគ៌បានចំណាយដើម្បីប្រមូលយកមកវិញនូវមនុស្សដែលបាត់បង់
ហើយនាំគេត្រឡប់ទៅកាន់នរគរព្រះវរបិតាវិញ។ ទោះបីជាឥទ្ធិពលដ៏ខ្លាំងក្លាឬទីភ្នាក់ងារទាំងឡាយណា
ដែលមានអំណាចក៏មិនដែលធ្វើកិច្ចកា

រនេះដែរៗរង្វាន់ដ៏លើសលប់ចំពោះសេចក្តីល្អត្រឹមត្រូវ
អំណររីករាយនៃស្ថានសួគ៌
សង្គមនៃពពួកទេវតា ការរួមប្រាស្រ័យ
និងសេចក្តីស្រលាញ់នៃព្រះវរបិតានិងព្រះរាជបុត្រា
ការលើកតំកើងនិងការចំរើនកំលាំងអំណាចដល់យើងក្នុងគ្រប់យុគសម័យដ៏អស់កល្ប..តើកិច្ចការទាំងអស់នេះមិនមែនជាគ្រឿងលើកទឹកចិត្ត
ដែលជំរុញឲ្យយើងប្រគល់ចិត្តនិងសេចក្តីស្រលាញ់របស់យើងដល់ព្រះដែលជាព្រះអាទិករ
និងជាព្រះដ៏ប្រោសលោះរបស់យើងទេឬអ្វី?

ហើយម្យ៉ាងទៀត
ការវិនិច្ឆ័យនៃព្រះជាម្ចាស់បានប្រកាស

ប្រឆាំងនឹង “ អំពើបាប ”..ពៀរវេរាដែលមិនអាចចៀសផុត ការបន្ទាបបន្ថោកនូវចរិតលក្ខណៈរបស់យើង
និងហាយនភាពចុងក្រោយបង្អស់បានបង្ហាញឲ្យឃើញក្នុងព្រះបន្ទូលព្រះជាម្ចាស់ដែលព្រមានយើង
ឲ្យចៀសវាងពីគ្រប់សកម្មភាពរបស់អារក្សសាតាំង។

តើយើងនឹងមិនទទួលយកសេចក្ដីអាណិតអាសូររបស់ព្រះជាម្ចាស់ទេឬអី? តើយើងចង់ឲ្យទ្រង់ធ្វើអ្វីថែមទៀតសំរាប់យើង?
ចូរយើងស្ថាបនាទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះជាម្ចាស់
ដែលទ្រង់បានស្រលាញ់យើងដោយសេចក្ដីស្រលាញ់ដ៏មហាស្ចារ្យរបស់ទ្រ

ង់។
សូមឲ្យយើងមានពេលគិតគូរចំពោះម
ធ្យោបាយដែលប្រកបដោយអំណាច
បំផ្លាស់បំប្រែខ្លួនយើងឲ្យបានដូចអង្គទ្
រង់..
ឲ្យយើងអាចទទួលនូវភាពដូចដើមវិញ
ដែលយើងអាចឋិតនៅជាមេត្រីមិត្តនឹង
ពពួកទេវតារបស់ព្រះហើយនិងឲ្យមាន
ភាពចុះសំរុង
ក្នុងការរួមប្រស្រ័យជិតស្និទ្ធជាមួយព្រះ
វរបិតានឹងព្រះរាជបុត្រា។

# ជំពូកទី ៣ — ការប្រែចិត្ត

តើមនុស្សលោកអាចល្អបរិសុទ្ធចំពោះព្រះយ៉ាងដូចម្តេច? តើធ្វើយ៉ាងដូចម្តេចដើម្បីឲ្យបាបជនក្លាយទៅជាមនុស្សសុចរិតទៅបាន? គឺមានតែតាមរយៈព្រះគ្រិស្ទមួយប៉ុណ្ណោះដែលទ្រង់នាំយើងទៅកាន់ភាពចុះសំរុងជាមួយព្រះជាម្ចាស់ដោយភាពបរិសុទ្ធ ប៉ុន្តែតើយើងចូលទៅកាន់ព្រះគ្រិស្ទបានដោយរបៀបណា? មានមនុស្សជាច្រើនបានសាកសួរនូវសំណួរដដែលៗនេះ ដូចជាហ្វូងមនុស្សនៅសម័យប៉ង់តាកូស (The Day of Pentecost) នៅពេលដែលដឹងថាមានបាបនោះ

គេបានស្រែកឡើងថា “
តើឲ្យយើងធ្វើដូចម្ដេច?
”ពាក្យដំបូងបង្អស់ក្នុងចំលើយសាវក
តេត្រុសគឺ “ត្រូវឲ្យប្រែចិត្តចុះ ”
..កិច្ចការ ២:៣៧.៣៨។
បន្ទាប់មកទៀតគាត់បានមានប្រសាស
ន៍បន្តថា
“ចូរប្រែចិត្ត..ហើយវិលមកចុះដើម្បីឲ្យ
បាបរបស់អ្នករាល់គ្នាត្រូវបានលុបចោ
លចេញ ”..កិច្ចការ ៣:១៩។

ការប្រែចិត្តគឺមានរួមទាំងការសោកស្តា
យចំពោះអំពើបាប
និងការងាកចេញពីអំពើបាប។
យើងនឹងមិនអាចបោះបង់អំពើបាប
ដើម្បីទទួលការផ្លាស់ប្តូរមួយដ៏ពិតប្រា
កដក្នុងជីវិតបានឡើយ
ប្រសិនបើយើងមិនស្គាល់អ្វីទៅជាអំពើ

បាប ហើយប្រសិនបើយើងមិនបានងាកចេញអំពីអំពើបាបនោះ ដោយអស់ពីចិត្តទេនោះ។

មានមនុស្សជាច្រើនដែលមិនយល់ពីលក្ខណៈពិតនៃការប្រែចិត្ត។ មនុស្សដ៏ច្រើនឥតគណនាមានសេចក្ដីព្រួយកង្វល់ដោយដឹងថាគេបានធ្វើអំពើបាប ហើយគេរមែងតែងតែប្រឹងប្រែងសំអិតសំអាងកែទំរង់តែផ្នែកខាងក្រៅ ហើយខំរំពឹងសង្ឃឹមក្នុងចិត្តថា ការនោះនឹងអាចជួយឲ្យគេបានរួចផុតពីសេចក្ដីវេទនា ដែលជាផលនៃបាបកម្មដែលគេបានសាង។ ក៏ប៉ុន្តែទង្វើបែបនេះពុំមែនជាការប្រែចិ

ត្តដែលត្រូវតាមន័យនៃព្រះគម្ពីរបរិសុទ្ធ
របស់ព្រះឡើយ។
គេទូញសោកចំពោះទុក្ខវេទនាជាជាង
ចំពោះអំពើបាប
ដូចជាសេចក្ដីសោកសង្រេងរបស់អេសាវ
នៅពេលដែលគាត់ឃើញថាសិទ្ធពីកំណើត (Birthright)
របស់គាត់ត្រូវបានបាត់បង់ពីគាត់រហូត
។ បាឡាមភ័យតក្កមាពេល
ឃើញទេវតាឈរនៅតាមផ្លូវ
ដែលគាត់ដើរទៅ
មានទាំងដាវដកហូតពីស្រោមថាំជាស្រេច។
គាត់ដឹងកំហុសរបស់គាត់ហើយភ័យខ្លាចចំពោះសេចក្ដីស្លាប់
ក៏ប៉ុន្តែពុំមានការប្រែចិត្តដ៏ពិតប្រាកដចំពោះអំពើបាបឡើយ..គ្មានការផ្លាស់ប្ដូរ

សេចក្ដីប៉ងប្រាថ្នា
និងគ្មានសេចក្ដីស្អប់ខ្ពើមចំពោះអំពើបាបឡើយ។
បន្ទាប់ពីបានក្បត់ព្រះជាម្ចាស់យូដាសអ៊ីស្ការីយ៉ុតបានស្រែកឡើងថាៈ
“ខ្ញុំបានធ្វើបាប
ដោយបានក្បត់នូវឈាមដែលគ្មានទោស ”..ម៉ាថាយ ២៧:៤។

ការលន់តួបានបង្ហំចេញអំពីព្រលឹងដែលមានកំហុសរបស់យូដាសអ៊ីស្ការីយ៉ុត ព្រោះគេបានដឹងការ
វិនិច្ឆ័យទោសដ៏គួរឲ្យរន្ធត់
និងទិដ្ឋភាពនៃការកាត់ទោសដ៏គួរឲ្យស្ញែងខ្លាច។
ផលវិបាកដែលផ្ដល់ចំពោះគាត់នោះធ្វើឲ្យគាត់ពោរពេញដោយក្ដីរន្ធត់
ក៏ប៉ុន្តែវាគ្មានការឈឺចាប់សោកសង្រេ

ងពិតដល់ទីជំរៅនៃព្រលឹងរបស់គាត់ ដែលបានក្បត់ចំពោះព្រះរាជបុត្រានៃ ព្រះដែលគ្មានអំពើបាបសោះ។ ព្រះថៅផារ៉ោននៅពេលដែលទទួលទុក្ខវេទនាក្រោមការដាក់ទោសពីព្រះជាម្ចាស់នោះបានព្រមទទួលថាបានធ្វើបាបទាស់នឹងព្រះមែន គឺក្នុងគោលបំណងគេចឲ្យផុតពីការដាក់ទណ្ឌកម្មបន្តទៅទៀតតែប៉ុណ្ណោះ ក៏ប៉ុន្តែទ្រង់បានបែរទៅកាន់ចិត្តអស្មិមានៈទាស់ទទឹងនៃអំណាចនៃស្ថានសួគ៌ឡើងវិញ នៅពេលដែលព្រះបានលើកសេចក្តីវេទនា(Plagues)ចេញ។ មនុស្សទាំងអស់នោះគេទួញសោកចំពោះលទ្ធផលនៃអំពើបាប ក៏ប៉ុន្តែគេពុំបានសោកស្តាយចំពោះអំពើបាបឡើយ។

នៅពេលដែលចិត្តបានចុះចូលនឹងឥទ្ធិពល នៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ សតិសម្បជញ្ញៈបានវិលត្រលប់មកវិញយ៉ាងឆាប់រហ័ស
ហើយមនុស្សមានបាបនោះនឹងមើលឃើញដល់ទីជំរៅនៃភាពពិសិដ្ឋ នៃក្រិត្យវិន័យបរិសុទ្ធរបស់ព្រះជាម្ចាស់ ដែលជាគ្រឹះនៃការគ្រប់គ្រងរបស់ទ្រង់ នៅលើស្ថានសួគ៌និងផែនដីផង។ “ឯពន្លឺដ៏ពិតនោះគឺជាពន្លឺដែលបំភ្លឺដល់មនុស្សទាំងអស់
ដែលកើតមកក្នុងលោកិយ៍
បំភ្លឺបន្ទប់អាថ៌កំបាំងនៃដួងព្រលឹង និងរបស់ដែលលាក់កំបាំងដោយភាពអន្ធការឲ្យបានឃើញច្បាស់ ”..
យ៉ូហាន ១:៩។
ជំនឿដែលជឿស៊ប់ពិតប្រាកដមានដក់

ជាប់ក្នុងវិញ្ញាណនិងដួងចិត្ត។
មនុស្សមានបាបមានអារម្មណ៍ដឹងពីភា
ពបរិសុទ្ធត្រឹមត្រូវនៃព្រះយេហូវ៉ា
ហើយមានអារម្មណ៍ភ័យខ្លាចនឹងការប
ញ្ចេញខ្លួន
ដែលមានពិរុទ្ធភាពនិងសេចក្តីសោក
គ្រោកចំពោះមុខអ្នកស្វែងរកវិញ្ញាណ
ដែលបាត់បង់។
គេឃើញសេចក្តីស្រលាញ់នៃព្រះជាម្ចា
ស់ សោភ័ណ្ឌភាពនៃសេចក្តីបរិសុទ្ធ
អំណរនៃភាពឥតមន្ទិល
នោះគេក៏មានចំណង់យ៉ាងពុះពោរចង់
បានការជំរះបាប
និងមានទំនាក់ទំនងថ្មីឡើងវិញជាមួយ
នឹងស្ថានសួគ៌។

— សេចក្តីអធិដ្ឋានរបស់ហ្លួងដាវីដ
បន្ទាប់ពីការធ្លាក់ចុះក្នុងអំពើឆ្គាំឆ្គងរប

ស់ទ្រង់នោះ
បានលើកបង្ហាញឲ្យច្បាស់នូវប្រភេទ
នៃការសោកស្ដាយដ៏ពិតប្រាកដចំពោះ
អំពើបាប។
ការប្រែចិត្តរបស់ទ្រង់គឺស្មោះត្រង់និងច្
បាស់លាស់ ដោយគ្មានការព្យាយាម
ដើម្បីបន្ធូរបន្ថយចំពោះកំហុសរបស់ទ្រ
ង់ឡើយ។
ដោយចិត្តរបស់ទ្រង់ដែលគ្មានបំណង
នឹងគេចវេះឲ្យផុតអំពីការកាត់ទោសដែ
លបានរង់ចាំទ្រង់
នោះបណ្ដាលឲ្យទ្រង់អធិស្ឋានទៅរកព្
រះ។
ហ្លួងដាវីដបានមើលឃើញនូវការប្រព្រឹ
ត្តិរំលងដ៏ធំរបស់ទ្រង់
និងបានឃើញនូវការធ្វើឲ្យស្មោកគ្រោ
កដល់ព្រលឹងរបស់ទ្រង់
នោះទ្រង់បានស្អប់ខ្ពើមអំពើបាប!

ទ្រង់មិនគ្រាន់តែអធិដ្ឋានសុំការអត់អោនទោសប៉ុណ្ណោះទេ
ប៉ុន្តែទ្រង់បានសូមឲ្យបានចិត្តបរិសុទ្ធទៀតផង។
ទ្រង់(ហ្លួងដាវីដ)ចង់បានដោយអន្ទះសារនូវសេចក្តីអំណររីករាយក្នុងភាពបរិសុទ្ធ
និងចង់បានទទួលការរួមប្រាស្រ័យផ្ទាល់សារជាថ្មីឡើងវិញជាមួយនឹងព្រះជាម្ចាស់។
ហ្លួងដាវីដបានបន្លឺសម្លេងពីព្រលឹងរបស់ទ្រង់ថា:

“មានពរហើយមនុស្សណាដែលការរំលងរបស់ខ្លួនត្រូវបានអត់ទោស
ឲ្យ
និងអំពើបាបរបស់គេត្រូវបានជូតសំអាតចេញ។

មានពរហើយមនុស្សណាដែលព្រះយេហូវ៉ាមិនរាប់ថាជាអ្នកមានទោស ហើយគ្មានកំហុសនៅក្នុងចិត្តឡើយ។ ” ..ទំនុកតំកើង ៣២:១.២

១..សូមអាណិតមេត្តាដល់ទូលបង្គំតាមសេចក្ដីសប្បុរសរបស់ទ្រង់ ដោយសេចក្ដីមេត្តាករុណាដ៏បរិបូណ៌របស់ទ្រង់ ហើយសូមលុបអំពើរំលងរបស់ទូលបង្គំចេញ ដោយសេចក្ដីមេត្តាករុណាដ៏បរិបូណ៌របស់ទ្រង់។
២..សូមលាងទូលបង្គំឲ្យយ៉ាងស្អាតពីអំពើទុច្ចរិតរបស់ទូលបង្គំ សូមសំអាតអំពើបាបរបស់ទូលបង្គំផង។

៣..ដ្បិតទូលបង្គំទទួលស្គាល់អំពើរំលងរបស់ទូលបង្គំហើយ ឯអំពើបាបរបស់ទូលបង្គំនោះក៏នៅចំពោះមុខទូលបង្គំជានិច្ច។

៧..សូមជំរះដោយមែកហ៊ីសុប នោះទូលបង្គំនឹងបានជ្រះស្អាត សូមដុសលាងទូលបង្គំនោះនឹងបានសជាងហិមៈ។

១០..ឱព្រះអង្គអើយ! សូមបង្កើតចិត្តបរិសុទ្ធក្នុងទូលបង្គំ ហើយកែ វិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើយ ។

១១..សូមកុំបោលទូលបង្គំចេញពីទ្រង់ ហើយសូមកុំដកយកវិញ្ញាណ

បរិសុទ្ធរបស់ទ្រង់ចេញពីទូលបង្គំឡើយ។

១២..សូមឲ្យទូលបង្គំមានចិត្តរីករាយចំពោះសេចក្តីសង្គ្រោះនៃទ្រង់ឡើងវិញ
ហើយទប់ទល់ទូលបង្គំដោយព្រះវិញ្ញាណដ៏សទ្ធានៃទ្រង់។
១៤.ឱព្រះអង្គជាព្រះដ៏ជួយសង្គ្រោះទូលបង្គំអើយ! សូមដោះទូលបង្គំឲ្យរួចពីទោសកំចាយឈាម
ឱព្រះអង្គដ៏សង្គ្រោះរបស់ទូលបង្គំអើយ!
ហើយអណ្តាតទូលបង្គំនឹងច្រៀងសរសើរតំកើងនូវភាព
សប្បុរសរបស់ទ្រង់” ។ .. ទំនុកទំកើង ៥១:១.១៤

ការប្រែចិត្តបែបនេះ
គឺហួសពីសមត្ថភាព
និងអំណាចរបស់យើងផ្ទាល់ដែលអាច
សំរេចទៅបាន។
កិច្ចការទាំងអស់នេះគឺបានមកតែពីអំពី
ព្រះគ្រីស្ទតែប៉ុណ្ណោះ
ដែលទ្រង់យាងឡើងស្ថានដ៏ខ្ពស់បំផុត
ហើយដែលទ្រង់បានប្រទានអំណោយ
ដល់មនុស្សទាំងឡាយ។

ក៏ប៉ុន្តែត្រង់នេះមានចំនុចមួយដែលមនុ
ស្សជាច្រើនភ័ន្តច្រលំដែលជាហេតុប
ណ្តាលឲ្យគេមិនបានទទួលយកសេច
ក្តីជំនួយពីព្រះគ្រិស្ទមានបំណងនឹងផ្ត
ល់ឲ្យគេ។
គេគិតថាគេមិនអាចចូលទៅកាន់ព្រះគ្
រិស្ទបានទេ
ដរាបណាគេបានប្រែចិត្តជាមុនសិនព្

ព្រោះថាការប្រែចិត្តនោះ
នឹងរៀបចំសំរួលផ្លូវដល់ការអត់ទោស
នៃអំពើបាបរបស់គេ។
គឺជាការពិតណាស់ដែលថាការប្រែចិត្ត
ត្រូវមានមុនការអត់ទោស អំពើបាប
ព្រោះថាមានតែចិត្តដែលសោកសង្រេ
ងនិងប្រកបទៅដោយវិប្បដិសារីទេដែ
លត្រូវការព្រះអង្គសង្គ្រោះ។
ប៉ុន្តែតើមនុស្សមានបាបត្រូវរង់ចាំរហូត
ដល់គេប្រែចិត្តសិនទើបគេអាចចូល
ទៅរកព្រះគ្រិស្ទឬ?
តើយើងធ្វើឲ្យការប្រែចិត្តនេះក្លាយជាឧ
បសគ្គរាំងខណ្ឌកណ្តាលយើងនឹងព្រះ
អង្គសង្គ្រោះឬ?

ព្រះគម្ពីរបរិសុទ្ធពុំបានបង្រៀនថាមនុ
ស្សមានបាបត្រូវតែប្រែចិត្តមុនពេលគេ
អាចទទួលនូវការហៅរករបស់ព្រះគ្រិ

ស្ទុះឡើយ។
“អស់អ្នកដែលនឿយព្រួយដែលមានបន្ទុកធ្ងន់អើយ! ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក ”..ម៉ាថាយ ១១:២៨។ មានតែគុណធម៌ដែលចេញអំពីព្រះគ្រិស្ទប៉ុណ្ណោះដែលអាចដឹកនាំទៅរកការប្រែចិត្តដ៏ពិតប្រាកដបាន។
សាវ័កពេត្រុសបានបង្ហាញការនេះឲ្យកាន់តែច្បាស់ឡើងថែម

ទៀតក្នុងសេចក្តីថ្លែងរបស់លោកទៅកាន់កូនចៅអ៊ីស្រាអែលដោយពាក្យទាំងនេះថា: “ព្រះបានតំកើងទ្រង់ឡើងដោយសារព្រះហស្តស្តាំ ឲ្យធ្វើជាព្រះអម្ចាស់និងជាព្រះអង្គសង្គ្រោះដើម្បីនឹងប្រោសប្រទានការប្

វែចិត្តដល់សាសន៍អ៊ីស្រាអែល
ប្រយោជន៍ឲ្យបានរួចពីបាប "..កិច្ចការ
៥:៣១។
យើងមិនអាចកែប្រែចិត្តដោយគ្មានព្រះ
វិញ្ញាណបរិសុទ្ធរបស់ព្រះគ្រិស្ទបានឡើ
យ
យ៉ាងណាមិញយើងមិនអាចទទួលការ
អត់អោនទោសបានដោយគ្មានព្រះគ្រិ
ស្ទដែរ(យើងត្រូវការវិញ្ញាណរបស់ព្រះ
គ្រីស្ទដើម្បីប្រែចិត្ត..យើងត្រូវការព្រះគ្
រិស្ទដើម្បីឲ្យអត់ទោសរួចអំពីបាប)។

ព្រះគ្រិស្ទគឺជាប្រភពនៃគ្រប់ទាំងថាមព
លដ៏ត្រឹមត្រូវ។
ព្រះអង្គគឺជាព្រះតែមួយប៉ុណ្ណោះ
ដែលអាចបណ្តុះនៅក្នុងចិត្តរបស់យើង
ក្នុងការប្រឆាំងយ៉ាងប្តូរផ្តាច់នឹងអំពើ
បាប។

គ្រប់ទាំងបំណងប៉ងប្រាថ្នាចំពោះសច្ចភាពនិងភាពបរិសុទ្ធ
គ្រប់ការទទួលសារភាពនូវអំពើបាបរបស់យើង
គឺជាភ័ស្តុតាងដែលព្រះវិញ្ញាណរបស់ព្រះអង្គគ្រប់គ្រងលើចិត្តរបស់យើង។

ព្រះយេស៊ូគ្រិស្ទមានបន្ទូលថា: “ឯខ្ញុំ បើសិនជា
ខ្ញុំត្រូវបានលើកពីដីឡើងនោះ
ខ្ញុំនឹងទាញមនុស្សទាំងអស់មកឯខ្ញុំ
”..យ៉ូហាន ១២:៣២។
ព្រះគ្រិស្ទបានបើកសំដែងឲ្យបាបជនបានឃើញយ៉ាងប្រច័ក្សច្បាស់ថាទ្រង់ជាព្រះអង្គសង្គ្រោះដោយការទទួលសុគតដើម្បីលោះបាបសំរាប់ពិភពលោកទាំងមូល
ហើយក្នុងខណៈដែលយើងសម្លឹងមើ

លទៅកូនចៀមនៃព្រះអម្ចាស់
ដែលនៅលើឈើឆ្កាងកាល់វ៉ារី
នោះអាថ៌កំបាំងនៃសេចក្ដីប្រោស
លោះចាប់ផ្ដើមលាតត្រដាងប្រាប់ដល់
ដួងចិត្តយើង
ហើយពេលនោះសេចក្ដីល្អរបស់ទ្រង់នឹ
ងដឹកនាំយើងទៅដល់ការប្រែចិត្ត។
ការសុគតរបស់ព្រះគ្រិស្ទនៅលើឈើឆ្
កាងជំនួសបាបជនទាំងឡាយ
បានបង្ហាញឲ្យយើងឃើញនូវសេចក្ដី
ស្រលាញ់មួយដែលយើងយល់មិនបា
នស្មានមិនដល់។
នៅពេលដែលមនុស្សមានបាបបាន
ឃើញសេចក្ដីស្រលាញ់ដ៏ធំធេងនេះ
នោះគេនឹងបន្ទន់ចិត្តដែលរឹងរូស
មានការចាប់អារម្មណ៍ចំពោះសេចក្ដីល្អ
ហើយក៏មានចិត្តស្ដាយក្រោយចំពោះអំ
ពើបាបដែលខ្លួនបានប្រព្រឹត្ត។

ជាការពិតណាស់
ដែលពេលខ្លះមនុស្សយើងមានការខ្មា
សអៀនចំពោះអំពើបាបរបស់ខ្លួនឯង
ហើយបានលះបង់ទំលាប់អាក្រក់ខ្លះរ
បស់គេចោលចេញមុនពេលដែលគេ
បានដឹងខ្លួនថា
គេកំពុងមានទំនាញចូលជិតព្រះគ្រិស្ទ
ជាម្ចាស់។ ក៏ប៉ុន្តែពេល
ដែលគេប្រឹងប្រែងបំផ្លាស់ប្រែដោយបំ
ណងដ៏ស្មោះត្រង់ចំពោះអំពើល្អនោះគឺ
អំណាចរបស់ព្រះគ្រិស្ទនឹងអូសទាញចិ
ត្តរបស់គេ។
ឥទ្ធិពលមួយដែលគេពុំបានដឹង
បានធ្វើការដល់ព្រលឹងរបស់គេ
ហើយបានធ្វើឲ្យមនសិការរបស់គេភ្ញា
ក់រលឹកឡើង
ហើយពេលនេះជីវិតខាងក្រៅក៏បានកែ

ប្រែទំរង់មួយថ្មី។
ក្នុងខណៈដែលព្រះគ្រិស្ទបាននាំគេឲ្យ
ក្រឡេកមើលទៅឯឈើឆ្កាងរបស់ទ្រង់
ឲ្យសង្កេតមើលទ្រង់ដែលបានទំលុះទំ
លាយអំពើបាបរបស់គេ
ពេលនោះទើបមនសិការបស់គេវិលម
ករកក្រិត្យវិន័យដើមរបស់ព្រះជាម្ចាស់
វិញ។
អំពើទុច្ចរិតក្នុងជីវិតរបស់គេ..អំពើបាប
ដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងព្រលឹ
ងរបស់គេ
បានបើកសំដែងឲ្យគេឃើញ។
គេចាប់ផ្តើមយល់អំពីសេចក្តីសុចរិតឥ
តខ្ចោះរបស់ព្រះគ្រិស្ទ
ទើបគេឧទានឡើងថា: "
តើអ្វីទៅជាអំពើបាប
ដែលតំរូវឲ្យមានការលះបង់បែបនេះ
ដើម្បី ប្រោសលោះមនុស្សរងគ្រោះ? "

តើសេចក្ដីស្រលាញ់ការរងទុក្ខវេទនា
និងភាពអាម៉ាស់
ទាំងអស់នេះធ្វើឡើងដើម្បីអ្វី?
តើដើម្បីកុំឲ្យយើងត្រូវទទួលសេចក្ដីវិ
នាស(សេចក្ដីស្លាប់)ប៉ុន្ដែឲ្យបាន
ទទួលជីវិតអមតៈវិញឬ?

មនុស្សមានបាបអាចប្រឆាំងនឹងសេច
ក្ដីស្រលាញ់នេះ
ឬអាចនឹងបដិសេធនឹងចូលមកជិតព្រះ
គ្រិស្ទ..ក៏ប៉ុន្ដែប្រសិនបើគេមិនប្រឆាំងរឹ
ងរូសទេ
នោះគេនឹងបាននាំចូលមកជិតព្រះគ្រិ
ស្ទ។
ការយល់ដឹងចំពោះផែនការសង្គ្រោះនឹ
ងដឹកនាំគេទៅកាន់គល់នៃឈើឆ្កាង
ក្នុងការប្រែចិត្តអំពើបាបរបស់គេ..អំពើ
បាបនោះហើយដែលបានធ្វើឲ្យមានកា

រលំបាកវេទនា
ដល់ព្រះរាជបុត្រាស្ងួនភ្ងាររបស់ព្រះវរ
បិតា។

ព្រះវិញ្ញាណនៃព្រះអរម្ចាស់ស្ងួគិដដែ
លនេះបានធ្វើការទៅលើវត្ថុសព្វសារ
ពើរនៃធម្មជាតិ
បានមានបន្ទូលទៅកាន់ដួងចិត្តនៃមនុ
ស្សលោក
ហើយបានបង្កើតនូវចំណង់យ៉ាងខ្លាំង
ដែលមិនអាចបរិយាយបានចំពោះវត្ថុ
ដែលគេពុំមាន។
វត្ថុផងទាំងឡាយនៅនាលោកិយនេះពុំ
អាចបំពេញចំណង់របស់គេបានឡើយ
។ ព្រះវិញ្ញាណនៃព្រះអម្ចាស់កំពុង
តែដង្ហោយហៅគេឲ្យស្វែងរកវត្ថុមួយប៉ុ
ណ្ណោះដែលអាចផ្តល់សុខសន្តិភាពនិង
ឈប់សំរាក

គឺព្រះគុណនៃព្រះគ្រិស្ដជាម្ចាស់នៃយើងបានធ្វើការគ្មានឈប់ឈរ
ដើម្បីទាក់ទាញអារម្មណ៍មនុស្សមានបាបឲ្យបោះបង់ចោលនូវរបស់លោកិយដែល
ជាសេចក្ដីសប្បាយមិនចេះស្កប់ស្កល់នៃអំពើបាប
ដើម្បីឲ្យបានយល់នូវព្រះពរបរិបូណ៌ដែលនឹងបានជាកម្មសិទ្ធិរបស់គេនៅក្នុងព្រះអង្គ។
ព្រះរាជសារនៃព្រះជាម្ចាស់ទៅកាន់មនុស្សទាំងឡាយដែលកំពុងស្វះស្វែងរកដោយឥតបានផលដើម្បីក្រេបទឹកអំពីប្រភពទឹក
ដែលផ្លុះធ្លាយនៅលោកិយ៍នេះថា:“អញ្ជើញមកចុះអស់អ្នកដែលស្រេក
ហើយអ្នកណាដែលចង់បាននោះសូម

យកទឹកជីវិតនេះចុះ ឥតចេញថ្លៃទេ..”
វិវរណៈ២២:១៧។

អ្នកដែលមានបំណង
ស្វែងរកវត្ថុមួយដែលប្រសើរជាងវត្ថុដែ
លលោកិយនេះផ្តល់ឲ្យនោះ
រមែងទូលស្គាល់ថាជាសេចក្តីប្រាថ្នាដ៏
ធំនេះជាសេចក្តីដង្ហោយហៅរបស់ព្រះ
ជាម្ចាស់មកកាន់ព្រលឹងរបស់គេ។
ចូរទូលសូមទ្រង់ប្រទាននូវការប្រែចិត្ត
និងសូមដល់ព្រះវរបិតា
សូមទ្រង់បង្ហាញដល់អ្នកព្រះគ្រិស្ទដែ
លពោរពេញដោយសេចក្តីស្រលាញ់
ដ៏គ្មានព្រំដែនដែលពោរពេញទៅដោ
យភាពបរិសុទ្ធឥតខ្ចោះ។
នៅក្នុងជីវិតនៃព្រះអង្គសង្គ្រោះ
ទ្រង់បានធ្វើជាគំរូដល់យើងឥតខ្ចោះតា
មរយៈគោល

ការណ៍ដែលក្រិត្យវិន័យ..គឺសេចក្ដីស្រ
លាញ់ដល់ព្រះនិងដល់មនុស្ស។
សេចក្ដីមេត្តាករុណា
សេចក្ដីស្រលាញ់ដ៏លើសលប់
គឺជាជីវិតនៃព្រលឹងទ្រង់។
នៅពេលដែលយើងសម្លឹងមើលទៅទ្រ
ង់ ក្នុងខណៈដែលកាំរស្មី
នៃព្រះអង្គសង្គ្រោះជះចំលើរូបយើង
នោះយើងនឹងឃើញសេចក្ដីទុច្ចរិតក្នុង
ដួងចិត្តយើង។

ជួនកាលយើងអាចមានសេចក្ដីអំនួតចំ
ពោះខ្លួនឯង ដូចជាលោក
នីកូដឹមអញ្ចឹងដែរ
ដែលតែងអួតថាជីវិតរបស់យើងត្រូវឥ
តខ្ចោះ រីឯសីលធម៌រស់នៅក៏ល្អហ្មត់
ហ្មង។
ពេលនោះយើងគិតថាយើងមិនត្រូវការ

បន្ទាប់កាយវាចាចិត្តចំពោះព្រះជាម្ចាស់ឡើយដូចជាមនុស្សមានបាបដទៃទៀតដែរ។
នៅពេលដែលពន្លឺចេញពីព្រះគ្រិស្តបញ្ចាំងមកក្នុងដួងចិត្តយើង
នោះយើងនឹងឃើញថាតើខ្លួនយើងមិនបរិសុទ្ធប៉ុណ្ណានោះ។
យើងនឹងមើលឃើញនូវសំទុះចិត្តដ៏ចង្អៀតចង្អល់..ភាពជាមារប្រឆាំងនឹងព្រះដែលបានបង្ខូចរាល់សកម្មភាពប្រចាំថ្ងៃ។
នៅពេលនោះទើបយើងដឹងថាអំពើសុចរិតរបស់យើងគឺជាកំណាត់សំពត់ដ៏ស្មោកគ្រោកដែលមានតែព្រះលោហិតនៃព្រះគ្រិស្តប៉ុណ្ណោះដែលអាចលាងសំអាតយើង
ពីភាពស្មោកគ្រោកនៃអំពើបាបហើយ

នឹងបំផ្លាស់បំប្រែចិត្តថ្មីតាមបែបសណ្ឋាន
នរបស់ទ្រង់។

ពន្លឺសិរីល្អនៃព្រះជាម្ចាស់
ជាកាំរស្មីដ៏ភ្លឺចិញ្ចែងនៃភាពបរិសុទ្ធរប
ស់ព្រះគ្រីស្ទបានជ្រៀតចូលទៅក្នុងព្រ
លឹងនៃបាបជន
ធ្វើឲ្យអំពើស្មោកគ្រោកក្នុងចិត្តរលាយ
សូន្យបង់អន្តរធាន
ហើយលាតត្រដាងនូវភាពមិនស្អាតនៃ
អត្តចរិតរបស់មនុស្ស។
ពន្លឺនេះបានបំភ្លឺឲ្យយើងមើលឃើញចំ
ណង់ដ៏ចង្អៀតចង្អល់
អំពើមិនស្មោះត្រង់នៃដួងចិត្តនិងបបូរ
មាត់ទុច្ចរិត។
អំពើមិនស្មោះត្រង់នៃមនុស្សមានបាប
ដើម្បីបំផ្លាញបង់ក្រិត្យវិន័យរបស់ព្រះ
ជាម្ចាស់ត្រូវបានបង្ហាញឲ្យឃើញនៅចំ

ពោះភ្លើករបស់គេ
ហើយវិញ្ញាណដ៏ខ្មៅចខ្មាំរបស់គេ
នឹងឈឺចាប់ក្រោមអនុភាពស្វែងរកនៃ
ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។
គេក៏ស្អប់ដល់ខ្លួនគេនៅពេលដែលគេ
បានឃើញនូវល័ក្ខណៈដ៏ល្អឥតខ្ចោះរ
បស់ព្រះគ្រិស្ទជាម្ចាស់នោះ។

នៅពេលដែលហោរាដានីយ៉ែលឃើញ
សិរីល្អ
ដែលព័ទ្ធហ៊ុំជុំវិញទេវតានាំសារពីស្ថាន
សួគ៌ដែលព្រះបានចាត់ឲ្យចុះមកឯគា
ត់
នោះហោរាដានីយ៉ែលមានចិត្តរំភើប
ញាប់ញ័រ
ហើយដឹងថារូបគាត់មានភាពកសោយ
នឹងភាពមិនបរិសុទ្ធដ៏សែនលើស
លប់។

ក្នុងការពិពណ៌នាពីឥទ្ធិពលនៃទស្សនីយភាពដ៏អស្ចារ្យមួយ
ដានីយ៉ែលមានពោលថា:“ខ្ញុំប្រែជាខ្សោះ ល្វើយទៅ
មុខខ្ញុំប្រែជាស្លេកស្លាំងហើយខ្ញុំឥតមានសល់កំលាំងឡើយ”..ដានីយ៉ែល១០:៨។
ព្រលឹងដែលបានយល់ភាពបរិសុទ្ធ
នោះនឹងស្អប់ភាពអាត្មានិយមរបស់ខ្លួនឯង
ហើយស្វែងរកភាពបរិសុទ្ធនៃដួងចិត្ត
ដែលចុះសំរុងជាមួយនឹងក្រិត្យវិន័យរបស់ព្រះជាម្ចាស់និងលក្ខណៈរបស់ព្រះគ្រិស្ទ។

សាវ័កបានពោលថា:“បើគិតពីភាពសុចរិតក្នុងក្រិត្យវិន័យ
ដោយន័យសេរៗនោះអាការៈខាងក្

ជៅរបស់គាត់គ្មានអ្វីគួរបន្ទោសបានឡើ
យ
ប៉ុន្តែបើគិតផ្ទៀងផ្ទាត់ដល់ជំរៅអំពីលក្ខ
ណ:បរិសុទ្ធនៃបញ្ញត្តិទ្រង់វិញនោះ
គាត់បានឃើញច្បាស់ថាគាត់ជាមនុស្
សមានបាប។”
បើធ្វើការវិនិច្ឆ័យតាមរយ:ក្រិត្យវិន័យ
ជាលាយលក្សអក្សរ ដែលមនុស្ស
អនុវត្តន៍ទៅនឹងជីវិតខាងក្រៅ
គាត់គិតថានឹងអាចចៀសផុតពីអំពើបា
បបាន
ក៏ប៉ុន្តែពេលដែលគាត់ពិនិត្យពិច័យដ
ល់ជំរៅនៃអត្ថន័យដ៏បរិសុទ្ធរបស់ក្រិត្យ
វិន័យ
ពេលនោះគាត់បានឃើញខ្លួនរបស់គា
ត់ដូចជាព្រះបានឃើញគាត់
នោះគាត់នឹងឱនក្រាបដោយភាពអៀន
ខ្មាសហើយ

និងលន់តួនូវទោសកំហុសរបស់គាត់។ គាត់មានប្រសាសន៍ថាៈ“កាលពីដើមខ្ញុំបានរស់នៅ ដោយគ្មានក្រិត្យវិន័យ ប៉ុន្តែនៅពេលដែលបញ្ញត្តិបានកើតឡើង នោះបាបក៏បានរស់ឡើងវិញ រូបខ្ញុំក៏ត្រូវស្លាប់”..រ៉ូម៧:៨។ នៅពេលដែលគាត់បានឃើញភាពបរិសុទ្ធពីកំណើតនៃក្រិត្យវិន័យ អំពើបាបក៏បានលេចចេញទាំងការខំលាក់បំពួន ពេលនោះគំនិតដែលខំលើកតំកើងតែខ្លួន ឯងរបស់គាត់ក៏រសាយបាត់ទៅ។

ព្រះជាម្ចាស់ពុំសំគាល់ថាអំពើបាបទាំងអស់មានទំហំស្មើៗគ្នានោះឡើយ។ ក្នុងការប៉ាន់ប្រមាណរបស់ទ្រង់ ក៏ដូចជាការកត់សំគាល់នៃមនុស្សដែរ គឺថាអំពើបាបឬពិរុទ្ធភាពវាមានកំរិតរប

ស់វា
ប៉ុន្តែទោះជាមនុស្សតែងសន្មតអំពើបា
បថាតូចឬធំទៅតាមការមើលឃើញរប
ស់គេយ៉ាងណាក្តី
ចំពោះព្រះនេត្ររបស់ទ្រង់វិញគ្មានអំ
ពើបាបណាដែលរាប់ថា“បាបបន្តិច”
នោះឡើយ។
ការវិនិច្ឆ័យរបស់មនុស្សពុំដែលត្រឹមត្រូ
វប្រាកដទេ
តែតែងមានភាពលំអៀងជាដរាប។
ព្រះជាម្ចាស់ប្រមើលមើលការទាំងអស់
ដោយសេចក្តីសុចរិត។
មនុស្សប្រមឹកគឺជាទីស្អប់ខ្ពើមនៃមនុស្
សផងទាំងឡាយ។
គេតែងនិយាយថាមនុស្សបែបនេះមិន
បានចូលនគរស្ថានសួគ៌ឡើយ
ប៉ុន្តែក្នុងខណៈដដែលនោះ
មនុស្សដែលក្រអឺតក្រទមលោភលន់និ

ងអាត្មានិយមបែរជាគ្មានកំហុសទៅវិញ!។
អំពើអស់ទាំងនេះគឺជាបាបដែលប្រឆាំងដាច់ខាតនឹងព្រះជាម្ចាស់ព្រោះអំពើអស់ទាំងនេះវាផ្ទុយស្រឡះពីអត្តចរិករបស់ព្រះដែលប្រកបដោយសេចក្តីមេត្តាករុណានិងសេចក្តីស្រលាញ់ដ៏លើសលប់ដែលជាបរិយាកាសមួយនៃលោកសន្និវាសដ៏មិនសាបសូន្យ។មនុស្សដែលធ្លាក់ចូលទៅក្នុងអំពើបាបដ៏ធ្ងន់ធ្ងរតែងមានអារម្មណ៍អៀនខ្មាសខ្វះខាត(ភាពល្អនៃព្រះ)និងត្រូវការព្រះគុណនៃព្រះគ្រីស្ទ
ក៏ប៉ុន្តែមនុស្សក្រអឺតក្រទមមានឬកពារឆ្មើងឆ្មៃមិនត្រូវការការនេះឡើយ។ គេបិទទ្វារចិត្តរបស់គេមិនព្រមទទួលយកព្រះពរដ៏ច្រើនឥតគណនា

ដែលព្រះទ្រង់បានយាងមកផ្តល់ដល់គេ។

អ្នកហូតពន្ធដ៏កំសត់ដែលបានអធិស្ឋានថា:
“ឱ!ព្រះជាម្ចាស់នៃទូលបង្គំអើយ! សូមមេត្តាករុណាចំពោះទូលបង្គំជាមនុស្សមានបាបផង”(លូកា ១៨:១៣)នោះគាត់បានចាត់ទុកខ្លួនគាត់ថាជាមនុស្សអាក្រក់បំផុត ហើយអ្នកដទៃទៀតក៏សម្លឹងឃើញគាត់ដោយអារម្មណ៍ដូច្នោះដែរ។ គាត់ត្រូវការជំនួយ ហើយដោយបន្ទុកនៃទោសកំហុស និងសេចក្តីអៀនខ្មាសទើបគាត់ចូលមកចំពោះព្រះជាម្ចាស់ដើម្បីទូលអង្វរសូមសេចក្តីមេត្តាករុណាអំពីទ្រង់។ ចិត្តរបស់គាត់បើកចំហរចំពោះព្រះហរិ

ញ្ញាណបរិសុទ្ធ
របស់ព្រះជាម្ចាស់ឲ្យបំពេញការដ៏ពិសិដ្ឋ
ក្នុងដួងចិត្តរបស់គាត់ដើម្បីនឹងរំដោះគាត់ឲ្យរួចពីអំណាចនៃអំពើបាប។
ការអធិស្ឋានដ៏អួតអាង
និងការដែលគិតថាខ្លួនឯងត្រូវ(ដូចពួកអាចារ្យផារីស៊ីតែងធ្វើនោះ)បង្ហាញថាចិត្តរបស់គេបិទជិតឈឹងមិនត្រូវការអនុភាពនៃព្រះវិញ្ញាណបរិសុទ្ធឡើយ។
ដោយសារគេឃ្លាតឆ្ងាយពីទ្រង់គេពុំទទួលស្គាល់ភាពខុសឆ្គងរបស់គេ
ដែលប្រឆាំងទៅនឹងភាពបរិសុទ្ធឥតខ្ចោះរបស់ព្រះជាម្ចាស់។
គេមានអារម្មណ៍ថាគេពុំត្រូវការអ្វីឡើយ ហើយគេនឹងពុំទទួលរង្វាន់អ្វីដែរ។

ប្រសិនបើអ្នកឃើញអំពើបាបរបស់អ្នក
សូមកុំតំអក់ចាំឲ្យខ្លួនអ្នកប្រសើរឡើងវិ
ញដោយឯកឯងនោះឡើយ។
តើមានមនុស្សប៉ុន្មាននាក់ហើយដែល
ពួកគេគិតថាគេពុំសមល្មមនឹងចូលមក
ឯព្រះគ្រិស្ត?
តើអ្នកសង្ឃឹមថាអ្នកនឹងបានប្រសើរ
ឡើងវិញដោយការព្យាយាម
ប្រឹងប្រែងផ្ទាល់ខ្លួនរបស់អ្នកឬ?
“តើសាសន៍អេត្យូពីអាចនឹងបំផ្លាស់ប្រែ
សម្បុរស្បែករបស់ខ្លួនបានដែរឬទេ?
ឬបើសត្វខ្លារខិនអាផ្លាស់សំបុរពញ្លាក់រ
បស់វាបាននោះឯងរាល់គ្នា
ដែលធ្លាប់ប្រព្រឹត្តល្អវិញបាន
ដែរ..យេរេមា១៣:២៣។ជំនួយតែមួយ
គត់ចំពោះរូបយើងគឺព្រះគ្រិស្តជាម្ចាស់
។យើងមិនត្រូវរង់ចាំការល្បួងលោមដ៏ខ្
លាំងក្លា

ឬឱកាសល្អប្រសើរឬចាំឲ្យស្រួលចិត្តសិនឡើយ។
យើងមិនអាចធ្វើអ្វីបានដោយខ្លួនយើងផ្ទាល់ឡើយ..ចូរយើងចូលមករកព្រះគ្រីស្ទជាម្ចាស់តាមបែបសណ្ឋានដែលយើងមាននោះចុះ។

ក៏ប៉ុន្តែទោះជាយ៉ាងណាក្តីកុំឲ្យភ័ន្តច្រឡំដោយនឹកស្មានថា
ព្រះជាម្ចាស់ដែលប្រកបដោយសេចក្តីស្រលាញ់ មេត្តាករុណា
នឹងប្រោសសង្គ្រោះដល់អ្នកដែលបដិសេធពុំទទួលព្រះគុណរបស់ទ្រង់នោះឲ្យសោះ។
អំពើបាបដ៏លើសលប់អាចវាស់ប្រមាណដោយសារពន្លឺនៃឈើឆ្កាងប៉ុណ្ណោះ។
នៅពេលដែលមនុស្សមានបាបនៅតែ

ទទួចថាព្រះជាម្ចាស់ទ្រង់ល្អណាស់
ទ្រង់មិនអាចនឹងបណ្ដេញមនុស្សមាន
បាបឲ្យចេញឆ្ងាយពីទ្រង់ឡើយ
នោះសូមសម្លឹងមើលទៅឯកាល់វ៉ារី(ជា
ទីដែលទ្រង់ត្រូវទទួលសុគតលើឈើឆ្
កាង)។ គ្មានមធ្យោបាយណាផ្សេង
ដែលមនុស្សមានបាបត្រូវបានសង្គ្រោះ
នោះទេ។
ប្រសិនបើគ្មានព្រះមហាបូជនីយកិច្ច
នេះទេ
មនុស្សជាតិមិនអាចគេចឲ្យផុតអំពីការ
វាតត្បាតនៃអំពើបាប
ហើយក៏មិនអាចមានទំនាក់ទំនងសារ
ជាថ្មីឡើងវិញជាមួយព្រះជាម្ចាស់បាន
ឡើយ
ហើយម្យ៉ាងទៀតគេមិនអាចទទួលចំ
ណែកក្នុងជីវិតមួយដែលប្រកបដោយវិ
ញ្ញាណបរិសុទ្ធឡើយ។

ដោយសារបញ្ហាអស់ទាំងនោះហើយ
ដែលព្រះគ្រិស្ទបានយកអង្គទ្រង់
មកពាំងពាររងអស់ទាំងអំពើបាបជួស
មនុស្សទមិទ្បល្មើស
និងរងវេទនាជំនួសមនុស្សមានបាបទាំ
ងទ្បាយ។
សេចក្តីស្រលាញ់ការឈឺចាប់និងការ
សុគតនៃព្រះរាជបុត្រានៃព្រះ
សរឲ្យឃើញយ៉ាងប្រច័ក្សច្បាស់ពីអំពើ
បាបដ៏ធំក្រៃលែង
ហើយក៏ប្រកាសឲ្យដឹងថាគ្មានមធ្យោ
បាយណាដើម្បីគេចឲ្យផុត
ពីអនុភាពនៃអំពើបាបនោះទ្បើយគ្មាន
សេចក្តីសង្ឃឹមចំពោះជីវិតថ្មីថ្កើងដែល
ប្រសើរជាងនេះក្រៅអំពីការថ្វាយខ្លួនចំ
ពោះ ព្រះគ្រិស្ទជាម្ចាស់នោះទ្បើយ៉។

ជួនកាលមនុស្សរឹងរូសខំបំបិទបំបាំងកំហុសរបស់គេ ដោយប្រៀបប្រដូចខ្លួនទៅនឹងអ្នកគ្រិស្ទាន ដែលកាន់ជំនឿខ្ជាប់ខ្លួន(Professed Christians)ថា:“បើនិយាយពីការលះបង់ ភាពស្រគត់ស្រគំ ឬការប្រយ័ត្នប្រយែងចំពោះកិរិយាមាយាទ មិនឃើញពួកហ្នឹងគ្រាន់បើជាងខ្ញុំឯណា! គេក៏ស្រលាញ់ភាពត្រេកត្រអាលនិងទំយើខ្លួនដូចតែខ្ញុំដែរ”។ ដូច្នេះហើយបានជាគេស្វែងរកចាប់កំហុសរបស់អ្នកដទៃដើម្បីជាការដោះសារពីការមិនអើរពើលើកាតព្វកិច្ចរបស់ខ្លួន។ ក៏ប៉ុន្តែអំពើបាបនិងទោសជាការដោះសារពីការមិនអើរពើលើកាតព្វកិច្ចរបស់ខ្លួន។

ក៏ប៉ុន្តែអំពើបាបនិងទោសពៃរ៍របស់អ្នក
ដទៃ
ពុំអាចនឹងជួយអ្នកណាម្នាក់ផ្សេងទៀត
ឲ្យរួចទោសបានឡើយ
ព្រោះថាព្រះជាម្ចាស់ពុំបានប្រទានឲ្យ
យើងនូវគំរូដែលខុសឆ្គងឡើយ។
ព្រះរាជបុត្រាដ៏បរិសុទ្ធបណ្តាច់នៃព្រះ
ជាម្ចាស់
បានប្រទានមកដើម្បីជាគំរូដល់យើង
បើអ្នកណាពោលថ្កោលនឹងពួកអ្នកគ្រិ
ស្ទានដែលកាន់ជំនឿខ្ជាប់ខ្ជួន
នោះគេត្រូវតែប្រព្រឹត្តឲ្យបានប្រសើរជា
ងអ្នកទាំងនោះប្រសិនបើគេយល់ដឹងច្
បាស់អំពីលក្ខណៈពិតរបស់អ្នកគ្រិស្ទា
ន
នោះតើគេនឹងឃើញអំពើបាបរបស់គេ
មានទំហំជាងអម្បាលម៉ានទៅទៀតពី
ព្រោះគេយល់ដឹងនូវអ្វីដែលត្រឹមត្រូវ

អ្វីដែលសុចរិត
តែគេមិនព្រមប្រព្រឹត្តតាម។

ចូរកុំតំអក់ចាំពេលក្រោយ..ចូរកុំបង្អែរ
បង្អង់នឹងបោះបង់ចោលអំពើបាបរបស់
អ្នកឡើយ។
ចូរស្ទុះស្វែងរកចិត្តដ៏បរិសុទ្ធដោយនូវអំ
ណាចនៃព្រះយេស៊ូគ្រិស្ទចុះ។
ត្រង់ចំនុចនេះ
មានមនុស្សទាំងសល់សែននាក់ដែល
មានការភ័ន្តច្រលំរហូតដល់បាត់បង់នូវ
ជីវិតដ៏អស់កល្បជានិច្ចជារៀងរហូត។
ត្រង់នេះខ្ញុំមិនផ្តោតលើជីវិតដែលមានរ
យៈពេលខ្លីនិងមិនច្បាស់លាស់នោះ
ទេ
ប៉ុន្តែមានឧបសគ្គមួយគួរឲ្យរន្ធត់ក្រៃ
លែងគឺជាឧបសគ្គដែលប្រាជ្ញាមនុស្ស
យល់មិនដល់

ក្នុងការពន្យាពេលមិនទទួលសម្លេងដ
ង្ហោយហៅនៃព្រះវិញ្ញាណបរិសុទ្ធរបស់
ព្រះជាម្ចាស់
ហើយបែរជាស្ម័គ្រទ្រាំរស់ក្នុងអំពើបាប
ទៅវិញ
នោះគឺជាការបង្អែរបង្អង់នោះឯង
ទើបបញ្ហានេះអាចកើតឡើងទៅបាន។
អំពើបាប
ទោះជាតិចតួចស្តួចស្តើងយ៉ាងណាក្តី
ក៏អាចបណ្តាលឲ្យមានគ្រោះមហន្តរា
យ
និងសេចក្តីហិនវិនាសដ៏អស់កល្បបាន
ដែរ។
បើយើងមិនប្រឹងយកជ័យជំនះលើអំពើ
បាបនេះបានទេ
នោះវានឹងយកជ័យជំនះលើយើងជាក់
ជាមិនខាន

ហើយវានឹងបង្កវិនាសកម្មដល់យើង ទៀតផង។

អាដ័មនិងអេវ៉ាបានល្បងចិត្តខ្លួនឯងថា រឿងកំប៉ិកកំប៉ុកដូចជាការបរិភោគផ្លែឈើដែលព្រះបានហាមឃាត់(Forbidden Fruit)នោះមិនអាចបណ្តាលឲ្យមានផលវិបាកដ៏ធ្ងន់ធ្ងរ ដូចជាព្រះបានមានព្រះបន្ទូលប្រកាសប្រាប់នោះឡើយ។ ក៏ប៉ុន្តែកំហុសដ៏តូចនេះគឺជាការប្រព្រឹត្តល្មើសរំលងនឹងក្រិត្យវិន័យដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ ជាក្រិត្យវិន័យដែលមិនអាចប្រែប្រួលបានសោះឡើយ។ វាថែមទាំងបានញែកបំបែកមនុស្សលោកអំពីព្រះជាម្ចាស់ហើយក៏បានបើកចំហរទ្វារទំនប់នៃសេចក្តីស្លាប់ព្រម

ទាំងបណ្តាសានៅលើពិភពផែនដីយើងនេះផង។
ពីយុគសម័យមួយទៅយុគសម័យមួយ ទំនួញសោយសោកនៃមរណៈទុក្ខដ៏មិនចេះអស់មិនចេះហើយ
តំអូញថ្ងូរនិងការទង្គិះខ្សឹកខ្សួលនៃសត្វលោក
និងសមិទ្ធផលទាំងឡាយដែលព្រះបានបង្កើតមកគឺជាសំរែកនៃការឈឺចាប់ ដែលជាផលវិបាកនៃការដែលមិនស្តាប់បង្គាប់ព្រះ។
សូម្បីនៅឯស្ថានសួគ៌ក៏នៅទទួលលទ្ធផលនៃការបះបោរពីសំណាក់សាតាំង ដែលប្រឆាំងនឹងព្រះជាម្ចាស់ដែរ។
ទីកាល់វ៉ារីបិតនៅជាអនុស្សាវរីយដ្ឋាន(ជាការរំលឹក)នៃព្រះមហាពលិកម្មដ៏អស្ចារ្យ
ដែលតម្រូវឲ្យព្រះគ្រិស្ទទទួលទណ្ឌកម្ម

លាងកំហុសចំពោះការប្រព្រឹត្តរំលងនឹងបញ្ញត្តិបរិសុទ្ធរបស់ព្រះ។
យើងមិនត្រូវចាត់ទុកអំពើបាបថាជាបញ្ហាកំប៉ិកកំប៉ុកសោះឡើយ។

គ្រប់សកម្មភាពនៃការប្រព្រឹត្តរំលង គ្រប់ទាំងការធ្វេសប្រហែសឬការបដិសេធចំពោះព្រះគុណរបស់ព្រះគ្រិស្តគឺជាប្រតិកម្មមួយមកលើខ្លួនអ្នកផ្ទាល់ដែលបណ្ដាលឲ្យមានទឹកចិត្តទទឹងរឹងរូស ..ទាញបង្វែរចិត្តឲ្យវង្វេងខុសផ្លូវ បណ្ដាលឲ្យស្ពឹកស្រពន់ចំពោះការយល់ដឹង
ហើយវាមិនគ្រាន់តែធ្វើឲ្យអ្នកមានចិត្តអល់អែកនឹងចុះចូលដល់ព្រះជាម្ចាស់ប៉ុណ្ណោះទេ
តែវាថែមទាំងធ្វើឲ្យអ្នកមិនអាចចុះចូលនឹងសេចក្ដីដង្ហោយហៅដ៏ស្រទន់នៃព្

រះវិញ្ញាណបរិសុទ្ធរបស់ព្រះនោះទៀតផង។

មនុស្សខ្លះរំងាប់មនសិការដ៏តប់ប្រមល់របស់ខ្លួនដោយមានគំនិតថាគេអាចបំផ្លាស់ប្រែទិសដៅនៃបាបកម្មបាននៅពេលដែលគេជ្រើសរើសផ្លូវរបស់គេដោយសេចក្ដីប្រមាថពាយ័ងាយទៅនឹងតំរាស់ហៅ(សេចក្ដីអញ្ជើញ)ដោយក្ដីមេត្តាករុណារបស់ព្រះ..ហើយគេនៅតែមានគំនិតយ៉ាងដូច្នេះដដែល។ គេគិតថាបន្ទាប់ពីមិនធ្វើតាមព្រះវិញ្ញាណនៃព្រះគុណ និងបន្ទាប់ពីបោះឥទ្ធិពលរបស់ខ្លួនខាងអវ័ក្សសាតាំង ហើយរំពេចនោះគេអាចផ្លាស់ប្ដូរទិសដៅរបស់គេបានភ្លាម។ ក៏ប៉ុន្តែតាមការពិតអំពើទាំងអស់នេះពុំ

មែនជាការងាយទេ។ បទពិសោធន៍
ចំណោះវិជ្ជាក្នុង មួយជីវិតរបស់គេ
បើត្រាប់តាមពុម្ពគំរូអត្តចរិកដ៏ពេញលេ
ញនៃព្រះនោះ
មានមនុស្សតិចតួចណាស់ដែលមានចិ
ត្តចង់ក្លាយឲ្យដូចជាព្រះយេស៊ូគ្រិស្ទ។

ស្ទូម្បីតែលក្ខណៈខុសឆ្គងរបស់អត្តចរិ
កចំណង់ដែលពោរពេញដោយអំពើបា
ប ចំណង់សប្បាយដែលមិនចេះចប់
ក៏អាចនឹងបន្សាបនូវឥទ្ធិពលនៃដំណឹង
ល្អបន្តិច ម្តងៗបានដែរ។
គ្រប់ការបណ្តោតបណ្តោយតាមអំពើបា
ប
និងធ្វើឲ្យកើននូវសេចក្តីសំអប់(ការមា
នះ)របស់ព្រលឹងវិញ្ញាណទៅកាន់ព្រះ
ជាម្ចាស់។ មនុស្សដែលបង្ហាញ
ភាពរឹងត្អឹងរបស់ខ្លួន

ឬភាពមិនរវល់អើពើរកោតក្រែងចំពោះ
សច្ចភាពរបស់ព្រះជាម្ចាស់
នោះនឹងរមែងច្រូតកាត់នូវផលដែលខ្លួនបានសាបព្រោះ។
នៅក្នុងព្រះគម្ពីរបរិសុទ្ធទាំងមូល
ពុំមានសេចក្តីព្រមានណាដែលគួរឲ្យរន្ធត់ចិត្ត
ជាងការព្រមានប្រឆាំងនឹងការបង្ខាតពេល
លេងសើចនឹងអារក្សសាតាំងដូចដែល
អ្នកប្រាជ្ញបណ្ឌិតបានពោលថា“អ្នកមានបាប
នឹងត្រូវចងជាប់ដោយចំនងរបស់ខ្លួនឯង”..សុភាសិត៥:២២។

ព្រះគ្រិស្ទបានត្រៀមជាស្រេច
ដើម្បីដោះលែងឲ្យយើងមានសេរីភាព
អំពើបាបក៏ប៉ុន្តែទ្រង់មិនបង្ខិតបង្ខំយើង

ឡើយ។
កាលណាការប្រព្រឹត្តល្មើសនៅតែបន្ត
នោះសុឆន្ទៈនឹងទោរទន់ទៅអារក្ស
ហើយពេលនោះយើងនឹងគ្មានចំណង់
ឲ្យបានរួចមានសេរីភាពឡើយ។
ប្រសិនបើយើងមិនទទួលយកព្រះគុ
ណរបស់ទ្រង់
ជួបយើងបានដូចម្តេចបាន?យើងបាន
បំផ្លាញខ្លួនយើងដោយសារការសំរេច
ចិត្តចំពោះសេចក្តីស្រលាញ់របស់ទ្រង់
។
“មើលឥឡូវនេះជាវេលាដែគាប់ព្រះហ
ឫទ័យរបស់ទ្រង់ថ្ងៃនេះជាថ្ងៃសង្គ្រោះ
ហើយ”..កូរិនថូស២៦:២។
“ថ្ងៃនេះបើអ្នកឮសម្លេងទ្រង់នោះកុំឲ្យ
តាំងចិត្តរឹងរូសឡើយ”..ហេព្រើ៣:៨.៩
។

“មនុស្សយើងសំឡឹងមើលតែឫកពាខាងក្រៅតែប៉ុណ្ណោះ
ប៉ុន្តែព្រះជាម្ចាស់ទ្រង់ទតមើលទៅក្នុងចិត្តវិញ។
ចិត្តរបស់មនុស្សតែងតែមានភាពទំនាស់នៃវេទនាអារម្មណ៍រវាង
អំណរនិងសេចក្ដីកង្វល់
ចិត្តរវើរវាយក្រឡិចក្រឡុចដែលជាជំរកនៃភាពមិនបរិសុទ្ធនិងការបោកបញ្ឆោត”..សាំងយូអែលទី១ ១៦:៧។
ទ្រង់ឆ្វេងយល់នូវចំណង់ចិត្ត
គោលបំណង
និងការប៉ងប្រាថ្នារបស់យើង។
ព្រលឹងវិញ្ញាណរបស់អ្នកប្រឡាក់ដិតដាមដោយអំពើបាបយ៉ាងណានោះ
ចូរអ្នកចូលមកឯទ្រង់ដោយបែបសណ្ឋាននោះ ចុះ
ឲ្យដូចជាអ្នកលើកទំនុកតំកើងបានសុ

កែឧទានដោយចំហាឡើងថា:“ឱព្រះអង្គអើយសូមពិនិត្យមើលឲ្យបានស្គាល់ចិត្តទូលព្រះបង្គំផង
សូមល្បងលឲ្យបានជ្រាបអស់ទាំងគំនិតនៃទូលបង្គំតាមផ្លូវដ៏អស់កល្បជានិច្ច”..ទំនុកតំកើង១៣៩:២៣.២៤។

មនុស្សជាច្រើនទទួលស្គាល់សាសនាដែលកើតដោយប្រាជ្ញា..ពេលណាចិត្តរបស់យើងមិនបានសំអាតទេនោះសេចក្តីជំនឿលើព្រះបានគ្រាន់តែជាទំរង់ប៉ុណ្ណោះ។
សូមឲ្យលោកអ្នកអធិស្ឋានបានដូច្នេះវិញថា:“ឱព្រះអង្គអើយ
សូមបង្កើតចិត្តបរិសុទ្ធ នៅក្នុងទូលបង្គំហើយកែវិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង”..ទំនុកតំកើង៥១:១០។
សូមពិចារណាដោយស្មោះត្រង់ជាមួយ

វិញ្ញាណរបស់អ្នកចុះ។
សូមយកចិត្តទុកដាក់រំពឹងដោយខ្ជាប់ខ្ជួនដល់ខ្លួនព្រះចុះ
ប្រសិនបើជីវិតរបស់អ្នកឋិតក្នុងភាពអន្តរាយ។
នេះគឺជាបញ្ហាមួយដែលអ្នកត្រូវកែតម្រូវរវាងព្រលឹងអ្នកនឹងព្រះជាម្ចាស់ឲ្យបានជានិច្ចនិរន្តន៍តទៅ។
សេចក្ដីសង្ឃឹមមួយដែលគ្រាន់សន្មត ហើយគ្មានគោលចរិកច្បាស់លាស់ នឹងផ្ដល់នូវភាពមហន្តរាយចំពោះរូបគេ។

ចូរសិក្សាព្រះបន្ទូលរបស់ព្រះដោយសេចក្ដីអធិស្ឋានដោយអស់ពីចិត្ត។ ព្រះបន្ទូលនោះនឹងលាតត្រដាងនៅចំពោះមុខអ្នកនូវក្រិត្យវិន័យរបស់ព្រះ និងព្រះជន្មរបស់ព្រះគ្រិស្ទដែលជាគោ

លក្ខណ៍ចំបងនៃភាពបរិសុទ្ធហើយ
បើគ្មានការទាំងនេះទេនោះ“គ្មានមនុ
ស្សណាអាចឃើញព្រះជាម្ចាស់ឡើយ”
..ហេព្រើ១២:១៤។
ព្រះបន្ទូលនោះអាចឲ្យយើងស្គាល់អំ
ពើបាបបានយ៉ាងច្បាស់
ហើយបង្ហាញយ៉ាងច្បាស់នូវមធ្យោបា
យសំរាប់សង្គ្រោះ។
ចូរយកចិត្តទុកដាក់នៅពេលដែលព្រះ
បន្ទូលរបស់ព្រះពោលមកកាន់វិញ្ញាណ
របស់អ្នក។

នៅពេលដែលអ្នកឃើញភាពធំសំបើម
នៃអំពើបាប
និងយល់ពីលក្ខណៈដ៏ពិតប្រាកដរបស់
អ្នកផ្ទាល់
នោះកុំឲ្យអ្នកចុះចាញ់ក្នុងភាពអស់ស
ង្ឃឹមឡើយ។

ព្រះគ្រិស្ទយាងមកដើម្បីសង្គ្រោះមនុស្សមានបាប។
យើងមិនចាំបាច់ផ្សះផ្សារូបយើងនឹងព្រះជាម្ចាស់ឡើយ
ក៏ប៉ុន្តែសេចក្តីស្រលាញ់ដ៏លើសលប់នៃព្រះជាម្ចាស់ដែលជាអង្គព្រះគ្រិស្ទដែលបានផ្សះផ្សារពិភពលោកដោយព្រះអង្គផ្ទាល់..“ព្រះទ្រង់គង់ក្នុងព្រះគ្រិស្ទកំពុងផ្សះផ្សារលោកិយ៍និងព្រះអង្គទ្រង់”..កូរិនថូស២៥:១៩។
ទ្រង់ល្ងលោមដោយសេចក្តីស្រលាញ់ដ៏ស្រទន់ទៅកាន់រាស្រ្តរបស់ទ្រង់កំពុងវង្វេងផ្លូវ។
សូម្បីមាតាបិតាទាំងឡាយនៅលើលោកនេះក៏ពុំមានសេចក្តីអំណត់អត់ធ្មត់ចំពោះកំហុសរបស់កូនឲ្យស្មើនឹងសេចក្តីអត់ធ្មត់របស់ព្រះជាម្ចាស់ចំពោះមនុស្សដែលទ្រង់កំពុងស្វែងរកដើម្បីសង្គ

ពោះនោះឡើយ។
គ្មានបប្ញរមាត់នៃមនុស្សឯណា
ដែលអាចបង្ហូរនូវការទទួចអង្វរយ៉ាង
ស្រទន់ចំពោះអ្នករង្វេងឲ្យបានដូចទ្រង់
ទេ។ គ្រប់ទាំងសេចក្តីសន្យា
និងការព្រមានរបស់ទ្រង់គ្មានអ្វីក្រៅពី
សេចក្តីស្រលាញ់ដែលពុំអាចពណ៌នា
បាននោះឡើយ។

នៅពេលដែលអារក្សសាតាំងមកប្រាប់
អ្នកថា
អ្នកគឺជាមនុស្សមានបាបដ៏ធ្ងន់នោះ
ចូរអ្នកងើបមើលទៅព្រះអង្គសង្គ្រោះ
ហើយថ្លែងពីគុណសម្បត្តិដ៏ឥតខ្ចោះរប
ស់ទ្រង់ចុះ។
លោកអ្នកអាចស្វែងរកសេចក្តីជំនួយ
បានកាលណាអ្នកស្វែងរកពន្លឺរបស់ទ្រ
ង់។ ចូរទទួលស្គាល់អំពើបាបរបស់អ្នក

ប៉ុន្តែសូមថ្លែងប្រាប់ទៅបច្ចាមិត្រវិញ
ថា:“ព្រះយេស៊ូគ្រិស្ទជាម្ចាស់យាងមក
ពិភពលោកយើងនេះគឺដើម្បីសង្គ្រោះ
មនុស្សមានបាប..ហើយរូបអ្នកនឹងត្រូវ
បានសង្គ្រោះដោយសេចក្តីស្រលាញ់ដ៏
ឥតអ្វីប្រៀបផ្ទឹមបាននោះ”..ធីម៉ូថេ១
១:១៥។
ព្រះយេស៊ូលើកសំនួរមួយសួរដល់ស៊ីម៉ូ
នអំពីមនុស្សដែលជំពាក់បំណុល២នា
ក់ ម្នាក់ជំពាក់តែបន្តិចបន្តួចប៉ុណ្ណោះ
ឯម្នាក់ទៀតជំពាក់យ៉ាងច្រើន។
តែនាយចៅហ្វាយសុខចិត្តបំភ្លេចបំណុ
លនោះចោល។
ព្រះយេស៊ូគ្រិស្ទសួរស៊ីម៉ូនថា
តើរវាងអ្នកជំពាក់បំណុលទាំងពីរនោះ
អ្នកមួយណាដែលស្រលាញ់ចៅហ្វាយ
ជាងគេ។
ស៊ីម៉ូនទទួលឆ្លើយថា:“គឺម្នាក់ដែលជំ

ពាក់បំណុលច្រើនជាងនោះដែលស្រលាញ់ចៅហ្វាយច្រើនជាងគេ”..លូកា ៧:៤៣។
យើងមានអំពើបាបយ៉ាងធ្ងន់ធ្ងរតែព្រះគ្រិស្ទបានទទួលការសុគតដើម្បីឲ្យយើងបានរួចផុតពីបាបនោះ
ពោលគឺដើម្បីលោះបាបនៃយើងរាល់គ្នា។
លក្ខណៈសម្បត្តិនៃការលះបង់ព្រះជន្មរបស់ទ្រង់(គឺជាមហាពលិកម្មនៅលើឈើឆ្កាង)គឺធ្ងនល្អមនឹងបង្ហាញចំពោះព្រះវរបិតាដើម្បីជាគុណប្រយោជន៍ជំនួសយើងហើយ។
នរណាដែលទ្រង់សន្តោសជាងគេនោះនឹងស្រលាញ់ទ្រង់ជាងគេដែរហើយគេនឹងឈរគាល់ទៀបបល្ល័ង្កទ្រង់ដោយ ច្រៀងសរសើរ
ដំកើងចំពោះសេចក្តីស្រលាញ់ដ៏ធំធេង

និងដង្វាយ
ដ៏លើសលន់ក្រៃលែងរបស់ទ្រង់។
នៅពេលដែលយើងយល់ពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់បានបរិបូណ៌
នោះយើងនឹងអាចយល់ដឹងច្បាស់អំពីភាពទុច្ចរិតនៃអំពើបាបដែរ។
នៅពេលដែលយើងឃើញខ្សែច្រវ៉ាក់ដ៏វែងដែលបានទំលាក់មកសំរាប់យើង..
នៅពេលដែលយើងយល់ពីព្រះមហាពលិកម្ម(ជាដង្វាយធួនបាបយើង)ដ៏លើសលប់ដែលព្រះគ្រិស្ទធ្វើដើម្បីយើងរាល់គ្នា
ពេលនោះចិត្តរបស់យើងនឹងរសាយដោយភាពស្រទន់
និងពោរពេញដោយការស្តាយក្រោយយ៉ាងខ្លាំង
ចំពោះកំហុសដែលយើងបានធ្វើ។

# ជំពូកទី ៤ — ការលន់តួបាប

“នរណាដែលគ្របបាំងការរំលងរបស់ខ្លួននោះនឹងមិនចំរើនឡើងទេតែនរណាដែលលន់តួហើយលះបង់អំពើនោះនឹងប្រទះបានសេចក្តីមេត្តាករុណាវិញ”។..សុភាសិត២៨:១៣

លក្ខខ័ណ្ឌដើម្បីឲ្យបានទទួលនូវសេចក្តីមេត្តាសន្តោសអំពីព្រះជាម្ចាស់គឺសាមញ្ញត្រឹមត្រូវនិងសមហេតុសមផល។ព្រះជាម្ចាស់មិនតម្រូវដាច់ខាតឲ្យយើងធ្វើការធ្ងន់ធ្ងរហួសប្រមាណទើបទ្រង់នឹងអត់ឱនអំពើបាបឲ្យយើងនោះឡើយ។យើងមិនចាំបាច់ធ្វើធម្មយាត្រាមួយដ៏យូរដែលបណ្តាលឲ្យហេវហត់ខ្លាំងឬក៏សំដែងការដាក់ទណ្ឌកម្មខ្លួនឯងដើម្បី

បង្ហាញឲ្យឃើញថាព្រលឹងវិញ្ញាណរបស់យើងបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ឬក៏ដើម្បីលុបលាងទោសកំហុសដែលបានប្រព្រឹត្តមកហើយនោះឡើយ។ប៉ុន្តែអស់អ្នកណាដែលលន់តួកំហុសនិងបោះបង់អំពើបាបរបស់ខ្លួនចោលចេញនោះនឹងបានទទួលសេចក្តីមេត្តាករុណាវិញ។

សាវ័កព្រះបានពោលថា:“ចូរអ្នករាល់គ្នាលន់តួទោសនឹងគ្នានិងអធិស្ឋានឲ្យគ្នាទៅវិញទៅមកប្រយោជន៍ឲ្យបានជាចុះ”..យ៉ាកុប៥:១៦។ចូរលន់តួអំពើបាបរបស់អ្នកនឹងព្រះជាម្ចាស់ព្រោះថាមានតែទ្រង់មួយអង្គប៉ុណ្ណោះដែលអាចអត់អោនទោសឲ្យបានហើយនិងសារភាពអំពើឆ្គាំឆ្គងនឹងគ្នាទៅវិញទៅមក។ប្រសិនបើអ្នកធ្វើឲ្យមិត្តភក្តិឬអ្នកជិតខាងទទួ

លការអាក់អន់ស្រពន់ចិត្តនោះអ្នកត្រូវតែសារភាពពីកំហុសរបស់អ្នករីឯការអត់អោនទោសនោះសំរេចលើអ្នកភាគីម្ខាងទៀត។បន្ទាប់អំពីនោះអ្នកនឹងស្វែងរកការអត់ឱនទោសពីព្រះជាម្ចាស់ពីព្រោះមនុស្សដែលអ្នកធ្វើឲ្យមានរបួសនោះជាកម្មសិទ្ធរបស់ព្រះជាម្ចាស់។ការធ្វើឲ្យគេរងគ្រោះនោះបានន័យថាអ្នកបានធ្វើបាបប្រឆាំងនឹងព្រះដែលជាព្រះបង្កើតលោកនិងជាព្រះដែលលោះបាបយើងផង។បញ្ហានេះបានដាក់នៅចំពោះអ្នកសំរុះសំរួលដ៏សុចរិត“ដែលជាសម្តេចសង្ឃដ៏ខ្ពស់បំផុតដែលទ្រង់បានទទួលសេចក្តីល្បួងគ្រប់យ៉ាងដូចយើងរាល់គ្នាដែរតែទ្រង់ឥតបានធ្វើបាបសោះឡើយហើយដែលយល់នូវភាពកំសោយរបស់យើងរាល់គ្នា
ព្រមទាំងអាចលាងសំអាតគ្រប់ទាំងអ

ពីទុច្ចរិតរបស់យើងផង”..ហេព្រឺ៩:១៥ ។

អ្នកទាំងឡាយដែលមិនព្រមបន្ទាបវិញ្ញាណរបស់ខ្លួនចំពោះព្រះក្នុងការទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្តនោះពុំបានបំពេញលក្ខ័ណ្ឌទី១ នៃការទទួលយកព្រះឡើយ។ប្រសិនបើយើងមិនដែលបានឆ្លងកាត់បទពិសោធន៍មួយក្នុងការប្រែចិត្តទេហើយមិនបានបន្ទាបព្រលឹងរបស់យើងក្នុងការសោកស្តាយក្នុងចិត្តនិងការលន់តួអំពើបាបដោយការស្អប់ខ្ពើមអំពើទុច្ចរិតរបស់យើងទេនោះយើងមិនអាចស្វែងរកការអត់ឱនទោសចំពោះអំពើបាបមួយដ៏ពិតប្រាកដបានឡើយ។ម៉្យាងទៀតប្រសិនបើយើងពុំបានស្វែងរកការងារ

នោះទេនោះយើងក៏មិនអាចជួបសេចក្ដីសុខ

សន្តិភាពក្នុងព្រះជាម្ចាស់បានឡើយ។ មូលហេតុតែមួយគត់ដែលបណ្ដាលឲ្យយើងមិនបានទទួលការលើកលែងទោសអំពីបាបគឺមិនព្រមបន្ទាបខ្លួនបន្ទន់ចិត្តរបស់យើងនិងអនុលោមទៅតាមលក្ខណ្ឌទាំងឡាយនៃពាក្យសច្ចៈ។មានសេចក្ដីបង្រៀនយ៉ាងច្បាស់លាស់ដែលបានពន្យល់ទាក់ទងទៅនឹងបញ្ហានេះ។ការលន់តួចំពោះអំពើបាបទោះជានៅទីសាធារណៈក្ដីឬទីកន្លែងស្ងាត់កំបាំងក្ដីត្រូវតែបញ្ចេញដោយស្មោះត្រង់និងគ្មានការលាក់លៀម។ការលន់តួពុំមែនធ្វើដោយរបៀបផ្ដេសផ្ដាសឬដោយធ្វេសប្រហែសឬដោយបង្ខិតបង្ខំទៅលើមនុស្សដែលពុំទាន់ទទួលស្គាល់នូវ

ន័យនៃការស្អប់ខ្ពើមដលើអំពើបាប នោះទេ។ការលន់តួគឺជាការបង្ហូរចេញ នូវជំរៅចិត្តនិងវិញ្ញាណដើម្បីស្វែងរកផ្លូវទៅកាន់ព្រះជាម្ចាស់ដែលមានព្រះទ័យមេត្តាករុណាដ៏ឥតព្រំដែន។អ្នកលើកទំនុកតំកើងសរសើរព្រហដោយពោលពាក្យថា:“ព្រះយេហូវ៉ាគង់នៅជិតបង្កើយនឹងអស់អ្នកដែលមានចិត្តសោកសង្រេងហើយទ្រង់ជួយសង្គ្រោះដល់អស់អ្នកដែលមានវិញ្ញណទន់ទាប”..ទំនុកតំកើង៣៩:១៨។

ការលន់តួបាបដ៏ពិតប្រាកដតែងតែសំដែងចេញតាមអត្តចរិកដ៏ជាក់លាក់និងទទួលស្គាល់អំពើបាបដោយឡែកពីគ្នា។អំពើបាបខ្លះត្រូវសារភាពចំ
ពោះព្រះតែប៉ុណ្ណោះ..វាអាចមានការខុសឆ្គងប្រសិនបើយើងសារភាពចំពោះ

បុគ្គលដែលយើងបង្កឲ្យមានការឈឺចាប់នោះ។អ្នកដែលធ្វើកំហុសចំពោះអ្នកដទៃគួរតែលន់តួកំហុសដែលគេបានប្រព្រឹត្តធ្វើឲ្យគេរងគ្រោះ..បើអ្នកបានធ្វើកំហុសជាសាធារណៈវិញនោះគួរតែលន់តួកំហុសជាសាធារណៈវិញដែរ។ ក៏ប៉ុន្តែការលន់តួទោសកំហុសត្រូវសំដែងឲ្យច្បាស់លាស់ចំៗចំនុចកុំឲ្យប្រាសចាកវិន័យទាំងយល់ព្រមទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្តផង។

នៅក្នុងសម័យហោរាសាំយូអែលជនជាតិអ៊ីស្រាអែលបានវង្វេងចេញឆ្ងាយអំពីព្រះ។ពួកគេបានទទួលទុក្ខវេទនាដែលជាផលវិបាកនៃអំពើបាបពីព្រោះតែគេបានបាត់បង់នូវសេចក្តីជំនឿក្នុងព្រះជាម្ចាស់..បាត់បង់នូវការយល់ដឹងពីឫទ្ធីបារមីនិងប្រាជ្ញាញាណរបស់ព្រះ

ក្នុងការគ្រប់គ្រងប្រជារាស្ត្ររបស់ទ្រង់ បាត់បង់នូវសេចក្តីទំនុកចិត្តចំពោះអំណាចបារមីរបស់ទ្រង់ក្នុងការការពារនិងគាំទ្របុព្វហេតុរបស់ទ្រង់។គេបានងាកចេញអំពីព្រះដ៏ជាព្រះដែលគ្រប់គ្រងលោកសន្និវាសទាំងមូលហើយបែរជាប្រាថ្នាចង់បានការគ្រប់គ្រងដូចជាប្រទេសនានានៅជុំវិញខ្លួនគេដែរ។មុនពេលដែលគេស្វែងរកឃើញសុខសន្តិភាពគេបានសំដែងការលន់តួសារភាពទោសកំហុសយ៉ាងច្បាស់លាស់ដូច្នេះថា:”យើងបានបន្ថែមអំពើបាបនេះក្នុងអំពើអាក្រក់របស់យើងដោយបានសូមស្តេចសំរាប់យើងខ្ញុំនេះ”..សាំយូអែល ១១២:១៩។គេត្រូវតែសារភាពចំពោះព្រះនូវអំពើបាបដែលខ្លួនបានប្រព្រឹត្តិខុសឆ្គងនោះ។ការរមិលគុណរបស់គេបានគាបសង្កត់ទៅលើព្រលឹងរបស់គេធ្វើ

ឲ្យចិត្តរបស់គេព្រួយកង្វល់ហើយព្រះជាម្ចាស់រឹងរឹតតែមិនសព្វព្រះហឫទ័យទៅទៀតអំពីការនេះ។

—

ព្រះពុំទទួលយកនូវការលន់តួដោយគ្មានការប្រែចិត្តនិងគ្មានការកែទម្រង់ដោយស្មោះស្ម័គ្រនោះឡើយ។ជីវិតត្រូវតែប្រដាប់ដោយការប្រែផ្លាស់មួយដោយមានការសំរេចចិត្តដ៏ច្បាស់លាស់។អ្វីៗដែលប្រឆាំងផ្ទុយនឹងព្រះជាម្ចាស់ត្រូវតែបំបាត់ចោល។ការបែបនេះហើយទើបពិតជាលទ្ធផលនៃការសោកស្តាយចំពោះអំពើបាបដ៏ពិតប្រាកដមែន។ចំណែកនៃការងារដែលយើងត្រូវធ្វើបានលាតត្រដាងយ៉ាងច្បាស់នៅមុខយើងរួចជាស្រេចដូចមានចែងក្នុងព្រះគម្ពីរអេសាយថា:”

ចូរលាងចេញចូរជំរះខ្លួនឲ្យស្អាតចុះចុះបំបាត់អំពើអាក្រក់ដែលឯងរាល់គ្នាបានប្រព្រឹត្តពីភ្នែករបស់អញចេញហើយលែងប្រព្រឹត្តអំពើអាក្រក់តទៅទៀត។ចូរហាត់រៀនធ្វើការល្អវិញចូរស្វែងរកឲ្យបានសេចក្តីយុត្តិធម៌ចូរការពារមនុស្សដែលត្រូវគេសង្កត់សង្កិនចូរកាត់ក្តីចំពោះពួកកំព្រាហើយកាន់ក្តីជំនួសពួកស្រ្តីមេម៉ាយ”..អេសាយ១:១៦.១៧។“បើមនុស្សអាក្រក់នោះនឹងប្រគល់របស់បញ្ចាំដល់ម្ចាស់វិញហើយព្រមប្រគល់មកវិញនូវរបស់ដែលខ្លួនបានលួចព្រមទាំងដើរតាមច្បាប់នៃជីវិតនេះឥតប្រព្រឹត្តិអំពើទុច្ចរិតទៀតនោះគេនឹងបានរស់នៅជាពិតឥតត្រូវស្លាប់ទេ”អេសេគាល៣៣:១៥។សាវ័កប៉ុលបានថ្លែងជាប់ទាក់ទិននឹងការងារនឹងការប្រែចិត្តនេះថា:

“ត្បិតមើលសេចក្តីនេះឯងគឺអ្នករាល់គ្នាមានសេចក្តីព្រួយដ៏គាប់ដល់ព្រះហឫទ័យនៃព្រះនោះបានបង្កើតឲ្យអ្នករាល់គ្នាមានសេចក្តីសង្វេគសេចក្តីដោះសារសេចក្តីគ្នាន់ខ្នាញ់សេចក្តីភ័យខ្លាចសេចក្តីនឹករលឹកសេចក្តីឧស្សាហ៍និងសេចក្តីសងសឹកជាខ្លាំងទាំងម៉្លេះអ្នករាល់គ្នាបានសំដែងយ៉ាងច្បាស់ថាខ្លួនបរិសុទ្ធក្នុងដំណើរនេះគ្រប់ជំពូក..កូរិនថូសទី២៧:១១។

នៅពេលដែលអំពើបាបបានរម្ងាប់ការយល់ដឹងផ្នែកសីលធម៌នោះមនុស្សដែលមានកំហុសពិតជាមើលពុំឃើញភាពខ្វោះខ្នាំឆ្គងនៃអត្តចរិករបស់ខ្លួននិងពុំអាចដឹងច្បាស់នូវអំពើទុច្ចរិតដ៏ធំធេងដែលខ្លួនបានប្រព្រឹត្តនោះឡើយ។ដរាបណាគេនៅតែមិនយល់ព្រមទទួលយ

កអំណាចអំពីព្រះវិញ្ញាណបរិសុទ្ធដែល
ទ្រង់ឆ្វេងយល់ពីគ្រប់ការដែលយើងធ្វើ
នោះទេគេនៅតែស្ថិតក្នុងភាពស្រពិច
ស្រពិលក្នុងអំពើបាបរបស់គេដដែល។
ការលន់តួកំហុសរបស់គេពិតជាពុំស្
មោះអស់ពីចិត្តឡើយ។ចំពោះគ្រប់ការ
ដែលស្គាល់កំហុសខ្លួនគេតែងមានការ
ដោះសារជានិច្ចដោយពោលថាប្រសិន
បើមិនឋិតក្នុងកាលៈទេសៈបែបនោះ
ទេនោះគេពិតជាពុំធ្វើដូច្នេះឡើយ។

បន្ទាប់ពីអាដ័មនិងអេវ៉ាបានបរិភោគផ្លែ
ឈើដែលព្រះបានហាមឃាត់នោះមក
នោះចិត្តរបស់គេបានពោរពេញទៅដោ
យសេចក្តីអៀនខ្មាសនិងការភ័យរន្ធត់
។ជាដំបូងគំនិតរបស់គេគឺធ្វើយ៉ាងណា
ដោះសារអំពើបាបរបស់គេនិងគេចចេ
ញពីទណ្ឌកម្ម

* * * * *

បន្ទាប់ពីអាដ័មនិងអេវ៉ាបានបរិភោគផ្លែឈើដែលព្រះបានហាមឃាត់នោះមក នោះចិត្តរបស់គេបានពោរពេញទៅដោយសេចក្ដីអៀនខ្មាសនិងការភ័យរន្ធត់ ។
ដ៏គួរឲ្យខ្លាចរអា..សេចក្ដីស្លាប់។នៅពេលដែលព្រះយេហូវ៉ាបានសាកសួរទាក់ទិននឹងអំពើបាបរបស់គេអាដ័មបានឆ្លើយដោយទំលាក់កំហុសពាក់កណ្ដាលទៅលើព្រះជាម្ចាស់និងពាក់កណ្ដាលទៀតទំលាក់ទោះលើគូគាប់របស់ខ្លួនដោយបោលពាក្យថា:“ស្ត្រីដែលទ្រង់ប្រទានឲ្យនៅជាមួយទូលបង្គំបានឲ្យផ្លែឈើនោះមកទូលបង្គំហើយទូលបង្គំក៏ទទួលទានទៅ”។រីឯស្ត្រីបានទំលាក់កំ

ហុសទៅលើពស់ថា:“ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ហើយខ្ញុំម្ចាស់ក៏ទទួលទានផ្លែឈើនោះទៅ”..លោកុប្បត្តិ៣:១២.១៣។ហេតុអ្វីបានជាព្រះអង្គបង្កើតសត្វពស់នឹងមក?
ហេតុអ្វីព្រះអង្គបណ្តោញវាឲ្យមកកាន់សួនច្បារអេដែន?
សំណួរទាំងនេះបានចោលស្រមោលន័យមួយដែលបង្ហាញពីការដោះសារចំពោះអំពើបាបរបស់នាងដោយចោទប្រកាន់ទៅព្រះក្នុងការទទួលខុសត្រូវចំពោះការធ្លាក់ចុះក្នុងអំពើបាបរបស់ពួកគេ។ព្រលឹងវិញ្ញាណដែលទាញតំរូវនឹងខ្លួនឯងបានចាប់កំណើតពីត្រឹមឪពុកម្ដាយដើមរបស់យើងដែលបានចេះភូតភរហើយក៏មានរៀងរាបដរាបមកតាមរយៈតំណពូជរបស់លោកអាដ័ម។ការលន់តួបាបតាមលំដាប់នេះមិនបានទទួ

លអំណាចពីព្រះវិញ្ញាណបរិសុទ្ធនៃព្
រះហើយព្រះជាម្ចាស់ពិតពុំទទួលស្គា
ល់នូវការលន់តួកំហុសបែបនេះឡើយ
។ការលន់តួដ៏ពិតប្រាកដនឹងនាំឲ្យគេទ
ទួលស្គាលកំហុសរបស់ខ្លួនហើយលទ្ធ
ផលដឹងដោយគ្មានបំភាន់បំភ្លៃឬដោយ
ពុតត្បុតក្រលិចក្រឡុចសោះឡើយ។ដូ
ចជាមនុស្សដ៏កំសត់ម្នាក់ដែលមិនហា
នទាំងងើបសំលឹងមើលទៅឯស្ថានសួ
គ៌
រួចស្រែកអំពាវឡើងថា:“ព្រះជាម្ចាស់
សូមមេត្តាករុណាចំពោះរូបខ្ញុំម្ចាស់ដែ
លមានបាបផង”។អស់អ្នកណាដែលព្
រមទទួលស្គាល់កំហុសរបស់ខ្លួននឹងត្រូ
វបានទទួកការកែតម្រូវឲ្យចុះសំរុងនឹង
ទ្រង់ត្បិតព្រះយេស៊ូបានសន្យាដោយនូ
វព្រះលោហិតរបស់ទ្រង់ដើម្បីជាបុព្វ

ហេតុដល់ព្រលឹងដែលបានប្រែចិត្តហើយ។

ឧទាហរណ៍ជាច្រើននៅក្នុងព្រះបន្ទូលរបស់ព្រះអំពីការប្រែចិត្តដ៏ពិតប្រាកដនិងការដាក់ខ្លួនបានបង្ហាញឲ្យឃើញនូវការលន់តួរបស់វិញ្ញាណដែលគ្មានការដោះសារចំពោះអំពើបាបឬការព្យាយាមដើម្បីកែតំរូវធ្វើឲ្យស្អាតបរិសុទ្ធដោយខ្លួនឯង។សាវ័កប៉ុលពុំបានព្យាយាមលាក់កំបាំងទោសកំហុសរបស់ខ្លួនឯងសោះតែគាត់បានលាតត្រដាងនូវកំហុសដ៏ខ្មៅក្រខ្វក់ទាំងនោះដោយគ្មានបំណងបន្ធូរបន្ថយសូម្បីតែបន្តិចសោះឡើយ។គាត់មានប្រសាសន៍ថាៈ"ទូលបង្គំបានចាប់មនុស្សបរិសុទ្ធជាច្រើនទៅដាក់គុកដោយបានទទួលអំនាចពីពួកសង្គ្រាចមកហើយកាលគេ

សម្លាប់ពួកអ្នកទាំងនោះទូលបង្គំក៏យល់ព្រមដែរ។ទូលបង្គំបានធ្វើទោសគេជាញឹកញយនៅគ្រប់ទាំងសាលាជំនុំទាំងបង្ខំឲ្យគេពោលពាក្យប្រមាថដល់ព្រះផងហើយដោយទូលបង្គំមានចិត្តក្ដៅក្រហាយជ្រុលពេកទើបទូលបង្គំទៅទុក្ខបៀតបៀនគេរហូតដល់ទីក្រុងនៃសាសន៍ដទៃផង"..កិច្ចការ២៦:១០.១១។គាត់មិនមានការរារែកនឹងប្រកាសថា:"ព្រះយេស៊ូគ្រិស្ទទ្រង់បានយាងមកក្នុងលោកនេះដើម្បីសង្គ្រោះមនុស្សមានបាបដែលរូបខ្ញុំនេះជាលេខមួយក្នុងពួកគេ ". . ធីម៉ូថេទី១ ១:១៥។

ចិត្តដែលខ្ទេចខ្ទាំនិងមិនលំទោននោះត្រូវបានបំពេញជាថ្មីដោយការប្រែចិត្ត។ ដ៏ពិតប្រាកដដែលពោលសរសើរដឹងគុណានូវសេចក្ដីស្រលាញ់របស់ព្រះជាម្ចា

ស់និងថ្ងៃលោះនៅឯភ្នំកាល់វ៉ារី ។ ដូចជាកូនប្រុសដែលសារភាពកំហុស ទៅកាន់ឪពុកជាទីស្រលាញ់របស់ខ្លួន នោះអ្នកដែលសារភាពកំហុសដ៏ពិតនឹងនាំយកអស់ទាំងអំពើបាបរបស់ខ្លួន ដែលបានប្រព្រឹត្តមកលាតត្រដាងនៅចំពោះមុខព្រះជាម្ចាស់យ៉ាងដូច្នេះដែរ ។ដូចមានសេចក្តីចែងទុកមកថា:“ប្រសិនបើយើងលន់តួបាបវិញនោះទ្រង់មានព្រះទ័យស្មោះត្រង់ហើយសុចរិតប្រយោជន៍នឹងអត់ទោសឲ្យយើងហើយលាងសំអាតយើងអំពីអពើទុច្ចរិតទាំងឡាយ”..យ៉ូហានទី១១:៩។

# ជំពូកទី ៥ — ការឧទ្ទិសខ្លួនចំពោះព្រះ

ព្រះជាម្ចាស់បានសន្យាដល់យើង:“ឯងរាល់គ្នានឹងស្វែងរកអញហើយនឹងរកឃើញកាលណាឯងស្វែងរកអញដោយអស់ពីចិត្ត”..យេរេមា២៩:១៣។យើងត្រូវតែថ្វាយចិត្តទាំងស្រុងដល់ព្រះជាម្ចាស់បើពុំដូច្នោះទេយើងពុំអាចមានការប្រែផ្លាស់ឲ្យបានទទួលរូបសណ្ឋានដូចទ្រង់ឡើយ។យើងបានមិនស្គាល់ព្រះតាំងពីកំណើតមកម្លេះ។ព្រះវិញ្ញាណបរិសុទ្ធបានពិពណ៌នាលក្ខណៈរបស់យើងដោយពាក្យដោយពាក្យដូចនេះតទៅថា:

“អ្នករាល់គ្នាស្លាប់ដោយសារការរំលងនឹងអំពើបាប”..អេភេសូរ២:១..“គ្រប់ទាំងក្បាលក៏ឈឺឯចិត្តក៏ទន់ល្វើយ”..អេ

សាយ១:៥“ពុំមានអ្វីល្អក្នុងខ្លួនឡើយ”..
អេសាយ១:៦។យើងបានជាប់យ៉ាងជ្
រៅនៅក្នុងអន្ទាក់របស់អារ័ក្សសាតាំង“
យើងបានចាប់ជាឈ្លើយទៅតាមទំនើ
ងចិត្តរបស់អារ័ក្សសាតាំង”..អេភេសូរ
២:១/ អេសាយ១:៥.៦/
ធីម៉ូថេទី២២:៦។ព្រះជាម្ចាស់ចង់ព្យាបា
លរបួសឲ្យយើងដោះលែងឲ្យយើងមា
នសេរីភាពជាថ្មីឡើងវិញ។ប៉ុន្តែដោយ
អំពើនេះតម្រូវឲ្យមានការប្រែរូបសណ្ឋា
នទាំងស្រុងគឺការផ្លាស់ប្រែថ្មីនូវលក្ខ
ណៈដើមរបស់យើងនោះយើងត្រូវតែ
ប្រគល់ខ្លួនយើងទាំងស្រុងថ្វាយដល់ព្
រះជាម្ចាស់។

សង្គ្រាមមួយដែលមនុស្សច្បាំងនឹងខ្លួន
ឯងគឺជាសមរភូមិមួយដ៏ធំបំផុតដែលម
នុស្សគ្រប់ប្រាណធ្លាប់បានប្រលូក។កា

វប្ាយខ្លួននឹងចុះចូលគ្រប់ទាំងអស់ទៅ
នឹងបំណងព្រះហឫទ័យរបស់ព្រះជាម្
ចាស់តម្រូវការតស៊ូពុំពារក៏ប៉ុន្តែព្រលឹង
វិញ្ញាណរបស់យើងត្រូវតែចុះចូលនឹងព្
រះជាម្ចាស់មុនពេលដែលព្រះអាចនឹង
ប្រទានវិញ្ញាណថ្មីមួយដែលឋិតក្នុងភា
ពល្អបរិសុទ្ធ។ការគ្រប់គ្រងរបស់ព្រះជា
ម្ចាស់ពុំមែនស្ថាបនានៅលើការចុះចូល
ដោយភាពរឹតងងល់ឬដោយការត្រួត
ត្រាដែលគ្មានហេតុផលដូចជាអារក្ស
សាតាំងបានប្រឌិតនោះទេ។ការគ្រប់គ្
រងនោះបានដាស់បញ្ញាស្មារតីនិងសតិ
សម្បជញ្ញៈរបស់យើងឲ្យមានការពិចារ
ណាដូចជាព្រះអម្ពីអេសាយ១:១៨បាន
ចែងថា:
“មកចុះយើងនឹងពិភាក្សាជាមួយគ្នា”..
គឺជាសេចក្តីដង្ហោយហៅរបស់ព្រះជាអ
ទិករទៅកាន់មនុស្សទាំងឡាយដែលទ្

រង់បានបង្កើតមក។ព្រះជាម្ចាស់ទ្រង់ពុំ
បានបង្ខិតបង្ខំចិត្តរបស់មនុស្សលោក
ដែលទ្រង់បានបង្កើតមកនោះឡើយ។
ទ្រង់ពុំអាចទទួល
យកនូវការស្វាគមន៍ដែលមិនបានចេ
ញពីដួងចិត្តបរិសុទ្ធនិងបញ្ញាជ្រះថ្លា
នោះទេ។ការចុះចូលដោយបង្ខំចិត្តដូច្
នោះវានឹងបង្អាក់ការចំរើនល្អតលាស់ដ៏
ពិតប្រាកដនៃគំនិតចរិយាផ្លូយទៅវិញ
វានឹងបណ្តាលឲ្យមនុស្សបានត្រឹមតែ
សភាវៈដូចជាម៉ាស៊ីនតែប៉ុណ្ណោះ។ល
ក្ខណៈបែបនេះគឺពុំមែនជាបំណងហឫ
ទ័យនៃព្រះដ៏បង្កើតលោកឡើយ។ទ្រង់
មានបំណងហឫទ័យចង់ឲ្យមនុស្សដែ
លលោកជាស្នាព្រះហស្តដ៏ឆ្នើមបំផុតរ
បស់ព្រះចេស្តាទ្រង់ក្នុងការបង្កើតលោ
ក
បានសំរេចទៅដល់ការវិវត្តដ៏ខ្ពស់បំផុត

ដែលគេអាចធ្វើទៅបាន។ទ្រង់បានរៀបចំជាស្រេចចំពោះមុខយើងនូវទំហំនៃព្រះពរដែលតាមរយៈព្រះគុណរបស់ទ្រង់យើងអាចសំរេចបានព្រះពរទាំងនោះ។
ទ្រង់ដង្ហោយហៅឲ្យយើងប្រគល់ខ្លួនចំពោះទ្រង់
ប្រយោជន៍ឲ្យទ្រង់អាចនឹងបានផ្តល់ព្រះវិញ្ញាណរបស់ទ្រង់ដល់យើង។ការនេះពឹតនៅលើខ្លួនយើងជាអ្នកធ្វើការសំរេចថាតើយើងនឹងអាចរំដោះខ្លួនឲ្យរួចពីចំណងនៃអំពើបាបដើម្បីរួមចំណែកនឹងសេរីភាពដ៏ត្រចះត្រចង់នៃព្រះរាជបុត្រានៃព្រះអម្ចាស់។

—

ក្នុងការថ្វាយរូបអង្គយើងដល់ព្រះជាម្ចាស់ជាការចាំបាច់យើងត្រូវបោះបង់នូវគុ

របស់អ្វីៗទាំងអស់ដែលអាចបំបែកបំបាក់
យើងអំពីព្រះជាម្ចាស់។ដូច្នេះហើយទើ
បព្រះអង្គសង្គ្រោះមានបន្ទូលថា:“ដូច្
នេះអស់អ្នកណាក្នុងពួកអ្នករាល់គ្នាដែ
លមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំ
ងអស់នោះធ្វើជាសិស្សខ្ញុំមិនបានឡើ
យ”..លូកា១៤:៣៣។អ្វីៗដែលអូសទា
ញចិត្តឲ្យឆ្ងាយពីព្រះត្រូវតែបោះបង់
ចោលចេញ។ភោគសម្បត្តិគឺជារូបសក្
ការ:
ចំពោះមនុស្សជាច្រើន។សេចក្តីស្រលា
ញ់ចំពោះទឹកប្រាក់និងទ្រព្យសម្បត្តិគឺ
ជាច្រវាក់មាសដែលចងភ្ជាប់ខ្លួនគេទៅ
នឹងអារក្សសាតាំង។កិត្តិយសនិងកិត្តិ
ស័ព្ទខាងលោកិយគឺជាព្រះរបស់ស្រទា
ប់វណ្ណ:មួយ..រីឯជីវិតដែលពេញចិត្តនឹ
ងភាពអាត្មានិយមនិងការគេចវេះពីការ
ទទួលខុសត្រូវគឺជារូបសក្ការ:ចំពោះម

នុស្សដទៃទៀត។ក៏ប៉ុន្តែចំណងបែប
នេះត្រូវតែកាត់ផ្ដាច់ចោលចេញ។យើង
មិនអាចចែកខ្លួនយើងពាក់កណ្ដាល
ជារបស់ព្រះអម្ចាស់និង
ពាក់កណ្ដាលទៀតជារបស់លោកិយ
ឡើយ។យើងពុំមែនជាកូនរបស់ព្រះជា
ម្ចាស់ឡើយលើកលែងតែយើងប្រគល់
រូបយើងទាំងស្រុងថ្វាយដាច់ដល់ទ្រង់
។

មានមនុស្សខ្លះទៀតដែលអះអាងថា
គេបំរើដល់ព្រះជាម្ចាស់ប៉ុន្តែគេពឹងផ្អែក
លើការប្រឹងប្រែងផ្ទាល់ខ្លួនដើម្បីគោរព
បទបញ្ញត្តរបស់ព្រះដើម្បីធ្វើចរិយាឲ្យ
បានត្រឹមត្រូវនិងដើម្បីឲ្យបានសង្គ្រោះ
។គេពុំបានរំភើបចិត្តដោយសារសេចក្ដី
ស្រលាញ់ដ៏ជ្រាលជ្រៅរបស់ព្រះគ្រិស្ដ
ឡើយប៉ុន្តែគេស្វះស្វែងសំដែងនូវភារកិ

ចូនៃជីវិតរបស់អ្នកគ្រិស្ទានហាក់បីដូច
ជាព្រះជាម្ចាស់តម្រូវឲ្យគេធ្វើដើម្បីទទួ
លបានរង្វាន់នៃស្ថានសួគ៌ដូច្នេះដែរ។
ការកាន់សេចក្ដីជំនឿសាសនាបែបនេះ
គឺគ្មានតម្លៃឡើយ។នៅពេលដែលព្រះ
គ្រិស្ទគង់សន្ថិតនៅក្នុងចិត្តនោះព្រលឹង
វិញ្ញាណនឹងពោរពេញទៅដោយសេច
ក្ដីស្រលាញ់របស់ទ្រង់និងដោយក្ដីអំ
ណរក្នុងការប្រាស្រ័យទាក់ទងជាមួយ
នឹងទ្រង់ពោលគឺយើងបានជាប់នឹងទ្រ
ង់ហើយ។ដោយសារការរំពឹងទុកចិត្តចំ
ពោះទ្រង់នោះភាពអាត្មានិយម៍នឹងត្រូវ
បំភ្លេចចោលឯសេចក្ដីស្រលាញ់ចំពោះ
ព្រះគ្រិស្ទនឹងលេចចេញជាសកម្មភាព
។
អស់អ្នកណាដែលយល់នូវក្ដីស្រលាញ់
ដ៏លើសលប់របស់ព្រះជាម្ចាស់ពិតជាពុំ
មានសំណួរថាតើត្រូវធ្វើប៉ុណ្ណាទើបស

ព្រះហឫទ័យព្រះឲ្យបានត្រូវនឹងសេចក្ដីតម្រូវរបស់ព្រះនោះឡើយ។គេនឹងមិនសូមពីព្រះនូវកំរិតមួយដែលទាបបំផុតប៉ុន្តែគេនឹងផ្ដង់គំនិតឆ្ពោះទៅកាន់ភាពចុះសម្រុងដ៏ឥតខ្ចោះដែលព្រះជាម្ចាស់នៃសេចក្ដីប្រោសលោះទ្រង់សព្វព្រះហឫទ័យវិញ។ដោយចំណង់ដ៏ស្មោះអស់ពីចិត្តគេនឹងលះបង់អ្វីៗទាំងអស់ហើយបង្ហាញនូវការចូលចិត្តដែលថ្លឹងថ្លែងទៅនឹងវត្ថុដែលគេកំពុងស្វែងរក។ការប្រកាន់ជំនឿចំពោះព្រះគ្រិស្ដដោយគ្មានការស្រលាញ់ដ៏ជ្រាលជ្រៅគ្រាន់តែជាពាក្យសំដីការបង្គ្រប់កិច្ចដ៏សោះកក្រោះឬការប្រព្រឹត្តមិនគប្បីតែប៉ុណ្ណោះ។

តើលោកអ្នកយល់ថាការដែលចុះចូលទាំងស្រុងថ្វាយដាច់ដល់ព្រះគ្រិស្ដជាព

លិកម្មដ៏ធ្ងន់ធ្ងរហ្សួសវិស័យឬយ៉ាងណា
?
សូមមេត្តាដណ្តឹងសួរខ្លួនឯងថាៈ“តើព្រះគ្រិស្ទបានប្រទានអ្វីខ្លះដល់ខ្ញុំ?”
ព្រះរាជបុត្រានៃព្រះជាម្ចាស់បានប្រគល់អ្វីៗទាំងអស់ដល់យើងពោលគឺៈជីវិត..សេចក្តីស្រលាញ់..និងការរងទុក្ខវេទនាដើម្បីជាតម្លៃលោះនៃយើងរាល់គ្នា។តើជាការស័ក្តិសមដែរឬចំពោះរូបយើងដែលមិនបានសំណំ
សោះនឹងសេចក្តីស្រលាញ់ដ៏ធំធេងនេះដែលនឹងដកចិត្តចេញអំពីព្រះយ៉ាងដូច្នេះ?
គ្រប់ពេលវេលាទាំងអស់ក្នុងជីវិតរបស់យើងៗជាអ្នកចូលរួមចំណែកទទួលព្រះពរអំពីព្រះគុណរបស់ទ្រង់ហើយពីព្រោះតែមូលហេតុនេះហើយបានជាយើងពុំអាចយល់ឲ្យបានពេញលេញនូវជំ

ពៅនៃភាពល្ងង់ខ្លៅនិងភាពទុរគ៌តរបស់ព្រះជាម្ចាស់បានរំដោះយើងចេញពីភាពទាំងនោះឡើយ។តើយើងអាចសំលឹងមើលទៅព្រះជាម្ចាស់ដែលត្រូវចាក់ទំលុះដោយអំពើបាបរបស់យើងហើយយល់ព្រមធ្វើតាមដើម្បីចំពោះសេចក្តីស្រលាញ់និងពលិកម្មរបស់ព្រះជាម្ចាស់បានឬទេ?

ក្នុងទិដ្ឋភាពនៃសេចក្តីអាម៉ាសដ៏រកថ្លែងពុំបានរបស់ព្រះជាម្ចាស់នៃសិរីល្អតើយើងរអ៊ូរទាំពីព្រោះតែយើងអាចមានជីវិតអស់កល្បតាមរយៈអធិករណ៍និងការបន្ទាបខ្លួននោះឬ?

ចំនោទសួររបស់មនុស្សក្រអឺតក្រទមគឺ:“ហេតុអ្វីបានជារូបអញត្រូវទទួលការស្តាយក្រោយនិងភាពអោនលំទោនជាមុនដើម្បីឲ្យព្រះជាម្ចាស់ទទួលរ៉ាប់រងស្គាល់រូបអញ?”។ខ្ញុំសូមចង្អុលបង្ហា

ញព្រះគ្រិស្ទចំពោះលោកអ្នកថាទ្រង់ពុំដែលមានអំពើបាបសោះឡើយលើសពីនេះទៅទៀតព្រះអង្គគឺជាស្តេចនៃនគរស្ថានសួគ៌ក៏ប៉ុន្តែដើម្បីជាផលប្រយោជន៍របស់មនុស្សលោកទ្រង់បានយាងមកទទួលបាបជំនួសសាសន៍ទាំងឡាយ។“គេបានរាប់ទ្រង់ក្នុងចំណោមពួកអ្នកទទឹងច្បាប់ប៉ុន្តែទ្រង់បានទទួលរងទោសនៃអំពើបាបរបស់មនុស្សជាច្រើនហើយបានអង្វរជំនួសមនុស្សដែលទទឹងច្បាប់វិញ”..អេសាយ៥៣:១២។

—

តើឲ្យយើងបោះបង់អ្វីចោលទៀតនៅពេលដែលយើងបានប្រគល់អស់ទៅហើយនោះ?

ចូរប្រគល់ចិត្តដែលជិតដាមដោយអំពើ

បាបថ្វាយដល់ព្រះគ្រិស្ទដើម្បីឲ្យទ្រង់ធ្វើឲ្យបរិសុទ្ធលាងសំអាតអំពើបាបដោយព្រះលោហិតរបស់ទ្រង់ហើយនិងសង្គ្រោះដោយសេចក្តីស្រលាញ់ដែលពុំអាចផ្ទឹមបាន។ប៉ុណ្ណឹងតែគេគិតថាគេនឹងពិបាកនឹងធ្វើទៀត!
ខ្ញុំមានការអៀនខ្មាសជំនួសចំពោះវាចាបែបនេះនិងអៀនខ្មាសចំពោះការសរសេរពាក្យទាំងនេះផងដែរ។

ព្រះជាម្ចាស់ពុំតម្រូវឲ្យយើងបោះបង់ចោលនូវអ្វីៗទាំងឡាយណាដែលយើងអាចរក្សាទុកបានដើម្បីជាប្រយោជន៍ដ៏សំខាន់សំរាប់យើងនោះឡើយ។ចំពោះគ្រប់អ្វីៗដែលទ្រង់ធ្វើទ្រង់ធ្វើទ្រង់តែងគិតដល់សុខុមាលភាពរបស់រាស្រ្តទ្រង់ក្នុងហាឫទ័យជា
និច្ច។សូម្បីអ្នកដែលពុំទាន់បានទទួល

យកព្រះគ្រិស្ទក៏អាចនឹងដឹងបានថាទ្រង់ផ្ដល់ឲ្យគេនូវរបស់ដែលមានតម្លៃវាងរបស់ដែលគេកំពុងតែស្វែងរកដោយខ្លួនឯងទៅទៀត។មនុស្សយើងបានធ្វើឲ្យមានរបួសយ៉ាងខ្លាំងនិងអយុត្តិធម៌ចំពោះព្រលឹងរបស់ខ្លួននៅពេលដែលគេគិតនិងប្រព្រឹត្តអ្វីផ្ទុយនឹងបំណងហឫទ័យរបស់ព្រះជាម្ចាស់។គ្មានអំណាររីករាយដ៏ពិតប្រាកដណាអាចមាននៅក្នុងគន្លងដែលព្រះទ្រង់បានហាមឃាត់នោះឡើយព្រោះព្រះជាម្ចាស់ទ្រង់ឈ្វេងយល់និងមានផែនការដ៏ល្អប្រពៃដើម្បីជាប្រយោជន៍ចំពោះសត្វលោកដែលជាសមិទ្ធិផលរបស់ទ្រង់។គន្លងនៃការល្មើសនឹងក្រិត្យវិន័យគឺជាគន្លងនៃភាពកំសត់ទុរគតនិងភាពមហន្តរាយ។

គឺជាកំហុសមួយរបស់យើងដែលតែង
មានគំនិតគិតថាព្រះជាម្ចាស់សព្វព្រះ
ហឫទ័យនឹងឃើញកូនចៅរបស់ទ្រង់រ
ងទុក្ខវេទនា។គ្រប់ទាំងទេវតានៃនគរ
ឋានសួគ៌ចង់ឃើញមនុស្សលោកទាំង
អស់ប្រកបដោយសុភមង្គល។ព្រះវរបិ
តានៃនគរឋានសួគ៌នៃយើងរាល់គ្នាមិន
ដែលបិទបាំងរាំងរាមហារិថីនៃអំណររី
ករាយចំពោះសត្វលោកដែលជាសមិទ្ធិ
ផលរបស់ទ្រង់ឡើយ។ការតម្រូវរបស់
ព្រះជាម្ចាស់គឺហៅឲ្យយើងចៀសចេញ
ឲ្យផុតពីការបណ្ដែតបណ្ដោយខ្លួនដែ
លនឹងនាំនូវទុក្ខវេទនានិងការអស់សង្
ឃឹមដែលជាឧបសគ្គរាំងរាយើងចូល
ទៅកាន់ទ្វារនៃសុភមង្គលនិងស្ថានសួ
គ៌។ព្រះដ៏ប្រោសលោះពិភពលោកទាំ
ងមូលទទួលយកមនុស្សទាំងឡាយ
ទោះជាមានបែបសណ្ឋានយ៉ាងណា

ទោះជាមានការខ្វះខាតភាពមិនបរិសុទ្ធឬភាពខ្សត់ខ្សោយក្ដី។ព្រះទ្រង់មិនត្រឹមតែលាងជំរះគេពីអំពើបាបនិងផ្ដល់ឲ្យគេនូវថ្ងៃប្រោសលោះដោយព្រះលោហិតរបស់ទ្រង់ប៉ុណ្ណោះទេតែទ្រង់ថែមទាំងបំពេញនូវចំណង់នៃចិត្តដែលយល់ព្រមទទួលនឹមរបស់ទ្រង់និងទទួលបន្ទុករបស់ទ្រង់ថែមទៀត។ទាំងអស់នេះគឺជាគោលបំណងហឫទ័យរបស់ព្រះជាម្ចាស់ដែលប្រោសប្រទាននូវសេចក្ដីសុខសន្តិភាពនិងការសំរាកដល់អស់អ្នកណាដែលចូលមករកទ្រង់ដើម្បីទទួលនំប៉័ងជីវិត។ទ្រង់តម្រូវឲ្យយើងបំពេញនូវភារកិច្ចដែលនឹងនាំជំហានយើងទៅកាន់សេចក្ដីអំណររីករាយគឺសេចក្ដីសុខក្សេមក្សាន្តប្រសើរឧត្តមដែលពួកអ្នកទទឹងច្បាប់មិនអាចទៅដល់ឡើយ។ជីវិតពិតនិងសេចក្ដីអំណររីករាយនៃ

ព្រលឹងមនុស្សគឺមានព្រះគ្រិស្ទគង់សណ្ឋិតនៅក្នុងខ្លួនដែលទ្រង់នោះហើយអាចផ្តល់សេចក្តីសង្ឃឹមប្រកបដោយសិរីល្អ។

—

មនុស្សជាច្រើនដណ្តឹងសួរថា:“តើខ្ញុំនឹងថ្វាយខ្លួនដល់ព្រះជាម្ចាស់បានយ៉ាងដូចម្តេចទៅ?”លោកអ្នកមានបំណងនឹងថ្វាយខ្លួនដល់ព្រះជាម្ចាស់ក៏ប៉ុន្តែអ្នកមានភាពកំសោយខាងអំណាចនៃផ្លូវចិត្ត(វិញ្ញាណ)..យ៉ាងនោះអ្នកជាទាសាទាសីនៃភាពចំងល់ដែលគ្រប់គ្រងដោយទំលាប់នៃជីវិតដែលមានអំពើបាប។សេចក្តីសន្យានិងការដោះស្រាយរបស់អ្នកគឺប្រៀបបានទៅនឹងខ្សែពួរដែលធ្វើពីដីខ្សាច់។អ្នកមិនអាចនឹងគ្រប់គ្រងគំនិតនិងពលវេគ(គឺការជំរុញផ្នែកផ្លូវចិត្ត

)
និងសេចក្ដីស្រលាញ់របស់អ្នក។ការយល់ដឹងអំពីការមិនគោរពពាក្យសន្យារបស់អ្នកនិងសេក្ដីសន្យាក្លែងក្លាយបានធ្វើឲ្យទន់ខ្សោយដល់ទំនុកចិត្តទៅលើភាពស្មោះត្រង់របស់ខ្លួនឯងហើយធ្វើឲ្យអ្នកមានគំនិតគិតថាព្រះជាម្ចាស់ពុំអាចទទួលរូបអ្នកបានឡើយ។
លោកអ្នកមិនត្រូវអស់សង្ឃឹមយ៉ាងដូច្នេះឡើយ។
ឆន្ទៈគឺជាកំលាំងដ៏ពិតប្រាកដដែលលោកអ្នកត្រូវការយល់ដឹងព្រោះវាជាអំណាចឃុំគ្រងទៅលើធម្មជាតិរបស់មនុស្សលោកជាអំណាចនៃការសម្រេចចិត្តនិងការជ្រើសរើស។អ្វីៗទាំងអស់ពឹងផ្អែកទៅលើសកម្មភាពដ៏ត្រឹមត្រូវនៃឆន្ទៈ។ព្រះជាម្ចាស់បានប្រគល់អំណាចទៅដល់មនុស្សហើយដូច្នេះមនុស្សអា

ចប្រើប្រាស់កម្មសិទ្ធិនេះទៅតាមចំណង់របស់ខ្លួន។លោកអ្នកមិនអាចផ្លាស់ប្តូរចិត្តហើយក៏មិនអាចថ្វាយដល់ព្រះនូវសេចក្តីស្រលាញ់នៃចិត្តនោះដោយខ្លួនឯងបានដែរក៏ប៉ុន្តែលោកអ្នកអាចបំរើព្រះជាម្ចាស់បាន។លោកអ្នកអាចថ្វាយទ្រង់នូវសុឆន្ទៈរបស់លោកអ្នករួចទ្រង់នឹងធ្វើការក្នុងចិត្តលោកអ្នកមានបំណងចិត្តនឹងប្រព្រឹត្តតាមភាពល្អប្រពៃនៃព្រះជាម្ចាស់។ពេលនោះរូបកាយពីកំណើតរបស់លោកអ្នកនឹងត្រូវគ្រប់គ្រងដោយវិញ្ញាណរបស់ព្រះគ្រិស្ត។សេចក្តីស្រលាញ់របស់អ្នកនឹងផ្តោតទៅលើតែទ្រង់មួយឯគំនិតរបស់អ្នកនឹងចុះសំរុងជាមួយទ្រង់ដែរ។

ចំណង់ចំពោះអំពើល្អនិងភាពបរិសុទ្ធបានល្អប្រពៃដរាបណាយើងនៅតែបន្ត

ជាប់ជានិច្ចក៏ប៉ុន្តែវានឹងពុំមានសារៈប្រយោជន៍អ្វីឡើយប្រសិនបើយើងឈប់ធ្វើការទៅទៀតនោះ។មនុស្សជាច្រើននឹងបាត់បង់នៅពេលដែលគេកំពុងតែមានសង្ឃឹមនិងមានចំណង់ចិត្តឲ្យក្លាយជាជនគ្រិស្ទាន។គេមិនទាន់បានទៅដល់ចំណុចដែលគេអាចនាំឲ្យគេមានឆន្ទៈចុះចូលនឹងព្រះជាម្ចាស់យ៉ាងនោះគេមិនបានក្លាយជាជនគ្រិស្ទានឡើយ។

តាមការអនុវត្តន៍ដ៏ត្រឹមត្រូវនៃឆន្ទៈការផ្លាស់ប្តូរទាំងស្រុងអាចកើតមានឡើងក្នុងជីវិតរបស់លោកអ្នក។ការចុះចូលនូវឆន្ទៈរបស់លោកអ្នកចំពោះព្រះគ្រិស្ទអ្នកបានភ្ជាប់ខ្លួនចងសម្ព័ន្ធទៅនឹងអំណាចមួយដែលលើសអស់ទាំងអំណាចផងនានានៅលើលោកិយនេះ។អ្នកនឹងទ

ទូលបោមពល(កម្លាំង)អំពីស្ថានសួគ៌ដើម្បីរក្សារូបអ្នកមិនឲ្យប្រែប្រួលហើយដោយតាមរយៈការលន់តួដ៏ស្មោះត្រង់ជាប់ជានិច្ចនៅក្នុងព្រះជាម្ចាស់អ្នកនឹងអាចរស់នៅក្នុងជីវិតមួយថ្មី..គឺជីវិតដែលពោរពេញដោយសេចក្តីជំនឿ។

# ជំពូកទី ៦ — សេចក្តីជំនឿនិងការទទួលយកព្រះ

នៅពេលដែលសតិសម្បជញ្ញៈរបស់អ្នកត្រូវបានបំភ្លឺដោយវិញ្ញាណបរិសុទ្ធនោះអ្នកនឹងមើលឃើញនូវសេចក្តីអាក្រក់អំពើបាបនិងអំណាចរបស់វានូវពិរុទ្ធភាពនិងភាពអមិត្ររបស់វាហើយអ្នកនឹងមើលទៅអំពើទាំងអស់នោះដោយសេចក្តីខ្ពើមរអើម។អ្នកនឹងមានអារម្មណ៍ដឹងថាអំពើបាបបានញែករូបអ្នកចេញអំពីព្រះជាម្ចាស់ហើយរូបអ្នកឋិតក្នុងកណ្តាប់ដៃអារក្ស។នៅពេលដែលអ្នកខំតស៊ូរត់កាន់តែខ្លាំងនោះអ្នកនឹងរឹតតែឃើញច្បាស់ពីភាពអស់សង្ឃឹមរបស់អ្នកកាន់តែខ្លាំងឡើងដែរ។បុព្វហេតុរបស់អ្នកមិនបរិសុទ្ធឯចិត្តរបស់អ្នកមិនបរិ

សុទ្ធដែរ។អ្នកនឹងឃើញថាជីវិតរបស់អ្នកពោរពេញដោយភាពអាត្មានិយមនិងអំពើបាប។អ្នកមានចំណង់ឲ្យបានរួចទោសឲ្យបានជំរះសំអាតពីអំពើបាបនិងឲ្យមានសេរីភាព។តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានការចុះសម្រុងជាមួយព្រះជាម្ចាស់និងឲ្យបានដូចជាអង្គទ្រង់?

—

អ្នកប្រាថ្នាចង់បានសេចក្តីសុខសន្តិភាព..គឺជាការលើកលែងទោសពីព្រះជាម្ចាស់និងសន្តិភាពនិងសេចក្តីស្រលាញ់នៅក្នុងព្រលឹងវិញ្ញាណរបស់អ្នកដែលប្រាក់ពុំអាចទិញបាន។ចំណេះពុំអាចផ្តល់ឲ្យបានប្រាជ្ញាពុំអាចសម្រេចបាន..អ្នកមិនអាចសង្ឃឹមបានលើការព្យាយាមដោយអំណាចខ្លួនឯង។“ក៏ប៉ុន្តែព្

រះជាម្ចាស់ផ្តល់មកឲ្យយើងជាអំណោយដែលមិនគិតតម្លៃអ្វីឡើយ”..អេសាយ៥៥:១។សន្តិភាពក្នុងព្រះជាម្ចាស់គឺជារបស់ផងអ្នកប្រសិនបើលោកអ្នកឈោងដៃទទួយក។ព្រះយេហូវ៉ាមានបន្ទូលថា:“ទោះបីជាអំពើបាបរបស់ឯងក្រហមទែងក៏ដោយក៏គង់នឹងបានដូចជាហិមៈទោះបីជាក្រហមឆ្អៅក៏ដោយគង់នឹងបានដូចជារោមចៀមវិញ”..អេសាយ១:១៨។“អញនឹងឲ្យឯងមានចិត្តថ្មីនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ”..អេសាយ៣៦:២៦។

អ្នកបានលន់តួអំពើបាបរបស់អ្នកហើយក្នុងចិត្តរបស់អ្នកក៏បានជំរះវាដាច់ស្រលះ។អ្នកបានសម្រេចចិត្តថ្វាយខ្លួនដល់ព្រះជាម្ចាស់។ឥឡូវសូមចូលមកទ្រង់

និងសូមឲ្យទ្រង់លាងជំរះអស់ទាំងអំពើបាបរបស់អ្នក
និងសូមទ្រង់ប្រគល់ឲ្យអ្នកនូវចិត្តថ្មី
ដោយជឿជាក់ថាទ្រង់នឹងធ្វើមែន“ព្រោះទ្រង់បានសន្យា”។
នេះគឺជាមេរៀនដែលព្រះយេស៊ូបានបង្រៀនកាលទ្រង់គង់នៅលើផែនដី
គឺថាអំណោយដែលព្រះជាម្ចាស់បានសន្យាជាមួយយើង
នោះយើងត្រូវតែមានជំនឿថាយើងពិតជាទទួលបាន
ហើយអំណោយនោះពិតជារបស់ផងយើង។
ព្រះយេស៊ូបានព្យាបាលមនុស្សឲ្យជាពីជំងឺ
នៅពេលដែលគេមានជំនឿដល់អំណាចចេស្ដារបស់ទ្រង់។
ទ្រង់បានជួយមនុស្សចំពោះរបស់ដែល

គេអាចមើលឃើញ
រួចក៏បណ្ដាលចិត្តឲ្យមានការទុកចិត្តដល់ទ្រង់ចំពោះរបស់ដែលគេមិនអាចមើលឃើញ
និងដឹកនាំឲ្យគេជឿដល់អំណាចរបស់ទ្រង់ក្នុងការអត់ទោសអំពើបាប។
ការនេះទ្រង់បានសម្ដែងឲ្យឃើញយ៉ាងច្បាស់នៅពេលទ្រង់ព្យាបាលមនុស្សស្លាប់ដៃជើង
ដែលអ្នកនឹងដឹងថាកូនមនុស្សមានអំណាចនៅលើផែនដីដែលអាចអត់ទោសអំពើបាបដូចមានចែងក្នុងព្រះគម្ពីរមួយវគ្គថា:“រួចទ្រង់មានបន្ទូលទៅមនុស្សជំងឺនោះថា
ចូរក្រោកឡើងយកគ្រែរបស់ឯងត្រលប់ទៅផ្ទះវិញចុះ”..ម៉ាថាយ៩:៦។
រីឯលោកយ៉ូហានជាអ្នកផ្សព្វផ្សាយដំណឹងល្អ

អំពីមហិទ្ធិរិទ្ធរបស់ព្រះគ្រិស្ទបានពោល
ថា:“មានសេចក្តីចែងទុកមកថាឲ្យអ្នក
រាល់គ្នាបានជឿដល់ព្រះយេស៊ូគ្រិស្ទ
ហើយគឺជាព្រះបុត្រានៃព្រះពិត
ហើយឲ្យអ្នករាល់គ្នាបានជីវិត
ដោយសារព្រះនាមទ្រង់ដោយមានសេ
ចក្តីជំនឿ”..យ៉ូហាន ២០:៣១។
ពីរឿងរ៉ាវសមញ្ញក្នុងព្រះគម្ពីដែលសម្តែ
ងឲ្យឃើញពីវិធីដែលព្រះយេស៊ូព្យាបា
លជំងឺ
យើងអាចដឹងការងារបានខ្លះៗទៀតអំ
ពីសេចក្តីជំនឿក្នុងទ្រង់ក្នុងការអត់ទោ
សបាប។
ឥឡូវនេះយើងត្រលប់ទៅឯមនុស្សស្លា
ប់ដៃជើងនៅឯស្រះបេថេស្តាវិញ។
មនុស្សរងគ្រោះដ៏អភ័ពគ្មានសង្ឃឹមឡើ
យ
គាត់ពុំដែលកំរើកដៃជើងអស់រយៈពេ

ល៣៨ឆ្នាំ។
ក៏ប៉ុន្តែព្រះគ្រិស្ទបានប្រាប់គាត់ថាៈ“ចូរក្រោកឡើងហើយយកគ្រែរបស់ឯងហើយដើរទៅ”។
មនុស្សជំងឺនោះអាចនឹងពោលក្នុងចិត្តថាៈ“ឱ!ព្រះជាម្ចាស់អើយ
ប្រសិនបើទ្រង់អាចព្យាបាលទូលបង្គំបាននោះ
ទូលបង្គំនឹងស្ដាប់តាមបន្ទូលទ្រង់”។
ក៏ប៉ុន្តែគាត់ជឿព្រះបន្ទូលព្រះគ្រិស្ទហើយជឿថាព្រះនឹងព្យាបាលឲ្យគាត់ជាហើយគាត់ក៏ព្យាយាមធ្វើមួយរំពេចនោះ។ គាត់មានចំណង់នឹងដើរហើយគាត់ក៏ដើររួចទៅ។
គាត់ធ្វើតាមព្រះបន្ទូល របស់ព្រះគ្រិស្ទហើយព្រះជាម្ចាស់ប្រទានអំណាចឲ្យគាត់ ហើយចុងបញ្ចប់គាត់ក៏បានជា។

នៅក្នុងសភាពដូចគ្នានេះដែរ
អ្នកជាមនុស្សមានបាបអ្នកមិនអាចទទួលទណ្ឌកម្មលាងកំហុសចំពោះអំពើបាបរបស់អ្នកនៅក្នុងអតីតកាលបានឡើយ
ហើយក៏មិនអាំចផ្លាស់ចិត្តរបស់អ្នករួចធ្វើឲ្យខ្លួនអ្នកបរិសុទ្ធដោយខ្លួនឯងបានដែរ។
ក៏ប៉ុន្តែព្រះជាម្ចាស់សន្យាថានឹងធ្វើកិច្ចការទាំងអស់នេះ
ចំពោះរូបអ្នកតាមរយៈព្រះគ្រិស្ដ
ប្រសិនបើអ្នកជឿដល់សេចក្ដីសន្យានេះ។
ពេលដែលលោកអ្នកលន់តួអំពើបាប
ហើយបានថ្វាយខ្លួនអ្នកចំពោះព្រះជាម្ចាស់
នោះអ្នកនឹងមានសុឆន្ទៈបំរើទ្រង់។
កាលណាអ្នកធ្វើការនេះបានដោយប្រា

កដក្នុងចិត្តបែបដូច្នេះនោះព្រះជាម្ចាស់នឹងបំពេញនូវសេចក្តីសន្យាចំពោះរូបអ្នក។
ប្រសិនបើអ្នកជឿដល់សេចក្តីសន្យានេះ
អ្នកត្រូវតែជឿថាអ្នកនឹងបានអត់ទោសបាបហើយលាងជំរះអំពើបាបព្រោះព្រះជាម្ចាស់ទ្រង់តែងតែផ្តល់នូវការពិត។
អ្នកនឹងត្រូវព្យាបាមឲ្យជាដូចជាព្រះគ្រិស្ទផ្តល់អំណាចចំពោះមនុស្សស្លាប់ដៃជើងឲ្យបានដើរឡើងវិញ
នៅពេលគាត់មានជំនឿថាគាត់នឹងត្រូវព្យាបាលឲ្យបានជា។
ការនេះនឹងកើតឡើងយ៉ាងដូច្នេះដែរចំពោះរូបអ្នក
ប្រសិនបើអ្នកជឿទុកចិត្តលើព្រះ។

ចូរកុំរង់ចាំដល់ខ្លួនអ្នកបានជា
ប៉ុន្តែត្រូវតែនិយាយថា:“ទូលបង្គំជឿ
ហើយការដែលកើតឡើងក្នុងចិត្តយ៉ាង
ដូច្នេះមិនមែនដោយទូលបង្គំមិននឹកស្មាននោះទេ
ប៉ុន្តែពីព្រោះព្រះជាម្ចាស់បាន សន្យា”។

ព្រះយេស៊ូបានមានបន្ទូលថា:
“គ្រប់ទាំងរបស់អ្វីដែលអ្នកប្រាថ្នា
កាលណាអ្នកអធិស្ឋានសូមនោះ
ចូរជឿថាអ្នកនឹងទទួលបានជាប្រាកដ”
ម៉ាកុស១១:២៤។
មានលក្ខខណ្ឌចំពោះសេចក្ដីសន្យា
នេះគឺ
យើងត្រូវអធិស្ឋានទៅតាមព្រះហឫទ័
យរបស់ព្រះជាម្ចាស់។
ដោយសារបំណងហឫទ័យរបស់ព្រះ
ជាម្ចាស់ដែលលាងសំអាតយើងពីអំពើ

បាបទទួលយើងជាកូនរបស់ទ្រង់
និងអាចឲ្យយើងរស់នៅក្នុងជីវិតបរិសុទ្ធ។
ដូច្នេះយើងអាចទទួលសូមពរព្រះទាំងនេះហើយជឿថាយើងនឹងបានទទួល
ហើយអរគុណព្រះជាម្ចាស់នៅពេលយើងបានទទួល។
យោលតាមសិទ្ធិរបស់យើងៗចូលមកចំពោះព្រះយេស៊ូគ្រិស្ទ
នោះទ្រង់នឹងលាងយើងឲ្យស្អាតពីអំពើបាប
ហើយយើងដែលយើងអាចឈរនៅចំពោះមុខក្រិត្យវិន័យ
ដោយគ្មានសេចក្ដីអៀនខ្មាស
ឬវិប្បដិសារីឡើយ។
"ហេតុនេះនៅជាន់នេះ
អ្នកណាដែលនៅក្នុងព្រះយេស៊ូគ្រិស្ទ
នោះគ្មានទោសឡើយ

ព្រោះទ្រង់ពុំបានដើរតាមសាច់ឈាម
ប៉ុន្តែទ្រង់ដើរតាមព្រះវិញ្ញាណបរិសុទ្ធវិ
ញ”..រ៉ូម៨:១។

ព្រោះហេតុដូច្នេះរូបអ្នកពុំមែនជាកម្ម
សិទ្ធិរបស់អ្នកទៀតទេ
ព្រោះទ្រង់បានចេញថ្លៃប្រោសលោះដ
ល់អ្នករាល់គ្នាហើយ។“ទ្រង់បានលោះ
អ្នកគ្នាមិនមែនដោយរបស់ពុករលួយដូ
ចជាប្រាក់និងមាសនោះទេ
គឺដោយសារព្រះលោហិតដ៏វិសេសរប
ស់ព្រះគ្រិស្ទ
ដែលដូចជាកូនចៀមឥតខ្ចោះឥតមាន
ស្លាកស្នាម”..ពេត្រុសទី១:១៨.១៩។តា
មរយៈជំនឿដ៏សាមញ្ញនៅក្នុងព្រះជាម្
ចាស់
នោះព្រះវិញ្ញាណបរិសុទ្ធនឹងចាប់បដិ
សន្ធិនៅក្នុងចិត្តរបស់អ្នក។

អ្នកគឺជាក្មេងដែលកើតក្នុងគ្រួសារនៃព្
រះជាម្ចាស់
តែទ្រង់ស្រលាញ់អ្នកដូចជាព្រះរាជបុត្
រារបស់ទ្រង់ដូច្នោះដែរ។

ឥឡូវដែលអ្នកបានថ្វាយខ្លួនចំពោះព្
រះគ្រីស្ទយេស៊ូហើយនោះ
ចូរកុំរាថយឲ្យសោះ
កុំឲ្យវាតចេញឆ្ងាយអំពីទ្រង់
ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃចូរនិយាយ
ថា:“ខ្ញុំជាកម្មសិទ្ធរបស់គ្រីស្ទ
ខ្ញុំបានថ្វាយខ្លួនចំពោះទ្រង់”
ហើយទូលសូមទ្រង់នូវព្រះវិញ្ញាណបរិ
សុទ្ធ
និងសូមឲ្យទ្រង់ឃុំគ្រងរក្សានូវព្រះគុ
ណរបស់ទ្រង់។
ដោយអ្នកបានថ្វាយខ្លួនដល់ព្រះជាម្ចា
ស់

ជឿជាក់ចំពោះទ្រង់នោះអ្នកនឹងបានក្លាយជាកូនរបស់ទ្រង់ដូច្នេះអ្នកនឹងរស់នៅក្នុងទ្រង់។ សាវ័កបានពោលថាៈ "ដូច្នេះដែលអ្នករាល់គ្នាបានទទួលព្រះគ្រិស្ទជាម្ចាស់បែបយ៉ាងណា នោះចូរដើរតាមទ្រង់បែបនោះចុះ"..កូលុស ២:៦។

អ្នកខ្លះដូចជាមានអារម្មណ៍ថាគេត្រូវទទួលការសាកល្បងជាមុនហើយត្រូវបង្ហាញដល់ព្រះជាម្ចាស់ឲ្យឃើញថាគេបានកែប្រែពិតប្រាកដមុននឹងអាចទទួលព្រះពរពីព្រះជាម្ចាស់។ ក៏ប៉ុន្តែពុំមែនដូច្នេះទេ គឺគេអាចទទួលព្រះពរពីព្រះជាម្ចាស់ក្នុងពេលនេះតែម្តង។ គេត្រូវតែមានព្រះគុណនៃព្រះវិញ្ញាណនៃព្រះយេស៊ូគ្រិស្ទដើម្បីជាជំនួយដល់

ភាពទន់ខ្សោយរបស់គេ
បើពុំដូច្នោះទេគេពិតជាពុំអាចទប់ទល់
នឹងអារក្សបាន ឡើយ។
ព្រះយេស៊ូសព្វព្រះហឫទ័យ
ឲ្យយើងចូលមករកទ្រង់ក្នុងសណ្ឋាន
លក្ខណៈដែលយើងមាន
ទោះទាំងមានអំពើបាប
ភាពតែលតោលឥត ទីពុំនាក់
មិនអាចឈរដោយខ្លួនឯងបានក្តី។
យើងអាចចូលមករកទ្រង់នៅពេលដែ
លយើងមាភាពទន់ខ្សោយទាំងមានអំ
ពើបាប
ហើយឱនក្រាបនៅទៀបព្រះបាទរបស់
ទ្រង់ដោយយល់ដឹងពីកំហុស
និងភាពឆ្គាំឆ្គងទាំងនោះចុះ។
គឺសិរីល្អរបស់ទ្រង់ដែលក្រសោបយើង
នៅក្នុងរង្វង់ព្រះ
ហស្តនៃសេចក្តីស្រលាញ់របស់ទ្រង់

ហើយព្យាបាលរបួសរបស់យើងនឹងសំអាតយើងអំពីការទុច្ចរិតទាំងប៉ុន្មាន។

មានមនុស្សរាប់ពាន់អ្នកដែលយល់ច្រលំត្រង់ចំនុចនេះឯងគឺពីព្រោះគេពុំជឿថា
ព្រះយេស៊ូអត់ទោសបាបឲ្យគេដោយផ្ទាល់រៀងៗខ្លួននោះឡើយ។
គេពុំជឿតាមព្រះបន្ទូលព្រះជាម្ចាស់។
គឺជាកម្មសិទ្ធចំពោះអ្នកទាំងឡាយណាដែលធ្វើតាមលក្ខ័ណ្ឌ
និងដោយដឹងដោយខ្លួនឯងថាការអត់ទោសបាបនៃព្រះជាម្ចាស់នេះគឺទ្រង់អាចអត់អោនទោសឲ្យរាល់អំពើបាប។
កុំឲ្យមានចំងល់ថាពាក្យសន្យារបស់ព្រះទាំងនេះគឺសម្រាប់រាល់បាបជនដែលបានប្រែចិត្ត។
កម្លាំងនិងសិរីល្អបានផ្តល់តាមរយៈព្

រះគ្រិស្ទ
ហើយពពួកទេវតាដំណឹងល្អបាននាំ
ទៅកាន់គ្រប់វិញ្ញាណដែលទទួលជឿ។
គ្មាននរណាម្នាក់មានអំពើបាបធ្ងន់ធ្ងរ
ហួតដល់គេពុំស្វែងរកកម្លាំង
ភាពបរិសុទ្ធ
និងសេចក្តីសុច្ចរិតនៅក្នុងព្រះគ្រិស្ទដែ
លសុគតដើម្បីរូបគេនោះឡើយ។
ទ្រង់តែងរង់ចាំនឹងដោះសំលៀកបំ
ពាក់ដែលប្រលាក់ជោគជាំដោយអំពើ
បាប
ហើយទ្រង់នឹងបំពាក់ឲ្យគេនូវសំលៀក
បំ ពាក់នៃភាពសុចរិតវិញ។
ទ្រង់លោះគេឲ្យរស់គេនឹងមិនស្លាប់ឡើ
យ។

ព្រះជាម្ចាស់
ទ្រង់ពុំប្រោស្រ័យទាក់ទងជាមួយមនុស្

សយើងដូចជាមនុស្សសាមញ្ញធ្វើនោះ
ទេ។
ព្រះហឫទ័យរបស់ទ្រង់គឺប្រកបដោយ
សេចក្ដីមេត្តាករុណា សេចក្ដីស្រលាញ់
និងព្រះទ័យអាណិតអាសូរដ៏ទន់ភ្លន់។
ទ្រង់មានព្រះបន្ទូលថា:“ត្រូវឲ្យមនុស្ស
អាក្រក់បោះបង់ចោលផ្លូវរបស់ខ្លួន
ហើយមនុស្សទុច្ចរិតបោះបង់គំនិត
ខ្លួនដែរ
រួចឲ្យគេត្រលប់មករកឯព្រះយេហូវ៉ាវិ
ញ
នោះទ្រង់អាណិតអាសូរដល់គេ..គឺឲ្យវិ
លត្រលប់មកឯព្រះនៃយើងរាល់គ្នា
នោះទ្រង់នឹងអាណិតមេត្តាដល់គេដ្បិត
ទ្រង់នឹងអត់ទោសឲ្យជាបរិបូណ៌”..អា
សាយ
៥៥:៧។“អញបានលប់អំពើរំលងរបស់
ឯងចេញដូចជាពពកយ៉ាងក្រាស់

និងអំពើបាបរបស់ឯងដូចជាពពកផង”
..អេសាយ៤៤:២២។

“ត្បិតអញគ្មានសេចក្ដីអំណរចំពោះការ
ស្លាប់របស់អ្នកដែលត្រូវស្លាប់នោះទេ
ដូច្នេះចូរឯងរាល់គ្នាវិលមកឲ្យបានរស់វិ
ញ
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូ
វ៉ា”..អេសេគាល ១៨:៣២។

អារក្សសាតាំងប្រុងប្រៀបជាស្រេច
នឹងលួចឆក់យកការធានារ៉ាប់រងដែល
ប្រកបដោយព្រះពរដែលព្រះជាម្ចាស់
ប្រទានដល់យើង។
វាមានចំណង់នឹងឆក់យកនូវគ្រប់ពន្លក
នៃក្ដីសង្ឃឹម
និងអស់ទាំងការស្មីដែលបំភ្លឺព្រលឹងរប
ស់អ្នក

ក៏ប៉ុន្តែអ្នកមិនត្រូវអនុញ្ញាតិឲ្យវាធ្វើយ៉ាងដូច្នោះទេ។
សូមកុំស្តាប់តាមមនុស្សអួសទាញឲ្យសោះតែ
សូមនិយាយយ៉ាងដូច្នេះវិញថា:
"ព្រះយេស៊ូសុគតដើម្បីឲ្យយើងខ្ញុំមានជីវិតរស់នៅ" ។ ទ្រង់ស្រលាញ់ខ្ញុំ
ហើយមិនបណ្តោយឲ្យរូបខ្ញុំវិនាសបាត់បង់ឡើយ។
ខ្ញុំមានព្រះវរបិតានៃស្ថានសួគ៌
ដែលពោរពេញដោយព្រះទ័យមេត្តាអាសូរ
ហើយទោះបើខ្ញុំប្រមាទសេចក្តីស្រលាញ់របស់ទ្រង់
ហើយទោះបីជាខ្ញុំបានខ្ជះខ្ជាយព្រះពរដែលបានទ្រង់ប្រទានមកខ្ញុំក៏ដោយ
ក៏ខ្ញុំនឹងក្រោកទៅឯព្រះវរបិតានៃខ្ញុំរួចពោលឡើងថា:

“ខ្ញុំបានធ្វើបាបប្រឆាំងនឹងព្រះ
ហើយនឹងលោកឪពុកមែន
ខ្ញុំនេះមិនគួរឲ្យគេហៅថាកូនលោកឪពុ
កទៀតទេ សូមទទួលខ្ញុំទុក
ដូចជាជើងឈ្នួលលោកឪពុកវិញចុះ”
។
រឿងប្រៀបប្រដូចនេះបានប្រាប់អ្នកថា
តើអ្នកដែលបានវង្វេងផ្លូវនោះបានទទួ
លអ្វីខ្លះ?
វគ្គនេះបន្តទៀតថា:“លុះឪពុកឃើញកូ
នពីចម្ងាយ
ហើយក៏មានចិត្តអាណិតមេត្តាហើយរ
ត់ទៅឱបថើបកូនរបស់គាត់”..លូកា
១៥:១៨.២០(Parable of the Great
Banquet)។

ទោះបីជារឿងប្រៀបប្រដូចនេះពិរោះរ
ណ្តំជាប់ចិត្តយ៉ាងនេះក្តី

ក៏នៅតែខ្វះមិនបានសំដែងឲ្យបានពេ
ញលេញនូវសេចក្តីអាណិតស្រលាញ់
ដ៏គ្មានព្រំដែននៃព្រះវរបិតានៃនគរស្ថា
នសួគ៌បានឡើយ។
ព្រះជាម្ចាស់បានសំដែងឲ្យដឹងតាមរ
យៈហោរារបស់ ទ្រង់ថា:
“អញបានស្រលាញ់ឯងដោយសេចក្តី
ស្រលាញ់ដ៏ស្ថិតស្ថេរអស់កល្ប
ហេតុនេះបានជាអញ
ទាញនាំឯងមកដោយសេចក្តីសប្បុរស
”..យេរេមា៣១:៣។
នៅពេលដែលមនុស្សមានបាបឋិតនៅ
ឆ្ងាយពីគេហដ្ឋានរបស់ឪពុកគេបានខ្ជះ
ខ្ជាយនូវភោគសម្បត្តិនៅឯស្រុកក្រៅប៉ុ
ណ្ណោះហើយចិត្តរបស់ឪពុកគេនៅតែនឹ
កដល់គេ។
ហើយគ្រប់ទាំងព្រលឹងវិញ្ញាណ
ដែលភ្ញាក់រឭកហើយវិលមករកទ្រង់វិ

ញគឺបណ្តាលមកអំពីការដង្ហោយហៅដ៏ទន់ភ្លន់នៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ដែលទទូចហៅគេ
អូសទាញអ្នកដែលវង្វេងនោះឲ្យត្រលប់មកកាន់សេចក្តីស្រលាញ់តាមព្រះហឫទ័យព្រះវរបិតា។

ដោយសេចក្តីសន្យាដ៏បរិបូណ៌នៃព្រះគម្ពីរបរិសុទ្ធ នៅនឹងចំពោះមុខអ្នក
តើអ្នកនៅតែមានចម្ងល់ទៀតឬ?
តើអ្នកអាចជឿថានៅពេលដែលមនុស្សមានបាបចង់វិលត្រលប់មកវិញ
ចង់លះបង់អំពើបាបរបស់គេហើយងាកមកឯទ្រង់ដោយចិត្តលះបង់ផ្លូវចាស់របស់ខ្លួនចោលនិងប្រែចិត្តទាំងស្រុងដើរតាមព្រះ
តើព្រះអម្ចាស់នឹងរុញច្រានគេចេញមិនឲ្យគេចូលមកទៀបព្រះបាទរបស់ទ្រង់

ឬយ៉ាងណា?
កុំឲ្យមានគំនិតបែបនេះឲ្យសោះ!គ្មានអ្វីអាចធ្វើឲ្យឈឺចាប់ដល់វិញ្ញាណរបស់អ្នកជាជាងគំនិតបែបនេះចំពោះព្រះវរបិតានៃស្ថានសួគ៌របស់យើងនោះឡើយ។ “ព្រះទ្រង់ស្អប់ខ្ពើមរអើមអំពើបាប ក៏ប៉ុន្តែទ្រង់ស្រលាញ់មនុស្សមានបាប” ដោយហេតុដូច្នោះហើយបានជាទ្រង់ប្រទានព្រះគ្រីស្ទឲ្យយាងចុះមកផែនដីនេះប្រយោជន៍ឲ្យអស់អ្នកដែលបានជឿនិងបានសង្គ្រោះនិងប្រកបដោយព្រះពរដ៏អស់កល្បនៅក្នុងអាណាចក្រនៃសិរីល្អ។
តើមានភាសាឯណាដែលនឹងទន់ភ្លន់ជាងនេះដែលអាចសំដែងពីសេចក្តីស្រលាញ់របស់ទ្រង់ចំពោះយើង?
ទ្រង់ប្រកាសថា“តើស្ត្រីនឹងភ្លេចកូនដែលកំពុងបៅដោះឥតមានអាណិតដល់

កូនដែលចេញមកពីផ្ទៃរបស់ខ្លួនបាន
ដែរឬទេ?អើគេនឹងភ្លេចបានក៏ប៉ុន្តែអ
ញមិនដែលភ្លេចឯងទេ”..អេសាយ៤៩:
១៥។

ឱ!អ្នកដែលមានចម្ងល់និងភ័យរន្ធត់អើ
យ!
សូមសម្លឹងមើលទៅស្ថានសួគ៌ព្រោះព្
រះយេស៊ូដែលគង់ព្រះជន្ម
នោះទ្រង់ធ្វើជាអ្នកអង្វរករជំនួសរូបអ្នក
ហើយ។
អរព្រះគុណចំពោះអំណោយទាននៃព្
រះរាជបុត្រាជាទីស្ងួនភ្ងាររបស់ទ្រង់
ហើយសូមអធិស្ឋានសូមកុំឲ្យការដែល
ទ្រង់សុគតជំនួសអ្នកនោះជាការឥតប្រ
យោជន៍ឡើយ។
ព្រះវិញ្ញាណបរិសុទ្ធដង្ហោយហៅលោក
អ្នកនៅថ្ងៃនេះ។

ចូរចូលមកចំពោះព្រះគ្រិស្ទដោយមូលចិត្តគំនិត
នោះអ្នកនឹងអាសូមព្រះពរពីព្រះអង្គដោយបរិបូណ៌។

នៅពេលដែលលោកអ្នកអានពាក្យសន្យានោះគឺសំដែងនូវសេចក្ដីស្រលាញ់និងអាណិតមេត្តាពុំអាចពណ៌នាបាន។
ដោយសេចក្ដីមេត្តាអាសូរដ៏ឥតព្រំដែនរបស់ព្រះ
ដួងចិត្តដ៏ប្រសើរឧត្តមនៃសេចក្ដីប្រោសលោះតាមរយៈព្រះលោហិតរបស់ទ្រង់គឺជាការអត់ទោសបាប..អេភេសូរ១:៧។
ពិតមែនហើយគឺមានលក្ខណៈសម្បត្តិសីលធម៌របស់ទ្រង់នៅក្នុងមនុស្សលោកយើង។
នៅពេលដែលអ្នកចូលទៅជិតទ្រង់ដោ

យមានការលន់តួ
និងការប្រែចិត្តនោះទ្រង់នឹងចូលជិតរូប
អ្នក
ដោយសេចក្តីករុណានិងអត់ទោសបា
បវិញ។

# ជំពូកទី ៧ —
# ការសាកល្បងនៃសាវ័កភាព

“អ្នកណាដែលឋិតនៅក្នុងព្រះគ្រិស្ទ នោះឈ្មោះថាបានកើតជាថ្មី ហើយអស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រលប់សារជាថ្មីវិញ”..កូរិនថូស៥:១៧។

—

ជួនកាលមនុស្សម្នាក់មិនអាចប្រាប់ពីពេលវេលា និងទីកន្លែងជាក់លាក់ឬក៏ចំណាំបានគ្រប់កាលៈទេសៈជាបន្តបន្ទាប់នៅក្នុងលំដាប់នៃសេចក្តីផ្លាស់ប្តូរជំនឿ(Conversion)បានឡើយ

ប៉ុន្តែការនេះមិនអាចកំណត់ថាគេមិន
បានប្តូរជំនឿរបស់គេឡើយ។
ព្រះយេស៊ូមានបន្ទូលទៅកាន់និកូឌិម
ថា:
“ឯខ្យល់ចង់បក់ទៅទីណាក៏ចេះតែបាន
ហើយអ្នកឮសូរសព្ទតែមិនដឹងជាមកពី
ណាឬទៅទីណាទេ
ចំណែកអស់អ្នកណាដែលកើតពីព្រះវិ
ញ្ញាណក៏ដូច្នោះដែរ”..យ៉ូហាន៣:៨។ដូ
ចជាខ្យល់ដែលមើលមិនឃើញតែផល
របស់វាអាចមើលឃើញ
និងដឹងយ៉ាងច្បាស់ការនេះក៏មិនដូចគ្នា
នឹងព្រះវិញ្ញាណបរិសុទ្ធនៃព្រះជាម្ចាស់
ដែលធ្វើការនៅក្នុងដួងចិត្តនៃមនុស្ស
លោកដែរ។
អំណាចដែលព្រះវិញ្ញាណបរិសុទ្ធបាន
បង្កើតឡើងជាថ្មីក្នុងព្រលឹងវិញ្ញាណម
នុស្សហើយក៏បង្កើតមនុស្សថ្មីឲ្យដូចអ

ង្គទ្រង់។
ការងារនៃព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុង
ភាពស្ងប់ស្ងាត់មិនអាចយល់បាន
តែផលនៃព្រះវិញ្ញាណនោះបានបើកប
ង្ហាញឲ្យឃើញយ៉ាងប្រចក្សច្បាស់។
ប្រសិនបើចិត្តបានកើតជាថ្មីដោយវិញ្ញា
ណបរិសុទ្ធនៃព្រះជាម្ចាស់
ជីវិតនោះនឹងធ្វើសេចក្តីបន្ទាល់នៃសេច
ក្តីពិត។
ដោយយើងមិនអាចធ្វើអ្វីដើម្បីផ្លាស់ប្តូរ
ចិត្តយើង
ឬនាំរូបយើងផ្ទាល់ឲ្យចុះសំរុងជាមួយព្
រះជាម្ចាស់បាននោះយើងមិនត្រូវទុកចិ
ត្តលើខ្លួនឯង
ឬអំពើល្អរបស់យើងបានទេ។
ជីវិតយើងនឹងបានដូចជាកត្តាមួយយ៉ា
ងសំខាន់
សំដែងឲ្យឃើញថាសិរីល្អនៃព្រះកំពុង

សណ្ឋិតនៅក្នុងរូបយើងឬយ៉ាងណា? ការផ្លាស់ប្តូរអាចមើលឃើញតាមរយៈអត្តចរិតទំលាប់
និងសកម្មភាពប្រឹងប្រែងរបស់យើង។ សភាពដែលជួយនឹងបានឃើញច្បាស់ និងត្រូវសំរេចចិត្តរវាងអំពើដែលបានកន្លងមកហើយ
និងអំពើដែលកំពុងកើតឡើង។ អត្តចរិតនឹងសំ
ដែងឲ្យឃើញគឺមិនមែនតាមរយៈអំពើល្អឬអពើអាក្រក់
ដែលកើតឡើងម្តងម្កាលនោះទេ ក៏ប៉ុន្តែដោយតាមទំនោរនៃពាក្យពេជន៍ ដែលក្លាយជាទំលាប់និងសកម្មភាព។

ជាពិតហើយដែលមនុស្សអាចមានឥរិយាបថខាងក្រៅល្អបានដោយមិនចាំបាច់ទទួលអំណាចជាថ្មីអំពីព្រះគ្រិស្ទ។

ការចង់បានឥទ្ធិពល និងការចង់ឲ្យអ្នកដទៃកោតក្រែង អាចបណ្តាលឲ្យគេខំរស់នៅដោយមានរបៀបរបបល្អប្រពៃទៅបាន។ អត្តគារវកិច្ច គឺការគោរពចំពោះខ្លួនឯង(Self respect)អាចនាំឲ្យយើងចៀសវាងអំពើទុច្ចរិតបាន។ ចិត្តដែលកំណាញ់ទ្រព្យក៏អាចបញ្ចេញនូវកាយវិការបែបសប្បុរសបានដែរ។ដូច្នេះតើយើងត្រូវសំរេចចិត្តប្រកាន់យកផ្នែកណាមួយដែលល្អប្រពៃសំរាប់ជីវិតរបស់យើងនិងដោយវិធីណា?

តើនរណាដែលស្រលាញ់យើង?
តើគំនិតយើងឋិតនៅជាមួយនរណា?
តើយើងចង់ពិភាក្សាអំពីនរណា?
តើយើងស្រលាញ់នរណាជាងគេ?

តើយើងចំណាយឋាមពលរបស់យើង
ដើម្បីនរណា?
ប្រសិនបើយើងជាកម្មសិទ្ធរបស់ព្រះគ្រិ
ស្ទចិត្តគំនិតរបស់យើង
នៅជាមួយនឹងទ្រង់ហើយចិត្តដ៏ទន់ភ្លន់
របស់យើងគឺជារបស់ទ្រង់ដែរ។
ភារកិច្ចរបស់យើងគឺឧទ្ទិសខ្លួនថ្វាយដ
ល់ទ្រង់ប៉ុណ្ណោះ។
យើងបាថ្រ្នាចង់បានដូចរូបទ្រង់ឲ្យមាន
វិញ្ញាណបរិសុទ្ធរបស់ទ្រង់ក្នុងដង្ហើមចេ
ញចូលមានសុឆន្ទៈធ្វើតាមព្រះទ័យរប
ស់ទ្រង់
និងសរសើរតំកើងដល់ទ្រង់នៅក្នុងគ្រ
ប់អ្វីៗទាំងអស់។

អ្នកទាំងឡាយណាដែលក្លាយជាមនុ
ស្សថ្មីនៅក្នុងព្រះយេស៊ូគ្រិស្ទនឹងបង្កើត
ផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធដែលជា“

សេចក្ដីស្រលាញ់ អំណររីករាយ
សុខសន្ដិភាព អំណត់អត់ធ្មត់
សុភាពរាបសារ សប្បុរស ស្មោះត្រង់
ស្លូតបូត
និងដឹងខុសត្រូវ”..កាឡាទី៥:២២.២៣
។
គេនឹងមិនតុបតែងខ្លួនតាមរបៀបតំរេក
ពីមុនទៀតឡើយ
ប៉ុន្ដែដោយសារមានសេចក្ដីជំនឿដល់
រាជបុត្រានៃព្រះជាម្ចាស់។
គេនឹងដើរតាមទ្រង់
ឆ្លុះបញ្ចាំងឲ្យឃើញនូវលក្ខណៈសម្ប
ត្តិរបស់ទ្រង់
ហើយក៏សំអាតខ្លួនឲ្យបានបរិសុទ្ធដូច
ទ្រង់ដែលជាព្រះបរិសុទ្ធដែរ។
អ្វីៗដែលគេស្អប់ពីមុន
ឥឡូវគេបែរជាស្រលាញ់
ហើយអ្វីៗដែលគេស្រលាញ់ពីមុនបែរ

ជាទីសំអប់របស់គេទៅវិញ។
មនុស្សដែលធ្លាប់មានអំនួតអួតក្អេងក្អាងប្រែក្លាយ ជាសុភាពរាបសារ។
មនុស្សដែលខ្ជិលខ្ជារឥតបានការប្រែជាម៉ឺងម៉ាត់ និងដឹងខុសត្រូវ។
មនុស្សប្រមឹកប្រែជាស្រគត់ស្រគំ
ហើយមនុស្សខ្ជះខ្ជាយប្រែជាល្អត្រឹមត្រូវ។
គេបានញែកខ្លួនចេញឲ្យដាច់ពីទំនៀមទំលាប់និងម៉ូត៏សម័យ
ផងលោកិយដែលគ្មានបានការ។
អ្នកគ្រិស្ទានពុំមែនស្វែងរក
“ការកែលម្អរផ្នែកខាងក្រៅទេ”
ក៏ប៉ុន្តែដោយរបស់ដែលលាក់កំបាំងក្នុងចិត្តវិញ
គឺដោយគ្រឿងដែលមិនចេះពុករលួយ
របស់វិញ្ញាណសំឡូតហើមរម្យទម..ពេត្រុសទី១ ៣:៤.៤។

ពុំមានភ័ស្តុតាងនៃការប្រែចិត្តដ៏ពិតប្រាកដឡើយ
លើកលែងតែមានការកែទំរង់ជាមុន។
ប្រសិនបើគេធ្វើតាមសេចក្តីសច្ចាដូចកាលពីដើមនោះដោយប្រគល់វិញនូវអ្វីៗដែលគេបានលួចយក
រួចលន់តួអំពើបាបរបស់គេ..ស្រលាញ់ព្រះជាម្ចាស់និងមនុស្សដទៃ
បាបជននោះនឹងបានឆ្លងផុតពីសេចក្តីស្លាប់ទៅឯជីវិតជាប្រាកដ។

ក្នុងខណៈដែលយើងជាមនុស្សមានបាបដែលតែងតែមានកំហុសចូលមករកព្រះគ្រិស្ទហើយក្លាយទៅជាអ្នករួមចំណែកទទួលព្រះគុណដែលអត់ទោសបាបអំពីទ្រង់នោះសេចក្តីស្រលាញ់នឹងលេចឡើងក្នុងដួងចិត្តរបស់យើង

បន្ទុកទាំងប៉ុន្មានប្រែជាធូរស្រាល
ព្រោះនឹមដែលព្រះគ្រិស្ទដាក់ឲ្យនោះគឺ
ងាយស្រួល។
កិច្ចការប្រែជាសេចក្តីរីករាយ
រីឯបូជនីយកិច្ចគឺការលះបង់ប្រែជាសេ
ចក្តីអំណរវិញ។
ផ្លូវដែលពីមុនហាក់បីដូចជាងងឹតសុង
គំឡូវប្រែជាភ្លឺត្រចះត្រចង់ដោយសាររ
ស្មីមកពីពន្លឺព្រះអាទិត្យនៃសេចក្តី
សុចរិត។

គេនឹងអាចមើលឃើញសេចក្តីស្រលា
ញ់នៃអកប្បកិរិយារបស់ព្រះគ្រិស្ទតាមរ
យៈអ្នកដែលទទួលដើរតាមទ្រង់។
ទ្រង់មានអំណាចរីករាយនឹងតាមព្រះ
ហឫទ័យនៃព្រះវរបិតា។
សេចក្តីស្រលាញ់ចំពោះព្រះវរបិតា
ការស្មោះស្ម័គ្រចំពោះសិរីល្អរបស់ទ្រង់

គឺជាអំណាចគ្រប់គ្រងនៅក្នុងព្រះជន្ម
នៃព្រះអង្គសង្គ្រោះរបស់យើងកាន់តែ
ប្រសើរឡើង និងថ្លៃថ្នូរឡើង។
សេចក្តីស្រលាញ់គឺជារបស់ផងព្រះ។
ចិត្តដែលមិនស្អាងដោយភាពបរិសុទ្ធឬ
ដែលមិនឧទ្ទិសថ្វាយដាច់
ដល់ព្រះមិនអាចបង្កើតឲ្យមានសេចក្តី
ស្រលាញ់ បានឡើយ។
កាលណាព្រះយេស៊ូគង់សណ្ឋិតនៅក្នុ
ងចិត្តអ្នកណាម្នាក់
នោះសេចក្តីស្រលាញ់នឹងកើតមានដ
ល់អ្នកនោះ។
យើងស្រលាញ់ទ្រង់ពីព្រោះទ្រង់បាន
ស្រលាញ់
យើងជាមុន..យ៉ូហានទី១៤:១៩។

នៅក្នុងចិត្តដែលបានកើតឡើងជាថ្មី
ដោយសារព្រះគុណនៃព្រះសេចក្តីស្រ

លាញ់គឺជាគោលការណ៍នៃសកម្មភាព។សេចក្តីស្រលាញ់កែលំអរអត្តចរិក..គ្រប់គ្រងលើសំទុះចិត្ត..ត្រួតពិនិត្យលើតណ្ហា..រំអាប់នូវភាពគំនុំហើយក៏បញ្ចាំងឲ្យសេចក្តីស្រលាញ់រាប់អានរឹតតែឧត្តុងឧត្តមឡើង។សេចក្តីស្រលាញ់នេះធ្វើឲ្យព្រលឹងរីករាយឡើងនិងធ្វើឲ្យជីវិតកាន់តែមានអត្ថន័យឡើងនិងជះឥទ្ធិពលដ៏ល្អប្រពៃដល់អ្នកនៅជុំវិញខ្លួន។

មានកំហុស២យ៉ាងដែលកូនចៅព្រះជាម្ចាស់ជាំពិសេសអ្នកដែលទើបនឹងមកជឿទុកចិត្តដល់ព្រះគុណរបស់ទរង់ត្រូវប្រុងប្រយ័ត្ន៖ទីមួយៈគឺអ្នកដែលខំប្រឹងប្រែងដោយខ្លួនឯងទុកចិត្តចំពោះអ្វីៗទាំងអស់ដែលគេអាចធ្វើបានដើម្បីអាចនាំឲ្យខ្លួនគេបានចុះសំរុងជាមួយនឹងព្រះជាម្ចាស់។អ្នកដែលព្យាយាមធ្វើឲ្យ

បានបរិសុទ្ធដោយសារអំពើរបស់ខ្លួន ដោយការគោរពបញ្ញត្តិគឺជាការប្រឹងប្រែងការដែលមិនអាចធ្វើទៅបាន។អ្វីទាំងទ្បាយណាដែលមនុស្សធ្វើដោយគ្មានព្រះគ្រិស្ទគង់ជាមួយតែងតែប្រលាក់ជិតដាមដោយភាពអត្មានិយមនិងអំពើបាប។យើងអាចបរិសុទ្ធតាមរយៈសេចក្តីជំនឿទៅលើព្រះគុណរបស់ព្រះគ្រិស្ទតែប៉ុណ្ណោះ។

រីឯកំហុសមួយទៀតដែលមានគ្រោះថ្នាក់មិនស្រាលដូចសេចក្តីបានបរិយាយខាងលើគឺការមានជំនឿថាពេលដែលបានទទួលជឿដល់ព្រះយេស៊ូហើយគេបានរួចអំពីការគោរពតាមបញ្ញត្តិរបស់ព្រះវរបិតាដោយសំអាងថាដោយសារសេចក្តីជំនឿតែមួយមុខប៉ុណ្ណោះយើងអាចក្លាយជាអ្នករួមចំណែកក្នុងការទទួ

ល
ព្រះគុណអំពីព្រះគ្រិស្ទតែងការងាររប
ស់យើងវិញគឺគ្មានការទាក់ទាមអ្វីនឹង
ការប្រោសលោះរបស់យើងឡើយ។

—

ក៏ប៉ុន្តែយើងគួរកត់សំគាល់ដែរថាការ
គោរពប្រណិបត្តន៍តាមគឺមិនមែនជាកា
រយល់ព្រមតែផ្នែកខាងក្រៅប៉ុណ្ណោះទេ
គឺជាការបំរើដោយសេចក្តីស្រលាញ់។
បទបញ្ញត្តិរបស់ព្រះជាម្ចាស់គឺជាការសំ
ដែងអំពីធម្មជាតិរបស់ទ្រង់..ជាតួសេច
ក្តីស្រលាញ់ហើយក៏ជាគ្រឹះនៃការគ្រប់
គ្រងរបស់ព្រះអង្គនៅឯនគរឋានសួគ៌និ
ងលោកិយផងដែរ។ប្រសិនបើចិត្តរប
ស់គេប្រែជាថ្មីហើយបានដូចជាព្រះជា
ម្ចាស់ហើយប្រសិនបើសេចក្តីស្រលា
ញ់របស់ព្រះជាម្ចាស់បានបណ្តុះនៅក្នុ

ងព្រលឹងនោះតើគេនឹងមិនអនុវត្តន៍តាមក្រឹត្យវិន័យរបស់ទ្រង់ក្នុងជីវិតរបស់គេទេឬអ្វី?
នៅពេលដែលគ្រិះនៃសេចក្តីស្រលាញ់បានបណ្តុះនៅក្នុងចិត្តហើយនៅពេលើដែលគេបានប្រែជាថ្មីទៅតាមរូបអង្គនៃព្រះជាម្ចាស់ដែលបានបង្កើតរូបគេនោះសេចក្តីសន្យាថ្មីរបស់ទ្រង់នឹងបានសម្រេចដុចដែលទ្រង់មានបន្ទូលថា:“អញនឹងដាក់បញ្ញត្តិរបស់អញក្នុងបេះដូងរបស់គេហើយអញនឹងសរសេរបញ្ញត្តិនេះក្នុងចិត្តរបស់គេដែរ”..ហេព្រើ១០:១៦។ប្រសិនបើក្រិត្យវិន័យបានកត់ក្នុងចិត្តហើយតើជីវិតគេមិនបានផ្លាស់ប្តូរទេឬអ្វី?
កិច្ចការបំរើព្រះនិងភាពស្មោះត្រង់ចំពោះសេចក្តីស្រលាញ់គឺជាសញ្ញាដ៏បិតនៃសាវ័កភាព។ហេតុដូច្នេះបានជាព្រះ

គម្ពីចែងថា:
“នេះគឺជាសេចក្តីស្រលាញ់របស់ព្រះគឺឲ្យយើងរាល់គ្នាកាន់តាមបញ្ញត្តិរបស់ទ្រង់”..យ៉ូហានទី១ ៥:៣។“នរណាបានស្គាល់ទ្រង់តែមិនកាន់តាមបញ្ញត្តិរបស់ទ្រង់ទេអ្នកនោះឈ្មោះថាជាអ្នកកុហកហើយសេចក្តីពិតមិនស្ថិតនៅក្នុងអ្នកនោះឡើយ..យ៉ូហានទី១ ២:៤។គឺមានតែសេចក្តីជំនឿមួយប៉ុណ្ណោះដែលអាចឲ្យយើងក្លាយទៅជាអ្នករួមចំណែកនៅក្នុងព្រះគុណនៃព្រះគ្រិស្ទហើយអាចឲ្យយើងចេះស្តាប់បង្គាប់តាមទ្រង់”។

យើងមិនអាចសន្សំសេចក្តីសង្គ្រោះដល់ការស្តាប់បង្គាប់ដល់ព្រះតែប៉ុណ្ណោះទេព្រោះថាសេចក្តីសង្គ្រោះគឺជាអំណោយនៃព្រះជាម្ចាស់ប្រទានឲ្យដោ

យឥតគិតថ្លៃហើយដែលយើងអាចទទួលបានតាមរយៈសេចក្ដីជំនឿតែមួយប៉ុណ្ណោះ។អ្នករាល់គ្នាដឹងហើយថាទ្រង់បានលេចមកដើម្បីដោះបាបយើងចេញហើយនៅក្នុងទ្រង់
នោះគ្មានបាបសោះ។“រីអស់អ្នកដែលនៅជាប់នឹងទ្រង់នោះមិនសាងបាបកម្មទេតែពួកអ្នកដែលធ្វើបាបវិញមិនបានឃើញទ្រង់ឡើយក៏មិនស្គាល់ទ្រង់ផង”..យ៉ូហានទី១៣:៥..៦។ការសាកល្បងដ៏ពិតគឺយ៉ាងដូច្នេះប្រសិនបើយើងនៅជាប់ក្នុងព្រះគ្រីស្ទហើយប្រសិនបើសេចក្ដីស្រលាញ់នៃព្រះជាម្ចាស់ស្ថិតនៅក្នុងចិត្តយើងនោះអារម្មណ៍របស់យើងគំនិតរបស់យើងគោលបំណងរបស់យើងហើយនឹងសកម្មភាពរបស់យើងនឹងចុះសំរុងជាមួយនឹងព្រះហឫទ័យនឹងព្រះជាម្ចាស់ដូចដែលបានបញ្ជាក់ក្នុងសិក្ខាប

ទទាំងឡាយនៃក្រិត្យវិន័យដ៏បរិសុទ្ធរប
ស់ទ្រង់។“កូនតូចៗរាល់គ្នាអើយចូរកុំឲ្
យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេងឡើ
យអ្នកណាដែលប្រព្រឹត្តិសេចក្តីសុចរិត
នោះឈ្មោះថាសុចរិតដូចជាទ្រង់ដែល
សុចរិតដែរ”..យ៉ូហានទី១៣:៧។អំពើ
សុចរិតត្រូវបានកំណត់និយមន័យទៅ
តាមគំរូនៃបញ្ញត្តិដ៏បរិសុទ្ធនៃព្រះជាម្ចា
ស់ដូចដែលទ្រង់បានបញ្ជាក់នៅក្នុងប
ទបញ្ញត្តិទាំង១០ប្រការដែលទ្រង់បាន
ប្រគល់ឲ្យដល់យើងនៅភ្នំស៊ីណៃ
នោះ។

សេចក្តីជំនឿព្រះគ្រិស្ទដែលមានការប
ន្ទូរបន្ថយឲ្យមនុស្សរួចពីការគោរពប្រ
ណិបត្តន៍ដល់ព្រះជាម្ចាស់នោះគឺពុំមែ
នជាសេចក្តីជំនឿទេក៏ប៉ុន្តែវាគ្រាន់ជា
ការសន្មតប៉ុណ្ណោះ។“ត្បិតគឺដោយព្រះ

គុណដែលអ្នករាល់គ្នាបានសង្គ្រោះតាមរយៈការសន្មតតាមរយៈសេចក្ដីជំនឿ..អេភេសូរ២:៨។ក៏ប៉ុន្ដែសេចក្ដីជំនឿក៏ដូច្នេះដែរគឺថាបើគ្មានការប្រព្រឹត្ដតាមទេក៏ស្លាប់ទៅវិញដែរ"..យ៉ាកុប២:១៧។"ព្រះយេស៊ូមានព្រះបន្ទូល"អំពីទ្រង់មុនពេលដែលទ្រង់យាងចុះមកផែនដីថា:"ទូលបង្គំមានសេចក្ដីអំណរនឹងធ្វើតាមព្រះហឫទ័យទ្រង់ឱ!ព្រះអម្ចាស់នៃទូលបង្គំអើយ..ក្រិត្យវិន័យរបស់ទ្រង់ក៏នៅក្នុងចិត្ដរបស់ទូលបង្គំដែរ..ទំនុកតំកើង៤០:៨។ហើយមុនពេលដែលទ្រង់យាងត្រលប់ទៅកាន់ស្ថានសួគ៌វិញទ្រង់បានប្រកាសថា:ខ្ញុំបានកាន់តាមបញ្ញត្ដិនៃព្រះវរបិតាខ្ញុំហើយក៏នៅជាប់សេចក្ដីស្រលាញ់របស់ទ្រង់ដែរ"..យ៉ូហាន១៥:១០។ព្រះគម្ពីបានចែងថា:"យើងរាល់គ្នាដឹងថាយើងស្គាល់ទ្រង់

ដោយសារសេចក្តីនេះគឺយើង
កាន់តាមបញ្ញត្តិរបស់ទ្រង់..នរណាដែ
លថាខ្លួននៅក្នុងទ្រង់នោះក៏ត្រូវតែប្រព្
រឹត្តដូចជាទ្រង់ដែរ..យ៉ូហានទី១២:៣.៦
។ពីព្រោះព្រះគ្រិស្ទក៏បានរងទុក្ខជំនួស
ពួកយើងដែរទាំងទុកតំរាប់ឲ្យយើងរា
ល់គ្នាដើរតាមលំអានដានរបស់ទ្រង់ផ
ង”..ពេត្រុសទី១២:២១។

“លក្ខ័ណចំពោះជីវិតអមតៈគឺនៅដដែ
លក៏ដូចលក្ខ័ណនៅឯស្ថានសួគ៍មុនពេ
លដែលមាតាបិតាដើមរបស់យើងធ្លាក់
ចុះក្នុងអំពើបាបដែរ។លក្ខ័ណនោះគឺត
ម្រូវឲ្យយើងមានការស្តាប់តាមបទបញ្ញ
ត្តិរបស់ព្រះជាម្ចាស់និងរក្សាភាពបរិសុ
ទ្ធឥតខ្ចោះ”។
ប្រសិនបើលក្ខ័ណចំពោះជីវិតអមតៈ
ខ្វះមិនដល់លក្ខ័ណដូចខាងលើនេះទេ

នោះសុភមង្គលនៃលោកិយទាំងមូលនឹងបានដល់នូវក្តីមហន្តរាយ។ទ្វារនឹងបើកចំហរឲ្យអំពើបាបដែលពោរពេញដោយការស្អប់ខ្ពើមនឹងលំបាកវេទនាមាននៅដ៏អស់កល្បជានិច្ចដែរ។

មុនពេលដែលធ្លាក់ចុះក្នុងអំពើបាបអាដ័មអាចកែប្រែអត្តចរិកឲ្យបរិសុទ្ធបានដោយគោរពតាមបទបញ្ញត្តិរបស់ព្រះជាម្ចាស់បានដែរ។ប៉ុន្តែគាត់ពុំបានធ្វើដូច្នេះទេហើយដោយសារតែអំពើបាបរបស់អាដ័មទើបធម្មជាតិរបស់យើងធ្លាក់ក្នុងអំពើបាបហើយយើងមិនអាចធ្វើឲ្យខ្លួនបរិសុទ្ធបានឡើយ។ដោយព្រោះតែយើងមានបាបមិនបរិសុទ្ធបានជាយើងមិនអាចគោរពតាមបទបញ្ញត្តិដ៏បរិសុទ្ធនោះឲ្យបានពេញលេញទៅបាន។យើងគ្មានភាពសុចរិតឯណាជារបស់យើង

ដែលអាចឲ្យស្មើរទៅនឹងការតម្រូវតាម
ក្រិត្យវិន័យរបស់ទ្រង់ឡើយ។ក៏ប៉ុន្តែព្
រះគ្រិស្ទបានបង្កើតផ្លូវមួយសំរាប់ឲ្យយើ
ងរត់គេចចេញ។ទ្រង់បានរស់នៅលើ
ផែនដីដែលទទួលសេចក្តីល្បួងល្បួង
នានាដូចដែលយើងរាល់គ្នាបានជួបប្រ
ទះដែរ។ទ្រង់បានរស់នៅក្នុងជីវិតមួយ
ដែលគ្មានបាបតាល់តែសោះ។ទ្រង់បា
នសុគតដើម្បីរូបយើងហើយឥឡូវនេះ
ទ្រង់យល់ព្រមទទួលយកនូវអំពើបាបរ
បស់យើងទាំងប្រគល់មកឲ្យយើងនូវ
ភាពបរិសុទ្ធរបស់ទ្រង់វិញ
ផង។ប្រសិនបើអ្នកប្រគល់រូបអ្នកដល
ទ្រង់ហើយទទួលទ្រង់ជាព្រះអង្គសង្គ
្រោះរបស់អ្នកនោះទោះជាអំពើបាបរប
ស់អ្នកធំប៉ុណ្ណាក៏ដោយអ្នកនឹងបានរាប់
ជាបរិសុទ្ធដោយសារតែព្រះគុណរបស់
ទ្រង់។អត្តចរិករបស់ព្រះគ្រិស្ទនឹងជំនួ

សអត្តចរិករបស់អ្នកហើយអ្នកនឹងត្រូវបា
នទទួលស្គាល់ចំពោះព្រះភ័ក្ររបស់ទ្រ
ង់ដូចជាអ្នកគ្មានបាបសោះ។

លើសពីនេះទៀតព្រះគ្រិស្ទបានផ្លាស់
ប្តូរទឹកចិត្តរបស់អ្នក។ព្រះអង្គទ្រង់គង់
ស័ណ្ឋិតនៅក្នុងចិត្តរបស់អ្នកដោយក្តីជំ
នឿ។អ្នកត្រូវរក្សាទំនាក់ទំនងជាមួយព្
រះគ្រិស្ទដោយសេចក្តីជំនឿនិងការចុះ
ចូលទាំងស្រុងជារៀងរាល់ថ្ងៃចំពោះទ្រ
ង់។បើអ្នកនៅតែប្រព្រឹត្តដូច្នោះព្រះអង្គ
នឹងធ្វើការក្នុងចិត្តរបស់អ្នកហើយអ្នកនឹ
ងប្រព្រឹត្តតាមហឫទ័យរបស់ទ្រង់ដោ
យអំនរ។ដូច្នេះអ្នកនឹងពោលថា:“ខ្ញុំរស់
ក្នុងសាច់ឈាមឥឡូវនេះនោះគឺរស់ក្នុ
ង់សេចក្តីជំនឿជឿដល់ព្រះរាជបុត្រានៃ
ព្រះដែលទ្រង់ស្រលាញ់ខ្ញុំក៏បានប្រគ
ល់អង្គទ្រង់ចំពោះខ្ញុំហើយ”..កាឡាទី២

:២០។“ព្រះយេស៊ូគ្រិស្ទមានព្រះបន្ទូល
ទៅកាន់សាវ័កទ្រង់ថាៈត្បិតមិនមែនជា
អ្នករាល់គ្នានិយាយទេគឺព្រះវិញ្ញាណរប
ស់ព្រះវរបិតានៃអ្នកទេតើដែលទ្រង់មា
នបន្ទូលក្នុងអ្នកវិញ..ម៉ាថាយ១០:២០។
ដោយមានព្រះគ្រិស្ទគង់សណ្ឋិតក្នុងខ្លួ
នអ្នកនោះអ្នកនឹងសំដែងឲ្យឃើញនូវព្
រះវិញ្ញាណរបស់ព្រះនិងប្រព្រឹត្តអំពើល្អ
ដូចទ្រង់បានធ្វើ”..គឺជាការងារនៃអំពើ
សុចរិតនិងការគោរពប្រណិបត្តន៍។

ដូច្នេះយើងគ្មានអ្វីនៅក្នុងខ្លួនយើងសំរា
ប់ឲ្យយើងអួតក្អេងក្អាងឡើយហើយក៏
គ្មានអ្វីជាគ្រឹះសំរាប់លើកតំកើងខ្លួនឯង
ដែរ។មានគ្រិះតែមួយគត់ដែលជាសេច
ក្តីសង្ឃឹមរបស់យើងគឺជាសុចរិតនៃព្រះ
យេស៊ូគ្រិស្ទដែលសណ្ឋិតក្នុងខ្លួនយើង
ហើយមានជារូបរាងដោយសារព្រះវិញ

ញាណបរិសុទ្ធដែលធ្វើការក្នុងរូបយើង និងតាមរយៈយើង។

នៅពេលដែលយើងនិយាយពីសេចក្ដីជំនឿនោះយើងត្រូវតែយល់ដឹងអំពីការដែលខុសប្លែកគ្នានៃសេចក្ដីជំនឿនេះផងដែរព្រោះអីវាមានជំនឿមួយដែលខុសគ្នាស្រលះពីសេចក្ដីជំនឿលើព្រះ។ការបិតបេរនៅនិងព្រះចេស្ដានៃព្រះជាម្ចាស់សច្ចៈភាពនៃព្រះបន្ទូលរបស់ទ្រង់គឺជាការពិតដែលសូម្បីតែអារក្សសាតាំងនិងបរិវារបស់វាក៏មិនហានបដិសេធដោយអស់ពីចិត្តដែរ។ព្រះគម្ពីរប៊ីប(ព្រះគម្ពីរបរិសុទ្ធ)បានចែងថា:“សូម្បីអារក្សក៏ជឿនិងមានការភ័យរន្ធត់ដែរ”..យ៉ាកុប២:១៩
“ប៉ុន្តែនេះពុំមែនជាសេចក្ដីជំនឿលើព្រះទេ”។នៅពេលដែលយើងមានសេច

ក្តីជំនឿក្នុងព្រះបន្ទូលទ្រង់ថែមទាំងមានការចុះចូលអស់ទាំងបំណងឆន្ទៈទៅនឹងទ្រង់នៅពេលដែលចិត្តរបស់យើងបានប្រគល់ដាច់ដល់ទ្រង់ហើយសេចក្តីស្រលាញ់របស់យើងបានភ្ជាប់ទៅនឹងទ្រង់នោះហើយគឺជាសេចក្តីជំនឿទុកចិត្តលើព្រះ(Faith)។សេចក្តីជំនឿទុកចិត្តលើព្រះនេះគឺជាការមួយដែលសំរេចឡើងដោយសេចក្តីស្រលាញ់និងការបញ្ចាំងឲ្យព្រលឹងវិញ្ញាណបាបបរិសុទ្ធផង។តាមរយៈសេចក្តីជំនឿលើព្រះជាម្ចាស់ចិត្តនឹងបានប្រែជាថ្មីទៅតាមរូបអង្គទ្រង់។រីឯចិត្តដែលពុំព្រមផ្លាស់ប្រែថ្មីទៅតាមបញ្ញត្តិច្បាប់នៃព្រះឥឡូវបែរជាមានអំណររីករាយចំពោះសិក្ខាបទដ៏បរិសុទ្ធទាំងស្រែកឧទ្ទានឡើងជាមួយអ្នកលើកទំនុកតំកើងថា:“ឱ!
ទូលបង្គំស្រលាញ់ក្រិត្យវិន័យរបស់ទ្រ

ង់ណាស់ហ្ន៎ទូលបង្គំរំពឹងគិតពីក្រឹត្យវិន័យនោះជាដរាបរាល់ថ្ងៃ”..ទំនុកតំកើង ១១៩:៩៧។សច្ចៈភាពនៃបទបញ្ញត្តិក៏បានបំពេញក្នុងខ្លួនយើងដែលមិនដើរតាមសាច់ឈាមទៀតឡើយគឺដើរតាមព្រះវិញ្ញាណវិញ..រ៉ូម៨:១។

មានអ្នកខ្លះបានដឹងពីការអត់ទោសបាបរបស់ព្រះគ្រិស្ទហើយមានចំណង់ចង់ក្លាយជាកូនចៅរបស់ទ្រង់ដ៏ពិតប្រាកដ ទន្ទឹមនឹងនោះគេក៏មើលឃើញថាអត្តចរិករបស់គេពុំល្អបរិសុទ្ធជីវិតរបស់គេមានកំហុសហើយគេសង្ស័យថាតើចិត្តរបស់គេបានកើតជាថ្មីដោយសារព្រះវិញ្ញាណបរិសុទ្ធហើយឬនៅ?
ចំពោះមនុស្សប្រភេទនេះខ្ញុំនឹងជំរាបទៅគេថា:“ចូរកុំថយក្រោយដោយក្ដីអស់សង្ឃឹមឡើយ”។ជាញឹកញយយើង

តែងលំអោនកាយទាងស្រែកយំនៅ
ទៀបព្រះបាទរបស់ព្រះយេស៊ូពីព្រោះ
តែគុណវិបត្តនិងកំហុសរបស់យើងក៏ប៉ុ
ន្តែយើងមិនត្រូវរួញរាឡើយ។ទោះបីជា
សត្រូវអាចយកជ័យជំនះលើរូបយើង
បានក៏ដោយក៏ព្រះជាម្ចាស់មិនដែលប
ណ្តោយឲ្យយើងបោះបង់ចោលឬបដិ
សេធយើងដែរ។ទេ!
ព្រះគ្រិស្តដែលគង់នៅខាងស្តាំព្រះហ
ស្តព្រះវរបិតានៅឯនគរស្ថានសួគ៌នោះ
ទ្រង់កំពុងអង្វករនិងលន់តួបាបចំពោះ
យើងរាល់គ្នា។សាវ័កយ៉ូហានដ៏ជាទីស្ន
នភ្ជាររបស់យើងបានពោលថា:“កូនតូ
ចៗរាល់គ្នាដែលខ្ញុំសេសេរសេចក្តីទាំង
នេះផ្ញើរមកនោះដើម្បីកុំឲ្យអ្នករាល់គ្នា
ធ្វើបាបទៀតតែប្រសិនបើជាអ្នកណាភ្
លាត់ធ្វើបាបវិញនោះយើងមានព្រះដ៏
ជាជំនួយមួយអង្គហើយដែលទ្រង់គង់

នៅចំពោះព្រះវរបិតាគឺជាព្រះយេស៊ូគ្រិស្ទជាព្រះដ៏បរិសុទ្ធ”..យ៉ូហានទី១២:១។

សូមកុំភ្លេចនូវព្រះបន្ទូលរបស់ព្រះគ្រិស្ទដែលមានមកយើងរាល់គ្នាថា:ព្រះបិតាខ្ញុំផ្ទាល់“ស្រលាញ់អ្នករាល់គ្នា..យ៉ូហាន១៦:២៧។ទ្រង់មានចំណង់នឹងប្រទានពរឲ្យអ្នកមានភាពដូចដើមវិញហើយទ្រង់ក៏ចង់ទតដែរនូវភាពល្អនិងបរិសុទ្ធឥតខ្ចោះរបស់ទ្រង់សណ្ឋិតក្នុងខ្លួនអ្នកដែរ”។ប្រសិនបើអ្នកយល់ព្រមចុះចូលនឹងទ្រង់នោះព្រះដែលផ្តើមនិងអំពើល្អក្នុងខ្លួនរបស់អ្នក
នឹងរក្សាការពាអ្នកឲ្យបានជាប់ក្នុងសេចក្តីនោះដរាបដល់ថ្ងៃនៃព្រះគ្រិស្ទជាម្ចាស់ នៃយើងបានមកដល់។

ចូរអធិស្ថានដោយគ្មានសេចក្តីនឿយណាយដោយជឿទុកចិត្តលើទ្រង់ទាំង

ស្រុងចុះ។
នៅពេលដែលយើងមិនទុកចិត្តចំពោះអំណាចរបស់យើង
នោះចូរយើងសរសើរតំកើងទ្រង់ព្រោះគឺជាសេចក្ដីចំរុងចំរើនដល់រូបកាយយើង
ពោលគឺទ្រង់ជាសេចក្ដីសង្ឃឹមរបស់យើង។

នៅពេលដែលអ្នកចូលទៅកាន់ទៅជិតឯព្រះយេស៊ូគ្រិស្ទ
នោះអ្នកនឹងមើលឃើញកំហុសរបស់ខ្លួនកាន់តែច្បាស់ឡើងៗដែរ
ពីព្រោះភ្នែករបស់អ្នកកាន់តែភ្លឺច្បាស់ឡើងហើយភាពមិនបរិសុទ្ធរបស់អ្នកកាន់តែមើលឃើញថាផ្ទុយស្រលះពីលក្ខណៈធម្មជាតិដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ដែរ។

ទាំងនេះគឺជាភ័ស្តុតាងបង្ហាញពីការបោកប្រាស់របស់អារ័ក្សសាតាំង ដែលបានបាត់បង់អំណាចទៅហើយ ហើយអនុភាពដ៏រស់រវើក នៃព្រះវិញ្ញាណរបស់ព្រះកំពុងដាស់ចិត្តអ្នក។

គ្មានសេចក្តីស្រលាញ់យ៉ាងជ្រាលជ្រៅចំពោះព្រះគ្រិស្ទ អាចសណ្ឋិតក្នុងចិត្តដែលពុំព្រមទទួលស្គាល់នូវអំពើបាបរបស់ខ្លួននោះឡើយ។ ព្រលឹងវិញ្ញាណដែលបានបំផ្លាស់ប្រែដោយសារព្រះគុណរបស់ព្រះគ្រិស្ទនឹងកោតសរសើរ ចំពោះលក្ខណៈរបស់ព្រះជាម្ចាស់ក៏ប៉ុន្តែយើងមិនមើលឃើញនូវការប្តូរទ្រង់ទ្រាយនៃទឹកចិត្តរបស់យើងទេ

នោះវាជាភ័ស្តុតាងដែលមិនអាចក្លែងប
ន្លំបានថាយើងមើលពុំឃើញសម្ផស្ស
និងភាពប្រសើរឧត្តមដ៏អស្ចារ្យរបស់ព្
រះគ្រិស្ទឡើយ។

បើយើងមិនសូវលើកកំពស់លើខ្លួនឯង
នោះយើងកាន់តែឲ្យតម្លៃខ្ពស់ទៅលើ
ភាពបរិសុទ្ធនិងភាពដ៏ជាទីមេត្រីចិត្ត
គឺការដែលជាទីស្រលាញ់ពេញចិត្តនៃ
ព្រះអង្គសង្គ្រោះនៃយើង។
ការមើលឃើញនូវអំពើបាបរបស់យើង
បានជំរុញយើងទៅកាន់ទ្រង់ដែលជាព្
រះដែលមានព្រះចេស្តា
ដែលអាចអត់ទោសបាបឲ្យយើងបាន
។
នៅពេលដែលយើងទទួលស្គាល់នូវភា
ពអស់សង្ឃឹមហើយឈោងដៃទៅរកព្
រះគ្រិស្ទនោះទ្រង់នឹងលេចចេញមក

ប្រកបដោយព្រះចេស្ដា។
នៅពេលដែលសេចក្ដីត្រូវការព្រះជំរុញ
ឲ្យយើងចូលមករកទ្រង់និងស្វែងរកព្
រះបន្ទូលរបស់ទ្រង់
នោះយើងនឹងឆ្លុះបញ្ចាំងនូវរូបអង្គទ្រង់
កាន់តែច្បាស់ឡើងដែរ។

# ជំពូកទី ៨ — ការរីកចំរើននៅក្នុងព្រះគ្រិស្ទ

ព្រះគម្ពីរបរិសុទ្ធបានចែងអំពីការប្រែចិត្ត ដែលយើងអាចក្លាយទៅជាកូនព្រះថា ជាការចាប់កំណើតថ្មី។ ព្រឹត្តិការណ៍នេះប្រៀបប្រដូចទៅនឹងការលូតលាស់ពន្លកនៃ គ្រាប់ធញ្ញជាតិដែលសាបព្រោះដោយកសិករ។ នៅក្នុងសភាពនេះដែរមនុស្សដែលទើបតែប្រែជំនឿរបស់ខ្លួនមកកាន់ព្រះគ្រិស្ទគឺជា“ទារកដែលទើបនឹងកើត ដែលនឹងលូតលាស់ទៅកាន់ភាពជាបុរស និងស្ត្រីពេញវ័យនៅក្នុងព្រះគ្រិស្ទយេស៊ូ”..ពេត្រុសទី១២:២/អេភេសូរ៤:១៥..

ឬក៏ដូចជាគ្រាប់ពូជដ៏ល្អដែលសាបព្រោះនៅឯចំការល្ងូតលាស់ឡើងរួចនឹងផ្តល់ទិន្នផលដល់ម្ចាស់។
ហោរាអេសាយបានពោលថា:
“គេនឹងហៅថាជា
ដើមឈើនៃសេចក្តីសុចរិត
គឺជាដើមដែលព្រះយេហូវ៉ាបានដាំដែលមានប្រយោជន៍ឲ្យទ្រង់បានថ្កើងផង
”..អេសាយ៦១:៣។ដូច្នេះតាមរយៈនៃជីវិតធម្មតា
ឧទាហរណ៍ប្រៀបធៀបបានលើកបង្ហាញជួយឲ្យយើងកាន់តែយល់ច្បាស់ឡើងនូវអត្ថន័យអាថកំបាំងនៃសច្ចៈភាពនៃជីវិតដោយព្រះវិញ្ញាណបរិសុទ្ធ(Spiritual Life)។

ប្រាជ្ញានិងការប៉ិនប្រសព្វរបស់មនុស្សមិនអាចបង្កើតសូម្បីជីវិតដ៏តូចមួយនៅ

ក្នុងធម្មជាតិបានឡើយ។
គឺមានតែតាមរយៈជីវិតដែលព្រះគ្រិស្ត
ជាម្ចាស់ផ្ទាល់គង់ជាមួយទេដែលរុក្ខជា
តិ និងសត្វពាហៈណាអាចរស់បាន។
ដូច្នេះមានតែជីវិតដែលចេញពីព្រះតែ
មួយ
ប៉ុណ្ណោះដែលជីវិតប្រកបដោយសេចក្ដី
ជំនឿអាចកើតមានទៅបាននៅក្នុងចិត្ត
របស់មនុស្សលោក។
បើមិនបានកើតអំពីព្រះនៃនគរឋានសួ
គ៍ទេនោះគេមិនអាចចូលរួម
ក្នុងការទទួលយកជីវិតដែលព្រះគ្រិស្ត
បានប្រទានឲ្យនោះឡើយ។
អ្វីដែលមានសម្រាប់ជីវិតនោះក៏ដូចគ្នា
នឹងជាមួយការលូតលាស់ដែរ។
គឺព្រះដែលបានបង្កើតឲ្យចេញជាពន្លក
រួចចេញជាផ្ការីកក្រសុំរហូតដល់បានផ
លផ្លែ។

គឺដោយសារតែព្រះចេស្តារនៃព្រះដែលគ្រាប់ពូជអាចដុះលូតលាស់បាន“ដំបូងចេញជាពន្លករួច បែកជាកួរ ហើយទីបញ្ចប់ក៏ចេញជាគ្រាប់”..ម៉ាកុស៤:២៨។

ហោរាហូសេបាននិយាយអំពីសាសន៍អ៊ីស្រាអែលថា:“
គេនឹងលូតឡើងដូចផ្កាកំភ្លឹង(Lily)” ។
“គេនឹងលាស់ឡើងថ្មីដូចជាសន្ទូង ហើយលូតលាស់ដូចដើមវល្លិ៍ទំពាំងបាយជូផង”..ហូសេ១៤:៥.៧។

ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់យើងថា:
“ចូរពិចារណាអំពីដើមកំភ្លឹងតើវាលូតលាស់របៀបណា”..លូកា១២:២៧។រុក្ខជាតិនិងបុប្ផាជាតិផងទាំងឡាយពុំមែនរីកលូតលាស់ដោយខ្លួនឯងនោះទេ ប៉ុន្តែបានលូតលាស់ដោយសារព្រះពរ

ដែលព្រះជាម្ចាស់បានផ្ដល់មក។
ក្មេងតូចៗមិនអាចរីកចំផាត់ដោយតែ
ការខ្វល់ខ្វាយឬដោយអំណាចរបស់ខ្លួ
នផ្ទាល់ឡើយ
យ៉ាងណាមិញការរីលូតលាស់ផ្នែកព្រ
លឹងវិញ្ញាណក៏លោកអ្នកមិនអាចបំផ្លា
ស់ប្រែបានដោយ
ការខ្វល់ខ្វាយឬការព្យាយាមដោយខ្លួន
ឯងបានដែរ។
រុក្ខជាតិក៏ដូចកុមារតូចៗដែរ
គឺអាលូតលាស់បានដោយសារបរិយា
កាសដែលនៅជុំវិញខ្លួនដែលជួយផ្គត់
ផ្គង់ដល់អាយុជិវិតរបស់គេ
ដូចជាខ្យល់ កាំរស្មីពន្លឺព្រះអាទិត្យ
និងចំណីអាហារ។
អំណោយពីធម្មជាតិទាំងនេះដែលផ្គត់
ផ្គង់ដល់អស់អ្នកណាដែលទុកចិត្តដល់
ទ្រង់ដែរ។

ព្រះអង្គជា:“ពន្លឺដ៏អស់កល្បជានិច្ច” របស់គេ..អេសាយ ៦០:១៩ “ជាព្រះអាទិត្យ និងជាខែល”..ទមនុកតំកើង៨៨:១១។ “ព្រះដូចជាទឹកសន្សើមដល់រាស្រ្តរបស់ទ្រង់”..ហូសេ ១៤:៥។ “ទ្រង់នឹងយាងមក ដូចជាទឹកភ្លៀងមកលើវាលស្មៅដែលបានច្រូតរំលីងហើយ”..ទំនុកតំកើង៧២:៦។ “ព្រះអង្គជា“ទឹកមានជីវិត” ជា “នំប៉័ងរបស់ព្រះវរបិតា” ដែលយាងចុះមកអំពីស្ថានសួគ៌ដែលប្រទានជីវិតដល់មនុស្សលោក”..យ៉ូហាន ៦:៣៣។

ដោយសារអំណោយដែលមិនអាចប្រៀបប្រដូចបាននៃព្រះរាជបុត្រារបស់ទ្រង់ព្រះវរបិតាបានគ្របដណ្តប់ពិភពលោកទាំងមូលដោយបរិយាកាសនៃព្

រះគុណរបស់ទ្រង់
ដូចជាខ្យល់ដែលហ៊ុំព័ទ្ធជុំវិញពិភពចក្រវាឡដូច្នេះដែរ។
អស់អ្នកណាដែលព្រមស្រូបយកនូវខ្យល់ដង្ហើមជីវិតនោះនឹងរស់នៅហើយល្អលាស់ហើយពេញរូបរាងជាបុរសនិងស្ត្រីនៅក្នុងព្រះយេស៊ូគ្រិស្ទ។

ឫក្សាដែលបែរទៅរកព្រះអាទិត្យ
ដើម្បីឲ្យកាំរស្មីដ៏ត្រចះត្រចង់នោះជួយលំអរសោភ័ណ្ឌភាពយ៉ាងណានោះ
យើងក៏ដូច្នេះដែរ
គឺយើងត្រូវបែរទៅរកព្រះអាទិត្យនៃសេចក្ដីសុចរិត
ដើម្បីឲ្យពន្លឺឋានសួគ៌បញ្ចាំងមកលើរូបយើង
នឹងញ៉ាំងឲ្យអត្តចរិករបស់យើងបានរីកចំរើនឡើងឆ្ពោះទៅរកលក្ខណៈដូចជា

ព្រះគ្រិស្ទ។ ព្រះយេស៊ូ
បានបង្រៀនមេរៀនដូចគ្នានេះដែរ
នៅពេលដែលទ្រង់មានព្រះមានបន្ទូល
ថា: “ចូរនៅជាប់នឹងខ្ញុំ
ហើយខ្ញុំនឹងនៅជាប់នឹងអ្នករាល់គ្នាដែរ
”។
ខ្នែងមិនអាចបង្កើតផលផ្លែដោយឯកឯ
ងបានឡើយបើមិនជាប់នឹងគល់ទេ
នោះ។
“គ្មាននរណាម្នាក់អាចធ្វើអ្វីបានទេលើ
កលែងតែនៅជាប់នឹងខ្ញុំ..ត្បិតបើដាច់
ចេញពីខ្ញុំអ្នករាល់គ្នាមិនអាចធ្វើអ្វីបាន
ទេ”..យ៉ូហាន១៥:៤.៥។“អ្នករាល់គ្នាត្រូ
វពឹងផ្អែកលើព្រះគ្រិស្ទដើម្បីឲ្យបានរស់
នៅក្នុងជីវិតមួយ
ដែលបរិសុទ្ធក៏ដូចជាខ្នែងដែលពឹងផ្អែ
កលើគល់ដើម្បីលូតលាស់
និងផ្តល់ផលដូច្នោះដែរ”។

បើឃ្លាតឆ្ងាយពីទ្រង់នោះអ្នកពុំមានជីវិតឡើយ។
បើនៅជាប់នឹងទ្រង់អ្នកនឹងបានចំរើនល្អតលាស់។
បើអ្នកឃ្លាតឆ្ងាយអំពីទ្រង់នោះអ្នកនឹងស្វិតស្រពោនគ្មានផ្លែផ្កាឡើយ។
អ្នកនឹងបានដូចដើមឈើដែលដុះតាមមាត់ទឹកដូច្នោះដែរ។

—

មានមនុស្សជាច្រើនយល់ថាគេត្រូវការកិច្ចការខ្លះដោយខ្លួនគេផ្ទាល់(ដោយមិនត្រូវការព្រះជាម្ចាស់)។
គេបានជឿទុកចិត្តលើព្រះគ្រិស្តដែលអត់ទោសបាប
ក៏ប៉ុន្តែឥឡូវគេបែរជាស្វះស្វែងរកការរស់នៅឲ្យបានត្រឹមត្រូវប្រពៃដោយសារភាពប្រឹងប្រែងរបស់ខ្លួនផ្ទាល់។

ការព្យាយាមបែបនេះមិនអាចសម្រេចឡើយ។ ព្រះយេស៊ូមានបន្ទូលថា: “បើគ្មានខ្ញុំអ្នករាល់គ្នាមិនអាចធ្វើអ្វីបានឡើយ”។

ការលូតលាស់នៅក្នុងព្រះគុណ..សេចក្ដីអំណរ និងផលព្រះគ្រិស្ទ។

គឺដោយសារការរួមសម្ពន្ធរបស់យើងជាមួយទ្រង់ជារៀងរាល់ថ្ងៃ..នៅជាប់នឹងទ្រង់គ្រប់ពេលវេលាហើយនោះដែលអាចឲ្យយើងបានរីកចំរើននៅក្នុងព្រះគុណរបស់ទ្រង់។

ព្រះអង្គមិនត្រឹមតែជាអ្នកចាប់ផ្ដើមប៉ុណ្ណោះទេ

គឺថែមទាំងជាអ្នកបង្គ្រប់ជំនឿរបស់យើងផង។ ព្រះគ្រិស្ទជាដើមកំណើត និងជាទីបញ្ចប់ជារៀងដរាប។

ព្រះអង្គគង់ជាមួយយើងមិនត្រឹមតែជាដើមកំណើតនិងទីបញ្ចប់នៃជីវិតប៉ុណ្

ណោះទេ
គឺគ្រប់ទាំងជំហានរបស់យើងក្នុងផ្លូវជីវិត។ លោកដាវីដមានប្រសាសន៍ថា: "ទូលបង្គំបានតាំងព្រះយេហូវ៉ានៅមុខទូលបង្គំជាដរាប
ហើយដោយសារព្រះអង្គគង់នៅស្តាំនៃទូលបង្គំ
បានជាទូលបង្គំមិនត្រូវរង្គើឡើយ"..ទំនុកតំកើង ១៦:៨។
តើលោកអ្នកដែលសួរថា:
តើធ្វើដូចម្តេចទើបខ្ញុំអាចនៅជាប់ជាមួយព្រះគ្រិស្ទបាន?
ចំលើយគឺអ្នកត្រូវប្រព្រឹត្តឲ្យដូចពេលដែលអ្នកទើបទទួលយកទ្រង់ជាលើកដំបូង។
"ដូច្នេះអ្នករាល់គ្នាបានទទួលយកព្រះគ្រិស្ទជាម្ចាស់បែបយ៉ាងណា
នោះចូរដើរតាមទ្រង់តាមបែបនោះចុះ"

..កុលុស២:៦។“មនុស្សសុចរិតនឹងរស់នៅដោយអាងលើសេចក្តីជំនឿ”..ហេព្រឺ១០:៣៨។អ្នកប្រគល់ខ្លួនអ្នកទាំងស្រុងទៅឯទ្រង់ដើម្បីបំរើនិងគោរពតាមទ្រង់ហើយអ្នកព្រមទទួលទ្រង់ជាព្រះអង្គសង្គ្រោះ។
អ្នកមិនអាចលាងបាបដោយខ្លួនឯងផ្ទាល់បានទេ
ឬក៏មិនអាចផ្លាស់ប្តូរចិត្តដោយខ្លួនឯងបានដែរក៏ប៉ុន្តែ
បើអ្នកប្រគល់រូបអ្នកដល់ព្រះជាម្ចាស់នោះ
អ្នកនឹងជឿថាដោយសារព្រះគុណរបស់ព្រះយេស៊ូគ្រិស្ទ
ព្រះជាម្ចាស់នឹងជួយសម្រេចនូវកិច្ចការទាំងអស់សម្រាប់រូបអ្នក។
ដោយសារសេចក្តីជំនឿអ្នកក្លាយទៅជាកម្មសិទ្ធរបស់ព្រះគ្រិស្ទ

ហើយដោយសារសេចក្តីជំនឿនេះអ្នកនឹងលូតលាស់ក្នុងទ្រង់ដោយថ្វាយដល់ទ្រង់
និងទទួលព្រះពរអំពីទ្រង់វិញដែរ។
អ្នកត្រូវតែប្រគល់អ្វីៗទាំងអស់
ទាំងចិត្តរបស់អ្នក បំណងរបស់អ្នក
ការងាររបស់អ្នក
ព្រមទាំងប្រគល់ខ្លួនរបស់អ្នកដល់ទ្រង់
ដើម្បីគោរពប្រណិបត្តន៍អស់ទាំងសេចក្តីដែលព្រះតម្រូវ
ហើយអ្នកត្រូវទទួលយកអ្វីៗទាំងអស់
ដូចជាព្រះគ្រិស្ទ
និងព្រះពរបរិបូណ៌ដើម្បីឲ្យបានជាប់ក្នុងចិត្តអ្នកជាថាមពលរបស់អ្នក
ជាសេចក្តីសុចរិតរបស់អ្នកជាអ្នកដែលជួយសង្គ្រោះដ៏អស់កល្បរបស់អ្នក
ដើម្បីផ្តល់អំណាចឲ្យអ្នកគោរពតាម។

ចូរអ្នកសម្អាតខ្លួនឲ្យបានបរិសុទ្ធចំពោះព្រះ
នៅវេលាព្រឹកជាមួយការងារមួយមុនដំបូង គេបង្អស់របស់អ្នក។
អ្នកត្រូវអធិស្ឋានយ៉ាងដូច្នេះថា: “ឱ! ព្រះជាម្ចាស់អើយ
សូមទ្រង់ទទួលយកព្រះទូលបង្គំជារបស់ទ្រង់ពេញទីចុះ”។
ទូលបង្គំនឹងដាក់គំរោងផែងការទាំងឡាយទ្រង់។
សូមទ្រង់ចាត់ទូលបង្គំថ្ងៃនេះឲ្យបំពេញកិច្ចការថ្វាយទ្រង់។
សូមទ្រង់គង់ជាមួយទូលបង្គំហើយឲ្យរាល់ការងាររបស់ទូលបង្គំបានគាប់ព្រះហឫទ័យរបស់ទ្រង់។
នេះជាកិច្ចការប្រចាំថ្ងៃ។
រៀងរាល់ព្រឹកចូរអ្នកញែកខ្លួនឲ្យបានបរិសុទ្ធសម្រាប់ព្រះឲ្យបានថ្ងៃនោះចុះ។

ចូរដាក់ថ្វាយទ្រង់រាល់ផែនការរបស់អ្នកចំពោះទ្រង់
ប្រយោជន៍ឲ្យទ្រង់បង្ហាញផ្លូវដល់អ្នកថា តើគួរធ្វើអ្វីតទៅទៀតឬ
ក៏ត្រូវឈប់ត្រឹមហ្នឹង។
ដូច្នេះហើយពីមួយថ្ងៃទៅមួយថ្ងៃ
អ្នកថ្វាយខ្លួនជីវិតរបស់អ្នកទៅក្នុងព្រះហស្តទ្រង់ហើយពេលនោះ
ជីវិតអ្នកនឹងយកពុម្ពគំរូតាមព្រះជន្មរបស់ ព្រះគ្រិស្ទយ៉ាងដូច្នោះដែរ។

ជីវិតក្នុងព្រះគ្រិស្ទជាជីវិតដែលពោរពេញទៅដោយការសំរាក។
ទោះជាមិនមានការសប្បាយហួសហេតុ
ក៏គង់មានសេចក្តីទំនុកចិត្តដ៏សុខសាន្តមួយនៅជាប់ជានិច្ចដែរ។
សេចក្តីសង្ឃឹមមិនមិននៅក្នុងអ្នក

ប៉ុន្តែឋិតក្នុងព្រះគ្រិស្ទ។
ភាពកំសោយរបស់អ្នកត្រូវបានផ្សារភ្ជាប់ទៅនឹងថាមពលរបស់ទ្រង់..ភាពល្ងង់ខ្លៅរបស់អ្នកទៅនឹងប្រាជ្ញាញាណរបស់ទ្រង់..ភាពទន់ខ្សោយរបស់អ្នកទៅនឹងអំណាចទ្រាំទ្ររបស់ទ្រង់។
ដូច្នេះអ្នកមិនត្រូវមើលមកខ្លួនឯង ហើយក៏មិនត្រូវអនុញ្ញាតិឲ្យគំនិតទៅនឹងអត្ត(Self)គឺខ្លួនរបស់អ្នកផ្ទាល់ឡើយ គឺត្រូវសម្លឹងមើលទៅឯព្រះគ្រិស្ទ។
សូមឲ្យគំនិតរបស់អ្នកបាននៅនឹងសេចក្តីស្រលាញ់របស់ទ្រង់ ហើយនឹងនៅជាប់នឹងសោភ័ណភាព និងភាពគ្រប់លក្ខណ៍នៃអត្តចរិករបស់ទ្រង់។
គោលដៅនៃការផ្តោតព្រលឹងនោះគឺព្រះគ្រិស្ទដែលប្រកបដោយការលះបង់អង្គព្រះអង្គ..ព្រះគ្រិស្ទនៅក្នុងសេចក្តី

ស្រលាញ់ដ៏គ្មានពីរ។
គឺមានតែស្រលាញ់ដល់ទ្រង់យកតម្រាប់តាមទ្រង់
ពឹងផ្អែកទាំងស្រុងលើទ្រង់ប៉ុណ្ណោះដែលអាចនាំឲ្យអ្នកបំផ្លាស់ប្រែបានដូចទ្រង់។

ព្រះគ្រិស្តយេស៊ូមានបន្ទូលថា:
“ចូរនៅជាប់នឹងខ្ញុំ”។
ព្រះបន្ទូលនេះដូចជាបង្ហាញមតិមួយក្នុងការសំរាក ស្សេរភាព
និងការទុកចិត្ត។
ម្តងទៀតព្រះអង្គបានអំពាវហៅយើងថា:
“ចូរមកឯខ្ញុំ..ខ្ញុំនឹងឲ្យអ្នកឈប់សំរាក”..ម៉ាថាយ
១១:២៨។សំនៀងនៃពួកអ្នកលើកទំនុកតំកើងក៏បានបញ្ចេញដូចគ្នានេះដែរ

ថា:
“ចូរសំរាកក្នុងទ្រង់ហើយចូររង់ចាំទ្រង់ដោយសេចក្ដីអំណត់ចុះ”..ទំនុកតំកើង ៣៧:៧។
លោកហោរាអេសាយបានផ្ដល់សេចក្ដីសន្យានេះថា:
“ឯងរាល់គ្នានឹងមានកម្លាំងដោយនៅស្ងៀមហើយមានសេចក្ដីទុកចិត្ត”..អេសាយ ៣០:១៥។
សេចក្ដីសំរាកនេះមិនមាននៅក្នុងភាពអសកម្មទេ
ដោយព្រោះថាក្នុងសេចក្ដីដង្ហោយហៅរបស់ទ្រង់
នោះសេចក្ដីសន្យានៃការសំរាក
ត្រូវបានផ្សារភ្ជាប់ទៅនឹងការងារដូចជាព្រះបន្ទូលត្រង់ម៉ាថាយ
១១:២៩ថែងថា: “ចូរទទួលយកនឹមខ្ញុំ នោះអ្នកនឹងបានការសំរាក”

។ចិត្តមួយដែលនៅជាប់ជាមួយព្រះគ្រិស្ទដ៏ពេញលេញនោះ
នឹងបានទទួលយ៉ាងច្រើនហើយសកម្មក្នុងការងារថ្វាយទ្រង់ផង។

ពេលណាចិត្តគំនិតគិតតែអាត្មាខ្លួនឯងនោះវានឹងងាកចេញពីព្រះគ្រិស្ទដែលជាប្រភពនៃថាមពល និងជីវិត។
សាតាំងដែលប្រឹងប្រែងជាប់ជានិច្ចដើម្បីប្រមូលទាំងគំនិតដែលបែកចេញពីអង្គសង្គ្រោះ
ហើយក៏រាំងការរួមសម្ព័ន្ធនៃព្រលឹងរបស់យើងនឹងព្រះគ្រិស្ទ។
បញ្ហាផងទាំងឡាយដូចជាការសប្បាយក្នុងផ្លូវលោកិយ
ការខ្វល់ខ្វាយនឹងជីវិត
ការច្របូកច្របល់ទ័លគំនិត
សេចក្តីទុក្ខព្រួយ កំហុសរបស់អ្នកដទៃ

កំហុសរបស់អ្នកផ្ទាល់
និងការមិនស្អាតស្អំ
ទោះជាភាគខ្លះឬទាំងស្រុងនោះឲ្យវា
នាំ
ឲ្យគំនិតរបស់យើងមានការងាករេ។
ចូរអ្នកប្រយ័ត្នក្រែងមានការនាំទៅក្នុង
ផ្លូវខុសដោយលកឧបាយរបស់សាតាំ
ង៍។
ក៏គង់មានមនុស្សជាច្រើនដែលមានម
នសិកា
ហើយមានចំនង់ចិត្តរស់នៅសំរាប់ព្រះ
ត្រូវសាតាំងនាំឲ្យធ្លាក់ទៅក្នុងកំហុស
និងភាពកំសោយរបស់វាហើយដោយ
ការបំបែកចេញអំពីព្រះគ្រិស្ទនោះវាស
ង្ឃឹមថាទទួលបានជោគជ័យ។
យើងមិនគប្បីដាក់ខ្លួនឯងនៅចំកណ្ដា
លហើយទំយើខ្លួននឹងការតក់ក្រហាល់
និងការភ័យខ្លាច៏

ចំពោះថាតើយើងបានទទួលសង្គ្រោះ
ឬយ៉ាងណានោះ។
ការទាំងនេះនាំឲ្យព្រលឹងឃ្លាតចេញ
ពីប្រភពថាមពល។
ចូរអ្នកប្តេជ្ញានឹងរក្សាព្រលឹងរបស់អ្នកចំ
ពោះព្រះហើយជឿទុកចិត្តលើទ្រង់ចុះ
។
ចូរអ្នកលើកការមន្ទិលសង្ស័យចេញឲ្យ
ឆ្ងាយ
ហើយក៏បណ្តេញសេចក្តីភ័យខ្លាចចោ
លចេញ
ហើយចូរតាមបន្ទូរតាមសាវ័កប៉ុលថា:
"..ខ្ញុំរស់នៅមិនមែនជាខ្ញុំទៀតគឺជាព្រះ
គ្រិស្ទទ្រង់រស់ខ្ញុំវិញហើយ
ខ្ញុំដែលរស់ក្នុងសាច់ឈាមឥឡូវនេះ
គឺរស់ដោយសេចក្តីជំនឿជឿដល់ព្រះរា
ជបុត្រានៃព្រះដែលទ្រង់ស្រលាញ់ខ្ញុំ
ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើ

យ"..កាឡាទី
២:២០។ចូរសំរាកក្នុងព្រះជាម្ចាស់
ទ្រង់អាចនឹងរក្សាអ្វីដែលអ្នកបានថ្វាយ
ដល់ទ្រង់ផង។
បើសិនអ្នកថ្វាយខ្លួនអ្នកទៅក្នុងព្រះហា
ស្តទ្រង់
នោះទ្រង់នឹងលើកអ្នកឡើងលើសជាង
អ្នកដែលឈ្នះតាមរយៈព្រះដែលបាន
ស្រលាញ់អ្នក។

ពេលដែលព្រះគ្រិស្ទបានយោនយកកំ
ណើតជាមនុស្ស
ពេលនោះទ្រង់បានភ្ជាប់ភាពមនុស្សជា
តិទៅនឹងទ្រង់ដោយសារចំណងនៃសេ
ចក្តីស្រលាញ់
ដែលមិនមានអំណាចណាមួយ
អាចនឹងបំបែកបំបាក់បានឡើយ
ក្រៅអំពីបំណងហាឫទ័យជ្រើសរើសរប

ស់ទ្រង់តែប៉ុណ្ណោះ។
សាតាំងនឹងបន្តការអុចអាលញុះញង់ដើម្បីបំបែកបំបាក់
ចំណងនេះក្នុងគោលបំណងរបស់វាបំបែកបំបាក់យើងចេញពីព្រះគ្រិស្ទ។
គឺដោយហេតុដូច្នេះហើយ
បានជាយើងត្រូវឃ្លាំមើល
ពុះពារអធិស្ឋានដើម្បីកុំឲ្យមានអ្វីមកអូសទាញយើង
ឲ្យជ្រើសរើសយកម្ចាស់ថ្មីទៀត
ព្រោះអីយើងមានសេរីភាពបរិបូណ៌ក្នុងការនេះ។
ចូរយើងផ្ដោតចក្ខុរបស់យើងទាំងគូឆ្ពោះតំរង់ទៅឯព្រះគ្រិស្ទនោះទ្រង់នឹងថែរក្សាយើង។
យើងនឹងបានសេចក្ដីសុខសាន្តបើយើងស្វែងរកទ្រង់។
គ្មានអ្វីអាចនឹងញែកយើងចេញពីពញ

រះហាស្គទ្រង់បានឡើយ។
ដោយសម្លឹងរំពឹងទៅទ្រង់ជាប់ជានិច្ច
នោះយើងនឹង
បានផ្លាស់ប្រែទៅតាមរូបអង្គទ្រង់ពីសិរី
ល្អមួយទៅ
សិរីល្អមួយទៀតដោយសារព្រះអម្ចា
ស់ដ៏ជាម្ចាស់ដ៏ជាព្រះវិញ្ញាណ..កូរិនថូ
ស២ ៣:១៨។

ពួកសាវ័ករបស់ព្រះ កាលពូសម័យមុន
មានលក្ខណៈដូចជាព្រះអង្គសង្គ្រោះ។
ពេលដែលគេបានឮព្រះបន្ទូលរបស់ព្
រះយេស៊ូគ្រិស្ទ
នោះគេត្រូវការទ្រង់នឹងទទួលយកទ្រង់
។ គេស្វែងរកទ្រង់
បានរកឃើញទ្រង់ហើយក៏សម្រេចចិត្ត
ដើរតាមទ្រង់ភ្លាម។
គេបាននៅជាប់នឹងទ្រង់ដូចជាសិស្សនិ

ងគ្រូ
ហើយក៏បានទទួលការបង្ហាត់បង្រៀន
ផ្ទាល់ អំពីទ្រង់ដូចជាសិស្សនឹងគ្រូ
ហើយក៏បានទទួលការបង្ហាត់បង្រៀន
ផ្ទាល់
អំពីទ្រង់ជារៀងរាល់ថ្ងៃគឺជាសេចក្តីបង្
រៀនអំពីសច្ចៈធម៌ដ៏បរិសុទ្ធ។
គេគោរពប្រណិបត្តន៍ទ្រង់
ដូចជាអ្នកបំរើនិងនាយចៅហ្វាយរបស់
ខ្លួនដើម្បីក្រេបជញ្ជក់យកករណីកិច្ចរប
ស់គេ។ ពួកសាវ័កទាំងនោះជាមនុស្ស
“ហើយមានចិត្តដូចយើងអញ្ចឹងដែរ”..
យ៉ាកុប ៥:១៧។
គេក៏មានការប្រយុទ្ធពុះពារនឹងអំពើបា
បដូចជាយើងមានអញ្ចឹងដែរ
ហើយគេក៏ត្រូវការព្រះគុណដដែល
នេះប្រយោជន៍ឲ្យបានរស់ក្នុងជីវិតមួយ
ដ៏បរិសុទ្ធដែរ។

ស្ទូម្បីយ៉ូហានដែលជាសាវ័កសំណព្វចិត្តរបស់ព្រះ
ជាអ្នកដែលមានភាពដូចជាព្រះជាងគេបំផុតនោះក៏ដោយ
ក៏គាត់មិនមានអត្តចរិកដែលពោរពេញដោយសេចក្តីស្រលាញ់នោះពីកំណើតមកដែរ។
លោកមិនមែនគ្រាន់តែជាមនុស្សម្នាក់ដែលមានអំនួត
និងមហិច្ឆតារកកិត្តិយសប៉ុណ្ណោះទេប៉ុន្តែគាត់ជាអ្នកមិនសូវពិចារណាវែងឆ្ងាយ ហើយឆេវឆាវមានចិត្តចង់តបវិញកាលណាមានការប៉ះទង្គិចដល់គាត់។
ប៉ុន្តែនៅពេលដែលលក្ខណៈបរិសុទ្ធនៃព្រះបានបើកសំដែងដល់គាត់
នោះគាត់បានមើលឃើញភាពខ្វះខាតរបស់គាត់ ហើយក៏បន្ទាបខ្លួន

ដោយស្គាល់ទ្រង់។ កម្លាំង
និងការអត់ធ្មត់
អំណាចនិងភាពទន់ភ្លន់
ភាពប្រសើរឧត្តម
និងភាពសំឡូតដែលគាត់បានឃើញក្នុ
ងជិវិតប្រចាំថ្ងៃ
នៃព្រះរាជបុត្រានៃព្រះបានចាក់បំពេ
ញក្នុងព្រលឹងរបស់គាត់បានចុះចូលនឹ
ងព្រះគ្រិស្ទ ដរាបទាល់តែគាត់មើល
មិនឃើញទៀតនូវអត្តទត្ថភាព
គឺភាពផ្ទាល់ខ្លួន
ព្រោះគាត់មានសេចក្ដីស្រលាញ់ចំ
ពោះព្រះជាម្ចាស់។
ចិត្តដែលប្រកបដោយការតូចចិត្ត
មហិច្ឆតា កំហឹងទាំងអំបាលម៉ាន
ក៏បានថយចុះចូលតាមពុម្ពគំរូនៃព្រះគ្
រិស្ទជាម្ចាស់។
ឥទ្ធិពលដែលបង្កើតឡើងថ្មីដោយព្រះ

វិញ្ញាណបរិសុទ្ធបានធ្វើឲ្យចិត្តរបស់គាត់ជាថ្មីឡើងវិញ។
អំណាចនៃសេចក្ដីស្រលាញ់របស់ព្រះគ្រិស្ទបានចារឹកនូវការផ្លាស់ប្រែអត្តចរិក។
នេះហើយគឺជាលទ្ធិផលដ៏ពិតនៃការរួមសម្ព័ន្ធនឹងព្រះគ្រិស្ទ។
កាលណាព្រះគ្រិស្ទគង់សណ្ឋិតនៅក្នុងចិត្ត សភាពទាំងស្រុងក៏ត្រូវផ្លាស់ប្រែ។
ព្រះវិញ្ញាណនៃព្រះគ្រិស្ទ
សេចក្ដីស្រលាញ់របស់ទ្រង់បានធ្វើឲ្យចិត្តផុសផុល គ្រប់គ្រងលើព្រលឹងនិងទាញគំនិតចំណង់ឲ្យបានមកឯព្រះនៃនគរឋានសួគ៌។

នៅពេលដែលព្រះគ្រិស្ទបានយាងត្រលប់ទៅកាន់នគរឋានសួគ៌វិញពួកសាវ័កទ្រង់នៅតែមានអារម្មណ៍ថាព្រះគ្រិស្ទ

នៅមានវត្តមាននៅនឹងពួកគេនៅឡើ
យ។
នោះគឺជាវត្តមានផ្ទាល់ដែលពោរពេញ
ដោយសេចក្តីស្រលាញ់ និងពន្លឺ។

ព្រះយេស៊ូគ្រិស្ទជាព្រះអង្គសង្គ្រោះដែ
លបានដើរជាមួយពួកគេ សាសង
និងអធិស្ឋានជាមួយពួកគេ
មានព្រះបន្ទូលជាមួយសេចក្តីសង្ឃឹម
បានជួយកំសាន្តចិត្តគេ។
ក្នុងខណៈដែលទ្រង់កំពុងមានព្រះបន្ទូ
លអំពីដំណឹងនៃសេចក្តីសុខសាន្តនោះ
ស្រាប់តែទ្រង់ត្រូវបានលើកឡើងទៅឯ
នគរឋានសួគ៌
ប៉ុន្តែពួកសាវ័កទាំងឡាយនៅតែឮព្រះ
សូរសៀងរបស់ទ្រង់មកកាន់គេដដែល
នៅពេលដែលពពួកទេវតាបានមកទទួ
លទ្រង់នៅក្នុងពពក។“ហើយមើលខ្ញុំក៏

នៅជាមួយនឹងអ្នករាល់គ្នាជារៀងដរាប
រហូតដល់ចុងបំផុតនៃកាល”..ម៉ាថាយ
២៨:២០។
ទ្រង់បានយាងត្រឡប់ទៅកាន់នគរស្ថា
នសួគ៌វិញទាំងរូបសណ្ឋានជាមនុស្ស។
ពួកគេបានដឹងយ៉ាងច្បាស់ថាព្រះដែល
ជាមិត្តសំលាញ់
និងជាព្រះអង្គសង្គ្រោះរបស់គេ
គង់នៅខាងមុខបល្ល័ង្គនៃព្រះ
ហើយទ្រង់នៅតែមានព្រះទ័យទន់ស
ណ្តោសឥតប្រែប្រួលឡើយ..ទ្រង់នៅ
តែចូលរួមប្រកបជា
មួយមនុស្សជាតិដែលមានទុក្ខវេទនា។
ទ្រង់បានលើកបង្ហាញចំពោះព្រះវរបិ
តានូវគុណសម្បត្តិនៃលោហិតដ៏ថ្លៃថ្លា
ស្នាមរបួសនៅដៃនិងជើងព្រះអង្គជាភ័
ស្តុតាងនៃថ្ងៃដែលទ្រង់បានចេញដល់
មនុស្ស ដែលទ្រង់បានប្រោសលោះ។

ពួកគេបានដឹងយ៉ាងច្បាស់ថាទ្រង់យាងទៅកាន់នគរឋានសួគ៍
គឺដើម្បីរៀបចំកន្លែងទុកសម្រាប់ពួកគេ រាល់គ្នា
ហើយថាទ្រង់នឹងយាងត្រលប់មកវិញ
មកទទួលយកគេទៅនៅជាមួយទ្រង់ផង។

ពេលដែលគេបានជួបប្រជុំគ្នាបន្ទាប់ពីទ្រង់បានយាងផុតទៅ
នោះគេបានថ្វាយរាល់សេចក្តីទូលសូម
អំពីព្រះវរបិតាក្នុងនាមព្រះយេស៊ូគ្រិស្ទ។
គេបានឱនក្រាបដោយសេចក្ដីស្ញែងខ្លាចនឹងយ៉ាងឱឡារិកក្នុងសេចក្ដីអធិស្ឋាន
ដោយបន្ទរឡើងនូវសេចក្ដីធានារ៉ាប់រងរបស់ទ្រង់ថា៖

“..អ្វីៗដែលអ្នករាល់គ្នានឹងសូមដល់ព្
រះវរបិតាដោយនូវឈ្មោះខ្ញុំនោះខ្ញុំ
នឹងប្រទានឲ្យ។
តាំងពីដើមមកអ្នករាល់គ្នាមិនបានសូម
អ្វីដោយនូវឈ្មោះខ្ញុំទេ ឥឡូវសូមចុះ
នោះអ្នករាល់គ្នានឹងបាន
ដើម្បីឲ្យអំណរអ្នករាល់គ្នាបានពោរពេ
ញពិត”..យ៉ូហាន ១៦:២៣.២៤។
គេបានលើកដៃដោយសេចក្ដីជំនឿឡើ
ងដោយអំណាចទាំង
ប្រកាសតតាំងថា:
“ត្បិតព្រះគ្រិស្ទដែលទ្រង់បានសុគត
នោះ ទ្រង់បានមានព្រះជន្មរស់
ឡើងវិញហើយ
ទ្រង់គង់នៅខាងស្ដាំព្រះហស្ដនៃព្រះវរ
បិតាផង
ដែលទ្រង់ជាអ្នកអង្វរករឲ្យយើងរាល់គ្
នា”..រ៉ូម

៨:៣៩។ប៉ុន្តែតាកូសបាននាំវត្តមាននៃព្រះដ៏ជួយដោះទុក្ខដែលព្រះគ្រីស្ទមានព្រះបន្ទូលអំពីពួកទាំងនោះថា“ទ្រង់គង់ជាមួយក៏នឹងសណ្ឋិតនៅក្នុងពួកគេរាល់គ្នាដែរ”
រួចទ្រង់មានព្រះបន្ទូលបន្តថា“ដែលខ្ញុំទៅនេះនឹងមានប្រយោជន៍ដល់អ្នករាល់គ្នាវិញត្បិតបើខ្ញុំមិនទៅទេនោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរតែបើខ្ញុំទៅនោះខ្ញុំនឹងចាត់ទ្រង់មក”..យ៉ូហាន១៤:១៧..១៦:៧។ដូច្នេះតាមរយៈព្រះវិញ្ញាណបរិសុទ្ធព្រះគ្រីស្ទនឹងគង់សណ្ឋិតជានិច្ចនឹងរាស្ត្ររបស់ទ្រង់។ឯការរួមប្រាស្រ័យជាមួយទ្រង់នោះរឹតតែមានភាពជិតស្និទ្ធជាងកាលដែលទ្រង់គង់នៅជាមួយនឹងគេផង។ពន្លឺនិងសេចក្តីស្រលាញ់និងអំណាចនៃព្រះគ្រីស្ទដែលគង់សណ្ឋិតនៅខាងក្នុងបានភ្លឺ

ចិញ្ចឹងតាមរយៈអ្នករាល់គ្នាដែលបញ្ចាំងឲ្យអដស់អ្នកណាដែលបានឃើញនោះក៏មាន“សេចក្តីអស្ចារ្យដោយដឹងថាពួកមនុស្សទាំងនោះធ្លាប់បានរស់នៅជាមួយព្រះយេស៊ូគ្រីស្ទ”..កិច្ចការ៤:១៣។

អ្វីដែលព្រះគ្រិស្ទចង់ឲ្យសិស្សរបស់ទ្រង់ធ្វើនៅជាន់នោះក៏ទ្រង់ចង់ឲ្យយើងរាល់គ្នាជារាស្រ្តរបស់ទ្រង់ធ្វើនៅសម័យបច្ចុប្បន្ននេះដែរ។នៅក្នុងសេចក្តីអធិស្ឋានចុងក្រោយបង្អស់ជាមួយនឹងសិស្សផ្ទាល់របស់ទ្រង់មួយក្រុមតូចដែលនៅជុំវិញទ្រង់នោះទ្រង់មានបន្ទូលថា:“ដែលខ្ញុំអធិស្ឋាននេះគឺមិនមែនសម្រាប់តែអ្នកទាំងនេះទេក៏ប៉ុន្តែសម្រាប់អស់អ្នកណាដែលមានជំនឿដល់ខ្ញុំតាមរយៈ

ពាក្យរបស់អ្នកទាំងនេះដែរ"..យ៉ូហាន ១៧:២០។

ព្រះយេស៊ូបានអធិស្ឋានឲ្យយើងរាល់គ្នាហើយទ្រង់ចង់ឲ្យយើងរាល់គ្នាហើយទ្រង់ចង់ឲ្យយើងបាននៅជាមួយទ្រង់នោះទ្រង់ជាព្រះដែលគង់នៅជាមួយព្រះវរបិតាក្តី។នេះជាការរួបរួមប្រកបដ៏អស្ចារ្យមែន!
ព្រះអង្គសង្គ្រោះមានព្រះបន្ទូលទៅកាន់ទ្រង់ថា:"ព្រះរាជបុត្រាមិនអាចធ្វើអ្វីដោយអង្គទ្រង់បានទេ..ព្រះវរបិតាដែលគង់នៅក្នុងខ្ញុំនោះទ្រង់សម្រេចការទាំងអស់"..យ៉ូហាន៥:១៩..១៤:១០។ដូច្នេះបើព្រះគ្រីស្ទទ្រង់គង់សណ្ឋិតជាមួយចិត្តយើងរាល់គ្នាឲ្យមានចំណង់ចង់ធ្វើការក្នុងយើង"ដ្បិតគឺជាព្រះហើយដែលបណ្តាលចិត្តអ្នករាល់គ្នាឲ្យមានចំ

ណាង់ចង់ធ្វើហើយឲ្យបានប្រព្រឹត្តតាម
បំណងព្រះហឫទ័យរបស់ទ្រង់ដែរ”..ភី
លីព២:១៣។“យើងនឹងធ្វើការដូចជាទ្រ
ង់នឹងនៅជាប់ជាមួយទ្រង់ដូចដែលព្រះ
វិញ្ញាណតែមួយដែលបានបើកសំដែង
មក។ដោយស្រលាញ់ទ្រង់និងនៅជាប់
ជាមួយទ្រង់នោះយើងនឹងបានរីកចំរើន
ឡើងគ្រប់ការទាំងអស់ក្នុងទ្រង់ដែលទ្
រង់ជាសិរសាគឺជាព្រះគ្រីស្ទយេស៊ូ”..អា
ភេសូ៤:១៥។

# ជំពូក ៩ — ការងារ និងជីវិត

ព្រះជាម្ចាស់គឺជាប្រភពនៃជីវិត
និងពន្លឺហើយនិងសេចក្ដីអំណររីករាយ
ដល់លោកសន្និវាសទាំងមូល។
ព្រះពរដែលព្រះជាម្ចាស់ប្រទានដល់
សត្វលោកដែលទ្រង់បានបង្កើតមក
នោះប្រៀបទៅនឹងកាំរស្មីពន្លឺព្រះអាទិ
ត្យ
ក៏ដូចជាចរន្តទឹកដែលលេចចេញអំពីប្
រភពទឹកដែលរស់។
នៅទីណាដែលព្រះគង់សណ្ឋិតនៅក្នុង
ចិត្តរបស់មនុស្សលោកនោះព្រះគុណរ
បស់ទ្រង់នឹងរីកសុះសាយ
ដល់អ្នកដទៃដោយសេចក្តីស្រលាញ់និ
ងព្រះពរ។

អំណរីករាយនៃព្រះអង្គសង្គ្រោះរបស់យើង គឺការលើកស្ទួយនិងការប្រោសលោះដល់មនុស្សមានបាប។
ដោយការនេះព្រះអង្គពុំដែលគិតដល់ព្រះជន្មរបស់ទ្រង់ឡើយ តែទ្រង់ស៊ូទ្រាំអត់ធ្មត់ទទួលការលំបាកនៅលើឈើឆ្កាង ទោះជាមានការអាម៉ាសយ៉ាងណាក៏ដោយ។
ដូចជាពពួកទេវតាធ្លាប់ចូលរួមធ្វើការដើម្បីអំណររបស់អ្នកឯទៀតដែរ។
នេះហើយគឺជាអំណរីករាយរបស់ពពួកទេវតាទាំងនោះ។
ក៏ប៉ុន្តែចិត្តដែលប្រកបដោយភាពអាត្មានិយមវិញនោះនឹងមើលការនេះជាការអាម៉ាសទាបថោកក្នុងការផ្សព្វផ្សាយដំណឹង

ដល់អ្នកមានឋានៈនិងអត្តចរិកទន់ទាប
ហើយថានោះជាការងាររបស់ពួកទេតា
ដែលបរិសុទ្ធវិញ។
ព្រះវិញ្ញាណនៃសេចក្តីស្រលាញ់ពោរ
ពេញដោយ
កាលៈបង់របស់ព្រះគ្រិស្ទគឺជាវិញ្ញាណ
ដែលជ្រួតជ្រាបពេញឋានសួគ៍ជាការ
ដែលសំខាន់បំផុតនៃបរមសុខ
និងអំណររីករាយនៃស្ថានសួគ៌។
ឯសាវ័ករបស់ព្រះគ្រិស្ទនឹងមានវិញ្ញា
ណ
និងការងាររបស់គេយ៉ាងដូច្នោះដែរ។

នៅពេលដែលសេចក្តីស្រលាញ់របស់
ព្រះគ្រិស្ទ
បានសណ្ឋិតនៅក្នុងចិត្តនោះគេក៏បាន
ដូចជាក្លិនពិដោរដ៏ក្រអូប
ដែលគ្មានអ្វីអាចបិទបាំងបានឡើយ។

អ្នកឯណាដែលបានជួបប្រទះ
នឹងបានជ្រួតជ្រាបនូវឥទ្ធិពលរបស់ព្រះ
គ្រិស្ទ។
ព្រះវិញ្ញាណរបស់ព្រះគ្រិស្ទដែលស
ណ្ឋិតនៅក្នុងចិត្តប្រៀបបានទៅនឹងទឹក
ផុសនៅទីវាលរហោស្ថាន
ដែលគេតែងស្រោចស្រព្វដល់មនុស្ស
គ្រប់រូប
ហើយក៏បញ្ចាំងឲ្យអ្នកដែលហៀបនឹងវិ
នាសបាត់បង់
មានចំណង់នឹងក្រេបជញ្ជក់ទឹកជីវិត
នោះវិញ។

សេចក្តីស្រលាញ់ចំពោះព្រះគ្រិស្ទនឹង
សំដែងឲ្យឃើញនូវចំណង់ធ្វើការអ្វីៗឲ្
យដូចទ្រង់បានធ្វើដើម្បីព្រះពរនិងការ
លើកស្ទួយមនុស្សជាតិឡើង។
ចំណង់នោះនឹងនាំមកនូវសេចក្តីស្រ

លាញ់ភាពទន់ភ្លន់
និងសេចក្តីអាណិតស្វរចំពោះសត្វលោ
កដែលជាសមិទ្ធិផលរបស់ព្រះ
ដែលស្ថិតនៅក្រោមការថែរក្សារបស់ព្
រះវរបិតានៃនគរស្ថានសួគ៌ជាព្រះនៃ
យើង។

ព្រះជន្មនៃព្រះអង្គសង្គ្រោះនៅលើផែន
ដីពុំមែនជាជីវិតមួយដ៏សុខុម
ហើយគិតតែអំពីព្រះអង្គទ្រង់នោះឡើ
យ
តែទ្រង់ទ្រាំទ្រដោយការព្យាយាមតស៊ូ
យកចិត្តទុកដាក់មិនខ្លាចការនឿយហា
ត់
ដើម្បីសេចក្តីសង្គ្រោះចំពោះមនុស្សជា
តិដែលបានបាត់បង់។
ចាប់តាំងពីពេលដែលទ្រង់បានប្រសូត្
រ មករហូតទល់នឹងកាល់វ៉ារី

ព្រះយេស៊ូគ្រិស្ទទ្រង់បានប្រកាន់ខ្ជាប់នូវមាគ៌ាមួយដែល
បដិសេធភាពអាត្មានិយម(Self-denial) ហើយទ្រង់ពុំដែលប្រាថ្នាគេចវេសអំពីភារកិច្ចដ៏លំបាកក្រៃលែង
ការធ្វើដំណើរដែលពោរពេញដោយការឈឺចាប់ ការថែរក្សា
និងការងារដ៏គួរឲ្យនឿយណាយឡើយ។ ទ្រង់មានបន្ទូលថា: “កូនមនុស្សបានមកពុំមែនឲ្យគេបំរើទ្រង់ទេ គឺនឹងមកបំរើគេវិញ
ហើយឲ្យជីវិតទ្រង់ទុកជាថ្លៃប្រោសលោះមនុស្សជាច្រើនផង”..ម៉ាថាយ២០:២៨។
“ទាំងនេះគឺជាគោលបំណងដ៏ធំមួយនៃព្រះជន្មរបស់ព្រះអង្គ។
អ្វីៗផ្សេងទៀតគឺជារបស់ទី២
នឹងបន្ទាប់បន្សំប៉ុណ្ណោះ។

ចំណង់ដែលព្រះធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតានិងដើម្បីបញ្ចប់ការងារទ្រង់គឺជាអាហាររបស់ទ្រង់”។
ការគិតពីប្រយោជន៍ផ្ទាល់ខ្លួនពុំមែនមានចំណែកក្នុងការងាររបស់ទ្រង់ទេ។

ដូច្នេះអ្នកឯណាដែលបានចូលរួមចំណែកព្រះគុណនៃព្រះគ្រិស្ទ នឹងរៀបចំខ្លួនជាស្រេចនឹងបូជាលះបង់ដើម្បីឲ្យអ្នកណាដែលព្រះជាម្ចាស់ទ្រង់បានសុគតជំនួសបានទទួលអំណោយនៃនគរស្ថានសួគ៌។
គេនឹងធ្វើអ្វីៗដែលគេអាចធ្វើទៅបានដើម្បី ឲ្យលោកិយដែលគេរស់នៅនេះបានល្អប្រសើរឡើង។
គំនិតនេះគឺបានកើតចេញមកពីមនុស្សដែលកែប្រែដ៏ពិតប្រាកដ។

នៅពេលដែលគេទទួលជឿដល់ព្រះគ្រិស្ទភ្លាម
គេក៏មានចំណង់ចិត្តចង់ជួយអ្នកដទៃ
ដើម្បីឲ្យគេបានស្គាល់ទ្រង់ជាមិត្ត
សម្លាញ់ដ៏ថ្លៃវិសេសម្នាក់
ដែលគេរកឃើញក្នុងព្រះគ្រិស្ទ។
នេះជាសច្ចៈធម៌ដ៏បរិសុទ្ធដែលអាចជួយសង្គ្រោះ
ហើយដែលគេមិនអាចលាក់ទុកក្នុងចិត្តបានឡើយ។
ប្រសិនបើយើងស្អាងខ្លួនដោយសេចក្ដីសុចរិតរបស់ព្រះគ្រិស្ទ
ហើយបានពោរពេញទៅដោយសេចក្ដីអំណរនៃព្រះវិញ្ញាណដ៏បរិសុទ្ធដែលគង់ក្នុងខ្លួន
នោះយើងមិនអាចលាក់ទុកនូវសេចក្ដីនោះដោយស្ងៀមស្ងាត់ក្នុងចិត្តយើងបានឡើយ។ ប្រសិនបើយើងសាកល្បង

ហើយដឹងថាព្រះវរបិតាជាព្រះដ៏ល្អបរិសុទ្ធ
នោះយើងពិតជាមានដំណឹងល្អសម្រាប់ប្រាប់អ្នកដទៃជាប្រាកដ។
យើងត្រូវធ្វើឲ្យដូចជាលោកហ្វីលីពនៅពេលដែលគាត់បានរកឃើញព្រះ
នោះគាត់បានអញ្ជើញអ្នកដទៃទៀតឲ្យចូលមកចំពោះវត្តមានរបស់ទ្រង់ដែរ។
យើងគួរតែខិតខំបង្ហាញឲ្យគេឃើញនូវការគួរឲ្យចាប់អារម្មណ៍របស់ព្រះគ្រិស្ទ
និងសច្ចៈធម៌ពីការអាថ៌កំបាំងផងទាំងឡាយពីអាណាចក្រដែលនឹងលេចមកពេលខាងមុខ។
គេនឹងមានចំណង់យ៉ាងខ្លាំងក្លាដើរតាមគន្លងផ្លូវដែលព្រះយេស៊ូគ្រិស្ទបានយាង។ យើងចង់បានយ៉ាងស្មោះត្រង់
និងឃើញអ្នកដែលនៅជុំវិញយើងស្រែកឧទានឡើងដោយពាក្យថា: “នុះហ្ន៎!

កូនចៀមនៃព្រះដែលដោះបាបមនុស្ស
លោក”..យ៉ូហាន១:២៩។

សេចក្តីព្យាយាមរបស់យើងដើម្បីឲ្យអ្ន
កដទៃទៀតបានទទួលព្រះពរ
នោះនឹងផ្តល់ព្រះពរដ៏បរិបូណ៌មកដល់
យើងវិញ។
នេះហើយជាបំណងហឫទ័យរបស់ព្
រះ
ក្នុងការប្រទានដល់យើងនូវចំណែកកា
រងារ
ចំពោះផែនការប្រោសលោះមនុស្សមា
នបាប។
ទ្រង់បានប្រទានឲ្យមនុស្សលោកនូវសិ
ទ្ធដើម្បីឲ្យគេក្លាយជាអ្នករួមចំណែកក្
ងកិច្ចការបរិសុទ្ធរបស់ទ្រង់
ហើយក៏ឲ្យគេអាផ្សព្វផ្សាយនូវព្រះពរ
នេះ ដល់មនុស្សផងទាំងឡាយបាន។

ទាំអនេះគឺជាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ជាអំណោយរីករាយដ៏លើសលប់ដែលព្រះជាម្ចាស់
ប្រទានមកដល់មនុស្សលោក។
អ្នកណាដែលរួមចំណែកក្នុងការងារនៃសេចក្ដីស្រលាញ់
អ្នកនោះបានឈានចូលទៅទៀបនឹងព្រះដ៏បង្កើតលោករបស់គេហើយ។

ព្រះជាម្ចាស់អាចនឹងចាត់ពួកទេវតានៃនគរស្ថានសួគ៌
ឲ្យបំពេញការងារដំណឹងល្អនេះឬក៏អាចមានមធ្យោបាយផ្សេងៗទៀតក្នុងការសម្រេចព្រះរាជបំណងរបស់ទ្រង់បាន ប៉ុន្តែដោយសារសេចក្ដីស្រលាញ់ដ៏ឥតព្រំដែនចំពោះមនុស្សបានជា
ទ្រង់ជ្រើសតាំងឲ្យយើងក្លាយជាសហាសេវិកជាមួយនឹងទ្រង់ជាមួយព្រះគ្រិស្ទ

និងពពួកទេវតារបស់ទ្រង់
ប្រយោជន៍ឲ្យយើងអាចទទួលនូវព្រះព
រ
សេចក្តីអំណរនិងចំរើនខាងផ្លូវព្រះវិញ្ញា
ណ
ដែលជាលទ្ធផលនៃការងារដ៏សប្បុរស
ជ្រះថ្លា។

យើងមានសមានចិត្តអាណិតអាសូររួម
ជាមួយព្រះគ្រិស្ទ
តាមរយៈការរួមចំណែកជាមួយក្តៅលំ
បាកវេទនារបស់ព្រះអង្គ។
គ្រប់កិច្ចការដែលយើងធ្វើដោយគ្មានគិ
តពីផលប្រយោជន៍ផ្ទាល់ខ្លួនដើម្បីសេ
ចក្តីល្អនៃអ្នកដទៃ
បានចំរើនកំលាំងវិញ្ញាណក្នុងចិត្តអ្នក
ដែលធ្វើ
ហើយក៏មានសម្ព័ន្ធភាពយ៉ាងជិតស្និទ្ធ

នឹងព្រះថៃមទៀតទៅនឹងងព្រះដ៏ប្រោសលោកដែល
“ទ្រង់ជាអ្នកមានតែទ្រង់បានត្រឡប់ជាក្រដោយព្រោះអ្នករាល់គ្នា
ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង
ដោយសាសេចក្ដីក្រលំបាករបស់ទ្រង់”
..កូរិនថូស២ ៨:៩។ “
គឺមានតែយើងរាល់គ្នា
បំពេញតាមបំណងហឫទ័យនៃព្រះជាម្ចាស់ដែលបានបង្កើតយើងមកនោះ
ទើបជីវិតអាចជាព្រះពរដល់យើងបាន”
។

ប្រសិនបើយើងនឹងធ្វើកិច្ចការដូចដែលព្រះជាម្ចាស់បានរៀបចំឡើង
ចំពោះសាវ័ករបស់ទ្រង់
ហើយបាននាំមនុស្សមកកាន់ព្រះអង្គ
អ្នកនឹងយល់ថាអ្នកត្រូវការពិសោធន៍ដ៏

ជ្រាលជ្រៅ
និងចំណេះវិជ្ជាដ៏ទូលំទូលាយក្នុងកិច្ចការរបស់ព្រះជាម្ចាស់
ហើយអ្នកក៏នឹងស្រេកឃ្លានចង់បានសេចក្តីសុចរិត។
អ្នកនឹងអង្វករជាមួយនឹងព្រះជាម្ចាស់
ហើយសេចក្តីជំនឿរបស់អ្នកកាន់តែរីកចំរើនឡើងផង។
ព្រលឹងអ្នកនឹងក្រេបយកទឹកជីវិត
អំពីអណ្តូងនៃសេចក្តីសង្គ្រោះ។
ដោយប្រឈមមុខនឹងការផ្លាញ់ផ្លាល
និងការសោកល្បង
នោះនឹងជំរុញឲ្យអ្នកមើលព្រះគម្ពីរ
នឹងអធិស្ឋានទៅរកព្រះ។
អ្នកនឹងចំរើនលូតលាស់នៅក្នុងព្រះគុណ
និងបទពិសោធន៍ហើយនឹងបានស្គាល់

ព្រះយេស៊ូគ្រិស្ទកាន់តែច្បាស់ឡើងថែមទៀត។

ការដែលធ្វើការបំរើអ្នកដទៃដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនជួយឲ្យចរិយាឲ្យមានលំនឹង
សេចក្តីស្រលាញ់ដ៏ជ្រាលជ្រៅ
ស្មោះភាពនិងសេចក្តីស្រលាញ់ដែលមានលក្ខណៈដូចជាព្រះគ្រិស្ទ
ព្រមទាំងនាំមកនូវសេចក្តីសុខសន្តិភាពនិងអំណររីករាយដែលអ្នកបានជួយគេនោះផងដែរ។
សេចក្តីប៉ងប្រាថ្នាកាន់តែប្រពៃឡើង
ហើយគ្មានកន្លែងណាសម្រាប់ភាពកំជិល និងភាពទ្រឹស្ទរឡើយ។
អ្នកណាដែលយកព្រះគុណមកអនុវត្តន៍ក្នុងជីវិត
ដោយភាពជាអ្នកគ្រិស្ទាននោះនឹងល្ងូត

លាស់ឡើងហើយ
កាន់តែរឹងមាំឡើងដើម្បីធ្វើការបំរើព្រះ
ជាម្ចាស់។
គេនឹងមានការយល់ដឹងខាងព្រលឹងវិ
ញ្ញាណកាន់តែច្បាស់ឡើង
សេចក្តីជំនឿរីកលូតលាស់នឹងមានស្ថេ
រភាព
និងភាពចំរើនអំណាចនៅក្នុងសេចក្តីអ
ធិស្ឋាន។ ព្រះវិញ្ញាណនៃព្រះអម្ចាស់
នឹងគ្រប់គ្រងលើវិញ្ញាណរបស់
គេ
រួចបណ្តាលឲ្យមានការចុះសំរុងដ៏បរិសុ
ទ្ធនៃព្រលឹងរបស់គេឆ្លើយតបនឹងការដ
ង្ហោយហៅរបស់ព្រះ។អ្នកណាដែល
លះបង់ខ្លួនដើម្បីបំរើកិច្ចប្រឹងប្រែងដោ
យក្តីជ្រះថ្លាដើម្បីអំពើល្អនៃអ្នកដទៃ
នោះគឺកំពុងញ៉ាំងឲ្យសេចក្តីសង្គ្រោះរ
បស់ខ្លួនផ្ទាល់ប្រាកដឡើងជាទីបំផុត។

ផ្លូវតែមួយគត់ដើម្បីឲ្យបានចំរើនក្នុងព្រះគុណ
គឺធ្វើការងារមួយដែលយើងមិនចង់ធ្វើ
ប៉ុន្តែជាកិច្ចការដែលព្រះគ្រិស្ទបានបន្ទុកបណ្ដាក់មកលើយើង
ចូរតាំងចិត្តធ្វើការនោះដោយខំអស់ពីសមត្ថភាព
ដើម្បីផ្ដល់ព្រះពរដល់អ្នកដែលត្រូវការសេចក្ដីជំនួយហើយដែលយើងអាចជួយបាន។
កម្លាំងកើនឡើងដោយការហាត់ប្រាណ
សកម្មភាពគឺជាលក្ខណដ៏សំខាន់សម្រាប់ជីវិត។
អ្នកណាដែលប្រឹងប្រែងរក្សានូវលក្ខណៈជាអ្នកគ្រិស្ទាន
ដោយគ្រាន់តែចាំទទួលព្រះពរតាមរ

យៈព្រះគុណ
ហើយពុំធ្វើការអ្វីសោះសម្រាប់ព្រះគ្រិស្ទ
នោះគឺដូចជាអ្នកដែលរស់នៅសម្រាប់
តែបរិភោគតែប៉ុណ្ណោះ។
ខាងឯព្រលឹងវិញ្ញាណវិញ
ក៏ដូចគ្នានឹងធម្មជាតិដែរ..សភាពបែប
នេះតែងតែផ្តល់នូវភាពវិចវិល ដុនដាប
និងសេចក្តីហិនវិនាស។
មនុស្សដែលពុំព្រមហាត់ប្រាណ
ដៃជើងរបស់គេនឹងបាត់បង់នូវថាមព
លសម្រាប់ធ្វើចលនា។

យ៉ាងណាមិញអ្នកគ្រិស្ទានដែលពុំព្រម
បញ្ចេញ
នូវអំណាចដែលព្រះជាម្ចាស់ប្រគល់ឲ្យ
នោះគេមិនត្រឹមតែមិនល្អតលាស់នៅក្នុ
ងព្រះគ្រិស្ទប៉ុណ្ណោះទេ

គឺថែមទាំងបាត់បង់នូវអំណាចដែលគេ
មានមកហើយនោះផង។

ព្រះវិហាររបស់ព្រះគ្រិស្ទគឺជាទីកន្លែង
ដែលព្រះជាម្ចាស់បានចាត់តាំងឡើង
ដើម្បីជាសេចក្តីសង្គ្រោះចំពោះមនុស្ស
លោក។បេសកកម្មរបស់ព្រះវិហារគឺនាំ
ដំណឹងល្អទៅកាន់លោកិយទាំងមូល។
រីឯកាតព្វកិច្ចគឺស្ថិតលើអ្នកគ្រិស្ទានគ្រ
ប់ៗរូប។
មនុស្សម្នាក់ដែលមានទេពកោសល្យនិ
ង និងពេលវេលាដែលអាចធ្វើទៅបាន
គឺត្រូវបំពេញការងារដែលព្រះជាម្ចាស់
ទ្រង់បានបន្ទុកបណ្តាក់ឲ្យ។
សេចក្តីស្រលាញ់របស់ព្រះគ្រិស្ទ
ដែលបានបង្ហាញដល់យើងរាល់គ្នា
ធ្វើឲ្យយើងជាអ្នកជំពាក់ដំណឹងល្អ
ចំពោះមនុស្សទាំងឡាយដែលមិនទាន់

បានស្គាល់ព្រះនាមទ្រង់។
ព្រះជាម្ចាស់បានប្រទានពន្លឺឲ្យយើងរាល់គ្នានោះគឺមិនមែនសម្រាប់តែយើងម្នាក់ប៉ុណ្ណោះទេ
គឺសម្រាប់ចែកចាយដល់អ្នកដទៃផងដែរ។

ប្រសិនបើអ្នកដែលដើរតាមព្រះយេស៊ូយល់ដឹងនូវករណីកិច្ចរបស់ខ្លួន
នោះនឹងមានមនុស្សរាប់ពាន់នាក់ជាអ្នកប្រកាសដំណឹងល្អ
នៅឯដែនដីហ៊ីថែន
(គឺជាដែនដីដែលមិនទាន់ស្គាល់ព្រះនាមព្រះ)ដែលឥឡូវនេះមានតែម្នាក់ប៉ុណ្ណោះ។
ហើយចំពោះអ្នកដែលមិនអាចចូលរួមដោយផ្ទាល់ខ្លួនក្នុងការងារនេះបាន
គេនឹងជួយគាំទ្រជាមធ្យោបាយផ្សេងៗ

និងការអធិស្ឋានរបស់គេ។
នោះនឹងមានការងារដ៏ស្មោះត្រង់អំពីចិត្ត
ចំរើនឡើងដើម្បីជួយដល់ព្រលឹងអ្នកឯទៀតនៅក្នុងប្រទេសដែលកាន់សាសនាព្រះយេស៊ូគ្រិស្ទ(ប្រទេសដែលមានអ្នកគ្រិស្ទានភាគច្រើន)។

យើងមិនចាំបាច់ទៅឯប្រទេសដែលមិនស្គាល់ព្រះ
ឬក៏ចាកចេញពីរង្វង់នៃគ្រួសារតូចរបស់យើងដើម្បីធ្វើការថ្វាយព្រះគ្រិស្ទ
នោះទេ
ប្រសិនបើអំពើទាំងនោះជាករណីកិច្ចរបស់យើងក្នុងកិច្ចការថ្វាយព្រះ។
យើងអាចបំពេញកាងារទាំងនោះនៅក្នុងរង្វង់គ្រួសារ នៅក្នុងព្រះវិហារ
ក្នុងចំណោមអ្នកឯណាដែលយើងរាប់

អាន
ទាក់ទងជាមួយអ្នកឯណាដែលយើងប្រកបរបរជាមួយគ្នា។
ជីវិតមួយផ្នែកធំរបស់ព្រះអង្គសង្គ្រោះនៃយើងនៅលើផែនដីនេះ
ទ្រង់បានចំណាយក្នុងការអត់ធ្មត់ក្នុងរោងជាងឈើឯស្រុកណាសារ៉ែត។
ទេវតានៃជំនឹងល្អបាននៅជាមួយព្រះអង្គដែលជាម្ចាស់ជីវិតនៅពេលដែលទ្រង់យាងជាមួយអ្នកស្រែចំការ
គូលីកម្មករ ដោយគ្មាននរណាស្គាល់ និងគ្មានអ្នកណាសរសើរលើកតំកើងទ្រង់។
ទ្រង់បំពេញកិច្ចការរបស់ទ្រង់នៅឯរោងជាងឈើដោយព្រះទ័យស្មោះត្រង់ក៏ដូចជាពេលដែលទ្រង់បានព្យាបាលមនុស្សមានជំងឺឲ្យបានជា
ឬនៅពេលដែលទ្រង់បានយាងកាត់

លើរលកគ្រាំគ្រេង
ដោយព្យុះនៅឯបឹងកាលីឡេ។
ដូច្នេះនៅក្នុងកិច្ចការដ៏ទន់ទាបបំផុត
និងឋានៈតូចតាចនៅក្នុងជីវិតនេះ
ក៏យើងអាចដើរតាមព្រះគ្រិស្ទ
និងបំពេញការងារជាមួយទ្រង់បានដែរ
។

សាវ័កទ្រង់បានមានប្រសាសន៍ថា
“ចំពោះមនុស្សគ្រប់ៗរូបក្នុងការដែលទ្
រង់បានហៅមក
នោះត្រូវតែនៅជាប់ជាមួយនឹងទ្រង់”
..កូរិនថូស១ ៧:២៤។ បុគ្គលិក
និយោជិតត្រូវបំពេញការងាររបស់គេ
តាមរបៀបរបបដែលលើកតំកើងដល់
ម្ចាស់
ដោយសារភាពស្មោះត្រង់របស់គេ។
ប្រសិនបើគេជាអ្នកដើរតាមព្រះគ្រិស្ទដ៏

ពិតប្រាកដមែនគេនឹងយកសាសនារបស់គេទៅគ្រប់កិច្ចការទាំងឡាយដែលគេធ្វើហើយក៏នឹងសំដែងឲ្យមនុស្សទាំងឡាយឃើញនូវវិញ្ញាណរបស់ព្រះគ្រិស្ទ។ យន្តការ
ក៏អាចជាអ្នកតំណាងដ៏ស្មោះត្រង់
និងដ៏យកចិត្តទុកដាក់ដល់ព្រះគ្រិស្ទជាម្ចាស់ដែលបានប្រកបការងារដ៏ទន់ទាបនៅឯជ្រលងភ្នំក្នុងស្រុកកាលីឡេ។
អ្នកណាដែលទទួលព្រះនាមរបស់ព្រះគ្រិស្ទ
គួរបំពេញកិច្ចការដើម្បីឲ្យអ្នកដទៃបានឃើញនូវអំពើដ៏ល្អទាំងនេះ
ដែលអាចនឹងសរសើរតំកើងព្រះដ៏បង្កើតលោក
និងព្រះអម្ចាស់ដ៏ប្រោសលោះនៃយើងរាល់គ្នា។

—
មានមនុស្សជាច្រើនបានយកលេសគេច
វេសពីការងារថ្វាយព្រះ
ពីព្រោះឃើញអ្នកឯទៀតមានលក្ខ
ណៈសម្បត្តិ និងមានរបៀបជាងខ្លួន។
គំនិតគេបានជំរុញឲ្យគិតថា
មានតែអ្នកដែលមានទេពកោសល្យខ្ព
ស់ទេដែលតម្រូវឲ្យសំអិតសំអាងសម
ត្ថិភាពរបស់ខ្លួនឲ្យបរិសុទ្ធ
ដើម្បីការងារថ្វាយព្រះជាម្ចាស់។
មនុស្សជាច្រើនហាក់ដូចជាយល់ថាព្
រះទ្រង់ប្រទានទេពកោសល្យ
ឲ្យតែមនុស្សមួយក្រុមដែលមានវណ្ណៈ
ខ្ពស់តែប៉ុណ្ណោះ

រីឯអ្នកផ្សេងទៀត
គឺព្រះមិនបានដាក់បញ្ចូលឲ្យរួមចំណែ
កនៅក្នុងការងារនិងការទទួលរង្វាន់ទេ

។
គំនិតដូច្នេះគឺពុំមានសំដែងនៅក្នុងរឿង
ប្រៀបបរដូចនៅក្នុងព្រះគម្ពីរទេ។
នៅពេលដែលម្ចាស់ផ្ទះបានហៅបាវបំ
រើរបស់លោកឲ្យចេញមក
គាត់បានប្រគល់ដល់មនុស្សគ្រប់ៗគ្នា
។

ដោយសេចក្តីស្រលាញ់
យើងអាចបំពេញការងារសាមញ្ញមួយ
បាន “ដូចជា
ព្រះជាម្ចាស់បានធ្វើដូច្នេះដែរ”
..កូលុស
៣:២៣។ប្រសិនបើសេចក្តីស្រលាញ់
នៃព្រះសណ្ឋិតនៅក្នុងចិត្ត
សេចក្តីស្រលាញ់នោះនឹងសំដែងឲ្យ
ឃើញនៅក្នុងជីវិតរបស់គេ។
បារមីស្រទន់នៃព្រះគ្រិស្ទនឹងគ្របដណ្តា

ប់យើង
ហើយឥទ្ធិពលរបស់យើងនឹងកើនឡើងប្រកបដោយព្រះពរ។

លោកអ្នកមិនត្រូវរងចាំដល់ឱកាសដ៏ទូលំទូលាយ
ឬសង្ឃឹមទៅលើសមត្ថភាព
ដ៏អស្ចារ្យមុនពេលលោកអ្នកចាប់ផ្តើមធ្វើការថ្វាយទ្រង់នោះទេ។
ហើយលោកអ្នកមិនត្រូវមានគំនិតឆ្ងល់អំពីលោកិយថាតើវានឹងគិតយ៉ាងណាអំពីរូបអ្នកឡើយ។
ប្រសិនបើជីវិតប្រចាំថ្ងៃរបស់អ្នកបានជាទីបន្ទាល់នៃភាពបរិសុទ្ធ
និងស្មោះត្រង់នៃសេចក្តីជំនឿ
ហើយអ្នកឯទៀតយល់ថាបំណងរបស់អ្នកគឺផ្តល់សារៈប្រយោជន៍ដល់រូបគេ

នោះការប្រឹងប្រែងរបស់លោកអ្នកពិតជាមិនបាត់បង់ទាំងស្រុងឡើយ។

សាវ័កដ៏សុភាពរាបសា និងក្រីក្រជាទីបំផុតរបស់ព្រះគ្រិស្ត ក៏អាចក្លាយជាព្រះពរចំពោះអ្នកដទៃបានដែរ។ គេប្រហែលជាមិនយល់ច្បាស់ថាគេបានធ្វើការងារដ៏ល្អពិសេសណាមួយទេ ក៏ប៉ុន្តែដោយសារឥទ្ធិពលរបស់គេមិនបានដឹងខ្លួនគេអាចបង្កើតនូវព្រះពរដ៏លើសលប់ដែលនឹងរីកធំឡើង និងជ្រាលជ្រៅឡើង ហើយគេពុំបានដឹងនូវលទ្ធផលនោះរហូតដល់ថ្ងៃទទួលរង្វាន់ចុងក្រោយបង្អស់។ គេមិនចាប់អារម្មណ៍ ឬដឹងថាគេធ្វើការងារដ៏ធំធេងនោះទេ។ គេមិនចាំបាច់ត្រូវការព្រួយបារម្ភអន្ទះ

សារពីជោគជ័យនោះឡើយ។
ការដែលគេត្រូវធ្វើនោះគឺ
បោះជំហានទៅមុខដោយស្មៀមស្ងាត់
ធ្វើការដែលព្រះជាម្ចាស់ប្រគល់ឲ្យសេ
ចក្ដីស្វាមីភក្ដិ
ហើយជីវិតរបស់គេពិតជាមានអត្ថន័យ
និងខ្លឹមសារជាទីបំផុត។
ព្រលឹងនិងព្រះវិញ្ញាណរបស់គេនឹងរីក
ចំរើនឡើងទៅកាន់ភាពល្អប្រសើររប
ស់ផងព្រះគ្រិស្ដកាន់តែខ្លាំងឡើង។
គេនឹងធ្វើការរួមគ្នាជាមួយព្រះជាម្ចាស់
ក្នុងជីវិតនេះ
ហើយសក្ដសមនឹងការងារដ៏ខ្ពង់ខ្ពស់
ថែមទៀត និងអំណររីករាយ
ដ៏ពិតប្រាកដក្នុងជីវិតដែលនឹងមកដល់
។

# ជំពូក ១០ — ការស្គាល់ព្រះ

មានមធ្យោបាយជាច្រើនដែលព្រះជាម្ចាស់ព្យាយាមសំដែងអង្គទ្រង់ឲ្យយើងរាល់គ្នាបានស្គាល់ទ្រង់ ដើម្បីឲ្យយើងបានចូលរួមសម្ព័ន្ធរបស់ទ្រង់។ ធម្មជាតិបានសំដែងមកកាន់វិញ្ញាណអារម្មណ៍របស់យើងឥតឈប់ឈរ។ ទ្វារចិត្តដែលបើកចំហរនឹងចាប់អារម្មណ៍ទៅលើសេចក្តីមេត្រីនៃព្រះ និងសិរីល្អរបស់ផងទ្រង់ដែលបានបើកសំដែង តាមរយៈស្នាព្រះហស្តរបស់ទ្រង់។ ត្រចៀកដែលត្រងចាំនឹងស្តាប់លឺ ហើយបានឮទំនាក់ទំនងនាំព្រះតាមរយៈធម្មជាតិ។ វាលស្រែដ៏ខៀវស្រងាត់

ដើមឈើខ្ពស់ស្រោងពន្លក
និងផ្កាដែលរីក ដុំពពកដែលរសាត់
គ្រាប់ភ្លៀងដែលធ្លាក់ចុះលើផែនពសុធា សម្លេងថ្ងូចថ្ងូរនៃទឹក
សិរីល្អនៃនគរស្ថានសួគ៌
របស់ទាំងនេះស្រដីមកកាន់ចិត្តយើង
ហើយបានណែនាំឲ្យយើងបានស្គាល់
ព្រះគឺព្រះដែលបានបង្កើតរបស់ទាំងនោះមក។

ព្រះអង្គសង្គ្រោះបានផ្សារភ្ជាប់មេរៀនដ៏ថ្លៃថ្លារបស់ទ្រង់ទៅនឹងរបស់ទាំងឡាយនៃធម្មជាតិ។ រុក្ខជាតិ បក្សាបក្សី
បុប្ផានៃជ្រលងភ្នំ ភ្នំតូចៗ ទន្លេ ស្ទឹង
អាកាសវេហាស៍ដ៏ស្រស់ត្រកាល
ក៏ដូចជាឧប្បត្តិហេតុ
និងបរិយាកាសនៃជីវិតប្រចាំថ្ងៃ
គឺបានភ្ជាប់នឹងព្រះបន្ទូលនៃសច្ចៈធម៌

ដែលធ្វើឲ្យយើងរឮកនឹកឃើញនៅក្នុងអារម្មណ៍ទោះជានៅពេលដែលមមាញឹកក្នុងការងារលំបាកនឿយហត់នៃជីវិតយ៉ាងណាក៏ដោយ។

ព្រះជាម្ចាស់ចង់ឲ្យរាស្រ្ដរបស់ទ្រង់សរសើរតំកើងពីស្នាដៃរបស់ទ្រង់ ព្រមទាំងមានអំណរនឹងសោភ័ណភាពដ៏សាមញ្ញ និងស្ងប់ស្ងាត់ ដែលទ្រង់បានលំអរទីលំនៅរបស់យើងនៅលើផែនដីនេះ។ ព្រះអង្គសព្វព្រះហឫទ័យនឹងអ្វីៗដែលល្អហើយលើសពីគ្រឿងទាក់ទាញអារម្មណ៍ខាងក្រៅនេះទៅទៀត ទ្រង់សព្វព្រះហឫទ័យដ៏លើសលន់លើសោភ័ណភាពនៃអត្តចរិក(ភាពលំអរឮដ៏ខាងក្នុងនៃមនុស្ស)។

ទ្រង់ចង់ឲ្យយើងបណ្តុះ ភាពបរិសុទ្ធ
ភាពសាមញ្ញ
និងភាពដ៏ស្ងប់ស្ងាត់នៃបុប្ផាជាតិ។
បើយើងនឹងស្តាប់ដោយយកចិត្តទុកដា
ក់ នោះសមិទ្ធិផលទាំងឡាយនៃព្រះ
នឹងបង្រៀនយើងនូវមេរៀនដ៏មានតម្លៃ
អំពីការស្តាប់បង្គាប់
និងការទុកចិត្តដល់ព្រះ។

ចាប់តាំងពីហ្វូងតារានិករទាំងឡាយ
មិនទាន់ដើរតាមគន្លងនៅក្នុងលំហអា
កាស
ពីយុគសម័យមួយទៅយុគសម័យ
ដរាបដល់មានគន្លងជាក់លាក់របស់វារ
ហូតដល់អាតូមដ៏តូចបំផុត
នោះបានបង្ហាញថាគ្រប់វត្ថុនៃធម្មជាតិ
គោរពតាមព្រះហឫទ័យនៃព្រះជាស្ថា
បត្យករ។

ព្រះអង្គថែរក្សានិងបំប៉នរបស់សព្វសារពើដែលទ្រង់បានបង្កើតមក។
ព្រះអង្គជាម្ចាស់ដែលទ្រទ្រង់គ្រប់ទាំងពិភពនានា
ដ៏រាប់មិនអស់នៅលើលោកសន្និវាសដ៏ធំធេងនេះ។
នៅពេលជាមួយគ្នានេះដែរ
ព្រះទ្រង់បំពេញសេចក្តីត្រូវការរបស់កូនបក្សីដ៏តូចមួយ
ដែលច្រៀងចម្រៀងពិរោះដោយគ្មានសេចក្តីភ័យខ្លាចដែរ។
នៅពេលដែលមនុស្សចេញទៅបំពេញកិច្ចការប្រចាំថ្ងៃ
នៅពេលដែលគេកំពុងអធិស្ឋាន
នៅពេលចូលដំណេក នៅវេលារាត្រី
ពេលភ្ញាក់ពីព្រលឹមពេលដែលអ្នកមានគេបរិភោគបាយហៀរក្នុងវិមានរបស់គេ
ឬក៏នៅពេលដែលអ្នកក្រទុរគតិប្រមូល

កូនចៅរបស់ខ្លួនមកបរិភោគអាហារដែល មានបន្តិចបន្តួច
នោះព្រះនៃនគរស្ថានសួគ៌ទ្រង់បានទតឃើញគ្រប់សកម្មភាពទាំងនោះដោយព្រះហឫទ័យមេត្រីដ៏ស្រទន់។
គ្មានដំណក់ទឹកភ្នែកណាដែលហូរ ដែលព្រះជាម្ចាស់ពុំបានកត់សម្គាល់ទេ។

ប្រសិនបើយើងជឿជាក់នឹងការនឹងនោះយើងនឹងបំភ្លេចចោលការអន្ទះសារមុនពេលដល់កំណត់ចោលចេញ។
ជីវិតយើងឥឡូវនេះក៏មិនផ្ទុកដោយការខកចិត្តព្រោះគ្រប់អ្វីៗទាំងអស់នោះតូចក្តីធំក្តី
បានថ្វាយដាច់ដាក់ក្នុងព្រះហស្តទ្រង់ហើយក៏មិនមានការស្មុគស្មាញចំពោះ

ការងារដ៏ច្រើនឥតគណនា
ឬក៏ស្លុតចំពោះទំងន់ការងារនោះទ្បើ
យ។
ពេលនេះយើងគួរតែអរសប្បាយចំ
ពោះការសម្រាកខាងព្រលឹងវិញ្ញាណ
ដោយមនុស្សជាច្រើនមិនទាន់បានទទួ
ល
ហើយនៅតែជាអ្នកដទៃចំពោះការនេះ
។
ក្នុងខណៈវិញ្ញាណារម្មណ៍របស់លោក
អ្នកត្រេកត្រអាលនឹងផែនដីដ៏ល្អជាប់ចិ
ត្តនេះសូមពិចារណាដល់ពិភពដែលនឹ
ងមកដល់
ជាពិភពដែលមិនយល់ពីអំពើបាប
និងសេចក្តីស្លាប់
ជាទីធម្មជាតិអស់មានបណ្តាសា។
សូមឲ្យលោកអ្នកគិតគូរក្នុងអារម្មណ៍ឲ្
យចេញជារូបភាព

និងឃើញលំនៅដ្ឋានរបស់ពួកដែលបា
នទទួលសេចក្តីសង្គ្រោះហើយសូមឲ្យ
នឹកចាំថា
ធាតុពិតនៃពិភពនេះនឹងប្រកបដោយ
ភាពរុងរឿង លើសជាងការស្រមៃ
គិតរបស់លោកអ្នកទៅទៀត។
ក្នុងបណ្តាអំណោយទានផងទាំង
ឡាយដែលព្រះជាម្ចាស់បានប្រទានក្នុ
ងធម្មជាតិ
យើងមើលឃើញពន្លឺដ៏ចាំងចែងនៃសិរី
ល្អនៃព្រះជាម្ចាស់បានយ៉ាងស្តួចស្តើង
បំផុត។ ក្នុងព្រះគម្ពីកូរិនថូស១ ជំពូក២
ខ៩បានចែងថា
“សេចក្តីដែលភ្នែកមិនបានឃើញ
ត្រចៀកមិនដែលបានឮ
និងចិត្តដែលមិនបាននឹកដល់
គឺសេចក្តីនោះឯងដែលព្រះបានរៀបចំ

ទុកសម្រាប់ពួកអ្នកដែលស្រលាញ់ទ្រង់។” ។

ពួកកវី
និងធម្មជាតិវិទូបានបរិយាយយ៉ាងច្រើនអំពីធម្មជាតិ
ក៏ប៉ុន្តែមានតែអ្នកគ្រិស្ទាន
ដែលមានអំណររីករាយចំពោះសោភ័ណភាពនៃផែនដី
ដោយការដឹងគុណដ៏ក្រៃលែង
ពីព្រោះគេបានទទួលស្គាល់នូវស្នាព្រះហស្តរបស់ព្រះជាម្ចាស់
និងឃើញសេចក្តីស្រលាញ់របស់ទ្រង់តាមរយៈបុប្ផាជាតិ ព្រៃព្រឹក្សា
និងរុក្ខជាតិ។
គ្មាននរណាម្នាក់អាចសំដែងសេចក្តីអំណរសរសើរឲ្យបានពេញលេញដល់សារៈសំខាន់នៃភ្នំទាំងឡាយ ជ្រោះ

ជ្រុង ទន្លេ បឹងបួរ និងសមុទ្រឡើយ ប្រសិនបើគេពុំយល់ថារបស់អស់ទាំងនេះគឺជាការសម្តែងនៃសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោកទេនោះ។

ព្រះជាម្ចាស់មានបន្ទូលមកកាន់យើងតាមរយៈកិច្ចការដែលទ្រង់បានប្រមើលមើលដោយឈ្វេងយល់ជាមុន និងតាមរយៈឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកលើចិត្តយើង។ នៅក្នុងកាលៈទេសៈ និងបរិយាកាសរបស់យើង និងក្នុងការផ្លាស់ប្តូរជារៀងរាល់ថ្ងៃដែលកើតមានឡើងនៅជុំវិញយើងៗ អាចរកឃើញនូវមេរៀនដ៏មានតម្លៃប្រសិនបើយើងបើកចំហរទទួលយកមេរៀនទាំងនោះ។

ពួកអ្នកលើកទំនុកតំកើងព្រះដែល
តាមដានការងាររបស់ទ្រង់បានប្រទាន
ដល់មនុស្សនោះបានពោលថា:
“ផែនដីមានពោរពេញទៅដោយសេច
ក្តីសប្បុរសនៃព្រះយេហូវ៉ា”
..ទំនុកតំកើង៣៣:៥។
“បើអ្នកណាមានប្រាជ្ញានោះនឹងរក្សាទុ
កនូវសេចក្តីទាំងនេះ
ហើយនឹងពិចារណាពីសេចក្តីសប្បុរស
របស់ព្រះយេហូវ៉ា”..ទំនុកតំកើង
១០៧:៤៣។

ព្រះជាម្ចាស់មានបន្ទូលមកកាន់យើង
ដោយព្រះបន្ទូលរបស់ទ្រង់។
ពេលនេះយើងបានយល់កាន់តែច្បាស់
ឡើងថែមទៀត
នូវការបើកសំដែងអំពីលក្ខណៈសម្បត្តិ
របស់ព្រះអង្គ

អំពីទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្ស
និងការងារដអស្ចារ្យក្នុងការប្រោសលោះយើងរាល់គ្នា។

ប្រវត្តិសាស្រ្តអំពីពួកចាស់ព្រឹទ្ធាចារ្យពួកហោរា
និងពួកវិសុទ្ធពីសម័យបុរាណបានបើកចំហនៅនឹងមុខយើង។
ពួកគេទាំងនោះក៏ជាមនុស្ស
"ដែលមានអារម្មណ៍ចិត្តគំនិតដូចយើងរាល់គ្នាដែរ" ..យ៉ាកុប ៥:១៧។
គេមានការតស៊ូយ៉ាងណាខ្លះនៅពេលដែលខូចទឹកចិត្តដូចដែលយើងធ្លាប់មាន។
យើងក៏ឃើញដែរនៅពេលដែលគេធ្លាក់ចុះក្នុងសេចក្តីល្បួងដូចយើងបានឆ្លងកាត់មកហើយ

ប៉ុន្តែគេបានតាំងចិត្តឡើងវិញ ហើយដណ្តើមជ័យជំនះតាមរយៈព្រះគុណនៃព្រះជាម្ចាស់។ ដោយសម្លឹងមើលទៅអ្នកនោះ យើងក៏បានពង្រឹងសេចក្តីក្លាហានក្នុងការប្រឹងប្រែងរកសេចក្តីសុចរិតរបស់យើង។ ដូច្នេះនៅពេលដែលយើងអានពីបទពិសោធន៍ដ៏មានតម្លៃរបស់គេ អំពីពន្លឺ និងសេចក្តីស្រលាញ់ និងព្រះពរដែលគេបានទទួលដោយសេចក្តីអំណររីករាយ ហើយនិងអំពីការងារដែលគេបានធ្វើឲ្យមានជារូបរាងឡើងតាមរយៈព្រះគុណដែលបានផ្តល់ឲ្យគេ នោះព្រះវិញ្ញាណដែលបណ្តាលចិត្តគេ នឹងបណ្តាលចិត្តយើងប្រៀបដូចជាភ្លើងដែលឆេះឡើងយ៉ាងសន្ធោរសន្ធៅក្នុ

ងចិត្ត
ហើយឲ្យមានចំណង់ត្រាបតាមភាពបរិសុទ្ធនិងអត្តចរិករបស់ព្រះ..ដូចជាពួកសាវ័កដែលដើរជាមួយនឹងទ្រង់ដូច្នេះដែរ។

ព្រះយេស៊ូមានព្រះបន្ទូលពីគម្ពីរសញ្ញាចាស់ហើយកើតក្នុងសញ្ញាថ្មីមានភាពពិតនោះលើសជាងប៉ុណ្ណាទៅ?“គឺជាព្រះគម្ពីរនោះឯងដែលជាទីបន្ទាល់ពីរូបខ្ញុំ”..យ៉ូហាន
៥:៣៩..ជាព្រះដ៏ប្រោសលោះ
ជាព្រះអម្ចាស់ដែលជាសេចក្តីប្រាថ្នាសង្ឃឹមរបស់យើងទៅឯជីវិតដ៏អស់កល្បពឹងផ្អែកលើទ្រង់។
ជាការពិតណាស់ដែលព្រះគម្ពីរទាំងមូលបានរៀបរាប់ប្រាប់យើងអំពីព្រះគ្រិស្ទជាម្ចាស់។

គឺចាប់តាំងពីប្រវត្តិដំបូងនៃការបង្កើត
លោកិយព្រោះថា
“បើគ្មានទ្រង់ក៏គ្មានអ្វីនឹងកើតបានឡើ
យ”..យ៉ូហាន១:៣..រហូតទៅដល់សេច
ក្តីសន្យាចុងក្រោយបង្អស់
យើងបានអានអំពីការងាររបស់ទ្រង់និ
ងស្តាប់នូវព្រះបន្ទូលរបស់ព្រះអង្គ
ដែលមានព្រះបន្ទូលថា:
“មើលអញនឹងមក ជាឆាប់”..វិវរណៈ
២២:១២។
ប្រសិនបើលោកអ្នកចង់ស្គាល់ព្រះអង្គ
សង្គ្រោះនោះសូមសិក្សាព្រះគម្ពីរបរិសុ
ទ្ធរបស់ទ្រង់ចុះ។សូមបំពេញចិត្តរបស់
លោកអ្នកដោយនូវព្រះបន្ទូលរបស់ព្
រះជាម្ចាស់។
ព្រះបន្ទូលរបស់ទ្រង់គឺជាទឹកដ៏រស់ដែ
លអាចបំបាត់នូវការស្រេកឃ្លានដ៏ក្រ
ហល់ក្រហាយរបស់លោកអ្នកបាន។

ព្រះបន្ទូលរបស់ទ្រង់គឺជាប៉ុងជីវិតមកពីសួគ៌ា
ព្រះយេស៊ូបានមានព្រះបន្ទូលប្រកាសថា: “បើអ្នករាល់គ្នាមិនបរិភោគសាច់ហើយមិនផឹកឈាមរបស់កូនមនុស្សនោះអ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ”..យ៉ូហាន ៦:៥៣។
ទ្រង់បានពន្យល់ឲ្យយើងដឹងពីទ្រង់ដោយព្រះបន្ទូលថា
“ឯពាក្យដែលខ្ញុំនិយាយទៅនោះត្រូវខាងវិញ្ញាណនិងជីវិតវិញ”
..យ៉ូហាន៦:៦៣។
រូបរាងកាយរបស់យើងបានរឹងមាំឡើងពីអ្វីៗដែលយើងបរិភោគនិងផឹក។
សភាវៈនៃធម្មជាតិ
ក៏ដូចជាសភាវៈនៃព្រលឹងវិញ្ញាណដែរ។ អ្វីៗដែលយើងភាវនាគិត
នឹងផ្តល់សូរសៀង

និងថាមពលដល់ព្រលឹងវិញ្ញាណរបស់
យើង។

ផ្ទៃរឿងនៃការប្រោសលោះគឺជាកិច្ចការ
មួយដែលពពួកទេវតាមានចំណង់នឹង
ពិនិត្យពិចារណា គឺជាទស្សនៈវិទ្យា
និងជាចំរៀងរបស់អ្នកដែលបានប្រោ
សលោះក្នុងយុគសម័យដ៏អស់កល្ប។
ក្នុងខណៈនេះតើវាមិនសមល្មមសម្រា
ប់ការពិចារណានិង
ការសិក្សាដ៏មធ្យ័តទេឬអ្វី?
សេចក្តីមេត្តាករុណា
និងសេចក្តីស្រលាញ់ដ៏គ្មានព្រំដែននៃ
ព្រះយេស៊ូ
ជាដង្វាយដំបូងសម្រាប់រូបយើងដែល
អំពាវនាវឲ្យយើងមានការត្រិះរិះពិចារ
ណាដ៏មុឺងម៉ាត់និងប្រាកដប្រជា។
យើងត្រូវប្រកាន់ខ្ជាប់តាមអត្តចរិកនៃព្

រះដ៏ប្រោសលោះ
និងជាព្រះដែលអង្វរករជំនួសយើងរាល់គ្នា(God the Intercessor)ជាព្រះដ៏ជាទីស្រលាញ់ដល់យើង។
យើងត្រូវតែសញ្ជឹងគិតអំពីបេសកកម្មរបស់ទ្រង់ដែលបានយាងមក
ដើម្បីជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ឲ្យរួចអំពីអំពើបាបរបស់យើង។
នៅពេលដែលយើងសម្លឹងមើលដោយយកចិត្តទុកដាក់នូវអត្ថន័យនៃស្ងួគាសេចក្តីជំនឿនិងសេចក្តីស្រលាញ់របស់យើង នឹងចំរើនមាំឡើង
ហើយការអធិស្ឋានរបស់យើង
នឹងបានជាទីគាប់ព្រះហឫទ័យរបស់ទ្រង់កាន់តែខ្លាំងឡើងៗដែរ
ពីព្រោះការអធិស្ឋានទាំងនោះពោរពេញដោយសេចក្តីជំនឿ

និងសេចក្តីស្រលាញ់។
ការអធិស្ឋាននោះនឹងកាន់តែឈ្លាសវៃ
និងប្រកបដោយចិត្តក្លៀវក្លាថែមទៀត
ផង។
យ៉ាងនោះយើងនឹងមានសេចក្តីទំនុកចិ
ត្តស្និតស្នេរទៅលើព្រះយេស៊ូហើយការ
រស់នៅប្រចាំថ្ងៃ ជីវភាពរស់នៅដោយ
អំណាចរបស់ទ្រង់
ដើម្បីជួយសង្គ្រោះដល់អ្នកដែលវិលម
កឯព្រះយេហូវ៉ាតាមរយៈទ្រង់ផង។

នៅពេលដែលយើងសញ្ជឹងគិតលើភា
ពល្អឥតខ្ចោះនៃព្រះសង្គ្រោះ
នោះយើងនឹងមានចំណង់ចង់បានការ
ផ្លាស់ប្តូរទាំងស្រុង
និងការបង្កើតជាថ្មីទៅក្នុងរូបភាពដ៏ល្អ
បរិសុទ្ធ ស្អាតស្អំរបស់ទ្រង់។
យើងនឹងមានចិត្តស្រេកឃ្លានចង់ឲ្យបា

នដូចជាព្រះជាម្ចាស់យើងសរសើរតំកើង។
នៅពេលដែលយើងគិតដល់ព្រះគ្រិស្ទកាន់តែខ្លាំងឡើងនោះ
យើងនឹងរឹតតែចង់សំដែងប្រាប់អំពីទ្រង់ទៅកាន់អ្នកដទៃ
ហើយនឹងឈរជាតំណាងរបស់ទ្រង់នៅក្នុងលោកិយនេះកាន់តែខ្លាំងក្លាឡើងដែរ។

ព្រះគម្ពីរពុំមែនចារិកទុកមកសម្រាប់តែបណ្ឌិតប៉ុណ្ណោះ
តែផ្ទុយទៅវិញព្រះគម្ពីរបានរៀបចំឡើងសម្រាប់មនុស្សសាមញ្ញទូទៅ។
សច្ចធម៌ដ៏ធំធេងនៃព្រះគម្ពីរដែលមានសារៈសំខាន់ចាំបាច់ចំពោះសេចក្តីសង្គ្រោះ
គឺបានសំដែងមកយ៉ាងច្បាស់ទែង

ដូចជាពន្លឺនាថ្ងៃត្រង់ជាក់ដូច្នោះដែរ ដែលគ្មាននរណាម្នាក់អាចនឹងវង្វេងបានឡើយ
លើកលែងតែអ្នកដែលដើរតាមប្រាជ្ញាកាត់យល់របស់ខ្លួន
ដោយមិនដើរតាមការបើកសម្តែងដ៏ប្រច័ក្សច្បាស់
នូវព្រះរាជហឫទ័យនៃព្រះជាម្ចាស់ប៉ុណ្ណោះ។

យើងមិនគួរត្រងត្រាប់យកទីបន្ទាល់របស់មនុស្សដែលពោលថាព្រះគម្ពីរបង្ហាត់បង្រៀនដូច្នោះ..ប៉ុន្តែយើងត្រូវសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយខ្លួនឯងផ្ទាល់។
ប្រសិនបើយើងអនុញ្ញាតឲ្យអ្នកដទៃទៀត
គិតគូរជំនួសរូបយើងនោះយើងនឹងធ្វើ

ឲ្យកម្លាំងថមថយចុះ
និងការបាត់បង់នូវការប៉ិនប្រសព្វរបស់
យើងផង។
អំណាចដ៏ប្រពៃនៃគំនិតនឹង
ក្រាបក្រិនចុះឱនថយដោយខ្វះការបំ
ពេញសមយុទ្ធ
ហ្វឹកហ្វឺនទៅលើកិច្ចការដែលសមល្មម
ដែលធ្វើទៅបាន
ហើយក៏បណ្តាលឲ្យបាត់បង់សមត្ថភា
ពក្រេបជញ្ជក់យកអត្ថន័យដ៏ជ្រាលជ្
រៅ នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។
គំនិតនឹងរីកចំម្រើនឡើងប្រសិនបើយើ
ងប្រើការ
តាមដានទំនាក់ទំនងនៃអត្ថបទសំខាន់
ៗនៃព្រះគម្ពីរប៊ីបដោយធ្វើការប្រៀប
ធៀបនឹងព្រះបន្ទូលព្រះ ពីមួយទៅមួយ
ហើយកិច្ចការដោយព្រះវិញ្ញាទៅនឹងព្
រះវិញ្ញាណ។

—

គ្មានអ្វីអាចចម្រើនកម្លាំងប្រាជ្ញាស្មារតី
ជាជាងការសិក្សាព្រះបន្ទូលរបស់ព្រះ
ទេ។
គ្មានសៀវភៅឯណាមានឥទ្ធិពលខ្លាំង
ក្លា អាចលើកស្ទួយសតិអារម្មណ៍ផ្តល់
នូវថាមពលដល់សតិបញ្ញា
ដូចជាសច្ចធម៌ដ៏ទូលំទូលាយនិងប្រ
សើរថ្លៃថ្លានៃព្រះគម្ពីរប៊ីបបានឡើយ។
ប្រសិនបើយើងសិក្សាព្រះបន្ទូលរបស់
ព្រះទៅតាមរបៀបដែលគួរនឹងធ្វើនោះ
យើងពិតប្រាកដមានទឹកចិត្តទូលំទូលា
យ អត្តចរិកថ្លៃថ្នូរ
ហើយនឹងមានដ៏ឲស្ថេរភាពក្នុងចំណង់
ប្រាថ្នា
ដែលកម្រនឹងឃើញមាននៅក្នុងសម័
យនេះ។

ការអានព្រះគម្ពីររបស់ព្រះ ដោយភាពប្រញាប់ប្រញាល់ផ្តល់អត្ថប្រយោជន៍បន្តិចបន្តួចប៉ុណ្ណោះដល់អ្នកអាន។ គេអាចអានព្រះគម្ពីរទាំងមូលចប់ក៏ប៉ុន្តែមិនបានឃើញនូវសោភ័ណភាព និងអត្ថន័យទូលំទូលាយនិងជ្រាលជ្រៅនិងសេចក្តីអាថ៌កំបាំងនៃព្រះគម្ពីរឡើយ។មួយវគ្គៗនៃព្រះគម្ពីរត្រូវតែសិក្សារហូតបានយល់ច្បាស់ពីខ្លឹមសារនៃវគ្គនេះនិងទំនាក់ទំនងទៅនឹងផែនការនៃសេចក្តីសង្គ្រោះបានលេចចេញជាភ័ស្តុតាងគឺនឹងមានតម្លៃជាជាងការអានច្រើនជំពូកដោយគ្រាន់តែត្រួសៗគ្មានគោលដៅច្បាស់លាស់នៅក្នុងអារម្មណ៍។ ការធ្វើបែបនេះមិនមានអ្វីចំរើនទេ។

ចូរយកព្រះគម្ពីរជាប់ជាមួយអ្នកជានិច្ច
។
នៅពេលណាដែលលោកអ្នកមានឱកាស
សូមអានព្រះគម្ពីរហើយផ្ដោតអារម្មណ៍របស់អ្នកទៅលើអត្ថបទដែលបានអាននោះ។
សូម្បីតែនៅពេលដែលដើរលំហែរតាមដងវិថី
ក៏លោកអ្នកអាចអានអត្ថបទមួយវគ្គ
ហើយត្រិះរិះពិចារណា
ដោយយកចិត្តទុកដាក់
វគ្គនោះនឹងដក់ជាប់ក្នុងអារម្មណ៍របស់លោកអ្នកជាក់ជាមិនខាន។

— គ្មានគតិបណ្ឌិតណា
ដែលបានមកដោយគ្មានការយកចិត្តទុកដាក់ដោយស្មោះអស់ពីចិត្ត

និងដោយការសំភីសិក្សាព្រមជាមួយនិងការអធិស្ឋាននោះទេ។ មានវគ្គខ្លះនៃព្រះគម្ពីរអាចងាយស្រួលនឹងភាន់ច្រលំណាស់
ក៏ប៉ុន្តែមានវគ្គខ្លះទៀតដែលមានអត្ថន័យមិនអាចយល់បាន
ប្រសិនបើមិនយកចិត្តទុកដាក់អានសារចុះសារឡើងដោយល្អិតល្អន់នោះទេ។
អត្ថបទនៃព្រះគម្ពីត្រូវតែប្រៀបធៀបជាមួយអត្ថបទព្រះគម្ពីរ។
អ្នកត្រូវធ្វើការស្រាវជ្រាវដ៏ប្រុងប្រយ័ត្ននិងធ្វើការសញ្ជឹងគិតដោយមានការអធិស្ឋានផង។
ការសិក្សាបែបនេះពិតជានឹងបានទទួលព្រះពរដ៏លើសលប់អំពីព្រះ។
អ្នកដែលស្វែងរកដោយអំណត់អត់ធ្មត់នូវព្រះបន្ទូលនៃព្រះជាម្ចាស់

នោះប្រៀបបានទៅនឹងកម្មករអណ្តូងរ៉ែ ដែលរកឃើញខ្សែកំណាប់រ៉ែនៃលោហធាតុដ៏មានតម្លៃដែលកប់យ៉ាងជ្រៅនៅក្រោមដីយ៉ាងដូច្នោះដែរ។
ព្រះបន្ទូលទុកដូចជាកំណប់ទ្រព្យដែលលាក់កំបាំងយ៉ាងជ្រៅ
គឺជាសច្ចធម៌ដែលមានតម្លៃឥតគណនាដែលបាំងពីភ្នែកអ្នកស្រាវជ្រាវដែលមានការធ្វេសប្រហែស។
ព្រះបន្ទូលដ៏រស់ដែលមកពីព្រះជាម្ចាស់បានចាក់បំពេញក្នុងចិត្តយើង និងលេចឡើងប្រៀបបានទៅនឹងចរន្តទឹកដែលហូរចេញមកពីប្រភពទឹកនៃជីវិត។

យើងមិនត្រូវសិក្សាព្រះគម្ពីរដោយគ្មានការអធិស្ឋាននោះទេ។

មុនពេលយើងបើកទំព័រព្រះគម្ពីរ
យើងត្រូវអធិស្ឋានសូមពន្លឺអំពីព្រះវិញ្ញា
ណ គឺជាវិញ្ញាណនៃការត្រិះដឹង
ដែលព្រះទ្រង់នឹងប្រទានដល់យើងរា
ល់គ្នាជាពិត។
នៅពេលដែលណាថាណែលមកឯព្រះ
យេស៊ូ
នោះព្រះអង្គសង្គ្រោះទ្រង់បានឱទាន
ឡើងថា: នុះហ្ន៎!
ជាសាសន៍អ៊ីស្រាអែលពិតមែនដែល
មានឧបាយកល។
ណាថាណែលក៏ទូលសួរថា:
“តើលោកស្គាល់ខ្ញុំពីពេលណាមក?”។
ព្រះយេស៊ូមានបន្ទូលឆ្លើយថា:
“មុនពេលហ្វីលីបហៅអ្នកមមក
កាលពីអ្នកនៅក្រោមដើមល្វានៅឡើ
យខ្ញុំបានឃើញអ្នក”..យ៉ូហាន
១:៤៧.៤៨។

ព្រះយេស៊ូនឹងទតឃើញយើងផងនៅឯទីស្ងាត់កំបាំងសម្រាប់អធិស្ឋាន ប្រសិនបើយើងស្វែងរកទ្រង់ និងទូលសូមពន្លឺដែលអាចឲ្យយើងមើលឃើញថាអ្វីទៅជាសេចក្ដីពិត អ្វីទៅជាសេចក្ដីមិនពិត។ ពពួកទេវតាដែលមកពីពិភពនៃពន្លឺនឹងស្ថិតនៅជាមួយ អ្នកណាដែលមានចិត្តសុភាពរាបសា ដែលដើរតាមការដឹកនាំនៃព្រះជាម្ចាស់។

ព្រះវិញ្ញាណបរិសុទ្ធសរសើរតំកើងព្រះអង្គសង្គ្រោះ។ កិច្ចការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ គឺបង្ហាញព្រះយេស៊ូគ្រិស្ទនូវភាពបរិសុទ្ធឥតខ្ចោះនៃសេចក្ដីសុចរិតរបស់ទ្រង់ ហើយនឹងសេចក្ដីសង្គ្រោះដ៏មហាស្ចារ្យ

ដែលយើងបានទទួលតាមរយៈព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលថា: “ព្រះវិញ្ញាណបរិសុទ្ធនឹងទទួលនូវភាពសុចរិតអំពីខ្ញុំ ហើយបង្ហាញឲ្យអ្នកទាំងអស់បានយល់ដឹង”..យ៉ូហាន ១៦:១៤។
ព្រះវិញ្ញាណនៃសច្ចៈធម៌គឺជាបរមគ្រូដែលបង្រៀនយើងពីសច្ចៈធម៌នៃនគរស្ថានសួគ៌។
តើព្រះឲ្យតម្លៃមនុស្សជាតិយ៉ាងលើសលប់យ៉ាងណាហ្ន៎ ដែលទ្រង់ប្រទានព្រះរាជបុត្រារបស់ទ្រង់មកសុគតដើម្បីមនុស្សទាំងឡាយ ហើយក៏បានចាត់តាំងព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ឲ្យមកបង្រៀនគេ និងធ្វើជាមគ្គុទេសក៍ ដឹកនាំគេជាដរាបរៀងទៅ!

# ជំពូក ១១ — សិទ្ធិនៃសេចក្ដីអធិស្ឋាន

ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើងរាល់គ្នាតាមរយៈធម្មជាតិ និងការបើកសម្ដែង និងតាមរយៈទិព្វញាណ និងដោយឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ប៉ុន្តែការទាំងនេះមិនទាន់គ្រាប់គ្រាន់នៅឡើយទេ គឺយើងត្រូវការសម្ដែងទឹកចិត្តរបស់យើងទៅទ្រង់ផងដែរ។ ដើម្បីឲ្យមានជីវិតមួយដែលប្រកបដោយព្រះវិញ្ញាណនិងថាមពល យើងត្រូវតែមានការទាក់ទងដ៏ពិតប្រាកដជាមួយព្រះវរបិតានៃនគរស្ថានសួគ៌។អារម្មណ៍របស់យើងផ្ដោតទៅលើទ្រ

ង់
នឹងនាំឲ្យយើងផ្ចង់គិតចំពោះការងាររបស់ទ្រង់ សេចក្ដីមេត្តាសណ្ដោស និងព្រះពររបស់ទ្រង់
តែការនេះបើតាមន័យល្អិតល្អន់គឺមិនមែនជាការរួមសម្ព័ន្ធនឹងព្រះនៅឡើយទេ។
ដើម្បីឲ្យមានទំនាក់ទំនងជាមួយព្រះជាម្ចាស់
យើងត្រូវតែថ្លែងទូលទ្រង់នូវបញ្ហាដែលទាក់ទងនឹងជីវិតដ៏ពិតប្រាកដរបស់យើង។

សេចក្ដីអធិស្ឋានគឺជាការបើកចំហរផ្លូវចិត្ត
ទៅឯព្រះជាម្ចាស់ក៏ដូចជាទៅកាន់មិត្តសម្លាញ់ម្នាក់ដូច្នោះដែរ។
គឺមិនមែនធ្វើដោយចាំបាច់ដើម្បីឲ្យព្រះ

ជាម្ចាស់ទត
ឃើញថាយើងជាអ្វីនោះទេ
ក៏ប៉ុន្តែគឺសម្រាប់យើងទទួលព្រះជាម្ចា
ស់។ សេចក្តីអធិស្ឋាន
គឺមិមែននាំព្រះចុះមកឯយើងនោះទេ
ផ្ទុយទៅវិញគឺនាំយើងឡើងនាំទៅជួប
ព្រះជាម្ចាស់។
កាលដែលព្រះយេស៊ូគង់នៅលើផែនដី
នៅឡើយនោះ
ទ្រង់បានបង្ហាត់បង្រៀនពួកសាវ័ករប
ស់ទ្រង់ឲ្យចេះអធិស្ឋាន។
ទ្រង់ណែនាំឲ្យគេចេះបង្ហាញសេចក្តីត្រូ
វការប្រចាំថ្ងៃរបស់គេទៅឯព្រះជាម្ចាស់
ហើយប្រគល់អស់ការកង្វល់របស់គេ
ទាំងប៉ុន្មានដល់ទ្រង់ដែរ។
ព្រះទ្រង់បានសន្យាថានឹងផ្ទៀងព្រះកា
ណ៌ស្តាប់សេចក្តីអធិស្ឋានរបស់គេ។
សេចក្តីសន្យានោះក៏មានចំពោះយើង

នាបច្ចុប្បន្ននេះដែរ។
ព្រះយេស៊ូអង្គទ្រង់ផ្ទាល់
ក៏ទ្រង់អធិស្ឋានជានិច្ចជាកាលដែរ
នៅពេលដែលទ្រង់គង់នៅក្នុងចំនោម
ហ្វូងមនុស្ស។
ព្រះអង្គសង្គ្រោះនៃយើងបានចូលរួមក្នុងសេចក្តីត្រូវការ
និងភាពកំសោយរបស់យើង
ដោយហេតុដូច្នោះហើយបានជាទ្រង់ក្លាយជា អ្នកផ្គត់ផ្គង់ អ្នកអង្វរករ
ជាអ្នកសូមសំណូមពរអំពីព្រះវរបតានៃទ្រង់ នូវថាមពលគ្រប់ពេលវេលា
ប្រយោជន៍ឲ្យទ្រង់អាចប្រឈមនឹងការងារ និងការលំបាកវេទនា។
ទ្រង់ជាគំរូដល់យើងក្នុងគ្រប់កិច្ចការទាំងអស់។
ព្រះអង្គគឺជាបងប្អូនស្ងួនភ្ងាររបស់យើង
នៅក្នុងវិការភាពរបស់យើង..ព្រះអង្គត្

រូវទទួលការល្បួងល្បងដូចជាយើងរា
ល់គ្នាដែរ
ប៉ុន្តែនៅក្នុងសភាពជាមនុស្សគ្មានបាប
ទើបលក្ខណៈធម្មជាតិរបស់ទ្រង់អាច
ងាកចេញពីអំពើទុច្ចរិតបាន។
ទ្រង់ទ្រាំទ្រការតស៊ូស្វិតស្វាញ
និងទារុណកម្មដល់ព្រលឹងនៅក្នុងពិភ
ពដែលពោរពេញដោយអំពើបាប។
លក្ខណៈមនុស្សជាតិរបស់ទ្រង់បានធ្វើ
ឲ្យសេចក្ដីអធិស្ឋានក្លាយជាការចាំបាច់
និងជាអភ័យឯកសិទ្ធ។
ទ្រង់បានទទួលនូវការល្បួងលោម
និងអំនររីករាយនៅក្នុងការរួមសម្ព័ន្ធជា
មួយព្រះវរបិតាទ្រង់។
ហើយប្រសិនបើព្រះអង្គសង្គ្រោះនៃបា
បជនទាំងឡាយ
ជាបុត្រានៃអម្ចាស់ទ្រង់ត្រូវការសេចក្ដី
អធិស្ឋានទៅហើយនោះ

ចុះទំរាំយើងជាមនុស្សទន់ខ្សោយដែល
ជាកម្មវត្ថុនៃសេចក្តីស្លាប់នោះតើយើង
ត្រូវការសេចក្តីអធិស្ឋាននេះអំបាលម៉ា
នទៅទៀត?
ព្រះវរបិតានៃស្ថានសួគ៌រង់ចាំជានិច្ចនឹង
ប្រទានឲ្យដល់យើងនូវព្រះពរដបរិបូ
ណ៌។
គឺជាសិទ្ធសេរីភាពរបស់យើងនឹងក្រេប
យកទឹកពីប្រភពនៃសេចក្តីស្រលាញ់
ដែលគ្មានព្រំដែនតាមសេចក្តីប៉ងប្រាថ្
នា។ គួរឲ្យអស្ចារ្យណាស់!
ទោះជាយើងអធិស្ឋានប៉ុនណាក៏ព្រះ
ជាម្ចាស់បំរុងជាស្រេច
និងពេញព្រះទ័យផ្ទៀងព្រះកាណ៌ស្តា
ប់នូវសេចក្តីអធិស្ឋាន

ដ៏ស្មោះអពីរាស្ត្រដ៏ស្រគត់ស្រគំរបស់ព្
រះអង្គ

ក៏ប៉ុន្តែយើងបែរជាមានការស្អាក់ស្ទើរ
យ៉ាងខ្លាំង នឹងទទួលថ្វាយទ្រង់
នូវការប៉ងប្រាថ្នារបស់យើងទៅវិញ។
តើពពួកទេវតានៃនគរស្ថានសួគ៌យល់
យ៉ាងណាចំពោះមនុស្សជាតិដ៏ទន់ខ្សោ
យ
ដែលត្រូវពើបប្រទះនឹងការល្បងល្បង
បែរជាអធិស្ឋានតែបន្តិចបន្តួចនិងមាន
ជំនឿខ្សត់ខ្សោយទៅវិញ
នៅពេលដែលព្រះហឫទ័យនៃព្រះជា
ម្ចាស់
ដែលពោរពេញទៅដោយសេចក្តីស្រ
លាញ់ដ៏គ្មានព្រំដែនអាណិតអាសូរចំ
ពោះរូបគេ
ហើដែលបំរុងជាស្រេចនឹងប្រទានឲ្យ
គេជាជាង អ្វីដែគេប្រាថ្នាសុំ
ឬយល់បានទៅទៀត។
ចុះហេតុអ្វីបានជាគេអធិស្ឋានតែបន្តិច

បន្តចដោយសារជំនឿដ៏ស្ដួចស្ដើងវិញ
?
ពពួកទេវតាស្រលាញ់ពេញចិត្តនឹងថ្វាយបង្គំទ្រង់និងនៅក្បែរទ្រង់។
ពពួកទេវតាទាំងនោះយល់ថាការជាប់នឹងព្រះជាម្ចាស់ដោយអំណររីករាយជាទីបំផុតរបស់ពួកគេ
ក៏ប៉ុន្តែរាស្ត្ររបស់ព្រះដែលនៅលើផែនដីនេះដែលត្រូវការ
យ៉ាងខ្លាំងនូវជំនួយអំពីព្រះជាម្ចាស់
បែរជាសុខចិត្តដើរដោយគ្មានពន្លឺនៃព្រះវិញ្ញាណបរិសុទ្ធ
ដែលជាព្រះវត្តមាននៃព្រះអរម្ចាស់ទៅវិញ។

ស្រមោលអន្ធការរបស់អារក្សសាតាំងបានស្រោបបិទបាំងអស់អ្នកដែលធ្វេសប្រហែសក្នុងការអធិស្ឋាន។

សម្លេងខ្សឹបខ្សៀវនៃភាពអមិត្តរបស់អារក្សបានអុជអាលចិត្តគេឲ្យធ្វើបាប ហើយការទាំងនេះកើតឡើង ពីព្រោះតែគេមិនបានប្រើសិទ្ធដែលព្រះបានប្រទានឲ្យគេក្នុងការដែលកំណត់ជួបព្រះដើម្បីអធិស្ឋាន។
តើមូលហេតុអ្វីបានជាកូនស្ងួនភ្ងាររបស់ព្រះជាម្ចាស់មានការរារែកនឹងអធិស្ឋាន
បើការអធិស្ឋាននោះជាកូនសោរនៅក្នុងកណ្តាប់ដៃនៃអ្នកដែលមានសេចក្តីជំនឿ
ដើម្បីនឹងបើកទ្វារឃ្លាំងនៃស្ថានសួគ៌ដែលជាប្រភពមិនចេះរីងស្ងួត ដែលផ្ទុកនូវសព្វានុភាព?
បើគ្មានការអធិស្ឋានដោយខ្ជាប់ខ្ជួនទេ ហើយបើគ្មានការឃ្លាំមើលដោយមានការប្រុងប្រយ័ត្នទេនោះយើងនឹងស្ថិត

នៅក្នុងភាពគ្រោះថ្នាក់
និងការធ្វេសប្រហែសដែលកើនឡើង
ជាលំដាប់និងការងាកវេចេញពីផ្លូវត្រូវ
។
បច្ចាមិត្ររបស់យើងស្វះស្វែងឥតឈប់
ឈរដើម្បីរាំងផ្លូវរបស់យើងដែលនាំ
ទៅកាន់ទីសន្តោសប្រោស។
បើយើងមិនបានអធិស្ឋានសុំ
និងមានជំនឿដ៏ស្មោះអស់ពីចិត្តទេ
នោះ
យើងមិនអាចទទួលនូវព្រះគុណនិងអំ
ណាចដើម្បីទប់ទល់នឹងការល្បួងល្បួង
នោះបានឡើយ។

មានល័ក្ខណាមួយចំនួនដែលយើងអាចរំ
ពឹងថាបានព្រះជាម្ចាស់នឹងផ្ទៀងព្រះ
កាណ៌ស្តាប់
និងឆ្លើយតបនឹងការអធិស្ឋានរបស់យើ

ង។
លក្ខណៈមួយក្នុងចំណោមលក្ខណៈទាំង
នោះគឺយើងត្រូវយល់ដឹងអំពីសេចក្ដីត្រូ
វការអំពីសេចក្ដីជំនួយរបស់ទ្រង់។
ព្រះអង្គបានសន្យាថា
“អញនឹងចាក់បង្ហូរទឹកទៅដល់អ្នកដែ
លស្រេក
ហើយផ្ដល់ទឹកដ៏ជោរជន់ទៅកាន់ទីស្ងួ
តហែង”..អេសាយ៤៤:៣។
អស់អ្នកណាដែលស្រេកឃ្លានចំពោះ
សេចក្ដីបរិសុទ្ធត្រឹមត្រូវ
ហើយដែប្រាថ្នាដើរតាមព្រះជាម្ចាស់អា
ចដឹងប្រាកដថាព្រះជាម្ចាស់នឹងបំពេញ
សេចក្ដីត្រូវការរបស់គេ។
ចិត្តត្រូវតែបើកចំហរទទួលយកឥទ្ធិព
ល នៃព្រះវិញ្ញាណបរិសុទ្ធ
ពុំនោះសោតទេយើងមិនអាចទទួលនូវ
ព្រះពររបស់ព្រះជាម្ចាស់បានឡើយ។

សេចក្តីត្រូវការដ៏ធំធេងរបស់យើងបាន
ជជែកតវ៉ា
និងអង្វរករដ៏ប៉ិនប្រសព្វឲ្យយើង។
ប៉ុន្តែយើងត្រូវតែស្វះស្វែងរកព្រះជាម្ចា
ស់
ដើម្បីទ្រង់ជួយសម្រេចការនេះសម្រាប់
យើង។ ទ្រង់មានព្រះបន្ទូលថាៈ
“ចូរសូមនោះអ្នកនឹងទទួលបាន”..ម៉ា
ថាយ៧:៧។
“ឯព្រះអង្គមិនដែលបានសំចៃទុកនូវព្
រះរាជបុត្រាទ្រង់តែមួយនោះមកជំនួស
យើងរាល់គ្នា
នោះតើមានទំនាក់ទំនងអ្វីឲ្យទ្រង់មិនប្
រទានគ្រប់ទាំងអស់មកយើងជាមួយនឹ
ងព្រះបុត្រាទ្រង់នោះផង”..រ៉ូម ៨:៣២។

ប្រសិនបើយើងស្គាល់អំពើទុច្ចរិតដែលស្ថិតនៅក្នុងចិត្តរបស់យើង..ប្រសិនបើយើងប្រកាន់ខ្ជាប់ទៅនឹងអំពើបាបដែលយើងស្គាល់
នោះព្រះជាម្ចាស់ពិតជាពុំឮសេចក្តីអធិស្ឋានរបស់យើងឡើយ។
ក៏ប៉ុន្តែការអធិស្ឋានរបស់អ្នកដែលមានវិប្បដិសារីគឺព្រលឹងដែលស្គាល់កំហុសនោះព្រះជាម្ចាស់តែងទទួលជានិច្ច។
នៅពេលដែលអំពើខុសឆ្គងទាំងប៉ុន្មានបានកែត្រឹមត្រូវឡើងវិញនោះ
យើងត្រូវជឿជាក់ថាព្រះជាម្ចាស់នឹងឆ្លើយតបទៅនឹងការទូលសូមរបស់យើង។
គុណសម្បត្តិនិងអំពើល្អរបស់យើងនឹងមិនដែលឲ្យយើងទទួលអនុគ្រោះអំពីព្រះជាម្ចាស់ឡើយ
គឺមានតែគុណសម្បត្តិនៃព្រះយេស៊ូគ្រិ

ស្ទុប៉ុណ្ណោះដែលនឹងជួយសង្គ្រោះយើងបាន។
ព្រះលោហិតរបស់ទ្រង់នឹងលាងជំរះយើងឲ្យស្អាតពីអំពើបាប
ប៉ុន្តែយើងមានការមួយដែរគឺយើងត្រូវធ្វើតាមព្រះហឫទ័យនៃព្រះជាម្ចាស់ដែលជាលក្ខណៈនៃការទទួលយល់ព្រមអំពីព្រះជាម្ចាស់។

មានកត្តាមួយទៀតដែលមានប្រសិទ្ធិភាពបំផុតក្នុងការអធិស្ឋាននោះគឺសេចក្តីជំនឿលើព្រះជាម្ចាស់។
អ្នកណាដែលមកឯព្រះជាម្ចាស់ត្រូវតែជឿថាទ្រង់គឺជាព្រះដ៏ពិត
ហើយជឿជាក់ថាទ្រង់គឺជាម្ចាស់អំណោយចំពោះអ្នកឯណាដែលស្វះស្វែងរកទ្រង់ដោយអស់ពីចិត្ត..ហេព្រើ១១:៦។

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័ករបស់ទ្រង់ថា: “វត្ថុអ្វីដែលអ្នកត្រូវការនៅពេលដែលអ្នកអធិស្ឋាន ចូរជឿជាក់ថាអ្នកនឹងទទួលវត្ថុនោះ ហើយអ្នកនឹងទទួលជាប្រាកដមែន”.. ម៉ាកុស ១១:២៤។ តើយើងយល់តាមដូចជាព្រះបន្ទូលរបស់ទ្រង់នេះដែរឬទេ?

— ការធានារ៉ាប់រងរបស់ព្រះនោះធំទូលាយនិងគ្មានព្រំដែនកំណត់ឡើយ ហើយព្រះជាម្ចាស់ទ្រង់ស្មោះត្រង់នឹងសេចក្តីសន្យារបស់ទ្រង់ដែរ។ នៅពេលដែលយើងពុំបានទទួលនូវវត្ថុដែលយើងសូម នៅពេលដែលយើងអធិស្ឋានសូមនោះ យើងនៅតែជឿជាក់ថាព្រះជាម្ចាស់បា

នព្
ហើយទ្រង់នឹងឆ្លើយតមនឹងការអធិស្ឋា
នរបស់យើង។
ដោយសារើងរមែងតែមានការខុសឆ្គង
ហើយមើលមិនឃើញវែងឆ្ងាយនោះទើ
បមានពេលខ្លះយើងទទួលសូមវត្ថុដែ
លមិនមែនជាព្រះពររបស់យើង
តែព្រះវរបិតានៃនគរស្ថានសួគ៍
ដែលប្រកបដោយសេចក្តីស្រលាញ់
ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់
យើងដោយប្រទានឲ្យយើងនូវវត្ថុអ្វីដែ
លល្អបំផុតសម្រាប់យើង។
អ្វីៗដែលយើងប្រាថ្នាចង់បាន
ប្រសិនបើជាមានការបំភ្លឺពីព្រះជាម្ចាស់
នោះយើងនឹងអាចមើលឃើញលក្ខ
ណៈដ៏ពិតប្រាកដនៃវត្ថុទាំងនោះ។
នៅពេលដែលការអធិស្ឋានរបស់យើង
ហាក់ដូចជាគ្មានចម្លើយឆ្លើយតបយើង

ត្រូវតែប្រកាន់ខ្ជាប់ទៅនឹងពាក្យសន្យា ព្រោះថាពេលវេលាសម្រាប់ឆ្លើយតប នោះពិតជានឹងមកដល់ហើយយើងនឹង បានទទួលព្រះពរដែលយើងត្រូវការជា ទីបំផុត។ ការអះអាងថា ការអធិស្ឋានតែងតែបានទទួលនូវចម្លើ យតបតាមសំណូមពររបស់យើងដូច្នេះ ឬដូច្នោះឬវត្ថុពិសេសដែលយើងប្រាថ្នា ចង់បានគឺជាការសន្មតប៉ុណ្ណោះ។ ព្រះជាម្ចាស់ទ្រង់មានទិព្វញាណហួស ពីការដែលមនុស្សបំភ័ន្តទ្រង់បាន ហើយទ្រង់ល្អជាទីបំផុត ហួសពីសេចក្ដីកំណាញ់លាក់ទុកនូវអ្វី ៗដែលល្អសម្រាប់អ្នកដែលដើរដោយ ផ្លូវសុចរិត។ ដូច្នេះចូរកុំភ័យខ្លាចនឹងជឿទុកចិត្តលើ ទ្រង់ ទោះបីជាអ្នកពុំបានឃើញការឆ្លើយតប

ភ្លាមៗទៅនឹងការអធិស្ឋានរបស់អ្នក។ ចូរទុកចិត្តលើពាក្យសន្យា ដ៏ប្រាកដរបស់ទ្រង់..“ចូរសូមនោះអ្នកនឹងបានទទួល” ។

ប្រសិនបើយើងរក្សាទុកនូវការសង្ស័យ ឬការភ័យខ្លាច ឬក៏ព្យាយាមដោះស្រាយនូវអ្វីៗដែលយើងមិនអាចឃើញច្បាស់លាស់ មុននឹងយើងមានសេចក្តីជំនឿដល់ព្រះ នោះភាពសមុគស្មាញ និងការទ័លគំនិតតែងកើតមានឡើងជាមិនខាន។

ប៉ុន្តែបើយើងចូលមកឯព្រះដោយភាពតែលតោល និងដោយគ្មានទីពឹងពំនាក់ ដោយដាក់ខ្លួនយ៉ាងសុភាព

និងដោយមានជំនឿទុកចិត្ត
ហើយទូលថ្វាយនូវអ្វីៗដែលយើងចង់បានដល់ព្រះ
ដែលទ្រង់ប្រកបដោយប្រាជ្ញាញាណដ៏គ្មានទីកំណត់
ដែលទ្រង់ទតឃើញរបស់សព្វសារពើនៅក្នុងលោក
ហើយនិងគ្រប់គ្រងលើរបស់សព្វសារពើដោ យនូវព្រះហឫទ័យ
និងព្រះបន្ទូលរបស់ទ្រង់
នោះទ្រង់អាចនឹងផ្ទៀងព្រះកាណ៌ស្តាប់នូវសេចក្តីដង្ហោយទូលសូមរបស់យើង
ហើយទ្រង់នឹងប្រទានពន្លឺបំភ្លឺនៅក្នុងចិត្តរបស់យើង។
ការអធិស្ឋានដ៏ស្មោះត្រង់បាននាំយើងចូលមកភ្ជាប់នឹងព្រះហឫទ័យនៃព្រះអម្ចាស់។

ទោះបីយើងមិនមានភ័ស្តុតាងកត់សម្គាល់
ក៏ព្រះទ្រង់តែងតែឱនព្រះភ័ក្រទ្រង់មកមើលយើងដោយព្រះទ័យមេត្តានិងស្រលាញ់ដែរ។
យើងប្រហែលជាមិនបានទ្រង់ពាល់ដោយផ្ទាល់មែន
តែព្រះហស្តរបស់ទ្រង់ស្ថិតនៅលើយើងដោយក្តីស្រលាញ់ និងភាពស្រទន់ និងមេត្តាអាសូរ។

នៅពេលយើងមកសុំសេចក្តីមេត្តាករុណា ពីព្រះពរអំពីព្រះជាម្ចាស់នោះ យើងត្រូវតែមានវិញ្ញាននៃសេចក្តីស្រលាញ់
និងការអត់ទោសនៅក្នុងចិត្តរបស់យើង។ តើឲ្យយើងអធិស្ឋានថា:
"សូមអត់ទោសសេចក្តីកំហុសរបស់ខ្ញុំ

ដូចជាយើងខ្ញុំបានអត់
ទោសដល់អ្នកដែលធ្វើខុសនឹងយើង
ដែរ”
តែយើងបែរជាផ្តេកផ្តួលទៅតាមវិញ្ញា
ណដែលគ្មានការសន្តោសអត់ទោស
ទៅវិញ..ម៉ាថាយ ៦:១២។
ប្រសិនបើយើងសង្ឃឹមថាព្រះនឹងឮ
ការអធិស្ឋានរបស់យើង
នោះយើងត្រូវអត់ទោសដល់អ្នកដទៃឲ្
យអ្នកដទៃក្នុងសណ្ឋាន
និងទំហំដែលយើងសង្ឃឹមថាព្រះជាម្ចា
ស់នឹងអត់ឱនទោសឲ្យដល់យើងដូច្
នោះដែរ។

ការព្យាយាមក្នុងការអធិស្ឋាន
គឺជាកំណត់លក្ខណៈមួយដើម្បីបានទទួ
លនូវចម្លើយតប។
យើងត្រូវតែអធិស្ឋានប្រសិនបើយើងច

ង់រីកចំរើនទៅនឹងសេចក្តីជំនឿ
និងការអនុវត្តន៍។
“យើងត្រូវតែកាន់ខ្ជាប់នូវការអធិស្ឋាន”
..រ៉ូម១២:១២ ត្រូវតែ
“ព្យាយាមក្នុងសេចក្តីអធិស្ឋាន
ទាំងចាំយាមក្នុងសេចក្តីនោះឯង
ដោយពាក្យអរព្រះគុណ”..កូលុស
៤:២។
សាវ័កពេត្រុសដាស់តឿនអ្នកជំនឿទាំ
ងប៉ុន្មានថា: “ចូរឲ្យមានគំនិតនឹងធឹង
ហើយចាំយាមក្នុងសេចក្តីអធិស្ឋានចុះ”
..ពេត្រុស១ ៤:៧។
ចំណែកសាវ័កប៉ុលណែនាំថា
“នៅក្នុងគ្រប់កិច្ចការទាំងអស់
ដោយសេចក្តីអធិស្ឋាន និងអង្វករ
ទាំងដោយពាក្យអរព្រះគុណដល់ព្រះ
ចូរថ្វាយគ្រប់ទាំងសំណូមពររបស់អ្នក
ទៅឯព្រះជាម្ចាស់”..ភីលីព ៤:៦។

ចំណែកយូដាសនិយាយថាៈ
ក៏ប៉ុន្តែអ្នករាល់គ្នាជាស្ងួនភ្ងារអើយ
ចូរអធិស្ឋានដោយនូវព្រះវិញ្ញាណបរិសុទ្ធ ចូរថែរក្សាខ្លួនរបស់អ្នក
នៅក្នុងសេចក្តីស្រលាញ់នៃព្រះជាម្ចាស់..យូដាស ៩២០.២១។
ការអធិស្ឋានឥតឈប់ឈរ
គឺជាសម្ព័ន្ធដ៏ជិតស្និទ្ធមួយនៃមនុស្សលោកនឹងព្រះជាម្ចាស់
ដើម្បីឲ្យជីវិតពីព្រះបានហូរមកក្នុងជីវិតយើងរាល់គ្នា
ហើយចេញអំពីនោះវិញជាភាពស្អាតស្អំ បរិសុទ្ធឥតខ្ចោះ
ហើយហូរត្រលប់ទៅឯព្រះជាម្ចាស់វិញ។

ការខ្ជាប់ខ្ជួនក្នុងការអធិស្ឋានជាការចាំបាច់បំផុតក្នុងការអធិស្ឋាន

ដូច្នោះចូរកុំឲ្យមានអ្វីមករារាំងអ្នកឡើយ។
ចូរព្យាយាមគ្រប់ទាំងផ្លូវដើម្បីរក្សាទំនាក់ទំនងរវាងព្រះយេស៊ូនិងព្រះវិញ្ញាណរបស់ខ្លួនយើង
ឲ្យបានបិតបេរគង់វង្ស។
ចូរស្វែងរកឱកាសពិសិដ្ឋចូលរួមក្នុងការអធិស្ឋានដែលរៀបចំឡើងជាទំលាប់
។
អ្នកណាដែលស្វះស្វែងរកការរួមសម្ព័ន្ធជិតស្និទ្ធនឹងព្រះ
ពិតជាមានមុខនៅក្នុងការប្រជុំអធិស្ឋាន (Prayer
meeting)បំពេញកាតាព្វកិច្ចរបស់គេ
ដោយសេចក្តីស្វាមីភក្រ
និងយកចិត្តទុកដាក់..មានចិត្តពុះពោរចង់លទ្ធផលចំរើនពីការងារដែលគេបានធ្វើ។ គេនឹងធ្វើឲ្យរីកចំរើនឡើង

នូវគ្រប់អស់ទាំងឱកាសពិសេសដោយប្រគល់ខ្លួនរបស់គេទៅទីកន្លែងណាដែលគេអាចទទួលនូវកាំរស្មីអំពីស្ថានសួគ៌។

យើងត្រូវអធិស្ឋាននៅក្នុងរង្វង់គ្រួសារ ហើយលើសអ្វីៗទាំងអស់ យើងមិនត្រូវភ្លេចការអធិស្ឋានដោយសម្ងាត់ឡើយ ព្រោះនេះហើយជាអាយុជីវិតនៃព្រលឹងវិញ្ញាណរបស់យើង។ ព្រលឹងវិញ្ញាណរបស់យើងមិនអាចរីកចំរើនបានល្អដោយគ្មានការអធិស្ឋានឡើយ។ ការអធិស្ឋាននៅក្នុងគ្រួសារ ឬនៅទីសាធារណៈគឺមិនទាន់គ្រប់គ្រាប់នៅឡើយទេ។ នៅឯទីកន្លែងស្ងាត់កំបាំងពីគេ ចូរយើងបើកចំហរព្រលឹងវិញ្ញាណរប

ស់យើងនៅចំពោះព្រះនេត្រនៃព្រះជាម្ចាស់។
មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលឮនូវការអធិស្ឋានដ៏សម្ងាត់នោះពុំមានត្រចៀកណាដែលចង់ឮសំណូមពរដ៏ទទួចទាំងនេះដែលជាបន្ទុកឡើយ។
នៅក្នុងការអធិស្ឋានសម្ងាត់ព្រលឹងរបស់យើងទំនេរពីឥទ្ធិពលនៅជុំវិញខ្លួនរួចចេញ ពីក្តីរំជើបរំជួលក្នុងអារម្មណ៍។
ដោយស្ងប់ស្ងាត់តែប្រកបដោយចិត្តក្លៀវក្លា
ការអធិស្ឋាននោះនឹងបានឮដល់ព្រះជាម្ចាស់។
អ្នកដែលទ្រង់ឃើញក្នុងទីអាថ៌កំបាំងនឹងបានទទួលឥទ្ធិពលដ៏ផ្អែមល្ហែមនិងពិនិត្យនៅជាប់នឹងទ្រង់
ដែលព្រះកាណ៌របស់ទ្រង់បើកចំហរផ្ទៀង

ស្តាប់ការអធិស្ឋានណាដែលចេញមក
អំពីចិត្តដ៏ពិតប្រាកដ។
ដោយសេចក្តីជំនឿដោយស្មៀមស្ងាត់
និងសាមញ្ញព្រលឹងរបស់អ្នកបិតក្នុងស
ម្ព័ន្ធភាពជាមួយព្រះជាម្ចាស់
ហើយប្រមែប្រមូល កាំរស្មីព្រះជា
ម្ចាស់មកចំរើនកម្លាំង
នឹងប្រកាន់ជំហរមាំមួនក្នុងការប្រយុទ្ធ
ជាមួយអារក្សសាតាំង។
ព្រះជាម្ចាស់គឺជាបន្ទាយនៃឋាមពលដ៏រឹ
ងមាំរបស់យើង។

សូមអធិស្ឋាននៅក្នុងបន្ទប់តូចរបស់អ្ន
ក នៅពេលចេញទៅធ្វើការជាប្រចាំថ្ងៃ
សូមលើកទឹកចិត្តរបស់អ្នកថ្វាយទៅព្
រះជាម្ចាស់។
អីណុកដើរជាមួយព្រះដោយធ្វើរបៀប
នេះ។

ការអធិស្ឋានស្មៀមស្ងាត់ទាំងនេះបង្ហើរ
ឡើងដូចជាគ្រឿងក្រអូបដ៏មានតម្លៃ
នៅចំពោះបល្ល័ងនៃព្រះគុណ។
អារក្សសាតាំងមិនអាចមានជ័យជំនះ
ទៅលើអ្នកដែលមានចិត្តស្អិតនៅជាប់
នឹងព្រះជាម្ចាស់ឡើយ។

ពេលគ្មានវេលាណា
ឬទីកន្លែងណាដែលមិនសក្តសមនឹងថ្វាយនូវសំណូមពរទៅព្រះជាម្ចាស់ឡើយ។
គ្មានអ្វីដែលអាចឃាត់ឃាំងយើងពីការលើកថ្វាយចិត្តរបស់យើងទៅព្រះជាម្ចាស់នៅក្នុងវិញ្ញាណនៃការអធិស្ឋានយ៉ាងស្មោះអស់ពីចិត្តនោះឡើយ។
នៅក្នុងហ្វូងមនុស្ស
តាមដងវិថីនៅពេលដែលជាប់ប្រឡូក
នឹងការងារ។

យើងអាចផ្ញើរនូវសំណូមពរមួទៅព្រះ
ជាម្ចាស់និងទូលសូមទ្រង់នូវមគ្គទេស
ក៍ក៏ដូចដែលលោកណេហាមាបានធ្វើ
នៅពេលដែលគាត់ផ្ញើរសំណូមពរចំ
ពោះស្តេច អាតាសេសឺសដូច្នោះដែរ។
បន្ទប់ដ៏តូចសម្រាប់ទំនាក់ទំនងជាមួយ
ព្រះជាម្ចាស់ពិតជាមានទោះយើងនៅ
កន្លែងណាក៏ដោយ។
យើងត្រូវតែបើកចំហរផ្លូវចិត្តជាដរាប
និងយាងព្រះយេស៊ូចុះមកគង់
នៅដូចជាភ្ញៀវកិត្តិយសនៃនគរស្ថាសួ
គ៌នៅក្នុងវិញ្ញាណរបស់យើង។

ទោះបីជាមានបរិយាកាសពោរពេញ
ដោយភាពទុច្ចរិត
និងពុករលួយនៅជុំវិញ
ខ្លួនយើងយ៉ាងណាក៏ដោយ
យើងមិនត្រូវស្រូបយកផ្សែងពុលពីបរិ

យាកាសនោះឡើយ
តែផ្ទុយទៅវិញយើងត្រូវស្រូបយកខ្យល់បរិសុទ្ធនៃស្ថានសួគ៌។
យើងអាចបិទគ្រប់ទ្វារ
នៃការស្រមៃដែលមិនស្អាតស្អំ
និងគំនិតមិនបរិសុទ្ធដោយលើកថ្វាយវិញ្ញាណទៅចំពោះព្រះជាម្ចាស់
តាមរយៈការអធិស្ឋានដ៏ស្មោះត្រង់។
អ្នកណាដែលមានចិត្តបើកចំហចាំទទួលយកសេចក្តីជំនួយ
និងព្រះពរពីព្រះជាម្ចាស់នឹងដើរក្នុងបរិយាកាសដ៏បរិសុទ្ធជាជាង
បរិយាកាសផែនដីហើយនឹងមានការរួមសម្ព័ន្ធជាប់ជាប្រចាំជាមួយនឹងស្ថានសួគ៌។

យើងត្រូវតែមានទស្សនៈឲ្យបានច្បាស់លាស់អំពីព្រះគ្រិស្ទ និងការយល់ឲ្យ

បានធំទូលំទូលាយឡើង
នូវតម្លៃនៃសភាពការណ៍ដែលឋិតនៅ
ដ៏អស់កល្ប។ សម្ផស្សនៃភាពបរិសុទ្ធ
នឹងបំពេញអស់ទាំងចិត្តនៃកូនស្ងួនភ្ងារ
របស់ព្រះជាម្ចាស់ហើយបើអំពើនេះ
បានបំពេញសព្វគ្រប់ហើយ
យើងគួរតែស្វែងរកនូវការបើកសម្ដែង
ដ៏បរិសុទ្ធអំពីព្រះនូវគ្រប់របស់នៃនគរ
ស្ថានសួគ៌។

ចូរឲ្យវិញ្ញាណយើងបានលើកឡើងដើ
ម្បីឲ្យព្រះជាម្ចាស់ប្រទានឲ្យយើងនូវដ
ង្ហើមនៃបរិយាកាសស្ថានសួគ៌។
យើងអាចរស់នៅយ៉ាងជិតស្និទ្ធទៅនឹង
ព្រះជាម្ចាស់ទោះជានៅពេលដែលមា
នបញ្ហាល្បួងល្បងកើតឡើងដោយថៃ
ដន្យក្ដី
ក៏ចិត្តរបស់យើងនឹងងាកបែរទៅរកកព្

រះជាម្ចាស់ដូចជានៅក្នុងធម្មជាតិដែល
បុប្ផាបែរទៅរកព្រះអាទិត្យដូច្នោះដែរ។

ចូរលើកថ្វាយគ្រប់ការប្រាថ្នារបស់អ្នក
អំណាររបស់អ្នក
សេចក្ដីទុក្ខសោករបស់អ្នក
សេចក្ដីកង្វល់របស់អ្នក
និងការភ័យខ្លាចរបស់អ្នកចំពោះព្រះ
ជាម្ចាស់។
យើងនឹងមិនជាបន្ទុកដល់ទ្រង់ឡើយ
ហើយទ្រង់ក៏មិនដើលនឿយណាយនឹ
ងយើងដែរ។
ព្រះជាម្ចាស់ដែលរាប់ដឹងនូវសសៃសក់
នៅលើក្បាលរបស់អ្នក
ពិតជាមិនព្រងើយកន្ដើយនឹងបំណាង
ប្រាថ្នាកូនចៅរបស់ទ្រង់ឡើយ។
"ព្រះជាម្ចាស់ទ្រង់មានព្រះហឫទ័យមេ
ត្តាករុណា

និងសេចក្តីអាណិតអាសូរពោរពេញដែរ”..យ៉ាកុប ៥:១១។
ព្រះហឫទ័យនៃសេចក្តីស្រលាញ់របស់ទ្រង់រំជួលដោយទុក្ខសោក
និងការត្អូញត្អែររបស់យើងអំពីទុក្ខសោកទាំងនោះ។
ចូរថ្វាយទ្រង់នូវគ្រប់អ្វីៗដែលធ្វើឲ្យចិត្តយើងទ័លគំនិត។
គ្មានអ្វីដែលហួសទ្រង់មិនអាចទ្រាំទ្របានឡើយព្រោះព្រះអង្គទ្រទ្រង់ពិភពលោកទាំងមូល។
ទ្រង់គ្រប់គ្រងលើអស់ទាំងបញ្ហាទាំងឡាយនៃលោកសន្និវាសទាំងមូល។
គ្មានអ្វីដែលទាក់ទងទៅនឹងសន្តិភាពរបស់យើងដែលលាក់កំបាំងដែលទ្រង់យល់មិនបាននោះឡើយ។
គ្មានការស្មុគស្មាញទ័លគំនិតឯណាដែ

លហួសពីសមត្ថភាពនឹងទ្រង់ដោះស្រាយបានឡើយ។
គ្មានវិនាសកម្មយ៉ាងណាដែលកើតមានដល់កូនចៅដែលតូចបំផុតរបស់ទ្រង់
ការអន្ទះអន្ទែងក្នុងចិត្ត
ការរំខានដល់វិញ្ញាណសម្រែកនៃអណរឯណា
ឬការអធិស្ឋានដ៏ស្មោះត្រង់ដែលចេញពីបបូរមាត់ឯណាដែលព្រះវរបិតានៃនគរស្ថានសួគ៌យើងមិនរមិលមើល
ឬដែលទ្រង់មិនយកព្រះទ័យទុកដាក់ជាបន្ទាន់នោះឡើយ។
“ទ្រង់ព្យាបាលអស់អ្នកណាដែលមានចិត្តសោក
សង្រេងបានជាក៏រុំរបួសឲ្យគេផង..ទំនុកតំកើង” ១៤៧:៣។
ទំនាក់ទំនងរវាងព្រះជាម្ចាស់ទៅនឹងមនុស្សនិមួយៗគឺច្បាស់លាស់

និងពេញលេញជាទីបំផុត
ហាក់បីដូចជាមានតែអ្នកនោះម្នាក់ហើ
យគ្មានអ្នកឯណាទៀតសោះ
នៅលើលោកិយនេះដែលទ្រង់ត្រូវថែរ
ក្សានឹងប្រទានព្រះរាជបុត្រារបស់ទ្រង់
ឲ្យមកសង្គ្រោះ។ព្រះយេស៊ូមានព្រះប
ន្ទូលថា“អ្នករាល់គ្នានឹងសូមដោយនូវ
ឈ្មោះខ្ញុំ ហើយខ្ញុំមិនថា
ខ្ញុំនឹងទទូលអង្វរដល់ព្រះវរបិតាជំនួស
អ្នករាល់គ្នានោះទេ
ត្បិតព្រះវរបិតាទ្រង់ក៏ស្រលាញ់អ្នករា
ល់គ្នាដែរ”..យ៉ូហាន១៥:១៦/
១៦:២៦.២៧។
ការអធិស្ឋាននៅក្នុងព្រះនាមព្រះគ្រិស្ទ
គឺមិនគ្រាន់តែជាការលើកព្រះនាមទ្រង់
នោះនៅគ្រាដំបូង
និងទីបញ្ចប់នៃការអធិស្ឋាននោះទេតែ
យើងត្រូវអធិស្ឋានដោយនូវចិត្ត

និងវិញ្ញាណនៃព្រះគ្រិស្ទនៅពេលដែល
យើងជឿទុកចិត្តលើព្រះបន្ទូលសន្យារបស់ទ្រង់
ពឹងផ្អែកលើព្រះគុណរបស់ទ្រង់និងធ្វើការរបស់ទ្រង់។

ព្រះជាម្ចាស់មិនមានព្រះបន្ទូលឲ្យយើងនិមួយៗក្លាយទៅជាឥសី
ឬសង្ឃនិងលាលែងពីលោកិយដើម្បីថ្វាយខ្លួនក្នុងការគោរពបូជានោះទេ។
ជីវិតរបស់យើងត្រូវតែបានដូចជាជីវិតព្រះគ្រិស្ទ ទោះបីជានៅក្នុងព្រៃភ្នំក្រាំថ្ម
ឬនៅក្នុងហ្វូងមនុស្ស។
មនុស្សណាដែលមិនធ្វើអ្វីសោះក្រៅពីការអធិស្ឋាន
នោះនឹងឈប់អធិស្ឋាននៅពេលដ៏ខ្លីឬក៏ការអធិស្ឋានរបស់គេនឹងក្លាយជាទំលាប់។

នៅពេលដែលមនុស្សញែកខ្លួនគេចេញពីជីវិតនៃសង្គមមនុស្ស
ចេញឆ្ងាយពីរង្វង់ភារកិច្ចរបស់អ្នកគ្រិស្ទាន និងការទ្រាំទ្រឈើឆ្កាង
នៅពេលដែលគេឈប់ធ្វើការយ៉ាងស្មោះត្រង់អស់ពីចិត្តដើម្បីព្រះជាម្ចាស់ដែល
ធ្វើការយ៉ាងស្មោះអស់ពីចិត្តសម្រាប់រូបគេ
នោះគេបាត់បង់នូវគោលការណ៍ដ៏សំខាន់នៃការអធិស្ឋាន
ហើយគេគ្មានទឹកចិត្តដើម្បីធ្វើការបូជាថ្វាយព្រះឡើយ។
ការអធិដ្ឋានរបស់គេទាំងប៉ុន្មាននឹងគ្រាន់តែជាបញ្ហាផ្ទាល់ខ្លួន
និងបំរើភាពអាត្មានិយមតែប៉ុណ្ណោះ។
គេមិនអាចអធិស្ឋានសម្រាប់សេចក្តីត្រូវការរបស់មនុស្សជាតិ

ឬការលើកតំកើងឡើងនៃអាណាចក្រនៃព្រះគ្រិស្ទ
ហើយគេមិនបានសូមនូវកម្លាំងដែលសម្រាប់ធ្វើការដែរ។

យើងទទួលបរាជ័យ
នៅពេលដែលយើងធ្វេសប្រហែសនូវសិទ្ធិសម្រាប់រូប រួមដើម្បីចំរើនកម្លាំង
និងលើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងការងារបំរើព្រះជាម្ចាស់។
សច្ចៈភាពនៃពញរះបន្ទូលរបស់ទ្រង់ពិតជាបាត់នូវសភាពរស់សរើក
និងសារៈសំខាន់នៅក្នុងអារម្មណ៍របស់យើង។
ចិត្តរបស់យើងឈប់ទទួលបានពន្លឺ
និងមិនបានលុះតាមឥទ្ធិពលដ៏បរិសុទ្ធហើយយើងក៏ធ្លាក់ចុះឱនថយខាងផ្នែកព្រលឹងវិញ្ញាណនៅក្នុងវង្វង់អ្នកគ្រិស្ទា

ន។
យើងបាត់បង់មនុស្សជាច្រើនដោយកា
រខ្វះខាតនូវការអាណិតអាសូរដល់គ្នា
ទៅវិញទៅមក។
អ្នកឯណាដែលបង្ខាំងខ្លួនសម្រាប់តែខ្លួ
នឯង
គឺមិនបានបំពេញនូវមុខងារដែលព្រះ
ជាម្ចាស់បានតាក់តែងមកទេ។
ការអប់រំត្រឹមត្រូវនៅក្នុងធម្មជាតិរបស់
យើង
នូវលក្ខណៈនៃការទាក់ទងគ្នាក្នុងសង្គ
ម
នាំឲ្យយើងមានចិត្តអាណិតអាសូរដល់
អ្នកដទៃ
និងជាមធ្យោបាយនៃការចំរើនល្អតលា
ស់និងជាថាមពលសម្រាប់យើងនៅក្នុ
ងការងារនៃព្រះជាម្ចាស់។

ប្រសិនបើអស់អ្នកគ្រិស្ទាននឹងរួបរួមគ្នា និយាយប្រាប់គ្នាទៅវិញទៅមកដោយ នូវសេចក្តីស្រលាញ់នៃព្រះជាម្ចាស់ និងសច្ចភាពដ៏មានតម្លៃនៃការប្រោស លោះនោះចិត្តរបស់គេនឹងបានប្រែពៃ ឡើងហើយគេនឹងកែលម្អដល់គ្នាទៅវិ ញទៅមកដែរ។

យើងអាចរៀនជារៀងរាល់ថ្ងៃថែមទៀ តអំពីព្រះវរបិតានៃស្ថានសួគ៌របស់យើ ងដើម្បីទទួលនូវការពិសោធន៍ថ្មីៗ នៃព្រះគុណរបស់ព្រះជាម្ចាស់ ហើយយើងមានចំណង់ចង់ថ្លែងអំពី សេចក្តីស្រលាញ់របស់ទ្រង់។ នៅពេលដែលយើងធ្វើដូច្នេះចិត្តរបស់ យើងនឹងបានកក់ក្តៅ និងប្រកបដោយការលើកទឹកចិត្តយ៉ាង ខ្លាំង។ ប្រសិនបើយើងគិតនិងនិយាយ តែអំពីព្រះយេស៊ូកាន់តែខ្លាំងឡើង

ប៉ុន្តែនិយាយតែបន្តិចបន្តួចសម្រាប់ខ្លួនយើង
នោះយើងកាន់តែទទួលបាននូវវត្តមាននៃព្រះជាម្ចាស់កើនឡើងជាលដាប់។

ប្រសិនបើយើងគិតអំពីព្រះឲ្យបានញឹកញាប់ដូចដែលយើងទទួលនូវភស្តុតាងនៃការថែរក្សារបស់ទ្រង់ចំពោះយើង
នោះយើងគួរតែនឹកដល់ទ្រង់នៅក្នុងចិត្តរបស់យើងជានិច្ច
យើងគួរតែមានអំណររីករាយនឹងថ្លែងអំពីទ្រង់
និងសរសើរតំកើងដល់ទ្រង់ជានិច្ចដែរ។
យើងនិយាយអំពីវត្ថុបណ្ដោះអាសន្នពីព្រោះយើងមានការចាប់អារម្មណ៍ទៅលើវត្ថុទាំងនោះ។
យើងនិយាយទៅកាន់មិត្តភ័ក្ររបស់

យើងពីព្រោះយើងស្រលាញ់គេ..សេច
ក្តីអំណរសប្បាយនិងការទុក្ខព្រួយរប
ស់ យើងនៅជាប់នឹងគេ។
ប៉ុន្តែមានមូលហេតុដ៏ធំធេងឥតគណ
នាជាងនេះដែលធ្វើឲ្យយើងស្រលាញ់
ព្រះជាម្ចាស់ជាជាងស្រលាញ់មិត្តភ័ក្ត
នៃលោកិយរបស់យើង។
គឺជាសភាវៈនៃធម្មជាតិនៅក្នុងលោក
នេះ
ដែលព្រះជាម្ចាស់ជារបស់ទីមួយនៅក្នុ
ងគំនិតរបស់យើង។
យើងនិយាយអំពីសេចក្តីសប្បុរសរប
ស់ទ្រង់
ហើយថ្លែងប្រាប់គេអំពីព្រះចេស្តារបស់
ទ្រង់។ អំណោយទានដច្រើនក្រៃលែង
ដែលព្រះជាម្ចាស់បានប្រគល់ឲ្យយើង
មិនមែនសម្រាប់ឲ្យយើងយកមកបំពេ
ញចិត្តគំនិតនិងសេចក្តីស្រលាញ់ខ្លួន

យើងផ្ទាល់ដែលនាំឲ្យយើងគ្មានអ្វីថ្វា
យទៅទ្រង់វិញនោះទេ។
អំណោយទានទាំងនោះគឺជាការរំលឹក
ដ៏ញឹកញាប់ដល់រូបយើងអំពីព្រះជាម្ចា
ស់
ហើយបានផ្សារភ្ជាប់យើងទៅនឹងចំណ
ងនៃសេចក្តីស្រលាញ់
និងការដឹងគុណទៅដល់ព្រះដ៏សប្បុរ
ស។
យើងនៅជិតទីទំនាបបំផុតនៃផែនដី។
ចូរយើងងើយបែរក្រសែចក្ខុរបស់យើង
សម្លឹងទៅឯទ្វារបើកចំហរ
នៃទីបរិសុទ្ធនៅឯនគរស្ថានសួគ៌
ជាទីដែលពន្លឺនៃសិរីល្អរបស់ព្រះជាម្ចា
ស់ចាំងភ្លឺចិញ្ចែងជះទៅព្រះភ័ក្រនៃព្រះ
គ្រិស្តជាម្ចាស់ដែល“អាចជួយសង្គ្រោះ
យើងសព្វគ្រប់បាន..គឺដល់មនុស្សទាំ

ងអស់ដែលចូលទៅឯព្រះដោយសារទ្រង់”..ហេព្រើ ៧:២៥។

យើងត្រូវសរសើរតំកើងទ្រង់ថែមទៀត “ដោយព្រោះសេចក្ដីសប្បុរសរបស់ទ្រង់
ហើយដោយព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់បានប្រោសដល់កូនចៅនៃមនុស្សជាតិ”..ទំនុកតំកើង ១០៧:២៥។ការអធិស្ឋានរបស់យើងមិនមែនគ្រាន់តែការអង្វរសុំនិងទទួលប៉ុណ្ណោះទេ។
ចូរយើងកុំគិតតែអំពីសេចក្ដីប្រាថ្នារបស់យើងហើយពុំដែលគិតអំពីផលប្រយោជន៍ដែលយើងបានទទួលនោះ។ យើងមិនអធិស្ឋានឲ្យច្រើនលើសលប់ពេកដោយគ្មានថ្វាយសេចក្ដីអំណរព្រះគុណដល់ព្រះជាម្ចាស់។

យើងជាអ្នកទទួលជានិច្ចនូវសេចក្ដីសន្ដោសប្រោសប្រណីរបស់ព្រះជាម្ចាស់ តែយើងបង្ហាញការដឹងគុណតែបន្តិចបន្តួចប៉ុណ្ណោះ។
យើងសរសើរតម្កើងទ្រង់តែបន្តិចបន្តួចប៉ុណ្ណាចំពោះអ្វីៗដែលទ្រង់បានធ្វើចំពោះយើង។

ពីបុរាណកាលនៅពេលគេមកជួបជុំគ្នាដើម្បីធ្វើការងាររបស់ទ្រង់ព្រះយេហូវ៉ាបានណែនាំកូនចៅអ៊ីស្រាអែលថា: “ត្រូវឯងរាល់គ្នាបរិភោគនៅចំពោះព្រះយេហូវ៉ាជាព្រះនៃឯង
ហើយឯងនិងពួកគ្រួសារឯងត្រូវអរសប្បាយឡើងដោយព្រោះគ្រប់ទាំងរបស់ដែលឯងលូកទៅចាប់យកទាំងប៉ុន្មាននោះគឺព្រះយេហូវ៉ាជាព្រះនៃឯងបានប្រទានពរដល់ឯងហើយ” ..ចោទិយកថា

១២:៧។
កិច្ចការដែលធ្វើឡើងដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់
ត្រូវតែធ្វើឡើងដោយអំនររីករាយ..ដោយទំនុកសរសើរ តំកើង
និងអរព្រះគុណ
គឺមិនមែនដោយភាពក្រៀមក្រំ
និងទុក្ខព្រួយឡើយ។

ព្រះជាម្ចាស់នៃយើងគឺជាព្រះវរបិតាដែលប្រកបដោយភាពស្រទន់
និងសន្ដោសប្រោសប្រណី។
យើងមិនត្រូវមើលកិច្ចការបម្រើទ្រង់ថាជាការងាប្រកបដោយភាពក្រៀមក្រំនិងនឿយណាយនោះទេ។
យើងគប្បីមានអណរសប្បាយនឹងថ្វាយបង្គំទ្រង់
និងរួមចំណែកក្នុងកិច្ចការថ្វាយទ្រង់។

ព្រះជាម្ចាស់ពិតជានឹងមិនឲ្យរាស្ត្ររបស់ទ្រង់ដែលទ្រង់ប្រោសប្រទានសេចក្ដីសង្គ្រោះដ៏ធំធេងនោះឲ្យសម្ដែងហាក់ដូចជាទ្រង់ជាចៅហ្វាយដ៏តឹងរ៉ឹងម៉ឺងម៉ាត់នោះទេ។
ទ្រង់គឺជាកល្យាណមិត្តរបស់យើងប្រទានព្រះពរកំសាន្តចិត្តយើង
បំពេញចិត្តយើងនូវអំណររីករាយនិងសេចក្ដីស្រលាញ់។
ទ្រង់មានព្រះហឫទ័យចង់ឲ្យរាស្ត្ររបស់ទ្រង់មានការសុខស្រួលក្នុងកិច្ចការរបស់ទ្រង់និងសេចក្ដីអំណររីករាយជាជាងការនឿយលំបាកនៅក្នុងការងាររបស់ទ្រង់ក្នុងជីវិតប្រចាំថ្ងៃ។
ទ្រង់មានព្រះហឫទ័យចង់ឲ្យអ្នកណាដែលចូលមកគោរពបូជាទ្រង់នឹងពាំនាំជាមួយគេនូវអារម្មណ៍ដ៏មានតម្លៃនៃការថែរក្សានិងសេចក្ដីស្រលាញ់រប

ស់ទ្រង់ដែលគេអាចមានអំណរសប្បាយនៅក្នុងគ្រប់កិច្ចការប្រកបអាជីវកម្មទាំងឡាយក្នុងជីវិតប្រចាំថ្ងៃ និងដើម្បីអាចទទួលព្រះគុណសម្រាប់ដោះស្រាយដោយស្មោះត្រង់នងជឿជាក់នៅក្នុងគ្រប់កិច្ចការទាំងអស់។ យើងត្រូវផ្ចង់គំនិតទៅឯឈើឆ្កាងរបស់ទ្រង់។ ព្រះគ្រិស្ទជាម្ចាស់ និងការសុគតរបស់ទ្រង់នៅលើឈើឆ្កាង គឺជាកម្មវត្ថុដ៏សំខាន់ក្នុងការសញ្ជឹងគិតការសន្ទនា និងក្នុងមនោសញ្ចេតនាដ៏រីករាយជាទីបំផុត របស់យើង។ យើងត្រូវតែចងចាំនៅក្នុងអារម្មណ៍របស់យើងគ្រប់ទាំងព្រះពរ ទាំងឡាយដែលយើងបានទទួលអំពីព្រះជាម្ចាស់

ហើយនៅពេលដែលយើងយល់ច្បាស់នូវសេចក្ដីស្រលាញ់ដ៏ធំធេងចំពោះទ្រង់។
យើងគួរតែយល់ព្រមទុកចិត្តលើព្រះហស្តទ្រង់បានបោះភ្ជាប់ទៅនឹងឈើឆ្កាងដើម្បីរូបយើងរាល់គ្នា។
ការសរសើរតម្កើងអាចនាំព្រលឹងយើងឈានទៅឡើងឯស្ថានសួគ៌។
ពពួកទេវតាគោរពប្ញជាព្រះជាម្ចាស់នៅឯនគរស្ថានសួគ៌ដោយនូវចម្រៀងនិងតន្ត្រី..ហើយនៅពេលដែលយើងសម្ដែងអំណរអរព្រះគុណរបស់យើងៗក៏ថ្វាយបង្គំដល់ទ្រង់ដូចជាពពួកទេវតានៃនគរស្ថានសួគ៌នោះដែរ។
អ្នកណាដែលថ្វាយដង្វាយជាសេចក្ដីអរព្រះគុណនោះក៏សរសើរតម្កើងអញដែរ..ទំនុកតម្កើង៥០:២៣។
ចូរយើងដែលប្រកបដោយអំណរកោត

ខ្លាចចូលមកចំពោះព្រះដ៏បង្កើតលោកិយដោយក្តីអំណរព្រះគុណ និងសម្លេងពិរោះរណ្តំផង..អេសាយ៥២:៣។

# ជំពូក ១២ — តើត្រូវធ្វើយ៉ាងណាចំពោះមន្ទិលសង្ស័យ

មានមនុស្សជាច្រើន ជាពិសេសអ្នកដែលមានការពិសោធន៍នៅក្មេងខ្ចីនៅក្នុងជីវិតជាអ្នកគ្រិស្ទាន ដែលមាពេលខ្លះមានបញ្ហានៃចម្ងល់ដែលមិនចេះចប់មិនចេះហើយ។ មានរឿងរ៉ាវជាច្រើននៅក្នុងព្រះគម្ពីប៊ីនដែលគេមិនអាចពន្យល់បានឬក៏មិនអាចយល់បាន។ ឆ្លៀតឱកាសនេះអារក្សសាតាំងបានប្រើការទាំងនេះជាមធ្យោបាយធ្វើឲ្យរង្គោះរង្គើសេចក្ដីជំនឿរបស់គេ ហើយថាជាការបើកសម្ដែងរបស់ព្រះជាម្ចាស់។ គេដណ្ដឹងសួរថា

“តើខ្ញុំអាចស្គាល់ផ្លូវនៃសេចក្តីសុច្ចរិតបានដោយរបៀបណា?”
ប្រសិនបើព្រះគម្ពីរពិតជាព្រះបន្ទូលរបស់ព្រះជាម្ចាស់មែន
តើធ្វើដូចម្តេចទើបខ្ញុំអាចរួចផុតអំពីសេចក្តីមន្ទិលសង្ស័យ
និងការភ័ន្តច្រលំទាំងនោះទៅបាន?

ព្រះជាម្ចាស់មិនតម្រូវឲ្យយើងមានជំនឿ
ដោយគ្មានផ្តល់នូវភស្តុតាងគ្រប់គ្រាន់ដែលជាគ្រិះមូលដ្ឋាននៃសេចក្តីជំនឿរបស់យើងនោះឡើយ។
ភាពបិតបេររបស់ទ្រង់លក្ខណៈរបស់ទ្រង់សច្ចភាពនៃបន្ទូលរបស់ទ្រង់
ស្ថាបនាឡើងដោយទីបន្ទាល់ដែលមានហេតុផល ហើយបរិបូណ៌ផង។
ប៉ុន្តែព្រះជាម្ចាស់មិនបានបំបាត់ចោល

នូវលទ្ធភាពនៃការបោះមន្ទិលចោលចេញទេ។
សេចក្ដីជំនឿរបស់យើងឋិតនៅលើភស្តុតាង
មិនមែនឋិតនៅលើការសម្ដែងឡើយ។
អ្នកណាដែលមានចំណង់នឹងឆ្ងល់នោះ
នឹងមានឱកាសសម្រាប់ការឆ្ងល់សង្ស័យ។
រីឯអស់អ្នកណាដែលមានបំណងចង់ដឹងការពិត
នោះនឹងរកឃើញនូវភស្តុតាងជាច្រើន
ដែលជាបង្អែកនៃសេចក្ដីជំនឿ។

គំនិតប្រាជ្ញានៃមនុស្សជាតិធម្មតាមិន
អាចយល់បានឲ្យបានពេញលេញនូវលក្ខណៈ
ឬការងាររបស់ព្រះជាម្ចាស់បានឡើយ។

ព្រះដ៏បរិសុទ្ធនឹងឋិតនៅជាសេចក្ដីអាថ៌កំបាំងដ៏ជ្រាលជ្រៅ
ចំពោះអ្នកដែលមានប្រាជ្ញាឈ្លាសវៃបំផុតដែលទទួលបានការរៀនសូត្របានខ្ពង់ខ្ពស់ទៅវិញ។
បើអ្នកខំស្វែងរកតើនឹងអាចស្គាល់សភាពនៃព្រះបានឬយល់ដល់
សេចក្ដីគ្រប់ល័ក្ខណ៍របស់ព្រះដ៏មានព្រះចេស្ដាបានដែរឬទេ?
"ព្រោះប្រាជ្ញាទ្រង់នោះខ្ពស់ជាងស្ថានសួគ៌ទៅទៀត
តើអ្នកអាចនឹងធ្វើយ៉ាងណាបាន
ជ្រៅជាងស្ថានឃុំព្រលឹងមនុស្សស្លាប់ផង ធ្វើដូចម្តេចឲ្យអ្នកយល់បាន"..យ៉ូប ១១:៧.៨។

សាវ័កប៉ុលឧទានថា: "អើហ្ន៎ ប្រាជ្ញានិងចំណេះដ៏បរិបូណ៌របសើព្រះ

ជ្រៅណាស់តើ! ឯព្រះតម្រិះរបស់ទ្រង់
តើមានអ្នកណានឹងស្ទង់បាន?
ហើយផ្លូវទ្រង់តើមានអ្នកណានឹងរកតា
មបាន”..រ៉ូម ១១:៣៣។
ក៏ប៉ុន្តែទោះជាពពក
និងភាពអន្ធិការហ៊ុំព័ទ្ធជុំជិតទ្រង់ក៏ដោ
យ ក៏សេចក្តីសុចរិត
និងសេចក្តីយុត្តិធម៌ជាគ្រឹះនៃបល្ល័ង្ករប
ស់ទ្រង់..ទំនុកតម្កើង៩៧:២។
យើងអាចយល់បាននូវការប្រាស្រ័យរ
បស់ទ្រង់ជាមួយយើង
ហើយដោយសារតែមូលហេតុដែលទ្រ
ង់បានធ្វើឡើង
នោះបណ្តាលឲ្យយើងអាចមើលឃើញ
នូវសេចក្តីស្រលាញ់
និងមេត្តាករុណាដ៏គ្មានព្រំដែនដែលផ្
សារភ្ជាប់ទៅនឹងអំណាចដ៏គ្មានទីកំណ
ត់ដែរ។

យើងអាចយល់យ៉ាងច្រើននូវព្រះរាជបំណងរបស់ទ្រង់ដែលជាគុណប្រយោជន៍ និងសេចក្តីល្អប្រពៃរបស់យើង។ លើសពីនេះទៅទៀតយើងនៅតែទុកចិត្ត
ទៅលើព្រះហស្តនៃព្រះដ៏មានគ្រប់ទាំងចេស្តា
និងព្រះហឫទ័យដែលពោរពេញទៅដោយសេចក្តីមេត្រីភាព។

— ព្រះបន្ទូលរបស់ព្រះជាម្ចាស់
ក៏ដូចជាអត្តចរិករបស់ទ្រង់ដែលជាម្ចាស់នៃការទាំងអស់
បង្ហាញនូវសេចក្តីអាថ៌កំបាំងដោយមនុស្សសាមញ្ញមិនអាចនឹងយល់បានដោយពេញលេញឡើយ។
ចំណុចនៃអំពើបាបមកក្នុងលោកិយ..
ការយោនយកកំណើតជាមនុស្សរបស់

ព្រះគ្រិស្ទ..ការបង្កើតជាថ្មីនៃមនុស្ស..
ការរស់ឡើងវិញរបស់ទ្រង់(ព្រះគិស្រ្ទ)
និង
កិច្ចការដ៏ច្រើនផ្សេងទៀតដែលលើកប
ង្ហាញនៅក្នុងព្រះគម្ពីរបរិសុទ្ធមានន័យ
អាថ៌កំបាំង
ដ៏ជ្រាលជ្រៅហួសពីប្រាជ្ញានៃមនុស្ស
ជាតិអាចពន្យល់បាន
ឬមិនអាចទាំងយល់ច្បាស់លាស់ទៀត
ផង។
យើងគ្មានហេតុផលអ្វីនឹងមន្ទិលសង្ស័
យអំពីការងាររបស់ព្រះជាម្ចាស់ទេ
គឺព្រោះយើងមិនអាចយល់ដឹងនូវអាថ៌
កំបាំងនៃផែនការរបស់ទ្រង់ឡើយ។
នៅក្នុងពិភពដែលយើងរស់នៅនេះយើ
ងម្នាក់ៗហ៊ុំព័ទ្ធដោយអាថ៌កំបាំងដែល
យើងមិនអាចប្រមើលមើលបាន។
ទំរង់នៃជីវិតដ៏សាមញ្ញបំផុតមួយក៏មាន

បញ្ហាអាថ៌កំបាំង
ដែលសូម្បីតែទស្សនវិទូដ៏ឈ្លាសវៃក៏មិនអាចមានលទ្ធភាពនឹងបកស្រាយបានដែរ។
គ្រប់ទីកន្លែងទាំងអស់ពោរពេញទៅដោយភាពអស្ចារ្យ
ដែលលើសអំពីការស្រមៃគិតរបស់យើង។
តើយើងមិនដឹងទេឬអីថាសូម្បីតែនៅក្នុង ពិភពនៃព្រលឹងវិញ្ញាណ(Spiritual world)ក៏គង់មានអាថ៌កំបាំងជាច្រើនដែលយើងមិនអាចយល់បានដែរ។
ការដែលពិបាកនឹងយល់នោះគឺឋិតនៅលើភាពកំសោយនិងភាពចង្អៀតចង្អល់នៃចិត្តមនុស្សលោកយើងតែប៉ុណ្ណោះ។
ព្រះជាម្ចាស់បានផ្តល់ឲ្យយើងនូវព្រះគម្ពីរដែលមានភស្តុតាងគ្រប់គ្រាន់អំពីល

ក្ខណៈរបស់ព្រះជាម្ចាស់ហើយយើងមិនត្រូវមានការសង្ស័យអំពីព្រះបន្ទូលរបស់ទ្រង់ឡើយ
ពីព្រោះយើងមិនអាចយល់ឲ្យអស់ពីអាថ៌កំបាំងទាំងឡាយ
នៃផែនការសង្គ្រោះរបស់ព្រះជាម្ចាស់ឡើយ។

សាវ័កពេត្រុសមានប្រសាសន៍ថាៈ
“នៅក្នុងព្រះគម្ពីរមានសេចក្តីខ្លះដែលពិបាកយល់
ហើយដែលពួកអ្នកខ្លៅល្ងង់
និងពួកអ្នកដែលមិនខ្ជាប់ខ្ជួនគេបង្វែរន័យនៃសេចក្តីទាំងនេះ
ដូចគេបង្វែរបទគម្ពីរឯទៀតៗដែរឲ្យខ្លួនគេត្រូវវិនាស”..ពេត្រុសទី២ ៣:១៦។
អ្នកដែលមានការសង្ស័យច្រើនជ្រើសសេចក្តីលំបាកនឹងយល់នៃព្រះគម្ពីរបរិ

សុទ្ធ។
ប៉ុន្តែទោះជាមានសេចក្តីបែបនេះកើតឡើងក៏ដោយ
ក៏ព្រះបន្ទូលរបស់ព្រះគម្ពីរគ្មានដំនើររឿងរ៉ាវនៃព្រះជាម្ចាស់ដោយអំណាចមកអំពីព្រះ។
ប្រសិនបើព្រះគម្ពីរគ្មានដំនើររឿងរ៉ាវនៃព្រះជាម្ចាស់ដែលអាចធ្វើឲ្យយើងយល់បានដោយងាយ..ប្រសិនបើប្រាជ្ញាមនុស្សដែលមានព្រំដែន
អាចយល់បាននូវភាពអស្ចារ្យនៃព្រះជាម្ចាស់នោះនឹងគ្មានអ្វីសម្គាល់ពីព្រះឡើយ។ ភាពដ៏អស្ចារ្យសម្បើម
និងអាថ៌កំបាំងនៃផ្ទៃរឿងដែលព្រះគម្ពីរបានបង្ហាញ
បានញ៉ាំងចិត្តយើងឲ្យមានជំនឿថានោះប្រាកដជាព្រះបន្ទូលនៃព្រះជាម្ចាស់មែន។

ព្រះគម្ពីរបរិសុទ្ធបានបើកសម្តែងនូវសច្ចភាពដោយភាពសាមញ្ញបំផុតនិងសមស្របតាមសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់មនុស្សលោក ដែលញ៉ាំងឲ្យអ្នកចេះដឹងជ្រៅជ្រះមានការស្ញើចសរសើរ និងមានការចាប់អារម្មណ៍ក្នុងខណៈដែលអ្នកល្ងង់ខ្លៅនិងមានចិត្តទន់ទាបអាចមើលឃើញផ្លូវទៅកាន់សេចក្តីសង្គ្រោះ។ សច្ចភាពដ៏សាមញ្ញ ដែលបានបញ្ជាក់មកនេះឋិតនៅលើរឿងរ៉ាវដ៏សំខាន់ នៅខ្ពស់ឆ្ងាយផុតពីអំណាចមនុស្ស ដែលអាចនឹងយល់បាន ដែលយើងអាចទទួលបានដោយសារតែព្រះជាម្ចាស់មានព្រះបន្ទូលប្រកាសប្រាប់យើងតែប៉ុណ្ណោះ។

ផែនការប្រោសលោះបានលាតត្រដាង
ចំហចំពោះយើង
ប្រយោជន៍ឲ្យមនុស្សគ្រប់ប្រាណអាច
មើលឃើញ
ជំហានដែលគេនឹងត្រូវហានឆ្ពោះទៅ
កាន់ការលន់តួបាប..ទៅកាន់ព្រះជាម្ចា
ស់
និងសេចក្តីជំនឿតម្រង់ទៅឯព្រះយេស៊ូ
គ្រិស្ទជាម្ចាស់
ដើម្បីទទួលបានសេចក្តីសង្គ្រោះពីព្រះ
ជាម្ចាស់ទៅតាមមធ្យោបាយដែលទ្រង់
បានគ្រោងទុក។
នៅក្នុងសច្ចភាពដែលងាយនឹងយល់
បានក៏ដោយ
ក៏គង់មានភាពអាថ៌កំបាំងនៃសិរីល្អរប
ស់ទ្រង់
ដែលជ្រៅលើសអស់ទាំងចិត្តដែលខំ
ស្វែងរក ក៏ប៉ុន្តែអំណាចនេះ

នឹងបើកសម្តែងដោយសេចក្តីជំនឿបា
នឃើញវិញ។
ពេលណាគេសិក្សាព្រះគម្ពីរបានកាន់
តែច្រើនឡើង
នោះគេនឹងមានសេចក្តីជំនឿកាន់តែមាំ
មួនឡើងដែរប្រាកដក្នុងចិត្តថា:
“នោះគឺជាព្រះបន្ទូលនៃព្រះដ៏រស់”។
ការលើកហេតុផលរបស់មនុស្សលោក
ត្រូវតែឱនក្រាបចំពោះភាពដ៏មហស្ចារ្យ
នៃការបើកសម្តែងនៃព្រះជាម្ចាស់។

ដើម្បីទទួលស្គាល់ថាយើងមិនអាចយ
ល់
សច្ចធម៌នៃព្រះបន្ទូលរបស់ទ្រង់នោះ
យើងត្រូវតែយល់ថាប្រាជ្ញារបស់មនុស្
សយើង
មិនអាចយល់បានពីប្រាជ្ញារបស់ព្រះ
ឡើយ។

តើធ្វើដូចម្តេចឲ្យយើងយល់ពីបំណង
ហឫទ័យនៃព្រះដ៏សព្វញ្ញាណទៅបាន
? ដោយព្រោះតែមិនអាចយល់
ដឹងគ្រប់ទាំងសេចក្តីអាថ៌កំបាំងទាំង
នោះហើយ ដែលអ្នកមេធ្វល់
និងពួកអ្នកមានចិត្តមិនស្មោះត្រង់មិនព្រមទទួលស្គាល់ព្រះបន្ទូលព្រះជាម្ចាស់
។
សូម្បីអ្នកដែលកាន់តាមព្រះគម្ពីរបរិសុទ្ធផងទាំងឡាយក៏មិនអាចចូលរួមចាកផុតពីគ្រោះថ្នាក់ត្រង់ចំនុចនេះបានគ្រប់ៗគ្នានោះដែរ។
សាវ័ករបស់ព្រះមានប្រសាសន៍ថា:
“ចូរមើចុះបងប្អូនអើយ!
ក្រែងលោក្នុងចំណោមអ្នករាល់គ្នាណាម្នាក់មានចិត្តដែលមិនជឿ
ដែលទាញអ្នកឲ្យបែរចេញ
ឆ្ងាយអំពីព្រះដ៏មានព្រះជន្មរស់”..ហេតុ

រី ៣:១២។
ជាការត្រឹមត្រូវណាស់ដែលយើងសិក្សាឲ្យបានច្បាស់និងឲ្យត្រូវតាមការបង្ហាត់បង្រៀននៃព្រះគម្ពីរបរិសុទ្ធនិងស្វែងយល់ឲ្យបានដល់ សេចក្ដីជំរៅនៃព្រះជាម្ចាស់..កូរិនថូស១ ២:១០តាមតែសេចក្ដីទាំងនោះដែលបើកសម្ដែងក្នុងព្រះគម្ពីរ។
ព្រះគម្ពីរចែងថា:
អស់ទាំងសេចក្ដីអាថ៌កំបាំងនោះស្រេចនៅលើព្រះយេហូវ៉ាជាព្រះនៃយើង..រីឯសេចក្ដីបើកសម្ដែងទាំងប៉ុន្មាននោះជាស្រេច
នៅលើយើងរាល់គ្នាវិញ..ចោទិយកថា ២៩:២៨។
កិច្ចការរបស់អារក្សសាតាំងវិញគឺអូសទាញមនុស្សណាដែលមានចិត្តមន្ទិលសង្ស័យអំពីព្រះ។

មោទនភាពបានចូលលាយឡំជាមួយ
នឹងការពិនិត្យពិចារណាទៅលើសច្ចៈធ
ម៌នៃព្រះគម្ពីរ
ដែលនាំឲ្យគេបាតើបង់ការអត់ធ្មត់
និងការទទួលអារម្មណ៍ដូចជាការបរាជ័
យ
ប្រសិនបើគេមិនអាចពន្យល់គ្រប់ផ្នែក
នៃព្រះគម្ពីរឲ្យសមស្របទៅតាមចំនង់
ពេញចិត្តរបស់គេ។
គេគិតថាការដែលមិនយល់នូវព្រះបន្ទុ
លរបស់ព្រះ
គឺជាការអាម៉ាសមុខមួយយ៉ាងខ្លាំង។
គេគ្មានសុឆន្ទៈនឹងរង់ចាំ
ដោយសេចក្តីអំណត់អត់ធ្មត់ដល់ព្រះ
ជាម្ចាស់យល់ថាជាការសមល្មមនឹងបើ
កបង្ហាញការពិតឲ្យគេបានដឹង។
គេយល់ថាប្រាជ្ញាមនុស្សដែលគ្មានជំនួ
យពីព្រះនោះគឺគ្រប់គ្រាន់នឹងអាចយ

ល់នូវអត្ថន័យនៃព្រះគម្ពីរ..ដោយការខ្វះខាតទាំងនេះគេប្រាកដជាបដិសេធនូវអំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជាការពិតណាស់ដែលមានទ្រឹស្តី និងគោលលទ្ធិប្រកបដោយប្រជាប្រិយភាពជាច្រើនដែលយើងតែងសន្មតថាបានដកស្រង់មកអំពីព្រះគម្ពីរ តែការបង្ហាត់បង្រៀនវិញគ្មានមូលដ្ឋាន ហើយការពិតការបង្រៀនអស់ទាំងនេះគឺផ្ទុយស្រលះទាំងស្រុងពីព្រះបន្ទូលនៃព្រះគម្ពីរផង។ បញ្ហាអស់នេះបានបង្កើតឡើងនៅការមោះមន្ទិលនិងភាពអល់អែកដល់មនុស្សជាច្រើន។ ការអស់ទាំងនេះមិនអាចចោទប្រកាន់ទៅលើព្រះបន្ទូលរបស់ព្រះបានទេ គឺវាកើតឡើងដោយការយល់ខុសរប

ស់មនុស្សទលើព្រះបន្ទូលរបស់ព្រះទេ
តើ។

ប្រសិនបើមនុស្សដែលជាសមិទ្ធិផលរ
បស់ព្រះ
មានលទ្ធភាពអាចនឹងយល់បានពេញ
ដ៏បរិបូណ៌អំពីព្រះនិងការងាររបស់ទ្រង់
នោះគេនឹងលែងមានការរកឃើញនូវ
សច្ចធម៌តទៅទៀតបាន
ក៏នឹងលែងមានការរីកចម្រើននៅក្នុងចំ
ណោះវិជ្ជានិងសមិទ្ធិផលនឹងឈប់លូត
លាស់ទៅមុខទៀត។
ចូរឲ្យយើងថ្លែងអំណរគុណដល់
ព្រះជាម្ចាស់ដែលរាំងទប់ឲ្យការនេះកើ
តទៅបាន។
ព្រះជាម្ចាស់គឺគ្មានអ្វីកំណត់បានឡើយ
។ នៅក្នុងទ្រង់មាន
“កំណប់នៃប្រាជ្ញានិងចំណោះវិជ្ជា”..កូ

លុស ២:៣។
ទោះបីជាមនុស្សខំស្រាវជ្រាវ
ខំរៀនសូត្ររហូតដល់ទីបំផុតក៏ដោយ
ក៏គេមិនអាចរៀនឲ្យអស់នូវកំណាប់ប្រា
ជ្ញារបស់ទ្រង់ សិរីល្អរបស់ទ្រង់
និងអំណាចរបស់ទ្រង់បានដែរ។

ព្រះមានព្រះហឫទ័យចង់ឲ្យរាស្ត្រទ្រង់
បានឃើញការសម្ដែងសច្ចធម៌នៃព្រះប
ន្ទូលរបស់ទ្រង់នៅក្នុងជីវិតរស់នៅរប
ស់គេម្នាក់ៗ។
មានតែមធ្យោបាយមួយប៉ុណ្ណោះ
ដែលអាចធ្វើឲ្យគេអាចទទួលបានចំ
ណេះវិជ្ជាទាំងនេះបាន។
យើងអាចទទួលការយល់ដឹង
នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរ
យៈការបំភ្លឺនៃព្រះវិញ្ញាណបរិសុទ្ធប៉ុ
ណ្ណោះ។ "អ្វីដែលព្រះជាម្ចាស់ដឹង

គឺគ្មានមនុស្សលោកណាអាចដឹងបាន
ឡើយ
ក្រៅអំពីព្រះវិញ្ញាណនៃព្រះជាម្ចាស់”..
កូរិនថូស១ ២:១១។
“ដ្បិតព្រះវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ព្រមទាំងសេចក្តីជ្រាលជ្រៅនៃព្រះដែរ”..កូរិនថូស១ ២:១០។
ឯព្រះបន្ទូលសន្យានៃព្រះអង្គសង្គ្រោះគឺ“កាលណាព្រះអង្គដែលជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់
នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត
ដ្បិតទ្រង់នឹងយកសេចក្តីតម្រូវអំពីខ្ញុំមកប្រាប់ដល់អ្នករាល់គ្នា”..យ៉ូហាន
១៦:១៣.១៤។

ព្រះជាម្ចាស់មានចំណង់ឲ្យមនុស្សលោក

ប្រើប្រាស់នូវអំណាចនៃការពិចារណារបស់គេ
ដើម្បីការសិក្សាព្រះគម្ពីរបរិសុទ្ធ
ដែលនឹងផ្តល់កម្លាំងនិងលើកតម្កើងនូវអារម្មណ៍របស់គេដែលគ្មានការរៀនសូត្របែបណាអាចប្រដូចបាន។
ក៏ប៉ុន្តែយើងត្រូវប្រុងប្រយ័ត្ន
នឹងមូលហេតុនៃការលើកសរសើរដំកើងខ្លួនឯងដែលជាចំនុចនៃភាពកំសោយ និងគុណវិបត្តិនៃមនុស្សជាតិ។
ប្រសិនបើយើងមិនចង់ឲ្យព្រះបន្ទូលនៃព្រះជាម្ចាស់លាក់កំបាំងអំពីការយល់ដឹងរបស់យើង
ដែលតែងតែធ្វើឲ្យសេចក្តីពិតដ៏ងាយស្រួលបែរ ជាមិនយល់ទៅវិញនោះ
យើងត្រូវតែធ្វើភាពសាមញ្ញនិងមានជំនឿដូចជាក្មេងតូចដែលរៀបខ្លួនជាស្រេចដើម្បីរៀន

និងអង្វរសុំសេចក្ដីជំនួយពីព្រះវិញ្ញាណបរិសុទ្ធ។ ការយល់ដឹងពីអំណាច និងគតិបណ្ឌិតរបស់ព្រះ និងការខ្វះសមត្ថភាពរបស់យើងក្នុងការយល់ដឹងដល់ភាពអស្ចារ្យនៃព្រះជាម្ចាស់ នឹងជំរុញឲ្យយើងបន្ទន់ចិត្តដោយសុភាពរាបសារ។ យើងត្រូវតែបើកព្រះបន្ទូលរបស់ព្រះឲ្យដូចជាយើងចូលទៅក្នុងវត្តមានរបស់ព្រះអង្គដោយក្ដីស្ញប់ស្ញែង។ នៅពេលដែលយើងមកសិក្សាព្រះគម្ពីរ យើងត្រូវដឹងថាមានអំណាចដែលលើសលប់លើអស់ទាំងហេតុផលទាំងប៉ុន្មាន និងប្រាជ្ញាផងទាំងឡាយយើងត្រូវតែឱនលំទោនទៅឯ "ព្រះជាម្ចាស់"ដ៏មហាស្ចារ្យ។

មានបញ្ហាជាច្រើនដែលហាក់ដូចជាលំបាក
ឬបែបស្រពិចស្រពិលដែលព្រះជាម្ចាស់ធ្វើឲ្យទៅជាសាមញ្ញ
និងងាយស្រួលនឹងយល់ចំពោះអ្នកដែលស្វែងរកឲ្យបានយល់នូវបញ្ហាទាំងនោះ។
បើគ្មានការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធទេ យើងនឹងមុខជា
នៅបន្តការឃ្លាតឆ្ងាយពីសច្ចធម៌នៃព្រះគម្ពីរ ឬនៅតែយល់ខុសអំពីព្រះគម្ពីរ។
មានការអានព្រះគម្ពីរខ្លះគ្មានបានទទួលផលប្រយោជន៍អ្វីដែរ
ហើយក៏បណ្ដាលឲ្យមានគ្រោះថ្នាក់ជាវិជ្ជមានថែមទៀតផង។
នៅពេលណាដែលគេបើកព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ
ដោយគ្មានសេចក្តីកោតខ្លាច

និងដោយគ្មានការអធិស្ឋានដល់ព្រះ..
នៅពេលណាដែលចិត្តគំនិត
និងសេចក្តីស្រលាញ់មិនផ្តោតភ្ជាប់ទៅ
លើព្រះជាម្ចាស់ឬមិនចុះសម្រុងជាមួ
យព្រះហឫទ័យរបស់ទ្រង់
នោះទឹកចិត្តរបស់គេនឹងត្រូវល្អក់កករ
ដោយសេចក្តីមន្ទិលសង្ស័យ
ហើយនៅពេលដែលសិក្សាព្រះគម្ពីរ
ចម្ងល់ដ៏មិនចេះអស់មិនចេះហើយក៏
កាន់តែកើតមានឡើង។
សាតាំងដែលជាបច្ចាមិត្រ
បានចូលមកត្រួតត្រាលើចិត្តគំនិតរប
ស់គេ
ហើយវានឹងឲ្យយោបល់ជាការបកស្រា
យដែលមិនត្រឹមត្រូវ។
ពេលណាមនុស្សមិនបានស្វែងរកពាក្
យសំដីនិងសកម្មភាពរបស់ខ្លួន
ឲ្យបានចុះសម្រុងនឹងព្រះទៅនោះ

ទោះជាគេមានចំណេះវិជ្ជាច្រើនយ៉ាងណាក៏ដោយ
ក៏គេនឹងមានការយល់ដឹងដោយខុសឆ្គងអំពីព្រះបន្ទូលរបស់ព្រះក្នុងគម្ពីរ
ដើម្បីរកចាប់ចំនុចកំហុសដោយអន្លើៗនោះគេពិតជាមិនបានទទួលចក្ខុវិស័យអំពីព្រះជាម្ចាស់ឡើយ។
ដោយការមើលឃើញដ៏ស្រពិចស្រពិលយ៉ាងនេះ
គេនឹងឃើញមូលហេតុជាច្រើនដែលបណ្តាលឲ្យមានសេចក្តីមន្ទិលសង្ស័យ
និងគ្មានសេចក្តីជំនឿទៅលើបញ្ហាដែលងាយស្រួលនិងសាមញ្ញាដ៏ពិតប្រាកដបានឡើយ។

—

ទោះបីជាគេខំបិទបាំងយ៉ាងណាក៏ដោយ

ក៏មូលហេតុដ៏ពិតប្រាកដនៃការមន្ទិលសង្ស័យ និងចម្ងល់ដ៏ឥតព្រំដែន
គឺជាការស្រលាញ់អំពើបាប។
មនុស្សដែលមានមោទនភាពអំនួត
និងសេចក្តីត្រេកត្រអាលនឹងអំពើបាប
ពុំព្រមទទួលស្វាគមន៍នូវការបង្ហាត់បង្រៀន
និងលក្ខខ័ណរបស់ព្រះជាម្ចាស់ឡើយ។
ចំណែកឯអ្នកដែលពុំព្រមគោរពតាមសេចក្តីតម្រូវនៃព្រះគម្ពីរ
គឺមានការមន្ទិលសង្ស័យរួចជាស្រេចអំពីអំណាចនៃព្រះគម្ពីរ។
ដើម្បីអាចឈានមកដល់សច្ចធម៌
យើងត្រូវតែមានចំណង់ដ៏ស្មោះត្រង់ចង់ដឹងនូវសេចក្តីពិត
ហើយនិងសុឆន្ទៈនឹងគោរពប្រណិបត្តន៍ដល់សច្ចធម៌ទាំងនោះ។

បើអ្នកឯណាដែលចូលមកសិក្សាព្រះគម្ពីរ
ដោយមានទឹកចិត្តយ៉ាងដូច្នោះនោះនឹងឃើញនូវភស្តុតាងដ៏បរិបូណ៌
ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់
ហើយគេនឹងមានការចម្រើនក្នុងការយល់ដឹងនៃសេចក្តីពិតនៃព្រះបន្ទូលទ្រង់
ដែលនឹងធ្វើឲ្យគេមានបញ្ញាឈ្លាសវៃ
ជាប្រយោជន៍ដល់សេចក្តីសង្គ្រោះ។

ព្រះគ្រិស្ទមានព្រះបន្ទូលថា:
“បើអ្នកណានឹងធ្វើតាមព្រះហឫទ័យទ្រង់
នោះនឹងបានដឹងថាជាសេចក្តីបង្រៀននេះមកពីព្រះ”..យ៉ូហាន៧:១៧។
ជាជាងការសាកសួរ
និងការយកចិត្តទុកដាក់ចំពោះកហុស
ដែលអ្នកពុំយល់ដឹងនោះ

ចូរប្រគល់អ្វីៗទាំងអស់ដោយចិត្តគោរពទៅរកពន្លឺដែលជះមកលើរូបអ្នកហើយនោះអ្នកនឹងបានទទួលពន្លឺថ្មីប្រសើរជាងថែមទៀត។
ដោយសារព្រះគុណនៃព្រះគ្រិស្ត
ចូរអ្នកប្រកបគ្រប់ភារកិច្ចដែលងាយស្រួលដល់ការយល់ដឹងរបស់អ្នក
ហើយអ្នកនឹងយល់ដល់កិច្ចការទាំងឡាយណាដែលអ្នកមានសេចក្តីមន្ទិលសង្ស័យ។

ភស្តុតាងតែមួយដែលបើកចំហរដល់មនុស្សគ្រប់រូប..ទាំងអ្នកមានចំណេះនិងអ្នកគ្មានចំណេះ..នោះគឺភស្តុតាងនៃបទពិសោធន៍។
ព្រះជាម្ចាស់ចង់ឲ្យយើងពិនិត្យពិច័យរកសេចក្តីពិតនៃព្រះបន្ទូលរបស់ទ្រង់និងសច្ចធម៌នៃសេចក្តីសន្យារបស់ទ្រង់

។ ទ្រង់បានហៅឲ្យយើង
“ភ្លក់មើលឲ្យឃើញថា
តើព្រះយេហូវ៉ាល្អយ៉ាងណា?..ទំនុកត
ម្កើង” ៣៤:៨។
យើងត្រូវសាកមើលដោយខ្លួនឯង
ជាជាងពឹងផ្អែកទៅលើពាក្យពេចន៍រប
ស់អ្នកឯទៀត។
ព្រះជាម្ចាស់មានព្រះបន្ទូលថា:
“ចូរឲ្យសុំនោះអ្នកបានទទួល”..យ៉ូហា
ន ១៦:២៤។
សេចក្តីសន្យារបស់ទ្រង់ទាំងប៉ុន្មាននឹង
ត្រូវបានបំពេញ។ទ្រង់មិនដែលខាននឹ
ងបំពេញអ្វីដែលទ្រង់បានសន្យាដល់
យើងនោះឡើយ។
នៅពេលដែលយើងចូលមកព្រះយេស៊ូ
កាន់តែជិតឡើងៗ
ហើយយើងមានអំនរសប្បាយ
និងសេក្តីស្រលាញ់ដ៏ពោរពេញនៅក្នុង

ទ្រង់ នោះពន្លឺនៃវត្តមានរបស់ទ្រង់
និងបំភ្លឺអស់ទាំងមន្ទិលសង្ស័យ
និងភាពអន្ធការរបស់យើង។

សាវ័កប៉ុលបានមានប្រសាសន៍ថា:
"ព្រះបានប្រោសឲ្យយើងរួចពីអំណាច
នៃសេចក្តីងងឹត
ហើយផ្លាស់យើងមកក្នុងនរគររបស់ព្
រះរាជបុត្រាស្ងួនភ្ងារនៃទ្រង់"..កូលុស
១:១៣។
ហើយមនុស្សម្នាក់ៗដែលដើរចេញពី
សេចក្តីស្លាប់មកឯជីវិតគឺអាច
យល់ព្រម
បោះត្រាដៅចំណាំទុកថាគេអាចធ្វើជា
ទីបន្ទាល់ថា:"ខ្ញុំត្រូវការជំនួយ
ហើយខ្ញុំរកឃើញសេចក្តីជំនួយនោះ
នៅក្នុងព្រះយេស៊ូ"។
សេចក្តីត្រូវការទាំងអម្បាលម៉ានក៏បាន

ផ្តល់
ហើយការស្រេកឃ្លាននៃព្រលឹងរបស់ខ្ញុំក៏បានបំពេញសព្វគ្រប់
ហើយឥឡូវនេះជំពោះរូបខ្ញុំព្រះគម្ពីរបរិសុទ្ធគឺជាការបើកសម្តែងនៃព្រះយេស៊ូគ្រីស្ទ។
បើលោកអ្នកនឹងសួរខ្ញុំថាហេតុអ្វីបានជាខ្ញុំមានជំនឿដល់ព្រះយេស៊ូគ្រីស្ទ
នោះខ្ញុំនឹងឆ្លើយជំរាបថា:“ចំពោះរូបខ្ញុំព្រះយេស៊ូគឺជាព្រះអង្គសង្គ្រោះ”។
ហេតុអ្វីបានជាខ្ញុំមានជំនឿលើព្រះគម្ពីរ? ..ពីព្រោះខ្ញុំបានរកឃើញថា
ព្រះគម្ពីរគឺជាព្រះបន្ទូលមកកាន់ព្រះព្រលឹងរបស់ខ្ញុំ។
យើងអាចមានកសិណសាក្សីដោយខ្លួនយើងផ្ទាល់
ថាព្រះគម្ពីរគឺពិតប្រាកដមែន
ដែលព្រះគ្រិស្ទគឺជាព្រះរាជបុត្រានៃព្

រះជាម្ចាស់។
យើងដឹងដោយប្រាកដថាយើងពុំមែន
ដើរតាមរឿងព្រេងនិទានដែលបង្កើត
ឡើងដោយល្បិចកលដ៏ប៉ិនប្រសប់
របស់មនុស្សនោះទេ។
លោកពេត្រុសដាស់តឿនដល់បងប្អូន
ស្ងួនភ្ងាររបស់គាត់ថា:
“ចូរអ្នករាល់គ្នាចម្រើនឡើងក្នុងព្រះគុ
ណ
និងក្នុងការស្គាលដល់ព្រះយេហូវ៉ាជាព្
រះនៃយើង
និងព្រះយេស៊ូគ្រិស្ទជាព្រះសង្គ្រោះនៃ
យើងរាល់គ្នា..ពេត្រុសទី២”៣:១៨។
នៅពេលដែលកូនចៅនៃព្រះ
រីកចម្រើនផ្នែកព្រះគុណ
គេនឹងបានទទួលជាប្រក្រតីនូវការយ
ល់ដឹងយ៉ាងច្បាស់លាស់នៃព្រះបន្ទូលរ
បស់ទ្រង់។ គេនឹងបើកឃើញពន្លឺថ្មី

និងសោភ័ណភាពនៃសច្ចធម៌ដ៏ពិសិដ្ឋ
ក្នុងពន្លឺនោះ។
ទាំងនេះគឺជាការពិតនៅក្នុងប្រវត្តិសា
ស្ត្រនៃក្រុមជំនុំគ្រប់សម័យកាល
ហើយការពិតនេះនឹងបន្តរហូតដល់ទីបំ
ផុតផង។
ផ្លូវរបស់មនុស្សសុចរិតធៀបដូចជា
ពន្លឺដែលកំពុងតែរះឡើង
ដែលភ្លឺកាន់តែខ្លាំង
ឡើងៗរហូតដល់ពេញកម្លាំង..សុភា
សិត ៤:១៨។

ដោយសារសេចក្តីជំនឿដល់ព្រះ
នោះយើងមើលឃើញចាប់ពីពេលនេះ
តទៅ
ហើយរក្សាខ្ជាប់នូវសេចក្តីសន្យានៃព្រះ
ជាម្ចាស់ដើម្បីឲ្យមានការលូតលាស់រីក
ចម្រើនខាងប្រាជ្ញាស្មារតី..ប្រាជ្ញាមនុ

ស្បូលោកផ្សារភ្ជាប់នឹងព្រះជាម្ចាស់
ហើយគ្រប់ទាំងអំនាចនៃយើងនាំចូល
មកផ្គាល់ជាមួយប្រភពពន្លឺ។
យើងអាចមានសេចក្តីអំណររីករាយ
ពីព្រោះអ្វីៗដែលធ្វើឲ្យយើងមានការស្
រពិចស្រពិលពីមុនមកបានក្លាយជាសា
មញ្ញ។
អ្វីដែលពិបាកយល់នឹងមានចម្លើយស្
រាយបំភ្លឺ
ហើយនៅទីណាដែលអារម្មណ៍
សាមញ្ញរបស់យើងតែងតែមានការភ័ន្ត
ច្រលំ
យើងនឹងឃើញនូវការចុះសម្រុងគ្នាយ៉ា
ងល្អឥតខ្ចោះទៅវិញ។
"ត្បិតឥឡូវនេះយើងមើលឃើញបែប
ស្រអាប់ដូចជាដោយសារកញ្ចក់
តែវេលានោះនឹងឃើញមុខទល់នឹងមុខ
..ឥឡូវនេះខ្ញុំស្គាល់មិនទាន់អស់តែនៅ

វេលានេះ
ខ្ញុំនឹងស្គាល់ដូចជាព្រះទ្រង់ស្គាល់ដែរ”.
.កូរិនថូសទី១ ១៣:១២។

# ជំពូក ១៣ — សេចក្ដីអំណររីករាយក្នុងព្រះអម្ចាស់

ព្រះអរម្ចាស់បានដង្ហោយហោរាស្រ្តរបស់ទ្រង់
ឲ្យធ្វើជាអ្នកតំណាងរបស់ព្រះគ្រិស្ទ
ដើម្បីនឹងធ្វើសេចក្ដីបន្ទាល់អំពីសេចក្ដីល្អ
និងសេចក្ដីអាណិតមេត្តារបស់ព្រះយេហូវ៉ា។
ដូចដែលព្រះគ្រិស្ទបានបើកសម្ដែងឲ្យយើងឃើញនូវអត្តចរិកដ៏ពិតប្រាកដនៃព្រះវរបិតា
ដូច្នោះយើងត្រូវតែបង្ហាញព្រះគ្រិស្ទ
ទៅកាន់លោកីយដែលពុំទាន់ស្គាល់នូវសេចក្ដីស្រលាញ់ដ៏ស្រទន់
និងសន្ដោសរបស់ទ្រង់ផងដែរ។

ព្រះគ្រិស្ទមានព្រះបន្ទូលថា:
“ដូចជាទ្រង់បានចាត់ទូលបង្គំឲ្យមកក្នុងលោកិយដែរ
ដូច្នោះហើយទើបទូលបង្គំចាត់គេឲ្យទៅក្នុងលោកិយដែរ”..យ៉ូហាន១៧:១៨។
គឺទូលបង្គំនៅក្នុងគេហើយទ្រង់គង់ក្នុងទូលបង្គំ
ប្រយោជន៍ឲ្យលោកិយបានដឹងថាគឺទ្រង់ដែលចាត់ទូលបង្គំមក..យ៉ូហាន១៧:២៣។
សាវ័កប៉ុលបានមានប្រសាសន៍ទៅកាន់សាវ័កដទៃទៀតថា:
“គឺអ្នករាល់គ្នាជាសំបុត្ររបស់ខ្ញុំហើយទាំងកត់ទុកក្នុងចិត្តយើងខ្ញុំផងដែលមនុស្សទាំងអស់ក៏ដឹងហើយអានមើលដែរ”..កូរិនថូស២ ៣:២។
ព្រះគ្រិស្ទផ្ញើរសំបុត្រទៅកាន់លោកិយ

តាមរយៈរាស្ត្ររបស់ទ្រង់គ្រប់ៗរូប។ ប្រសិនបើអ្នកជាអ្នកដើរតាមព្រះគ្រិស្ទ នោះអ្នកជាអ្នកនាំសាររបស់ព្រះ ទៅកាន់ក្រុមគ្រួសារ ភូមិស្រុកគ្រប់ច្រកល្ហកដែលអ្នករស់នៅ។

ព្រះគ្រិស្ទដែលគង់នៅក្នុងខ្លួនអ្នកមានចំណង់យ៉ាខ្លាំងនឹងមានព្រះបន្ទូលទៅកាន់ចិត្តអស់អ្នកណាដែលមិនទាន់ស្គាល់ទ្រង់។

ប្រហែលជាគេមិនដែលបានអានព្រះគម្ពីរឬ កំពុំឃើញសេចក្តីស្រលាញ់នៃព្រះជាម្ចាស់តាមរយៈការងាររបស់ទ្រង់ផង។ ប្រសិនបើអ្នកជាអ្នកតំណាងរបស់ព្រះគ្រិស្ទដ៏ពិតប្រាកដមែននោះអ្នកដទៃនឹងបានណែនាំឲ្យយល់ខ្លះៗនូវសិរីល្អរបស់ទ្រង់

និងមានសេចក្តីស្រលាញ់និងបំរើដល់
ព្រះជាម្ចាស់តាមរយៈរូបអ្នក។

អ្នកគ្រិស្ទានដែលកាន់ពន្លឺប្រទីប
បំភ្លឺផ្លូវទៅឯស្ថានសួគ៌។
គេត្រូវតែបង្ហាញទៅដល់លោកិយនូវព
ន្លឺដែលចេញមកអំពីព្រះគ្រិស្ទ។ ជីវិត
និងអត្តចរិក
របស់គេគួរតែជាគំរូរដល់អ្នកដទៃ
ប្រយោជន៍ឲ្យអ្នកទាំងនោះទទួលការ
យល់ដឹងដ៏ត្រឹមត្រូវអំពីព្រះគ្រិស្ទ
និងកិច្ចការរបស់ព្រះអង្គ។

ប្រសិនបើយើងតំណាងឲ្យព្រះគ្រិស្ទ
យើងនឹងធ្វើកិច្ចការរបស់ទ្រង់លេចឡើ
ង
គួរឲ្យចាប់ចិត្តទៅតាមធាតុពិតនៃកិច្ច
ការទាំងនោះដែរ។

អ្នកគ្រិស្ទានដែលប្រមូលផ្ដុំតែភាពអពមង្គល
និងហ្មងសៅដាក់ក្នុងវិញ្ញាណរបស់គេ
ហើយខ្សឹមខ្សៀវនិង រអ៊ូរទាំ
គឺបានបង្ហាញអ្នកដទៃនូវភាពតំណាងក្លែងក្លាយរបស់ព្រះជាម្ចាស់
និងជីវិតមានសេចក្ដីសុខសាន្តឡើយ
ហើយដោយសារដូច្នោះគេមានសេចក្ដីបន្ទាល់ក្លែងក្លាយប្រឆាំងនឹងព្រះវរបិតានៃស្ថានសួគ៌របស់យើង។

អារក្សសាតាំងអបអរក្រៃលែងនៅពេលដែលវាអាចដឹកនាំកូនចៅរបស់ព្រះឲ្យចូលក្នុងភាពគ្មានជំនឿ
និងភាពអស់ទឹកចិត្ត។
វាសប្បាយរីករាយដោយឃើញយើងមិនទុកចិត្តនឹងព្រះជាម្ចាស់
មានសេចក្ដីមន្ទិលសង្ស័យអំពីព្រះរាជ

បំណងនិងព្រះចេស្ដារបស់ទ្រង់ក្នុងផែនការសង្គ្រោះយើង។
វាពេញចិត្តនឹងធ្វើឲ្យយើងទទួលអារម្មណ៍ថាព្រះអម្ចាស់នឹងធ្វើឲ្យមានការគ្រោះថ្នាក់
ដល់រូបយើងដោយសារតែទិព្វញាណរបស់ទ្រង់។
គឺជាការងាររបស់អារក្សសាតាំងដែលបង្ហាញឲ្យគេឃើញព្រះបែបដូចជាខ្វះធម្មមេត្តានិងសេចក្តីអាណិតអាសូរ។
វាបំភ្លៃសច្ចធម៌ដែលទាក់ទិនដល់ព្រះជាម្ចាស់។
វាបំពេញអារម្មណ៍នូវការស្រមើស្រមៃនិងអារម្មណ៍មិនពិតដែលទាក់ទងនឹងព្រះជាម្ចាស់ហើយដោយមិនតាំងលើសច្ចធម៌ព្រះជាម្ចាស់នោះយើងបែរជាផ្ចង់អារម្មណ៍របស់យើងទៅលើការបង្ហាញខុសនៃអារក្សសាតាំងហើយបង្

អាប់បង្អោនព្រះជាម្ចាស់ដោយការមិនទុកចិត្តទ្រង់
ព្រមទាំងខ្សិបខ្សៀវប្រឆាំងនឹងទ្រង់។ អារក្សសាតាំងថែមទាំងស្វែងរកឱកាសនឹងធ្វើឲ្យអស់អ្នកមានសេចក្តីជំនឿសាសនាមានការស្រពាប់ស្រពោន។ សាតាំងចង់ធ្វើឲ្យមានការនឿយណាយនិងបាកវេទនា
ហើយនៅពេលអ្នកគ្រិស្ទានមើលឃើញ
ជីវិតរបស់គេក្នុងទិដ្ឋភាពនៃសាសនាបែបនេះ
កាលបើគេពុំមានសេចក្តីជំនឿមទាំផងនោះក៏ធ្លាក់ចុះទៅក្នុងការកុហកបោកប្រាសរបស់អារក្សសាតាំងជាលើកទី២។

— មានមនុស្សជាច្រើន
ដើរតាមគន្លងផ្លូវនៃជីវិតរស់នៅតែលើ
កំហុស ការបរាជ័យ
និងការខកចិត្តហើយចិត្តរបស់គេពោរ
ពេញទៅដោយភាពទុក្ខសោកនិងការ
អស់សង្ឃឹម។
នៅពេលខ្ញុំទៅឯប្រទេសនៅទ្វីបអឺរ៉ុប
មានស្ត្រីម្នាក់ដែលធ្វើបែបនេះ
ហើយមានទុក្ខកង្វល់យ៉ាងធ្ងន់បានសរ
សេរសំបុត្រមកខ្ញុំដើម្បីសូមនូវពាក្យ
លើកទឹកចិត្តខ្លះៗ។
នៅរាត្រីបន្ទាប់ខ្ញុំអានលិខិតរបស់ស្ត្រី
នោះហើយខ្ញុំបានសុបិន្តឃើញថាខ្ញុំបា
នទៅឯសួនច្បារមួយ
ហើយមានមនុស្សម្នាក់ដែលហាក់ដូច
ជាម្ចាស់នៃសួនច្បារនោះជាអ្នកជួយដឹ
កនាំខ្ញុំតាមគន្លងនៃសួនច្បារ។
ខ្ញុំកំពុងតែបេះផ្កាផងទាំងឡាយ

ក្នុងចិត្តត្រេកត្រអាលនឹងគន្ធពិដោរនៃ
ផ្កាទាំងនោះស្រាប់តែស្ត្រីនោះដែលដើ
រមកពីម្ខាងខ្ញុំបានហៅខ្ញុំឲ្យបែរអារម្ម
ណ៍មកឯបន្លាខ្លះ
ដែលមើលមិនឃើញនៅច្រូងច្រាងរាំង
លើផ្លូវនាង។
នៅទីនោះនាងបានខ្វល់ខ្វាយចិត្តយ៉ាង
ខ្លាំង។
នាងមិនបានដើរតាមគន្លងផ្លូវអ្នកដែល
នាំនាងនោះទេ
ប៉ុន្តែបែរជាដើរនៅកណ្តាលបន្លាទៅវិ
ញ។ នាងទួញសោកថា:
“ឱ!គួរឲ្យស្តាយណាស់ដែលសួនច្បារ
ដ៏ស្រស់ត្រកាលនេះបែរជាខូចដោយ
សារបន្លទៅវិញ!”។
នៅពេលនោះអ្នកនាំផ្លូវក៏ពោលថា:
ចូរកុំរវល់នឹងបន្លាទាំងនោះវានាំឲ្យតែអ្ន
កមានរបួសផ្លូវចិត្តទេ

ចូរប្រមែប្រមូលផ្កាគ្រប់យ៉ាងទាំងនេះទៅ។

តើគ្មានចំណុចដ៏ភ្លឺថ្លាណានៅក្នុងការពិសោធន៍របស់អ្នកទេឬអី?
តើអ្នកមិនដែលមានរយៈពេលដ៏ថ្លៃថ្លាណាមួយនៅពេលដែលចិត្តរបស់លោកអ្នកប្រកបដោយក្ដីអំណររីករាយក្នុងការឆ្លើយតបទៅនឹងព្រះវិញ្ញាណនៃព្រះយេហូវ៉ាទេឬ?
នៅពេលដែលលោកអ្នកក្រលេកមើលទៅទំព័រនៃការពិសោធន៍ជីវិតរបស់លោកអ្នក
តើលោកអ្នកមិនបានឃើញទំព័រដែលប្រកបដោយសេចក្ដីអំណរសប្បាយទេឬអី?
តើទាំងអស់នេះមិនមែនគឺជាពាក្យសន្យានៃព្រះជាម្ចាស់ដែលប្រៀបបានទៅ

នឹងគន្ធពិដោនៃបុប្ផាជាតិដែលដុះលូត
លាស់នៅតាមផ្លូវរបស់លោកអ្នក
គ្រប់ទាំងជំហាន៍នោះទេឬអ្វី?
តើលោកអ្នកនឹងមិនឲ្យសោភ័ណភាព
និងភាពផ្អែមល្ហែមទាំងនោះបំពេញចិត្ត
លោកអ្នកដោយសេចក្ដីអំរទេឬអ្វី?

បន្លាទាំងនោះនឹងគ្រាន់តែធ្វើឲ្យអ្នកមា
នរបួសតែប៉ុណ្ណោះ
ហើយប្រសិនបើលោកអ្នកប្រមែប្រមូ
លតែរបស់ទាំងនោះ
ហើយបង្ហាញទៅកាន់អ្នកដទៃនោះ
ក្រៅអំពីការប្រមាថដល់ព្រះគុណដ៏វិ
សេសវិសាលនៃព្រះជាម្ចាស់ដោយរូប
អ្នកផ្ទាល់
តើមិនមែនជារូបអ្នកដំណើរឯទៀតដែ
លនៅជុំវិញអ្នកមិនឲ្យដើរទៅក្នុងវិថីជីវិ
ត?

វាមិនមែនជាអំពើដែលប្រកបដោយគតិបណ្ឌិតសោះ
បើយើងប្រមែប្រមូលតែ
អនុស្សាវរីយដែលមិនល្អទាំងឡាយពីអតីតកាល..អំពើអាក្រក់
និងការខកចិត្តនិយាយតែអំពីរឿងនិងយំសោកតែអំពីរឿងនោះដរាបដល់យើងទន់ខ្សោយដោយការអស់ទឹកចិត្ត។
មនុស្សដែលអស់ទឹកចិត្តមានចិត្តពោរពេញទៅដោយភាពអន្ធការបិទបាំងអស់ទាំងពន្លឺពីព្រះជាម្ចាស់ដែលបំភ្លឺវិញ្ញាណរបស់គេហើយស្រមោលនោះក៏បិទបាំងរាំងផ្លូវអ្នកដទៃទៀត។

ចូរយើងថ្លែងអំណរគុណដល់ព្រះជាម្ចាស់ចំពោះរូបភាពដ៏ត្រចង់ច្បាស់ដែលទ្រង់បង្ហាញដល់យើងរាល់គ្នា។
ចូរយើងរាល់គ្នាប្រមែប្រមូលអស់ទាំង

សេចក្ដីអះអាងផានាវ៉ាបរង់មានពរនៃ
សេចក្ដីស្រលាញ់របស់ទ្រង់
ប្រយោជន៍យើងអាចមើលទៅសេចក្ដី
វ៉ាប់រងទាំងនោះជានិច្ចជាកាល។
ព្រះរាជបុត្រានៃព្រះជាម្ចាស់ចាកចោ
លបល្ល័ង្គនៃព្រះវរបិតារបស់ទ្រង់
ហើយបានប្រដាប់ព្រះកាយទ្រង់ដោយ
ភាពជាមនុស្ស ដើម្បីអាចជួយ
សង្គ្រោះយើងរាល់គ្នាឲ្យរួចអំពីអំណាច
នៃអារក្សសាតាំង។
ជ័យជំនះរបស់ទ្រង់ដើម្បីបុព្វហេតុរប
ស់យើង
បើកចំហស្ថានសួគ៌ចំពោះមនុស្សលោ
កហើយបង្ហាញដល់គេនូវវត្តមាននៃទី
បរិសុទ្ធ
ដែលព្រះជាម្ចាស់បើកសម្ដែងឲ្យឃើញ
នូវសិរីល្អរបស់ទ្រង់។
ដំណពូជនៃមនុស្សបានក៏បានលើកថេ

ញអំពីរណ្តៅនៃសេចក្តីវិនាសដែលអំពើបាបបានជំរុញទំលាក់ទៅ
ហើយបាននាំគេឲ្យមានការភ្ជាប់ទាក់ទងឡើងវិញជាមួយព្រះជាម្ចាស់ដ៏អស់កល្ប
ហើយគេទ្រាំអត់ធន់នឹងការសាកល្បងនៃព្រះរម្ចាស់តាមរយៈសេចក្តីជំនឿនៅក្នុងព្រះដ៏ប្រោសលោះនៃយើង..គ្របដណ្តប់ដោយនូវភាពសុចរិតនៃព្រះគ្រិស្ទ
និងសរសើរតម្កើងដល់បល្ល័ង្គនៃព្រះជាម្ចាស់។
ទាំងអស់នេះជារូបភាពដែលព្រះជាម្ចាស់ឲ្យយើងផ្ចង់ចិត្តមើល។

នៅពេលណាដែលយើង
ហាក់ដូចជាមន្ទិលសង្ស័យចំពោះសេចក្តីស្រលាញ់របស់ទ្រង់

ហើយមិនទុកចិត្តលើពាក្យសន្យារបស់ទ្រង់
នោះយើងប្រមាថមើលងាយដល់ទ្រង់ ហើយធ្វើឲ្យមានកង្វល់ដល់ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ផង។
តើមាតាទទួលអារម្មណ៍យ៉ាងណាដែរ ប្រសិនបើកូនរបស់នាងរអ៊ូរទាំជាប់តែអំពីនាងហាក់ដូចជារូបនាងជាមាតាគ្មានបំណងល្អចំពោះរូបគេ?
តែតាមការពិតការព្យាយាមនៃជីវិតរបស់នាងទាំងស្រុងគឺដើម្បីតែផលប្រយោជន៍
និងភាពសុខស្រួលរបស់កូន?
បើប្រសិនគេមន្ទិលសង្ស័យចំពោះសេចក្តីស្រលាញ់របស់នាង
គេធ្វើឲ្យនាងជាមាតាមានការខកចិត្តយ៉ាងខ្លាំង។
តើមាតាបិតាទទួលអារម្មណ៍យ៉ាងណា

ទៅនៅពេលដែលកូនប្រព្រឹត្តយ៉ាងដូច្នោះមកលើរូបគាត់?
តើព្រះវរបិតានៃនគរស្ថានសួគ៌មានព្រះហឫទ័យយ៉ាងដូចម្ដេច
នៅពេលដែលយើងមិនទុកចិត្តដល់សេចក្ដីស្រលាញ់របស់ទ្រង់..ជាសេចក្ដីស្រលាញ់ដែលនាំឲ្យទ្រង់ប្រទានព្រះរាជបុត្រាដ៏ជាទីស្ងួនភ្ងាតែមួយអង្គគត់របស់ទ្រង់ដើម្បីឲ្យយើងមានជីវិតគង់នៅនោះ? សាវ័កម្នាក់បានសរសេរថា: “ឯព្រះអង្គដែលមិនបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើត
គឺបានបញ្ជូនទ្រង់មកជំនួសនៃយើងរាល់គ្នា
នោះតើមានទំនងអ្វីឲ្យទ្រង់មិនប្រទានគ្រប់របស់ទាំងអស់មកយើងរាល់គ្នា”..រ៉ូម៨:៣២។
ប៉ុន្តែតើមានមនុស្សប៉ុន្មាននាក់ដែល

ទោះជាគេមិនបញ្ចេញវាថា
ក៏បានសម្ដែងចេញឲ្យឃើញតាម
រយៈសកម្មភាពរបស់គេថាៈ
ព្រះជាម្ចាស់ពុំមានបំណងបែបនេះមក
កាន់គេឡើយ។
ប្រហែលជាទ្រង់ស្រលាញ់អ្នកដទៃ
ក៏ប៉ុន្តែទ្រង់មិនស្រលាញ់ខ្ញុំទេ។
គំនិតបែបនេះធ្វើឲ្យមានគ្រោះថ្នាក់ដ
ល់ព្រលឹងអ្នកផ្ទាល់
ព្រោះថាគ្រប់ពាក្យនៃការមន្ទិលសង្ស័
យ ដែលពោលចេញពីបបេរមាត់យើង
គឺជាការអន្ទងហៅសេចក្តីល្បួងល្បួងរ
បស់អារក្សសាតាំង។
ការល្បួងល្បួងនេះនឹងបង្កើនទមនោចិ
ត្តរបស់អ្នកដែលមន្ទិលសង្ស័យ
នោះឲ្យកើនឡើងហើយវាបណ្ដាលឲ្យ
ពពួកទេវតានៃដំណឹងល្អមានការព្រួយ
ចិត្តផងដែរ។

នៅពេលដែលអារក្សសាតាំងល្បួងល្បួងអ្នក
ចូរកុំបន្លឺចេញនូវពាក្យមួយម៉ាត់ណាដែលមានការមន្ទិលសង្ស័យឬសេចក្ដីងងឹតឡើយ។
ប្រសិនបើអ្នកសម្រេចចិត្តបើកចំហរទ្វារទទួលសំណូមពររបស់អារក្សសាតាំងចិត្តរបស់អ្នកនឹងត្រូវបានបំពេញដោយការមិនទុកចិត្ត
និងសេចក្ដីចម្ងល់ប្រឆាំងបះបោរតតាំងនឹងព្រះ។
ប្រសិបើអ្នកបញ្ចេញអារម្មណ៍ដែលមានការមន្ទិលសង្ស័យគ្រប់ទាំងសេចក្ដីមន្ទិលដែលអ្នកសម្ដែងចេញមកនោះ
មិនត្រឹមតែមានប្រតិកម្មមកលើខ្លួនអ្នកប៉ុណ្ណោះទេ
ប៉ុន្តែក៏ជាគ្រាប់ពូជដែលដុះពន្លកលូតលាស់ឡើង

បង្កើតផ្លែផ្កាទៅក្នុងជិវិតអ្នកដទៃថែម
ទៀតផង។
អំពើនោះវាមិនអាចនឹងបន្សាបឥទ្ធិពល
នៃពាក្យរបស់អ្នកឡើយ។
លោកអ្នកផ្ទាល់ប្រហែលជាអាចរើបំរះ
ចេញអំពីរជ្ជូវនៃសេចក្ដីល្បួងនោះ
និងរួចពីអន្ទាក់របស់អារក្ស៊សាតាំងបា
នក៏ប៉ុន្តែ
អ្នកដទៃទៀតដែលត្រូវបានរវាតចេញ
ដោយឥទ្ធិពលរបស់អ្នក
ប្រហែលជាមិនអាចរត់គេចអំពីការបា
ត់បង់សេចក្ដីជំនឿដែលអ្នកបានបង្ក
នោះឡើយ។
ដូច្នោះជាការសំខាន់ណាស់ដែលយើង
ត្រូវតែពោលតែអ្វីដែលនឹងផ្ដល់នូវកម្លាំ
ងដល់វិញ្ញាណនិងជិវិតតែប៉ុណ្ណោះ។

ពពួកទេវតាកំពុងតែត្រងត្រាប់ពាក្យពេចន៍របស់អ្នក
តើអ្នកពោលបែបណាទៅកាន់លោកិយអំពីព្រះជាម្ចាស់នៃស្ថានសួគ៌។
ចូរឲ្យការសន្ទនារបស់អ្នកនិយាយតែអំពីព្រះអម្ចាស់ដែលគង់នៅ
ដើម្បីជួយអង្វរករជំនួសយើងចំពោះព្រះភ័ក្រព្រះវរបិតា។
នៅពេលដែលអ្នកកាន់ដៃមិត្តរបស់អ្នក
ចូរឲ្យការសរសើរតម្កើងទៅដល់ព្រះជាម្ចាស់បានស្ថិតនៅលើបបូរមាត់របស់អ្នក
និងជ្រាបដល់ឰដ៏ផ្ទៃក្នុងនៃចិត្តរបស់អ្នក។
កាយវិការបែបនេះនឹងទាក់ទាញអារម្មណ៍របស់គេទៅលើព្រះយេស៊ូ។

គ្រប់គ្នាមានសេចក្តីវេទនា
និងទុក្ខព្រួយដែលលំបាកនឹងទ្រាំទ្រ
និងការល្បួងល្បងដែលលំបាក
នឹងទប់ទល់។
ចូរកុំប្រាប់បញ្ហាទាំងប៉ុន្មានរបស់អ្នក
ទៅមនុស្សផងទាំងឡាយដែលមាននិ
ស្ស័យសាច់ឈាមទន់ខ្សោយជាកម្មវត្ថុ
នៃសេចក្តីស្លាប់
ប៉ុន្តែចូរថ្វាយគ្រប់ទាំងអ្វីៗដល់ព្រះក្នុង
សេចក្តីអធិស្ឋាន។
ចូរបង្កើតជាច្បាប់មួយសម្រាប់រូបអ្នក
ដែលមិនពោលពាក្យមួយម៉ាត់ណា
លៃមានមន្ទិលសង្ស័យ
ឬការអស់ទឹកចិត្ត។
អ្នកមានលទ្ធភាពយ៉ាងច្រើនដើម្បីជួយ
បំភ្លឺជីវិតអ្នកដទៃទៀត
និងចម្រើនកម្លាំងដល់ការព្យាយាមប្រឹ
ងប្រែងរបស់គេ

ដោយនូវពាក្យសំដីដែលប្រកបដោយសេចក្តីសង្ឃឹម
និងសេចក្តីអំណរបរិសុទ្ធ។

— មានមនុស្សក្លាហានជាច្រើន ដែលទទួលសម្គាល់យ៉ាងឈឺចុកចាប់ ដោយសារតែការល្បងល្បង ហើយស្ទើរតែបាត់បង់ស្មារតីក្នុងការវិវាទជាមួយអំណាចនៃអារក្សសាំតាំង។ ចូរកុំឲ្យមានករាអស់ទឹកចិត្តដូចអ្នកដែលធ្វើការតស៊ូយ៉ាងលំបាកស្វិតស្វាញនេះ។
ចូរជួយអបអរគេដោយពាក្យពេចន៍ប្រកបដោយក្តីសង្ឃឹម
និងសេចក្តីក្លាហានដែលនឹងជួយជំរុញគេ ឲ្យធ្វើដំណើរតាមផ្លូវតទៅទៀត។ ធ្វើដូច្នោះពន្លឺនៃព្រះគ្រីស្ទនឹងភ្លឺចិញ្ចែងចេញពីរូបអ្នក។

“ត្បិតគ្មាននរណាម្នាក់ក្នុងចំណោមមនុស្សយើងដែលរស់សម្រាប់ខ្លួនឯងទេ”.. រ៉ូម ១៤:៧។
អ្នកដទៃបានទទួលការលើកទឹកចិត្តនិងចម្រើនកម្លាំង ឬក៏អស់ទឹកចិត្ត ឬរវាតឆ្ងាយអំពីព្រះគ្រិស្ទ និងសេចក្តីពិតរបស់ទ្រង់ដោយសារតែឥទ្ធិពលដែលចេញពីយើង ដោយមិនដឹងខ្លួនសឹងក៏មាន។

មានមនុស្សជាច្រើនដែលមានគំនិតយល់ខុសអំពីជីវិតនិងអត្តចរិកនៃព្រះគ្រិស្ទជាម្ចាស់។ គេគិតថាទ្រង់គ្មានភាពកក់ក្តៅ និងសប្បាយរីករាយទាល់តែសោះពោលគឺទ្រង់តែងតែ ម៉ឺងម៉ាត់ និងគ្មានអំណរ។ នៅក្នុងករណីជាច្រើនដែលការអនុវត្ត

ន៍ក្នុងសាសនាទាំងមូល
គឺត្រូវបានលាបពណ៌ដោយទស្សនៈដ៏
ស្រអាប់ដូច្នេះទៅវិញ។
គេតែងនិយាយថាព្រះយេស៊ូទ្រង់តែង
តែព្រះកន្សែង
ក៏ប៉ុន្តែគេមិនដែលឃើញទ្រង់ញញឹម
សោះ។
ព្រះសង្គ្រោះនៃយើងពិតជាព្រះមួយអ
ង្គពោរពេញដោយសេចក្តីទុក្ខព្រួយ
ហើយស្គាល់តែសេចក្តីសោយសោក
ពីព្រោះតែទ្រង់បើកចំហចិត្តរបស់ទ្រង់
ទៅគ្រប់អស់ទាំងសត្រូវនៃមនុស្សលោ
ក។
ទោះបីជាជីវិតរបស់ទ្រង់គឺជាការបរិច្ចា
កនិងគ្របដណ្តប់ដោយការឈឺចាប់
និងការខ្វល់ខ្វាយក៏ដោយ
ក៏ព្រះវិញ្ញាណរបស់ទ្រង់មិនបែកបាក់
ឡើយ។

ទឹកមុខរបស់ទ្រង់ពុំបង្ហាញនូវទុក្ខសោ
កនិងហ្មងសៅ
ប៉ុន្តែជាទឹកមុខដែលមានភាពស្ងប់ស្ងា
ត់ ប្រកបដោយសន្តិភាពក្នុងផ្លូវចិត្ត។
ព្រះហឫទ័យរបស់ទ្រង់គឺជាប្រភពទឹក
ផុសនៃជីវិត
ហើយនៅគ្រប់ទីកន្លែងដែលទ្រង់យាង
ទៅដល់ទ្រង់នាំទៅជាមួយនូវការសំរា
ក..សេចក្តីស្ងប់សន្តិភាព..ភាពរីករាយ
និងអំណរសប្បាយ។

ព្រះអង្គអង្គសង្គ្រោះនៃយងគឺប្រាកដប្
រជាណាស់
ហើយក៏ស្មោះអស់ពីចិត្តយ៉ាងប្រាកដ
ដែរ
ក៏ប៉ុន្តែទ្រង់មិនដែលស្រពាប់ស្រពោន
នឹងទុក្ខព្រួយឡើយ។
ជីវិតរបស់អ្នកណា

ដែលគ្រាប់តាមទ្រង់នឹងបានពោរពេញទៅដោយគោលបំណងដ៏ស្មោះជាទីបំផុត។
គេនឹងមានចិត្តទទួលខុសត្រូវយ៉ាងខ្ពស់។
អ្នកឯណាដែលលេងសើចមិនយកចិត្តទុកដាក់នឹងត្រូវកែប្រែអប់រំ។
សំណើចស្រវឹងក្អាកក្អាយ
ការកំប្លែងសើចចំអក
នឹងមិនមានឡើយ
ក៏ប៉ុន្តែសាសនានៃព្រះយេស៊ូ
ផ្តល់មកនូវសន្តិភាពដូចជាទឹកទន្លេហើយមិនមែនមកបំបាត់អំណរសប្បាយឬធ្វើឲ្យកករល្អក់ដល់ទឹកមុខញញឹមរីករាយនោះក៏ទេដែរ។
ព្រះយេស៊ូគ្រិស្ទយាងមកមិនមែនសម្រាប់ឲ្យយើងបៀនប្រដៅទ្រង់ទេ
តែទ្រង់យាងមកនេះដើម្បីបៀនប្រដៅ

យើងវិញ
ហើយនៅពេលដែលសេចក្តីស្រលាញ់
របស់ទ្រង់សណ្ឋិតនៅក្នុងចិត្ត
នោះយើងនឹងដើរតាមគំរូដ៏ត្រចះរបស់
ទ្រង់។

ប្រសិនបើយើងគិតផ្តោតអារម្មណ៍យ៉ា
ងខ្លាំងទៅលើអំពើអយុត្តិធម៌ និង
អសប្បុរសរបស់អ្នកដទៃ
នោះយើងនឹងមិនអាចស្រលាញ់គេដូច
ដែលព្រះគ្រិស្តស្រលាញ់យើងឡើយ
ប៉ុន្តែប្រសិនបើចិត្តរបស់យើងស្ថិតនៅ
លើសេចក្តីស្រលាញ់
និងសេចក្តីអាណិតមេត្តាដ៏អស្ចារ្យ
របស់ព្រះគ្រិស្តមកលើរូបយើង
នោះវិញ្ញាណបែបនេះនឹងហូរទៅកាន់
អ្នកដទៃ។
យើងនឹងស្រលាញ់និងគោរពគ្នាទៅវិ

ញទៅមកថ្វីបើមានកំហុសនិងភាពខុសឆ្គងដែលយើងមើលទៅឃើញ។ យើងត្រូវតែបណ្តុះបណ្តាលការបន្ទប់បន្ទាបខ្លួន
និងការមិនទុកចិត្តចំពោះខ្លួនឯង (Self-distrust) ពីព្រោះការទុកចិត្តលើខ្លួនឯងពេកបណ្តាលឲ្យមានគំនិតល្អឿង..យើងនឹងបណ្តុះឲ្យមានអំនត់អត់ធ្មត់យ៉ាងស្រទន់ជាមួយកំហុសរបស់អ្នកដទៃ។ អំពើទាំងនេះនឹងបំបាត់ចោលនូវភាពអាត្មានិយមយ៉ាងចង្អៀតចង្អល់ប៉ុន្តែនឹងធ្វើឲ្យយើងមានចិត្តទូលាយនិងសប្បុរសវិញ។

អ្នកកវីទំនុកតម្កើងពោលថា: "ចូរទុកចិត្តនឹងព្រះយេហូវ៉ា ហើយប្រព្រឹត្តការល្អចុះ

យ៉ាងនោះអ្នកនឹងបាននៅក្នុងស្រុក
ហើយចំអែតខ្លួនដោយសេចក្ដីពិត”..ទំនុកតម្កើង ៣៧:៣។
“ចូរទុកចិត្តនឹងព្រះយេហូវ៉ាចុះ”។ថ្ងៃនិមួយៗមានបញ្ហារបស់វាហើយក្ដីអំពល់អល់អែកតែងមាននៅក្នុងយើងរាល់គ្នាព្រោះនៅពេលណាដែលយើងជួបគ្នាម្ដងៗ
ហើយមានជាស្រេចនឹងថ្លែងប្រាប់គ្នាទៅវិញទៅមកអំពីការទាំងនោះ។
បញ្ហាដែលជារបស់មិនមែនផងខ្លួននឹងចូលមកលុយលុយក្នុងចិត្ត
ហើយគេទំយើនឹងសេចក្ដីភ័យខ្លាច។
ទម្ងន់នៃសេចក្ដីអន្ទះសារដែលសម្ដែងចេញមក
ធ្វើឲ្យអ្នកឯទៀតគិតស្មានថាយើងពុំមានព្រះអង្គសង្គ្រោះដែលប្រកបដោយសេចក្ដីស្រលាញ់និងអាណិតមេត្តា

ដដែលផ្ទៀងព្រះកាណ៌ជាស្រេចចាំស្តាប់នូវសំណូមពរទាំងឡាយរបស់យើង និងជាជំនួយនៅគ្រប់ពេលវេលាដែលយើងត្រូវការទ្រង់ទេ។

មានអ្នកខ្លះទៀតតែងមានសេចក្ដីភ័យខ្លាច
និងទទួលបញ្ហាដែលមិនមែនជារបស់ផងខ្លួន។
ភ័ស្តុតាងនៃសេចក្ដីស្រលាញ់របស់ព្រះបិតនៅជុំវិញខ្លួន
ហើយគេត្រេកអរនឹងព្រះពរដ៏សំបូរហូរហៀជារៀងរាល់ថ្ងៃ
ក៏ប៉ុន្តែគេមើលមិនឃើញនូវព្រះពរទាំងអស់នោះឡើយ។
ចិត្តរបស់គេនៅតែជិតជាប់ជានិច្ចទៅលើបញ្ហាដែលគេមិនចុះសំរុង
ហើយដែលគេមានអារម្មណ៍ខ្លាចថានឹ

ងកើតមានឡើង
ឬក៏មានការលំបាកខ្លះកលតឡើងជាបុ
រាកដទោះបីជាតិចតួចក៏ដោយ
ក៏វាបិទបាំងភ្នែករបស់គេពីបញ្ហាជាច្រើ
ន
ដែលតម្រូវឲ្យគេសម្ដែងការដឹងគុណដ
ល់ព្រះជាម្ចាស់។ ការលំបាកជា
ច្រើនដែលគេពើបប្រទះ
មិនដែលនាំគេឲ្យចូលមកឯព្រះជាម្ចា
ស់ជាប្រភពតែមួយនៃជំនួយរបស់គេឡើ
យ
តែវាបែរជាបំបែកបំបាក់រូបគេឲ្យឆ្ងាយ
ពីទ្រង់ទៅវិញពីព្រោះតែគេបែប្រឆាំងនិ
ងរអ៊ូរទាំអំពីទ្រង់។
តើយើងមានជំនឿបែបនេះឬ?
តើហេតុអ្វីបានជាយើងមានចិត្តអកត្ត
ញ្ញូ
នឹងពុំមានទំនុកចិត្តលើព្រះយ៉ាងដូច្នេះ

?
ព្រះយេស៊ូគឺជាមិត្តសម្លាញ់របស់យើង
គ្រប់ទាំងស្ថានសួគ៌គឺយកចិត្តទុកដាក់
ចំពោះសុខុមាលភាពរបស់យើង។
យើងមិនគួរអនុញ្ញាតឲ្យការកង្វល់អល់
ឯក
និងការព្រួយបារម្ភចំពោះជីវិតប្រចាំថ្ងៃ
មកបង្ករទុក្ខក្នុងអារម្មណ៍និងល្អក់កករ
ដល់ទឹកមុខរបស់យើងឡើយ។
ប្រសិនបើយើងធ្វើយ៉ាងដូច្នេះយើងនឹង
មានបញ្ហាខ្លះដែលធ្វើឲ្យមួម៉ៅរំខានចិត្ត
។
យើងមិនគួរបណ្តែតបណ្តោយទៅលើ
សេចក្តីកង្វល់ដោយគ្រាន់តែធ្វើឲ្យយើ
ងមួម៉ៅ និងនឿយណាយតែប៉ុណ្ណោះ
ក៏ប៉ុន្តែវាពុំបានជួយឲ្យយើងទ្រាំទ្រចំ
ពោះការវេទនាឡើយ។

លោកអ្នកប្រហែលជាអស់អែកនៅក្នុង
មុខរបរជំនួញពាណិជ្ជកម្មសេចក្តីសង្ឃឹ
មរបស់លោកអ្នកប្រហែលកាន់តែងងឹ
តទៅៗហើយលោកអ្នកប្រហែលជាទ
ទួលការគំរាមកំហែងពីសំណាក់ការបា
ត់បង់។
ទោះជាយ៉ាងនោះក្តីសូមលោកអ្នកកុំអ
ស់កម្លាំងទឹកចិត្តឲ្យសោះ។
ចូរដាក់ក្តីកង្វល់របស់លោកអ្នកថ្វាយព្
រះជាម្ចាស់ហើយសូមលោកអ្នកនៅតែរឹង
ប៉ឹងនិងអរសប្បាយចុះ។
ចូរអធិស្ឋានសូមប្រជ្ញាអំពីព្រះដើម្បីរៀ
បចំកិច្ចការរបស់លោកអ្នកដោយប្រុង
ប្រយ័ត្ន។
បើធ្វើយ៉ាងដូច្នោះសូមលោកអ្នកអាច
ការពារមិនឲ្យបាត់បង់នឹងទទួលក្តីមហា
ន្តរាយទៅបាន។
ចូរធ្វើគ្រប់ទាំងអ្វីៗដែលលោកអាចធ្វើ

ទៅបាន
ដើម្បីនាំមកនូវលទ្ធផលដ៏គួរឲ្យពេញចិត្ត។
ព្រះយេស៊ូគ្រិស្ទបានសន្យាថានឹងជួយដល់យើងថែមទៀត។
នៅពេលដែលលោកអ្នកអាចធ្វើទៅបាន
រួចសូមយកទូផលដោយអំណរសប្បាយ។

ព្រះរាជបំណងរបស់ព្រះជាម្ចាស់គឺពុំមែនឲ្យរាស្ត្រផងទ្រង់ត្រូវទទួលនូវបន្ទុកនៃសេចក្តីកង្វល់ឡើយ។
ព្រះជាម្ចាស់មានព្រះទ័យសុចរិតហើយតែងតែបំពេញសេចក្តីសន្យារបស់ទ្រង់។
ទ្រង់មិនមានព្រះបន្ទូលមកកាន់យើងថា:“ចូរកុំភ័យខ្លាចអ្វី នៅក្នុងផ្លូវជី

វិតរបស់អ្នកគ្មានឧបសគ្គអ្វីឡើយ”នោះទេ។
ទ្រង់ឈ្វេងយល់ថាមានបញ្ហាវេទនា និងគ្រោះថ្នាក់ដែលទ្រង់នឹងជួយដោះស្រាយជាមួយយើងយ៉ាងសាមញ្ញ។ ទ្រង់ពុំបានស្នើរសុំថាឲ្យយកវាស្រ្តរបស់ទ្រង់ចេញពីពិភពនៃអំពើបាប និងទុច្ចរិត
ក៏ប៉ុន្តែទ្រង់ចង្អុលបង្ហាញគេនូវលំនៅដ្ឋានដែលឋិតបេរនៅដ៏អស់កល្ប។ សេចក្តីអធិស្ឋានរបស់ទ្រង់ចំពោះសាវ័ករបស់ទ្រង់គឺយ៉ាងដូច្នេះវិញថា: “ទូលបង្គំមិនសូមឲ្យយកគេចេញពីលោកិយទេ
គឺសូមទ្រង់រក្សាគេឲ្យរួចពីសេចក្តីអាក្រក់វិញ”..យ៉ូហាន ១៧:១៥។
ទ្រង់មានព្រះបន្ទូលថា:
“នៅក្នុងលោកិយ៍នេះ

អ្នករាល់គ្នាមានសេចក្ដីវេទនាមែន
ក៏ប៉ុន្ដែចូរឲ្យអ្នកអរសប្បាយឡើង
ព្រោះខ្ញុំបានឈ្នះលោកីយហើយ”..យ៉ូហាន ១៦:៣៣។

ក្នុងការអធិប្បាយរបស់ទ្រង់នៅលើភ្នំ
ព្រះគ្រិស្ទជាម្ចាស់បានបង្ហាត់បង្រៀន
សាវ័ករបស់ទ្រង់នូវមេរៀនយ៉ាងថ្លៃថ្លា
ទៅលើការចាំបាច់ក្នុងការទុកចិត្តដល់
ព្រះជាម្ចាស់គ្រប់យុគសម័យ
ហើយមេរៀនទាំងនេះក៏ធ្លាក់មកដល់
សម័យបច្ចុប្បន្នយើងនេះពោរពេញទៅ
ដោយការបង្ហាត់បង្រៀន
និងការកំសាន្ដចិត្ត។
ព្រះអង្គសង្គ្រោះបានចង្អុលបង្ហាញដល់ពួកសាវ័ករបស់ទ្រង់
នូវបក្សាបក្សីនៅពួដ៏នភាល័យនៅពេលដែលវាបានបន្លឺ

សម្លេងដែលសម្តែងនូវ
ការសរសើរតម្កើង
មិនអើរពើរនឹងគំនិតនៃការកង្វល់ពីព្
រោះ “វាមិនបានសាបព្រោះ
ហើយវាក៏មិនត្រូវច្រូតកាត់ដែរ”។
ទោះជាយ៉ាងណាក៏ដោយព្រះវរបិតាដ៏
មានមហិទ្ធិរិទ្ធនៅតែបំពេញសេចក្តីត្រូវ
ការរបស់វា។
ព្រះអង្គសង្គ្រោះមានព្រះបន្ទូលថា:
“តើអ្នកទាំងអស់គ្នាពុំមានតម្លៃដ៏លើស
លប់ជាងពពួកបក្សាបក្សីទាំង
នោះទេឬអ្វី?”..ម៉ាថាយ..៦:២៦។
ព្រះដែលជួយផ្គត់ផ្គង់ចំពោះមនុស្ស
និងសព្វសត្វលោកព្រះហស្ថរបស់ទ្រង់
និងផ្គត់ផ្គង់ដល់សព្វសត្តនិករ។
បក្សាបក្សីនៅលើអាកាស
ក៏ពុំមែននៅឆ្ងាយផុតពីក្រសែព្រះនេត្រ
របស់ទ្រង់ដែរ។

ទ្រង់ពុំបានទាំលោក់អាហារទៅក្នុងជំពុះរបស់វាមែន
តែទ្រង់បានផ្តល់សេចក្តីត្រូវការនៃសត្វទាំងនោះ។
សត្វទាំងនោះត្រូវតែប្រមែប្រមូលអស់ទាំងគ្រាប់ធញ្ញជាតិ
ដែលទ្រង់បានផ្តល់យ៉ាងបរិបូណ៌ពាសពេញដី។
ពពួកបក្សាបក្សីទាំងនោះត្រូវរៀបចំធ្វើសំបុករបស់ខ្លួនហើយក៏ត្រូវបញ្ចុកចំណីដល់កូនតូចៗរបស់វាដែរ។
វារហើរចេញទៅដោយសម្លេងអំណរខ្ញៀវខ្ញារអំពីការងាររបស់វាពីព្រោះ
"ព្រះវរបិតានៃស្ថានសួគ៌របស់អ្នករាល់គ្នាបានប្រទានចំណីអាហារដល់បក្សាបក្សីទាំងនោះ"។
តើលោកអ្នកមិនមានតម្លៃលើសជាងពពួកបក្សាបក្សីនោះទេឬអ្វី?

តើលោកអ្នកមិនមែនជាអ្នកគោរពបូជាដល់ព្រះដ៏ឆ្លាតវាងវៃ
ដែលមានតម្លៃលើសពពួកបក្សាបក្សីនៅលើអាកាសនោះទេឬអ្វី?
តើនោះមិនមែនជាព្រះដែលបង្កើតយើងរាល់គ្នា..ជាព្រះដែលថែរក្សាជីវិតរបស់យើង..ជាព្រះដែលបានជប់សូនរាងកាយរបស់យើងទៅតាមរូបសណ្ឋាននៃទ្រង់ផ្ទាល់
ដែលបានផ្ដល់នូវគ្រប់សេចក្ដីត្រូវការរបស់យើង
ប្រសិនបើយើងគ្រាន់តែជឿទុកចិត្តដល់ទ្រង់នោះទេឬអ្វី?

ព្រះគ្រិស្តបានចង្អុលទៅផ្កានៅទីវាលបង្ហាញដល់សាវ័ករបស់ទ្រង់។
បុប្ផាជាតិទាំងនោះដែលលូតលាស់ដ៏ស្រស់បំព្រងដោយនូវសម្រស់យ៉ាង

សាមញ្ញដែលព្រះវរបិតានៃស្ថានសួគ៌
បានផ្តល់ឲ្យ
គឺជាការសម្តែងចេញនូវសេចក្តីស្រលា
ញ់របស់ទ្រង់ចំពោះមនុស្សនៅនាលោ
កិយនេះ។ ទ្រង់មានព្រះបន្ទូលថា:
“ចូរគិតពិចារណាមើលពីផ្កាកំភ្លឹងនៅទី
វាល
តើវាដុះលូតលាស់យ៉ាងដូចម្តេច?”សំរ
ស់នឹងភាពសាមញ្ញនៃបុប្ផាជាតិ
ក្នុងធម្មជាតិអស់ទាំងនេះគឺលើសអស់
ទាំងសម្លៀកបំពាក់ដ៏ឆើតឆាយនៃហ្វូង
សាឡូម៉ូនទៅទៀតផង។
សម្លៀកបំពាក់ដ៏ឆើតឆាយនដែលរៀប
ចំឡើងដោយស្នាដៃមនុស្សមិនអាចប្
រៀបធៀបនឹងសម្រស់ដ៏សមសួននៃធ
ម្មជាតិដ៏ស្រស់ត្រកាលនៃធម្មជាតិទាំង
នោះ
ដែលជាស្នាព្រះហស្តរបស់ព្រះជាម្ចា

ស់បានឡើយ។
ព្រះយេស៊ូមានព្រះបន្ទូលថា:
“ប្រសិនបើព្រះទ្រង់បានតុបតែងតិណជាតិនៅលើវាលដែលយើងចាត់ទុកថាជារបស់មិនសំខាន់ដែលត្រូវបង្គរដុតចោលនោះ
តើទ្រង់មិនតុបតែងឲ្យអ្នករាល់គ្នាលើសជាងនេះទៅទៀតទេឬអ្វី? ឱ! មនុស្សដ៏មានជំនឿតិចអើយ!”..ម៉ាថាយ៦:៣០។
ប្រសិនបើព្រះជាម្ចាស់ជាវិចិត្រករតាក់តែងឲ្យផ្កាសាមញ្ញដែលនឹងវិនាសបាត់ក្នុងថ្ងៃណាមួយនូវពណ៌គ្រប់ប្រភេទនឹងដ៏ប្រណិត
តើទ្រង់យកព្រះទ័យទុកដាក់ប៉ុណ្ណាទៅចំពោះមនុស្សជាតិដែលទ្រង់បង្កើតមកដូចជាអង្គទ្រង់នោះ?
មេរៀនរបស់ព្រះគ្រិស្តនេះគឺជាការស្តី

បន្ទោសដល់គំនិតអន្ទះអន្ទែង..ការអេល់អែក
និងការមន្ទិលសង្ស័យនៃមនុស្សដែលគ្មានចិត្តជឿ។

ព្រះយេហូវ៉ានឹងធ្វើឲ្យបុត្រាបុត្រីរបស់ទ្រង់អរសប្បាយ
មានសុខសន្តិភាពនិងមានចិត្តគោរពប្រណិបត្តដល់ព្រះ។
ព្រះយេស៊ូមានបន្ទូលថា:“ខ្ញុំឲ្យសេចក្តីសុខ សាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា
ហើយដែលខ្ញុំឲ្យនោះ
មិនមែនដូចជាលោកិឲ្យទេកុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឬភ័យឡើយ”..យ៉ូហាន ១៤:២៧។
ខ្ញុំបាននិយាយសេចក្តីទាំងនេះប្រាប់ដល់អ្នករាល់គ្នា
ដើម្បីឲ្យសេចក្តីអំណាររបស់ខ្ញុំបាននៅ

ជាប់ក្នុងអ្នករាល់គ្នា
ហើយឲ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញផង..យ៉ូហាន១៥:១១។

សុភមង្គលដែលបានមកមូលហេតុអាត្មានិយម
ក្រៅអំពីផ្លូវនៃព្រះជាម្ចាស់គឺមិននឹងនរមិនទៀងទាត់និងមិនឋិតបេរ។
សុភមង្គលនោះនឹងបាត់បង់ទៅហើយចិត្តគេនឹងពោរពេញទៅដោយភាពឯកា និងទុក្ខព្រួយ។
ប៉ុន្តែមានសេចក្ដីអំណរសប្បាយ
និងការពេញចិត្តនៅក្នុងការងារបំរើព្រះជាម្ចាស់។
អ្នកគ្រិស្ទានមិដែលត្រូវបោះបង់
ឲ្យដើរតាមផ្លូវដែលមិនច្បាស់លាស់ឡើយ។

គេមិនដែលទទួលការបោះបង់ទុកឲ្យ
នៅក្នុងវិប្បដិសារី
និងការខកចិត្តឥតអំពើនោះទេ។
ប្រសិនបើយើងមិនមានការសប្បាយ
នៅក្នុងជាតិនេះ
យើងនៅតែមានអំណរសប្បាយដោយ
សារតែយើងមានរំពឹងដល់ជីវិត
នាពេលអនាគតកាលដែលព្រះជាម្ចា
ស់នឹងប្រទានឲ្យជាពិត។

ទោះជាយ៉ាងណាក៏ដោយអ្នកគ្រិស្ទាន
អាចមានអំណរសប្បាយក្នុងការរួមស
ម្ព័ន្ធនឹងព្រះគ្រិស្ទ។
គេអាចមានពន្លឺនៃសេចក្ដីស្រលាញ់រប
ស់ទ្រង់ ផាសុកភាពដ៏ជានិរន្ត
នៃវត្តមានរបស់ព្រះអង្គ។
គ្រប់ជំហាននៅក្នុងជីវិតអាចនាំយើងឲ្
យចូលទៅជិតព្រះយេស៊ូគ្រិស្ទ..អាចផ្ត

ល់ឲ្យយើងនូវការពិសោធន៍ដ៏ជ្រាលជ្
រៅឡើងអំពីសេចក្ដីស្រលាញ់របស់ទ្រ
ង់ ហើយនាំឲ្យយើងឈាន
មួយជំហានថែមទៀតទៅជិតលំនៅឋា
នដ៏សុខសាន្តប្រកបដោយព្រះពរ។
ដូច្នេះសុំកុំឲ្យយើងបោះបង់ចោលនូវ
សេចក្ដីទំនុកចិត្តរបស់យើង
ក៏ប៉ុន្ដែសូមឲ្យយើងមានការធានាអះអា
ងដ៏រឹងមាំជាជាងពេលមុនទៅទៀត។
“ដរាបដល់ពេលឥឡូវនេះព្រះយេហូវ៉ា
បានជួយខ្ញុំ”..សាំយ៉ូអែលទី១
៧:១២ហើយទ្រង់នឹងជួយរហូតដល់ទី
បញ្ចប់។
ចូរយើងក្រលេកមើលទៅសរសរនៃវិ
មានដែលជាសេចក្ដីរំលឹកយើង
នូវអ្វីៗដែលព្រះយេហូវ៉ាបានធ្វើដើម្បីកំ
សាន្តចិត្តយើង
និងជួយសង្គ្រោះយើងឲ្យផុតពីកណ្ដាប់

ដៃនៃមេបំផ្លិចបំផ្លាញ(អារក្សសាតាំង)
។
ចូរយើងចងចាំជានិច្ចនៅក្នុងអារម្មណ៍
នៃយើង
នូវទឹកភ្នែកដែលទ្រង់បានជូតសម្អាត
ការឈឺចាប់ដែលទ្រង់បានជួយសម្រា
ល..ការអន្ទះអន្ទែងដែលទ្រង់បានដក
ចេញទៅ
សេចក្តីភ័យខ្លាចដែលទ្រង់ជួយបំបាត់
ចេញ..សេចក្តីប្រាថ្នាដែលទ្រង់ជួយបំ
ពេញ..ព្រះពរទាំងឡាយដែលទ្រង់បា
នប្រទានឲ្យដល់យើងនោះ
គឺដើម្បីជួយចម្រើនកម្លាំងដល់យើងឲ្យ
អាចទប់ទល់នឹងការលំបាក
ដែលនឹងអាចជួបប្រទះនៅក្នុងឆាកជីវិ
តធម្មយាត្រារបស់យើង។

យើងមិនត្រូវទន្ទឹងរង់ចាំមើលតែការទ័
លគំនិតថ្មីៗ
នៅក្នុងអធិករណ៍ដែលនឹងកើតមាន
នោះឡើយ
ក៏ប៉ុន្តែយើងត្រូវក្រលេកមើលទៅអ្វីដែ
លកន្លងហួសទៅក៏ដូចជាអ្វីដែលនឹង
កើតមានដល់ដែរ រួចពោលថា:
“ដរាបមកដល់ឥឡូវនេះព្រះយេហូវ៉ា
បានជួយយើងខ្ញុំ
ចូរឲ្យអ្នកមានកម្លាំងនៅក្នុងថ្ងៃនៃអាយុ
របស់អ្នកចុះ”.. ចោទិយកថា៣៣:២៥។
ការលំបាកវេទនានឹងមិនដែលធ្ងន់ធ្ងរ
ហួសកម្លាំងដែលព្រះប្រទានឲ្យយើង
សម្រាប់ទ្រាំទ្រវានោះទេ។
ដូច្នេះចូរឲ្យយើងទទួលនូវការងារថ្វាយ
ព្រះនៅទីណាដែលយើងអាចធ្វើបាន
ចុះ។ ចូរជឿជាក់ថា
ព្រះនឹងប្រទានកម្លាំងដល់យើងសម្រា

ប់ទ្រទ្រង់
ដែលធ្ងន់ល្មមនឹងការលំបាកដែលនឹង
កើតមានឡើងដល់យើងជាពិត។
បន្តិចម្តងៗទ្វារនៃនគរស្ថានសួគ៌នឹងបើ
កចំហចាំទទួលកូនចៅរបស់ព្រះជាម្ចា
ស់។ ព្រះដ៏ប្រកបដោយសិរីល្អ
នឹងប្រសិទ្ធពរដ៏ពិរោះរណ្តំដូចជាតន្ត្រីភិ
រម្យដល់គេថា: “ឱ!
ពួកអ្នកដែលព្រះវរបិតានៃយើងបានប្រ
ទានពរអើយ
ចូរមកទទួលមរតកចុះគឺជានគរដែល
បានរៀបចំទុកសម្រាប់អ្នករាល់គ្នាតាំង
ពីកំណើតលោកិយមក”..ម៉ាថាយ
២៥:៣៤។

ពេលនោះអ្នកដែលបានសង្គ្រោះ(ត្រូវ
បានប្រោសលោះ
ដោយសារការសុគតរបស់ព្រះគ្រិស្ទ)នឹ

ងបានទទួលការស្វាគមន៍ឲ្យចូលមកក្នុងដំណែងដែលព្រះយេស៊ូបានរៀបចំសម្រាប់ពួកគេ។
នៅឯទីនោះមិត្តភ័ក្ររបស់គេនឹងពុំមែនជារបស់ផងលោកិយដ៏អប្រិយមនុស្សកំភូត
អ្នកគោរពរូបសំណាកអ្នកមិនបរិសុទ្ធនិងអ្នកដែលគ្មានជំនឿឡើយ
ក៏ប៉ុន្តែគេនឹងចូលរួមជាមួយអ្នកទាំងឡាយណាដែលឈ្នះទៅលើអារក្សសាតាំងឡើយក៏ប៉ុន្តែគេនឹងចូលរួមជាមួយអ្នកទាំងឡាយដែលឈ្នះទៅលើអារក្សសាតាំងហើយតាមរយៈព្រះគុណនៃព្រះជាម្ចាស់
អត្តចរិកដ៏ល្អឥតខ្ចោះបានចាប់កំណើតឡើង។
គ្រប់ទាំហាទំនោរដែលទាញទៅរកអំពើបាប..គ្រប់ទាំងភាពមិនបរិសុទ្ធដែលធ្

ធ្វើឲ្យគេមានទុក្ខវេទនានៅលើផែនដី
ក៏ត្រូវបានបំបាត់ចោលបង់ដោយសារ
តែព្រះលោហិតរបស់ព្រះគ្រិស្ទ
ហើយភាពអស្ចារ្យ
និងភ្លឺថ្លានៃសិរីល្អរបស់
ទ្រង់ដែលលើសអស់ទាំងពន្លឺដ៏ត្រចះត្
រចង់នៃព្រះអាទិត្យក៏បានប្រទានឲ្យដ
ល់គេ។
សោភ័ណភាពខាងសីលធម៌ដ៏ល្អឥតខ្
ចោះនៃលក្ខណៈរបស់ទ្រង់
នឹងបញ្ចាំងចេញពីចិត្តគេមកហើយភ្លឺ
លើសអស់ទាំងភាពរុងរឿងទាំងឡាយ
ដែលនៅខាងក្រៅផង។
គេគ្មានកំហុសទាល់តែសោះនៅចំ
ពោះមុខសេតបល្ល័ង្គ(White
Throne)ដ៏ស្ដុកស្ដម្ភហើយទទួលនូវកិត្តិ
យស
និងសិទ្ធិដូចជាពពួកទេវតានៃព្រះដែរ។

ក្នុងទិដ្ឋភាពនៃបតិកដ៏អស្ចារ្យ
ដែលអាចក្លាយជាកម្មសិទ្ធរបស់មនុស្សជាតិតើមនុស្សនឹងយកអ្វីទៅដូរឲ្យបានព្រលឹងរបស់ខ្លួនវិញ?..ម៉ាថាយ១៦:២៦។
ប្រហែលជាគេជាអ្នកក្រីក្រមែន
ក៏ប៉ុន្តែនៅក្នុងខ្លួនរបស់គេៗមានទ្រព្យសម្បត្តិនិងកិត្តិយសដែលលោកិយនេះមិនអាចប្រគល់ឲ្យបានសោះឡើយ។

ដោយនូវសិទ្ធិដ៏វិសេសវិសាល
ដែលឧទ្ទិសថ្វាយចពោះកិច្ចការបំរើព្រះព្រលឹងមួយ(មនុស្សម្នាក់)ដែលបាន
ប្រោសលោះ
និងលាងសំអាតអំពើបាបនោះមានតម្លៃដ៏លើសលប់ក្រៃលែង។
ហើយនឹងមានអំណាចសប្បាយនៅឯ

ស្ថានសួគ៌នៅក្នុងវត្តមាននៃព្រះជាម្ចាស់
និងពពួកទេវតាបរិសុទ្ធទៅលើព្រលឹងមួយនោះដែលបានទទួលការប្រោសលោះ..គឺជាអំណរដែលសម្តែងចេញជាទំនុកនៃជ័យជំនះរបស់ព្រះ៕